ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# រាជរដ្ឋាភិបាលកម្ពុជា

# ការវិភាគស្ថានភាពដំបូង

# ស្ដីពី

# ការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ

# តាមប្រព័ន្ធអនឡាញនៅកម្ពុជា

ឆ្នាំ២០១៩

ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ

ក្រុមការងារបច្ចេកទេសអន្តរក្រសួង ដើម្បីពិនិត្យផ្តល់យោបល់ លើការសិក្សាស្រាវជ្រាវ
ការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញនៅកម្ពុជា៖

ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
MINISTRY OF POSTS AND TELECOMMUNICATIONS

សូមអរគុណដល់អង្គការដៃគូរដែលបានគាំទ្រផ្នែកហិរញ្ញវត្ថុ និងបច្ចេកទេស៖

terre des hommes stops child exploitation

APLE

Save the Children

PLAN INTERNATIONAL

ឧបត្ថម្ភដោយ៖

terre des hommes stops child exploitation

# មាតិកា


អារម្ភកថា ១
សេចក្ដីថ្លែងអំណរគុណ ៤
និយមន័យ ៥
អក្សរកាត់ ៧
សេចក្ដីសង្ខេប ៩
វគ្គទី១ : សេចក្ដីផ្ដើម ១៣
១.១. ទម្រង់ផ្សេងៗនៃ OCSE ១៤
១.២. ការឆ្លើយតប ១៧
១.៣. បរិបទនៅក្នុងប្រទេសកម្ពុជា ១៩
វគ្គទី២: វិធីសាស្ត្រនៃការវិភាគស្ថានភាពដំបូងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ ២៣
២.១. ការកំណត់សំណាកគំរូ ២៤
២.២. ការរៀនសូត្រពីកុមារនៅក្នុងសហគមន៍ ២៥
២.៣. ការរៀនសូត្រអំពីសមត្ថភាពការពារកុមារពី OCSE ២៨
វគ្គទី៣: បទពិសោធន៍របស់កុមារតាមប្រព័ន្ធអនឡាញ ៣០
៣.១. សិក្ខាសាលារៀនសូត្រ ៣០
វគ្គទី៤: យន្តការជាតិ និងអន្តរជាតិសម្រាប់រាយការណ៍អំពី OCSE ៤៩
៤.១. អង្គភាពជំនាញរបស់រាជរដ្ឋាភិបាល ៤៩
៤.២. មជ្ឈមណ្ឌលជាតិការពារកុមារដែលបានបាត់ខ្លួននិងរងគ្រោះដោយការកេងប្រវ័ញ្ច (NCMEC) ៤៩
៤.៣. បណ្ដាញរាយការណ៍បន្ទាន់តាមប្រព័ន្ធអនឡាញនៃអង្គការ APLE ៥២
៤.៤. បណ្ដាញទូរស័ព្ទជំនួយកុមារកម្ពុជា ៥៥
៤.៥. ការស៊ើបអង្កេតលើសេចក្ដីរាយការណ៍ស្ដីពី OCSE ៥៥
៤.៦. បញ្ហាប្រឈមចំពោះការស៊ើបអង្កេត ៦១
វគ្គទី៥: សមត្ថភាពនិងភាពខ្វះចន្លោះរបស់ប្រទេសកម្ពុជា ៦៤
៥.១. យុត្តិធម៌ព្រហ្មទណ្ឌ ៦៤
៥.២. ការផ្ដល់សេវាអ៊ិនធឺណិត ៧០
វគ្គទី៦: ការពិភាក្សា-អ្វីដែលយើងរៀនសូត្របាន ៧១
៦.១. អ្វីដែលយើងដឹងអំពីចរិត OCSE នៅក្នុងប្រទេសកម្ពុជា ៧២
៦.២. អ្វីដែលយើងដឹងអំពីទំហំ OCSE នៅក្នុងប្រទេសកម្ពុជា ៧៤
៦.៣. អ្វីដែលយើងបានរៀនសូត្រអំពីសមត្ថភាពរបស់យើងក្នុងការដោះស្រាយបញ្ហា ៧៥
វគ្គទី៧: កាលានុវត្តភាពសម្រាប់ការអភិវឌ្ឍ ៧៩
៧.១. គោលនយោបាយ និងអភិបាលកិច្ច ៧៩
៧.២. ការផ្ដល់សេវាអ៊ិនធឺណិត ៨០
៧.៣. យុត្តិធម៌ព្រហ្មទណ្ឌ ៨០
៧.៤. សង្គម ៨១
ឧបសម្ព័ន្ធ ១: ការអង្កេតមានរចនាសម្ព័ន្ធ ៨២
បញ្ជីឈ្មោះឯកសារយោង ៩០


ទ.ស.១

# អារម្ភកថា

ការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ (OCSE) គឺជាបញ្ហាសកលដែលកើតឡើងក្នុងទម្រង់ផ្សេងៗរួមមាន ការផលិត ការកាន់កាប់ ការចែកចាយ និងការផ្សព្វផ្សាយ រូបភាពវីដេអូអាសអាភាសរបស់កុមារ តាមរយៈមធ្យោបាយដែលអាចបង្កើត ការរំលោភបំពានផ្លូវភេទលើកុមារ ដូចជាការប្រើប្រាស់គេហទំព័រ កំព្យូទ័រ បណ្ដាញទំនាក់ទំនងសង្គម និងកម្មវិធីទូរស័ព្ទផ្សេងៗ និងការលួងលោមជនរងគ្រោះដើម្បីបំពេញចំណង់ផ្លូវភេទតាមប្រព័ន្ធអនឡាញ។

ទោះបីជាប្រព័ន្ធបច្ចេកវិទ្យា បានជួយសម្រួលដល់សកម្មភាព ការងារនិងការរស់នៅប្រចាំថ្ងៃរបស់ប្រជាជនក្នុងពិភពលោកក៏ដោយ ក៏មានបញ្ហាប្រឈម និងឧក្រិដ្ឋកម្មតាមប្រព័ន្ធអនឡាញជាច្រើន បានកើតឡើងជាបន្តបន្ទាប់ផងដែរ មានដូចជា ការចាប់ជំរិត ការជួញដូរខុសច្បាប់ ការរំលោភបំពាននិងការកេងប្រវ័ញ្ចផ្លូវភេទជាពិសេសទៅលើស្ត្រីនិងកុមារ។ល។ ហើយបញ្ហាទាំងនេះបានកើនឡើងច្រើន និងរីករាលដាលយ៉ាងឆាប់រហ័សលើសកលលោក ជាពិសេសក្នុងតំបន់អាស៊ីអាគ្នេយ៍និងប៉ាស៊ីហ្វិក។ ទន្ទឹមនឹងនោះ ការប្រើប្រាស់ឧបករណ៍អេឡិចត្រូនិច (ទូរស័ព្ទឆ្លាត-Smart Phone កុំព្យូទ័រ កុំព្យូទ័របន្ទះ ម៉ាស៊ីនថត...) មានការពេញនិយម រួមទាំងល្បិចកលរបស់ជនល្មើសក្នុងការកេងប្រវ័ញ្ចនិងរំលោភបំពានផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញកាន់តែមានភាពស្មុគស្មាញនិងសម្បូរបែប ជំរុញឲ្យបញ្ហានេះក្លាយជាប្រធានបទថ្មីមួយទៀត ដែលទាមទារឲ្យភាគីពាក់ព័ន្ធទាំងសាធារណជន អាណាព្យាបាលរបស់កុមារ អាជ្ញាធរ សង្គមស៊ីវិល និងកុមារខ្លួនឯងផ្ទាល់ ចាំបាច់ធ្វើការរួមគ្នាដើម្បីបង្ការទប់ស្កាត់ និងដោះស្រាយឲ្យបានទាន់ពេលវេលា។

រាជរដ្ឋាភិបាលដឹកនាំដោយសម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានបោះជំហានទៅមុខក្នុងការស្ដារសង្គមនិងសេដ្ឋកិច្ចឡើងវិញ ដែលក្នុងពីរទសវត្សរ៍ចុងក្រោយនេះសម្រេចកំណើនសេដ្ឋកិច្ចជាមធ្យមប្រមាណ៧.៧% ហើយបាននិងកំពុងវិភាជន៍ ធនធានបន្ថែមទៀតដល់វិស័យសុខាភិបាល អប់រំ សង្គមកិច្ច និងវិស័យផ្សេងៗទៀត សម្រាប់ជំរុញការអភិវឌ្ឍធនធានមនុស្ស រួមទាំងការអភិវឌ្ឍកុមារ សំដៅសម្រេចឲ្យបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា ២០១៦-២០៣០ ដែលក្នុងនោះបានផ្ដោតសំខាន់លើការអភិវឌ្ឍសុខុមាលភាពកុមារផងដែរ។ រាជរដ្ឋាភិបាលកម្ពុជា ក៏បានយកចិត្តទុកដាក់ខ្ពស់ចំពោះការអនុវត្តច្បាប់អន្តរជាតិនានា ជាពិសេសអនុសញ្ញាស្ដីពីសិទ្ធិកុមារ និងពិធីសារបន្ថែម ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់កុមារ និងកិច្ចការពារជាពិសេសសម្រាប់កុមារ ដើម្បីរស់នៅក្នុងសេរីភាព សន្តិភាព និងការអភិវឌ្ឍ តាមរយៈការដាក់ចេញនូវវិធានការជាច្រើន រួមមាន ការរៀបចំច្បាប់ គោលនយោបាយ ផែនការយុទ្ធសាស្ត្រនិងលិខិតបទដ្ឋាននានាជាច្រើន។ ការលើកកម្ពស់និងការការពារកុមារ គឺជាបញ្ហាអាទិភាពរបស់រាជរដ្ឋាភិបាល ដោយបានដាក់បញ្ចូលទៅក្នុងកម្មវិធីគោលនយោបាយ ជាពិសេស យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ក្នុងយុទ្ធសាស្ត្រទី១ **"ការអភិវឌ្ឍធនធានមនុស្ស"** និងផែនការមួយចំនួនដែលពាក់ព័ន្ធកិច្ចការពារ និងលើកកម្ពស់សិទ្ធិកុមារ។

ដើម្បីការពារឧត្តមប្រយោជន៍កុមារ ប្រទេសកម្ពុជា បានផ្ដល់សច្ចាប័នលើអនុសញ្ញាស្ដីពីសិទ្ធិកុមារ នៅថ្ងៃទី១៥ ខែតុលា ឆ្នាំ១៩៩២ និងពិធីសារបន្ថែមនៃអនុសញ្ញាស្ដីពីសិទ្ធិកុមារ។ ជាមួយគ្នានេះដែរ មាត្រា៣១ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ទទួលស្គាល់ និងគោរពសិទ្ធិមនុស្ស ដូចមានចែងនៅក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ

សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញា ព្រមទាំងអនុសញ្ញាទាំងឡាយពាក់ព័ន្ធនឹងសិទ្ធិមនុស្ស សិទ្ធិនារី និងសិទ្ធិកុមារ។ មាត្រា៤៨ រដ្ឋធានារក្សាការពារសិទ្ធិរបស់កុមារ ដែលមានចែងក្នុងអនុសញ្ញាស្តីពីសិទ្ធិកុមារ ជាពិសេសសិទ្ធិមានជីវិតរស់នៅ សិទ្ធិទទួលបានការអប់រំរៀនសូត្រ សិទ្ធិត្រូវបានទទួលការគាំពារក្នុងស្ថានភាពមានសង្គ្រាម និងការការពារប្រឆាំងនឹងអាជីវកម្មសេដ្ឋកិច្ច ឬកាមគុណលើកុមារ។ រដ្ឋគាំពារប្រឆាំងនឹងការងារទាំងឡាយណាដែលអាចធ្វើឲ្យខូចដល់ការអប់រំ និងរៀនសូត្ររបស់កុមារ ឬដែលនាំឲ្យអន្តរាយដល់សុខភាព ឬសុខុមាលភាពរបស់កុមារ។

ប្រទេសកម្ពុជាបាននិងកំពុងសមាហរណកម្មខ្លួនចូលទៅក្នុងតំបន់ និងពិភពលោកដែលធ្វើឲ្យកម្ពុជាទទួលបានឱកាសជាច្រើនក្នុងការកសាង និងអភិវឌ្ឍប្រទេសជាតិ។ ស្របពេលជាមួយគ្នានេះ រាជរដ្ឋាភិបាលនីតិកាលទី៦នៃរដ្ឋសភា បានដាក់ចេញនូវយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ២០១៦-២០៣០ ដោយបានត្រៀមខ្លួនជាស្រេចក្នុងការចូលរួមក្នុងបដិវត្តឧស្សាហកម្មទី៤ ដែលផ្តោតជាពិសេសទៅលើវិស័យបច្ចេកវិទ្យាហើយពិភពលោក ក៏កំពុងប្រើប្រាស់វាក្នុងការបំពេញមុខងារទាំងក្នុងផ្នែកនយោបាយ សេដ្ឋកិច្ច និងសង្គមកិច្ចបានយ៉ាងមានប្រសិទ្ធភាពទៀតផង។ ការរីកចម្រើនផ្នែកបច្ចេកវិទ្យាព័ត៌មានរបស់ពិភពលោក បានរីករាលដាលទៅគ្រប់ទីកន្លែង ក្នុងនោះក៏មានកម្ពុជាផងដែរ។ ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានបានជួយជំរុញដល់ការរីកលូតលាស់ ការងារនយោបាយ សេដ្ឋកិច្ច និងសង្គមកិច្ច និងទំនាក់ទងរបស់កម្ពុជាជាមួយបណ្តាប្រទេសក្នុងតំបន់ និងពិភពលោកថែមទៀតផង។

ដោយមើលឃើញនូវផលប៉ះពាល់ និងបញ្ហាប្រឈមដែលបានកើតឡើងក្នុងពេលថ្មីៗនេះ ព្រះរាជាណាចក្រកម្ពុជា បានចូលជាសមាជិកនៃប្រទេសភាពជាដៃគូសកល ដើម្បីលុបបំបាត់អំពើហិង្សាលើកុមារ ( Path Finding Country ) នៅថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៩នេះ។ មិនតែប៉ុណ្ណោះ ព្រះរាជាណាចក្រកម្ពុជា ក៏បានចុះហត្ថលេខាលើសេចក្តីថ្លែងការណ៍ WePROTEC នៅទីក្រុងអាប៊ុយដាប៊ី ក្នុងឆ្នាំ២០១៥ ពាក់ព័ន្ធនឹងសកម្មភាពទប់ស្កាត់ ការរំលោភបំពាន និងកេងប្រវ័ញ្ចកុមារតាមប្រព័ន្ធអនឡាញ ដែលមានក្រសួងមហាផ្ទៃជាតួអង្គសម្របសម្រួល។ ការវិវត្តជាវិជ្ជមាននេះស្របគ្នាទៅនឹងផែនការសកម្មភាពទប់ស្កាត់ និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារ ឆ្នាំ២០១៧-២០២១ ដែលបានលើកទឹកចិត្តឲ្យមានសកម្មភាពទប់ស្កាត់អំពើហិង្សា និងកេងប្រវ័ញ្ចផ្លូវភេទកុមារ តាមប្រព័ន្ធអនឡាញផងដែរ។

ដើម្បីដោះស្រាយបញ្ហាប្រឈមខាងលើ អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ (ក.ជ.ក.) សហការជាមួយអង្គការដៃគូ ធ្វើការវិភាគស្ថានភាពដំបូងនេះ ដើម្បីប៉ាន់ប្រមាណផលប៉ះពាល់លើការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ (OCSE) នៅក្នុងប្រទេសកម្ពុជា តាមនីតិវិធីមួយចំនួន ដូចជា៖ ប៉ាន់ប្រមាណ ទីកន្លែង និងវិធីសាស្ត្រដែលជាកត្តាជំរុញកុមារឲ្យស្ថិតក្នុងស្ថានភាពងាយរងគ្រោះ ព្រមទាំងកំណត់នូវសមត្ថភាព និងភាពខ្វះចន្លោះនៃគោលនយោបាយជាតិ លិខិតបទដ្ឋានគតិយុត្ត យុត្តិធម៌ព្រហ្មទណ្ឌ សេវាសង្គម និងវិស័យឯកជន។ ការប៉ាន់ប្រមាណនេះធ្វើឡើងក្នុងគោលបំណងកំណត់នូវ "អនុសាសន៍ដែលអាចធ្វើបានដោយផ្អែកលើភស្តុតាង" ដើម្បីឆ្លើយតបទៅនឹង OCSE នៅក្នុងបរិបទនៃប្រទេសកម្ពុជា ដែលអនុលោមទៅតាមគំរូនៃការឆ្លើយតបជាតិ WePROTECT ដោយរៀនពីការអនុវត្តល្អកម្រិតជាតិនិងថ្នាក់អន្តរជាតិ។

ខ្ញុំសូមថ្លែងអំណរគុណដល់ក្រុមការងារបច្ចេកទេសOCSE ពីក្រសួងមហាផ្ទៃ ក្រសួងការពារជាតិ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

អគ្គលេខាធិការដ្ឋាន ក.ជ.ក និងអង្គការ**ដៃនដីមនុស្ស-ហូឡង់ដ៏ប្រចាំកម្ពុជា** (Terre des Hommes Netherlands in Cambodia) អង្គការសកម្មភាពដើម្បីកុមារ (APLE) អង្គការ Save the Children និងអង្គការពាក់ព័ន្ធ ដែលបានឧបត្ថម្ភគាំទ្រទាំងផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុដល់ការវិភាគស្ថានភាពនេះ។

*ថ្ងៃ សុក្រ ១កើត ខែ បុស្ស ឆ្នាំ កុរ ឯកស័ក ព.ស ២៥៦៣*

*រាជធានីភ្នំពេញ, ថ្ងៃទី ១០ ខែ មករា ឆ្នាំ២០២០*

**ប្រធានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ**

**ទេង_សុត**

# សេចក្តីថ្លែងអំណរគុណ

ការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ(OCSE) នេះគឺជាទម្រង់នៃការកេងប្រវ័ញ្ចនិងការរំលោភបំពានផ្លូវភេទលើកុមារកំពុងរាលដាល ដែលត្រូវបានធ្វើឡើងនៅតាមប្រព័ន្ធអនឡាញ។ រាជរដ្ឋាភិបាលកម្ពុជា គឺជារដ្ឋភាគីហត្ថលេខីនៃសេចក្តីថ្លែងការណ៍សកម្មភាពសកល WePROTECT ដែលត្រូវបានចុះហត្ថលេខា នៅឯកិច្ចប្រជុំកំពូលជាសាកល នាទីក្រុងអាប៊ុយដាប៊ី ឆ្នាំ២០១៥។ គំរូនៃការឆ្លើយតបជាតិ (MNR) នៃ WePROTECT សង្កត់ធ្ងន់លើសារសំខាន់នៃការចូលរួមរបស់អ្នកពាក់ព័ន្ធនានា និងកំណត់នូវឧស្សាហកម្មពាក់ព័ន្ធធំៗនៅក្នុងកិច្ចការពារកុមារតាមប្រព័ន្ធអនឡាញ។

ការវិភាគស្ថានភាពដំបូងស្តីពីការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ (OCSE) បានប៉ាន់ប្រមាណឃើញថា ការប្រើប្រាស់ ឬភ្ជាប់អ៊ិនធឺណិតកំពុងតែពង្រីកខ្លួនយ៉ាងខ្លាំងនៅប្រទេសកម្ពុជា ក្នុងកំឡុងពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ហើយនិន្នាការនេះ ត្រូវបានព្យាករណ៍ថា នឹងបន្តមានទៅពេលអនាគតនៅក្នុងប្រទេសកម្ពុជា។ ការវិភាគស្ថានភាព OCSE នេះ មានគោលបំណងកំណត់អនុសាសន៍ ផ្អែកលើភស្តុតាងនិងដែលអាចស្តែងជាសកម្មភាពបានសម្រាប់អន្តរាគមន៍ជាក់លាក់ចំពោះប្រទេសកម្ពុជា ដោយផ្អែកលើក្របខណ្ឌគំរូនៃការឆ្លើយតបថ្នាក់ជាតិ (MNR) នៃ WePROTECT ដែលនឹងបញ្ចូលទៅក្នុងការរៀបចំផែនការសកម្មភាពសម្រាប់ឆ្លើយតបនឹង OCSE នៅក្នុងប្រទេសកម្ពុជា។

ខ្ញុំសូមសម្តែងនូវការដឹងគុណដ៏ជ្រៀលជ្រៅបំផុតចំពោះ**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** និងជាប្រធានកិត្តិយសនៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន** ដែលដឹកនាំការស្តារនិងអភិវឌ្ឍន៍ប្រទេសជាតិរីកចម្រើនលើគ្រប់វិស័យ ដោយក្នុងនោះក៏បានផ្សារភ្ជាប់ និងគិតពីឧត្តមប្រយោជន៍កុមារ និងផ្តល់នូវសេចក្តីអាណិតស្រឡាញ់ និងសន្តោសប្រណីចំពោះកុមារគ្រប់ៗរូប។

ខ្ញុំសូមកោតសរសើរ ថ្លែងអំណរគុណ និងវាយតម្លៃខ្ពស់ចំពោះសមាជិក សមាជិកាក្រុមប្រឹក្សាជាតិកម្ពុជា ដើម្បីកុមារ គណៈកម្មការការពារកុមារថ្នាក់ជាតិ ក្រុមការងារបច្ចេកទេសOCSE ក្រសួង ស្ថាប័នពាក់ព័ន្ធ និង អង្គការ Terre des Hommes Netherland ដៃគូអភិវឌ្ឍន៍នានា ព្រមទាំងក្មួយៗកុមារ ដែលបានចូលរួមយ៉ាងសកម្មក្នុងការពិនិត្យ និងផ្តល់យោបល់ដល់ការវិភាគស្ថានភាពដំបូងនេះ។ ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា បន្ទាប់ពី "អនុសាសន៍ដែលអាចធ្វើបានដោយផ្អែកលើភស្តុតាង" ត្រូវបានកំណត់ យើងនឹងបន្តសហប្រតិបត្តិការយ៉ាងសកម្មក្នុងការរៀបចំផែនការសកម្មភាពដើម្បីឆ្លើយតប ទប់ស្កាត់ និងអន្តរាគមន៍ដើម្បីជាឧត្តមប្រយោជន៍កុមារកម្ពុជា។៨១

ថ្ងៃ សុក្រ ៤កើត ខែបុស្ស ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣

រាជធានីភ្នំពេញ,ថ្ងៃទី២៧ ខែ ធ្នូ ឆ្នាំ២០១៩

**អគ្គលេខាធិការ**

ញៀប_សុភាព

# និយមន័យ

ការវិភាគស្ថានភាពដំបូងនេះប្រើប្រាស់និយមន័យដូចខាងក្រោម ភាគច្រើនត្រូវបានដកស្រង់ចេញពីគោលការណ៍ណែនាំនៃប្រទេសលុចហ្សំបួរ ស្តីពីវាក្យស័ព្ទសម្រាប់កិច្ចការពារកុមារពីការកេងប្រវ័ញ្ចនិងការរំលោភបំពានផ្លូវភេទ ឆ្នាំ២០១៦ និង WePROTECT ឆ្នាំ២០១៦។

**ការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ**
Online Child Sexual Exploitation_OCSE

សំដៅដល់ទម្រង់នៃការផលិត កាន់កាប់ ចែកចាយ ឬផ្សព្វផ្សាយ ការរំលោភបំពាននិងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ(CSEA) សម្ភារពាក់ព័ន្ធ CSAM រួមទាំងការលួងលោមជនដែលអាចនឹងរងគ្រោះ តាមរយៈការប្រើប្រាស់អ៊ិនធឺណិត។[1]

**ការរំលោភបំពាន និងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ**
Child Sexual Exploition and Abuse_CSEA

សំដៅដល់ទំនាក់ទំនងរវាងបុគ្គលណាម្នាក់ជាមួយកុមារ ដើម្បីប៉ះពាល់ដោយផ្ទាល់ ឬប្រយោល ស្ទាបអង្អែលកេរភេទ ឬផ្នែកភេទផ្សេងទៀតរបស់កុមារ ឬជាអំពើដែលបុគ្គលណាម្នាក់គៀបសង្កត់ដល់កុមារ ឬការធ្វើទំនាក់ទំនងផ្លូវភេទជាមួយកុមារ ឬផ្នែកឯកជនណាមួយនៃរាងកាយកុមារ ដោយមានឬគ្មានការយល់ព្រមពីកុមារ ដើម្បីផ្តោះផ្តូរនឹងវត្ថុមានតម្លៃ ឬអាហារ ឬកន្លែងស្នាក់នៅ។[2] (ចំណុចនេះមានចែងក្នុងច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ និងក្រមព្រហ្មទណ្ឌ )

**សម្ភារពាក់ព័ន្ធនឹងការរំលោភបំពានផ្លូវភេទលើកុមារ**
Child Sexual Abuse Material_CSAM

សំដៅដល់សម្ភារពាក់ព័ន្ធនឹងកុមារដែលអាចមើលឃើញនឹងភ្នែក ដូចជារូបថត វីដេអូ រួមទាំងសម្ភារអេឡិចត្រូនិច ដែលពិពណ៌នាអំពីកេរភេទ ឬភាពអាសអាភាសប្រហាក់ប្រហែលផ្សេងទៀត។ (ចំណុចនេះមានចែងក្នុងច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ និងក្រមព្រហ្មទណ្ឌ)

**សម្ភារពាក់ព័ន្ធនឹងកេងប្រវ័ញ្ចផ្លូវភេទលើកុមារ**
Child Sexual Exploitation Material_CSEM

សំដៅដល់ការផលិត ឬប្រើប្រាស់សម្ភារពាក់ព័ន្ធនឹងកុមារដែលអាចមើលឃើញនឹងភ្នែកដូចជារូបថត វីដេអូ រួមទាំងសម្ភារអេឡិចត្រូនិចដែលពិពណ៌នាអំពីកេរភេទ ឬរូបភាពអាសអាភាសប្រហាក់ប្រហែលផ្សេងទៀត។[3] (ចំណុចនេះមានចែងក្នុងច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ)

[1]ក្រុមការងារអន្តរទីភ្នាក់ងារស្តីពីការកេងប្រវ័ញ្ចផ្លូវភេទកុមារ ឆ្នាំ២០១៦ "គោលការណ៍ណែនាំស្តីពីវាក្យស័ព្ទសម្រាប់កិច្ចការពារកុមារពីការកេងប្រវ័ញ្ចផ្លូវភេទនិងការរំលោភបំពានផ្លូវភេទ" ទាញយកពី ៖ http://luxembourgguidelines.org/.

[2] *Ibid.*

[3] *Ibid.*

**ការផ្សាយផ្ទាល់ពីអំពើរំលោភបំពានផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ**
Live Online Child Sexual Abuse

សំដៅដល់ការបង្ហាញរូបភាព ឬវីដេអូ ដែលអនុញ្ញាតឲ្យអ្នកទស្សនាចូលរួមមើលដំណាលគ្នា ស្របពេលដែលការរំលោភបំពានកំពុងកើតឡើងតាមប្រព័ន្ធអនឡាញ។[4]

**ការលួងលោម**
Grooming

សំដៅដល់ការពោលពាក្យផ្អែមល្ហែម បង្ហាញរូបភាព ឬសំណេរដល់កុមារដើម្បីបំពេញចំណង់ផ្លូវភេទ។ នៅក្នុងបរិបទ OCSE សំដៅដល់ដំណើរការនៃការបង្កើត ឬការកសាងទំនាក់ទំនងជាមួយកុមារដោយផ្ទាល់ ឬតាមរយៈប្រព័ន្ធអនឡាញ ឬបច្ចេកវិទ្យាផ្សេងទៀត ដើម្បីឈានទៅដល់ទំនាក់ទំនងផ្លូវភេទតាមប្រព័ន្ធអនឡាញ ឬជួបផ្ទាល់ជាមួយនឹងកុមារនោះ។[5]

**ការគំរាមកំហែងផ្លូវភេទ**
Sextortion

សំដៅដល់ការគំរាមបុគ្គលណាម្នាក់ ដោយប្រើប្រាស់រូបភាព ឬវីដេអូថតដោយខ្លួនឯងរបស់បុគ្គលនោះ ដើម្បីគំរាមឲ្យមានការយល់ព្រមផ្លូវភេទ លុយកាក់ ឬផលប្រយោជន៍ផ្សេងទៀតពីបុគ្គលនោះ (ឧទាហរណ៍ដូចជាការបង្ហោះរូបភាព ឬវីដេអូ តាមបណ្ដាញទំនាក់ទំនងសង្គម)។[6]

**ការបញ្ជូនរូបភាពផ្លូវភេទរបស់ខ្លួនឯង**
Sexting

សំដៅដល់ការបង្កើតរូបភាពអាក្រាត ឬស្ទើរតែអាក្រាត ដោយខ្លួនឯងក្នុងគោលបំណងផ្ញើ ឬផ្លាស់ប្ដូររូបភាពពាក់ព័ន្ធនឹងផ្លូវភេទរបស់ខ្លួនតាមរយៈទូរស័ព្ទដៃ ឬប្រព័ន្ធអ៊ិនធឺណិត។[7]

Human Centered Design_**HCD**

សំដៅដល់ការបង្កើតវិធីសាស្ត្រក្នុងការដោះស្រាយបញ្ហា ដោយយកមនុស្សជាចម្បង ក្នុងគោលដៅដោះស្រាយបញ្ហាប្រកបដោយភាពច្នៃប្រឌិត ដោយចាប់ផ្ដើមជាមួយនឹងការស្ដាប់ និងការសិក្សាពីមនុស្សព្រមទាំងបញ្ចប់ជាមួយនឹងដំណោះស្រាយថ្មី ដែលមានប្រសិទ្ធភាពជាងមុន សមស្របនឹងតម្រូវការជាក់ស្ដែងរបស់ពួកគេ។

---

[4] *Ibid.*

[5] *Ibid.*

[6] *Ibid., 52*

[7] *Ibid., 44*

# អក្សរកាត់

| | |
|---|---|
| **AHTJP**<br>Anti Human Trafficking and Juvenile Protection | នាយកដ្ឋានប្រឆាំងអំពើជួញដូរមនុស្ស និងការពារអនីតិជន |
| Anti Cybercrime Department | នាយកដ្ឋានប្រឆាំងបទល្មើសបច្ចេកវិទ្យា |
| **APLE** | អង្គការសកម្មភាពដើម្បីកុមារ |
| **CHC**<br>Child Helpline Cambodia | អង្គការបណ្ដាញទូរស័ព្ទជំនួយកុមារកម្ពុជា |
| **CNCC**<br>Cambodia National Council for Children | ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ |
| **ECPAT**<br>End Child Prostitution, Abuse and Trafficking | អង្គការបញ្ចប់អំពើពេស្យាចារ ការរំលោភបំពាន និងការជួញដូរកុមារ |
| **NCMEC**<br>National Center for Missing and Exploited Children | មជ្ឈមណ្ឌលជាតិការពារកុមារបាត់ខ្លួន និងរងគ្រោះដោយការកេងប្រវ័ញ្ច។ មជ្ឈមណ្ឌលនេះ គឺជាអង្គការឯកជនមិនរកប្រាក់ចំណេញ មានមូលដ្ឋាននៅសហរដ្ឋអាមេរិក ដើម្បីផ្ដល់ព័ត៌មាន និងជួយស្វែងរកកុមារ ដែលត្រូវបានគេរាយការណ៍ថាបានបាត់ខ្លួន ក្នុងគោលបំណងជួយដល់កុមារ ដែលទទួលរងនូវការរំលោភបំពានផ្លូវកាយនិងផ្លូវភេទ។ អង្គការនេះបានក្លាយទៅជាផ្នែកដ៏សំខាន់មួយនៃប្រព័ន្ធរាយការណ៍ និងបញ្ជូនជាសាកលពាក់ព័ន្ធនឹងសម្ភាររំលោភបំពានផ្លូវភេទលើកុមារ |
| **ICT**<br>Information communications technology | បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន |
| **ISP**<br>Internet Service Provider | ក្រុមហ៊ុនផ្ដល់សេវាអ៊ិនធឺណិត |
| **MCFA**<br>Ministry of Culture and Fine Arts | ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ |

| | |
|---|---|
| **MNR**<br>Model National Response | គំរូនៃការឆ្លើយតបជាតិ |
| **MPTC**<br>Ministry of Posts and Telecommunications | ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ |
| **MoEYS**<br>Ministry of Education Youth and Sport | ក្រសួងអប់រំយុវជន និងកីឡា |
| **MoI**<br>Ministry of Interior | ក្រសួងមហាផ្ទៃ |
| **MoIF**<br>Ministry of Information | ក្រសួងព័ត៌មាន |
| **TRC**<br>Telecommunication Regulator of Cambodia | និយ័តករទូរគមនាគមន៍កម្ពុជា |
| **UNODC**<br>United Nations Office on Drugs and Crime | ការិយាល័យអង្គការសហប្រជាជាតិទទួលបន្ទុកគ្រឿងញៀននិងឧក្រិដ្ឋកម្ម |

# សេចក្តីសង្ខេប

ការវិភាគស្ថានភាពដំបូងនេះ ធ្វើឡើងដើម្បីប៉ាន់ប្រមាណលើការគំរាមកំហែងនាពេលបច្ចុប្បន្ន នៃការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ (OCSE) នៅក្នុងប្រទេសកម្ពុជា៖ ប៉ាន់ប្រមាណ ទីកន្លែង និងវិធីសាស្ត្រដែលជាកត្តាជំរុញកុមារឲ្យស្ថិតក្នុងស្ថានភាពងាយរងគ្រោះ ព្រមទាំងកំណត់នូវសមត្ថភាព និងភាពខ្វះចន្លោះនៃគោលនយោបាយជាតិ លិខិតបទដ្ឋានគតិយុត្ត យុត្តិធម៌ព្រហ្មទណ្ឌ សេវាសង្គម និងវិស័យឯកជន។ ការប៉ាន់ប្រមាណនេះធ្វើឡើងក្នុងគោលបំណងកំណត់នូវ"អនុសាសន៍ដែលអាចធ្វើបានដោយផ្អែកលើភស្តុតាង" ដើម្បីឆ្លើយតបទៅនឹងOCSE នៅក្នុងបរិបទនៃប្រទេសកម្ពុជា ដែលអនុលោមទៅតាមគំរូនៃការឆ្លើយតបជាតិ WePROTECT ដោយរៀនពីការអនុវត្តល្អកម្រិតជាតិនិងថ្នាក់អន្តរជាតិ។

OCSE គឺជាទម្រង់នៃការរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទលើកុមារដែលកំពុងរាលដាល និងបង្ករឡើងតាមរយៈប្រព័ន្ធអនឡាញ ការប្រើប្រាស់គេហទំព័រ បណ្តាញទំនាក់ទំនងសង្គម និងកម្មវិធីទូរស័ព្ទផ្សេងៗ។ ក្នុងនោះរួមមានការផលិត កម្មសិទ្ធិ និងការចែកចាយសម្ភារពាក់ព័ន្ធនឹងការរំលោភបំពានផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ ព្រមទាំងការលួងលោមកុមារដែលអាចជាជនរងគ្រោះតាមប្រព័ន្ធអនឡាញ ក្នុងចេតនាកេងប្រវ័ញ្ច ឬរំលោភបំពានផ្លូវភេទ និងការផ្សាយផ្ទាល់អំពីការរំលោភបំពានផ្លូវភេទលើកុមារ។[8]

តម្លៃសមរម្យនៃសេវាអ៊ិនធឺណិត កុំព្យូទ័រផ្ទាល់ខ្លួន និងទូរស័ព្ទដៃវៃឆ្លាត កំពុងរីកដុះដាលយ៉ាងឆាប់រហ័សនៅក្នុងសហគមន៍ដែលងាយរងគ្រោះនៅក្នុងប្រទេសកម្ពុជា ហើយការភ្ជាប់អ៊ិនធឺណិតចល័ត បណ្តាញទំនាក់ទំនងសង្គម និងការប្រើប្រាស់បច្ចេកវិទ្យា បានពង្រីកខ្លួនយ៉ាងខ្លាំងនៅក្នុង កំឡុងពេលប៉ុន្មានឆ្នាំចុងក្រោយនេះ។ បច្ចុប្បន្ននេះប្រជាជនកម្ពុជាជាងពាក់កណ្តាលនៃប្រជាជនសរុប មានទូរស័ព្ទដៃវៃឆ្លាតយ៉ាងតិចបំផុតម្នាក់១គ្រឿង (កើនឡើងចំនួន២១% ធៀបនឹងឆ្នាំ២០១៥) និងចំនួន៤៨% កំពុងប្រើប្រាស់Facebook[9]។ ស្របពេលដែលសេវានិងឧបករណ៍ភ្ជាប់អ៊ិនធឺណិត ទំនើបហើយមានតម្លៃកាន់តែសមរម្យ កើនឡើងគ្រប់ទីកន្លែងរួមទាំងនៅតាមសហគមន៍មានប្រាក់ចំណូលទាប បង្កជាសក្តានុពលប្រកបដោយហានិភ័យខ្ពស់គួរឲ្យកត់សម្គាល់ចំពោះកុមារ និងមនុស្សវ័យក្មេងដែលទំនងជាអ្នកជំនាញក្នុងការប្រើប្រាស់អ៊ិនធឺណិតយ៉ាងសកម្មក្នុងបណ្តាញទំនាក់ទំនងសង្គម។

បច្ចុប្បន្ននេះ មានការដឹងតិចតួចនៅប្រទេសកម្ពុជា អំពីវត្តមាននិងទំហំនៃOCSE (APLE, ២០១៦) ហើយការយល់ដឹងរបស់សហគមន៍នៅមានកម្រិតទាប។[10] ផែនការសកម្មភាពដើម្បីទប់ស្កាត់ និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារ(២០១៧-២០២១) កំណត់ភាពខ្វះចន្លោះយ៉ាងច្បាស់នៅក្នុងច្បាប់ សមត្ថភាពអនុវត្តច្បាប់ ការយល់ដឹងរបស់សហគមន៍ និងឧស្សាហកម្មឯកជនក្នុងការឆ្លើយតបចំពោះបញ្ហាOCSE។ រាជរដ្ឋាភិបាលកម្ពុជា គឺជាភាគីហត្ថលេខីនៃសេចក្តីថ្លែងការណ៍សកម្មភាព WePROTECT ដែលត្រូវបានចុះហត្ថលេខានៅឯកិច្ចប្រជុំកំពូលជាសកល នៅទីក្រុងអាប៊ុយដាប៊ី ក្នុងឆ្នាំ២០១៥។ គំរូនៃការឆ្លើយតបថ្នាក់ជាតិនៃ WePROTECT សង្កត់ធ្ងន់លើសារៈសំខាន់នៃការចូលរួមរបស់អ្នកពាក់ព័ន្ធនានា និងកំណត់នូវឧស្សាហកម្មអ្នកពាក់ព័ន្ធសំខាន់ នៅក្នុងកិច្ចការពារកុមារតាមប្រព័ន្ធអនឡាញ។

---

[8] WePROTECT. (2016)

[9] UNICEF. (2016)

[10] ក្រសួងកិច្ចការនារី (ឆ្នាំ២០១៤)

**វិធីសាស្ត្រ**: ការវិភាគស្ថានភាពដំបូងនេះ ប្រើប្រាស់សិក្ខាសាលារៀនសូត្រ ការអង្កេតតាមប្រព័ន្ធអនឡាញ និងការពិភាក្សាស៊ីជម្រៅ ដើម្បីបង្កើតនូវការយល់ដឹងទូលំទូលាយអំពីចរិត និងទំហំនៃOCSE នៅក្នុងប្រទេសកម្ពុជានៅកម្រិតសហគមន៍ រាប់បញ្ចូលទាំងការប៉ាន់ប្រមាណសមត្ថភាពការពារកុមារ ដោយរដ្ឋាភិបាល យុត្តិធម៌ព្រហ្មទណ្ឌ សង្គមស៊ីវិល និងឧស្សាហកម្មឯកជន។ ការសិក្សានេះ មានគោលបំណងកំណត់អនុសាសន៍ ផ្អែកលើភស្តុតាង និងដែលអាចស្តែងជាសកម្មភាពបាន សម្រាប់អន្តរាគមន៍ជាក់លាក់ចំពោះប្រទេសកម្ពុជា ដោយផ្អែកលើក្របខណ្ឌគំរូនៃការឆ្លើយតបជាតិ WePROTECT ដែលនឹងរៀបចំជាផែនការសកម្មភាពសម្រាប់ឆ្លើយតបទៅនឹង OCSE នៅក្នុងប្រទេសកម្ពុជា។

សិក្ខាសាលារៀនសូត្រ ឆ្លើយតបនឹងសំណួរសំខាន់ៗនៃការសិក្សានេះ និងរិះរកទម្រង់ផ្សេងៗ នៃOCSE ដែលត្រូវបានជួបប្រទះ ក្នុងចំណោមកុមារកម្ពុជា។ សិក្ខាសាលារៀនសូត្រចំនួន១៣លើក ត្រូវបានរៀបចំឡើងជាមួយកុមារចំនួន២២០នាក់ ដែលមានអាយុចាប់ពី៨ ដល់១៧ឆ្នាំ និងគ្រូបង្រៀនចំនួន៤៥នាក់ មកពីសាលារៀនរដ្ឋ សាលារៀនឯកជន និងមណ្ឌលសាលារៀនអង្គការមិនមែនរដ្ឋាភិបាល នៅក្នុងតំបន់ចំនួនបីនៃប្រទេសកម្ពុជា រួមមាន ខេត្តព្រះសីហនុ ខេត្តសៀមរាប និងរាជធានីភ្នំពេញ។ បន្ថែមលើនេះ សិក្ខាសាលាចំនួន៣ត្រូវបានរៀបចំឡើងជាមួយគ្រូបង្រៀនចំនួន៤៥នាក់ នៅក្នុងតំបន់ទាំងបីនោះ ដើម្បីបង្កើតការយល់ដឹងអំពី របៀបគិតនិងដំណោះស្រាយរបស់ពួកគេពាក់ព័ន្ធនឹងបញ្ហាកិច្ចការពារកុមារនៅលើប្រព័ន្ធអនឡាញ។ ទាក់ទងនឹងការប៉ាន់ប្រមាណសមត្ថភាពកិច្ចការពារកុមារ ការសម្ភាសស៊ីជម្រៅចំនួន៤៥ដង ត្រូវបានធ្វើឡើងជាមួយអ្នកតំណាងសំខាន់ៗ មកពីអង្គភាពអនុវត្តច្បាប់ ទីភ្នាក់ងារ ឬស្ថាប័នរដ្ឋាភិបាល និងអង្គការការពារកុមារថ្នាក់ជាតិ ថ្នាក់តំបន់ និងថ្នាក់អន្តរជាតិ ព្រមទាំងអ្នកពាក់ព័ន្ធក្នុងវិស័យឯកជននៅកម្ពុជា។ ការសម្ភាសន៍ទាំងនេះបានប៉ាន់ប្រមាណមើលការយល់ដឹង និងសមត្ថភាពរបស់អ្នកឆ្លើយសំណួរទាក់ទងនឹងOCSE ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់កុមារនិងសហការជាមួយដៃគូ និងទីភ្នាក់ងារពាក់ព័ន្ធក្នុងការទប់ស្កាត់ការរំលោភបំពាន និងការកេងប្រវ័ញ្ចលើកុមារតាមប្រព័ន្ធអនឡាញនៅប្រទេសកម្ពុជា។

ជាចុងក្រោយ ការអង្កេតតាមប្រព័ន្ធអនឡាញ ត្រូវបានធ្វើឡើងជាមួយយុវសិស្សចំនួន១៣៩នាក់ នៅខេត្តបាត់ដំបង។ ចេតនាដំបូងនៃការស្រាវជ្រាវនេះ គឺដើម្បីប្រមូលសំណាកតំណាងជាតិពីយុវវ័យកម្ពុជានៅតាមសាលារៀនរដ្ឋ សាលារៀនឯកជន និងសាលារៀនបំពេញវិជ្ជា ប៉ុន្តែដោយសារពេលវេលាមានកំណត់ និងឧបសគ្គនយោបាយធ្វើឲ្យទំហំនៃការអង្កេតនេះនៅមានកម្រិត។ ទិន្នន័យដែលបង្ហាញនៅក្នុងការអង្កេតនេះមិនអាចធ្វើជាតំណាងជាតិទាំងមូលបានឡើយ ប៉ុន្តែវាបានផ្តល់នូវបណ្តុំនៃការរៀនសូត្រសំខាន់ៗ អំពីការប្រើប្រាស់អ៊ិនធឺណិតក្នុងចំណោមក្រុមយុវវ័យ និងការប្រៀបធៀបដ៏មានសក្តានុពលខ្ពស់ជាមួយនឹងការរៀនសូត្រផ្សេងៗទៀត ដែលបានដកស្រង់ចេញពីការសិក្សាស្រាវជ្រាវនេះ។ របកគំហើញនៃការសិក្សានេះ ត្រូវបានបញ្ចូលជាឧបសម្ព័ន្ធ នៅក្នុងរបាយការណ៍នេះ និងឆ្លុះបញ្ចាំងនៅក្នុងការពិភាក្សា និងអនុសាសន៍សំខាន់ៗនៃការសិក្សានេះ។ ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ (ក.ជ.ក) សង្ឃឹមថានឹងមានគំនិតផ្តួចផ្តើមលើការសិក្សាស្រាវជ្រាវដែល គ្រប់ដណ្តប់នូវសំណាកថ្នាក់ជាតិ ដោយសហការជាមួយអ្នកពាក់ព័ន្ធ ដើម្បីកសាងបន្ថែមលើរបកគំហើញដែលមានកម្រិតនេះ ដោយមានការចូលរួមពីយុវជននៃកម្មវិធីអប់រំសាធារណៈ ឯកជន និងកម្មវិធីអប់រំបំពេញវិជ្ជា។

**កុមារ និងសហគមន៍**: កុមារបានបង្ហាញយ៉ាងច្បាស់នូវហានិភ័យOCSE និងការយល់ដឹងសំខាន់ៗអំពីហានិភ័យទាំងនោះក្នុងកម្រិតសហគមន៍លើប្រព័ន្ធអ៊ិនធឺណិត។

តាមរយៈការធ្វើសិក្ខាសាលាចំនួន១៣លើក ជាមួយកុមារចំនួន៤៧ក្រុម នៅក្នុងខេត្តនិងក្រុងទាំង៣ បង្ហាញថា២៨% នៃក្រុមទាំងនេះ បានពណ៌នាអំពីការយល់ដឹងអំពីរបៀបដែលបណ្តាញទំនាក់ទំនងសង្គមតាមប្រព័ន្ធអ៊ិនធឺ

ណិត ជាពិសេស Facebook ដែលត្រូវបានប្រើប្រាស់សម្រាប់លួងលោមកុមារ ដើម្បីកេងប្រវ័ញ្ចផ្លូវភេទលើប្រព័ន្ធអ៊ីនធឺណិត និងជាបុគ្គល។ ២៧% បានពណ៌នាថា ការទាក់ទាញនិងការចែកចាយសម្ភារពាក់ព័ន្ធនឹងការរំលោភបំពានផ្លូវភេទលើកុមារ (CSAM) ជាបញ្ហាប្រឈមខ្ពស់។ ២៤,១% បានពណ៌នាអំពីទម្រង់ផ្សេងៗនៃការផ្សាយផ្ទាល់អំពីការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ និង៦០,៣% បានពណ៌នាអំពីការចែកចាយសម្ភារអាសអាភាសរបស់មនុស្សពេញវ័យថាជាបញ្ហាប្រឈមខ្ពស់នៅក្នុងប្រព័ន្ធអ៊ីនធឺណិត។

ក្នុងចំណោមកុមារចំនួន២២០នាក់ ដែលជាអ្នកចូលរួមក្នុងសិក្ខាសាលាខាងលើ មានកុមារចំនួន៣៧នាក់ ឬស្មើនឹង១៧% (១ក្នុងចំណោម៦នាក់) បានចែករំលែកបទពិសោធន៍ផ្ទាល់ខ្លួនអំពីហានិភ័យពាក់ព័ន្ធនឹងOCSE ហើយមាន២៩នាក់ក្នុងចំណោមកុមារទាំង៣៧នាក់នេះ បានពណ៌នាអំពី OCSE ក្នុងរូបភាពលួងលោម ឬទម្រង់ផ្សេងៗនៃការប៉ុនប៉ងពាក់ព័ន្ធនឹងផ្លូវភេទ ប្រព្រឹត្តដោយមនុស្សពេញវ័យតាមប្រព័ន្ធអ៊ីនធឺណិត។ មានកុមារ១ក្នុងចំណោមកុមារ៤នាក់ឬ២៥% បានចែករំលែកយោបល់ផ្ទាល់ខ្លួនផ្សេងៗ(១៨នាក់) ឬខ្លឹមសារពីអ្នកដទៃ(១១នាក់) អំពីការលួងលោម ឬការប៉ុនប៉ងពាក់ព័ន្ធនឹងផ្លូវភេទ ប្រព្រឹត្តដោយមនុស្សពេញវ័យតាមប្រព័ន្ធអ៊ីនធឺណិត មានកុមារ១ក្នុងចំណោមកុមារ៥នាក់ឬ២០% បានចែករំលែកសេណារីយ៉ូចម្រុះគ្នា ដែលមនុស្សពេញវ័យ និងកុមារផ្សេងទៀតផ្សព្វផ្សាយតាមអ៊ីនធឺណិត ដែលធ្វើឲ្យពួកគេមើលឃើញសម្ភារអាសអាភាសរបស់មនុស្សពេញវ័យយ៉ាងច្បាស់ ហើយ ៦នាក់ ឬ៥% បានចែករំលែកនូវហេតុការណ៍នៃការថត ឬចែករំលែករូបភាពផ្លូវភេទរបស់ពួកគេផ្ទាល់ និងរបស់កុមារផ្សេងទៀតតាមប្រព័ន្ធអ៊ីនធឺណិត។

បន្ថែមលើរបកគំហើញទាំងនេះ របាយការណ៍ឆ្នាំ២០១៨ (ពីខែមករា ដល់ខែវិច្ឆិកា) ដែលដាក់ជូនដោយមជ្ឈមណ្ឌលជាតិការពារកុមារបាត់ខ្លួននិងរងគ្រោះដោយការកេងប្រវ័ញ្ច(NCMEC) ទៅការិយាល័យស៊ើបអង្កេតសន្តិសុខមាតុភូមិនៃសហរដ្ឋអាមេរិក(HSI) នៅរាជធានីភ្នំពេញបានបង្ហាញ ឲ្យឃើញនូវការកើនឡើងចំនួន៤៩០% (ចំនួន ២៥.៣៣២ករណី ក្នុងឆ្នាំ២០១៧ និង១២៣.៨៩៦ករណីក្នុងឆ្នាំ២០១៨) នៃសម្ភារពាក់ព័ន្ធនឹងការរំលោភបំពានផ្លូវភេទលើកុមារ(CSAM)នៅកម្ពុជា។ កាន់តែគួរឲ្យកត់សម្គាល់ជាងនេះទៅទៀត ស្មើតែ១ភាគ៣នៃករណីសរុបនេះ (២៩% ឬ៣៥.៩១៣ករណី) ត្រូវបានចាត់ទុកថាជាហេតុការណ៍ថ្មីដែលអាចចាត់វិធានការបាន និងចង្អុលបង្ហាញអំពីការកើនឡើងមិនត្រឹមតែការចែកចាយCSAMប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងមានការផលិតសម្ភារថ្មីៗផងដែរ។

**សមត្ថភាពកិច្ចការពារកុមារជាតិ:** ថ្នាក់ដឹកនាំសំខាន់នៃនាយកដ្ឋានប្រឆាំងអំពើជួញដូរមនុស្ស និងការពារអនីតិជន (ដែលមានភារកិច្ចឆ្លើយតបចំពោះទម្រង់ផ្សេងៗនៃការកេងប្រវ័ញ្ចផ្លូវភេទ និងអំពើហិង្សាលើកុមារ) មានការយល់ដឹងយ៉ាងច្បាស់ជុំវិញករណីបែបបុរាណនៃការរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទកុមារ ដែលជនខិលខូចម្នាក់ប្រើប្រាស់កម្មវិធីអ៊ីនធឺណិត (ជាពិសេស Facebook) សម្រាប់រៀបចំការណាត់ជួបកុមារ ដើម្បីរំលោភបំពាននៅក្រៅអ៊ីនធឺណិត និងមើលរំលង ឬមិនបានពិចារណាអំពី ការកេងប្រវ័ញ្ច ដែលកើតមានតាមអ៊ីនធឺណិតទាំងស្រុង។ ទោះជាយ៉ាងណាក៏ដោយ ការយល់ដឹងពាក់ព័ន្ធនឹងភាពទូទៅនៃOCSE ឬវិសាលភាពនិងតួនាទីរបស់អ៊ីនធឺណិតជាវិធីដ៏ស្រួលនៃការរំលោភបំពាននិងកេងប្រវ័ញ្ចផ្លូវភេទលើកុមារក្នុងសហគមន៍កម្ពុជា នៅមានកម្រិតនៅឡើយ។

បន្ថែមលើនេះ អង្គភាពប្រឆាំងបទល្មើសបច្ចេកវិទ្យា ដែលទទួលខុសត្រូវក្នុងការតាមដាន និងស៊ើបអង្កេតឧក្រិដ្ឋកម្មទាក់ទងនឹង OCSE គឺជាអង្គភាពដែលមានជំនាញឯកទេសជាក់លាក់ផ្តោតលើការស៊ើបអង្កេតបែបកោសល្យវិច្ច័យផ្ទាល់លើភស្តុតាង ដែលមាននៅក្នុងឧបករណ៍អេឡិចត្រូនិក បានមកពីការឆ្មក់ចូលឆែកកន្លែងកើតហេតុបទល្មើស។ នេះជាការមើលរំលងឧក្រិដ្ឋកម្មពាក់ព័ន្ធនឹងOCSE ភាគច្រើន និងបង្ហាញនូវភាពខ្វះចន្លោះគួរឲ្យកត់សម្គាល់

នៅក្នុងសមត្ថភាពរបស់ជាតិ ក្នុងការឆ្លើយតបចំពោះបញ្ហាOCSE ប្រកបដោយប្រសិទ្ធភាព។ ជារួមអង្គភាព នេះមិនទាន់មានសមត្ថភាពពេញលេញក្នុងការស៊ើបអង្កេតឧក្រិដ្ឋកម្ម ដែលប្រព្រឹត្តតាមប្រព័ន្ធអ៊ិនធឺណិតនៅឡើយ។

**ឧបសគ្គក្នុងយុត្តិធម៌ព្រហ្មទណ្ឌ** រួមមាន: កង្វះចំណេះដឹងថ្មីអំពីបច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍ ដែលយុវវ័យកំពុងប្រើប្រាស់ និងនិន្នាការសំខាន់ៗផ្នែកបច្ចេកវិទ្យា កង្វះធនធានស៊ើបអង្កេតនៅតាមសហគមន៍ កង្វះទំនាក់ទំនងជាមួយអ្នកឯកទេសបច្ចេកទេសនិងធនធានអន្តរជាតិដែលមានស្រាប់ និងការពឹងផ្អែកខ្លាំងលើវិធីសាស្ត្រស៊ើបអង្កេតផ្ទាល់បែបបុរាណ ដែលមិនមានសារប្រយោជន៍ខ្លាំងក្នុងការដោះស្រាយបទល្មើសក្នុងបរិបទឌីជីថល។

**អនុសាសន៍សំខាន់ៗ :** សិស្ស និងគ្រូបង្រៀនរបស់ពួកគេបានសង្កត់ធ្ងន់លើតម្រូវការឲ្យមានការបណ្តុះបណ្តាលអំពីអ៊ិនធឺណិត និងការលើកកម្ពស់ការយល់ដឹងជុំវិញបញ្ហាOCSE រួមមានវគ្គបណ្តុះបណ្តាលអំពីវិធី ១).ប្រើប្រាស់និងការកំណត់ឯកជនភាពនៅតាមបណ្តាញទំនាក់ទំនងសង្គមដើម្បីធ្វើឲ្យរូបភាព និងព័ត៌មានផ្ទាល់ខ្លួនរបស់ពួកគេប្រកបដោយសុវត្ថិភាពខ្ពស់។ ២).វិធីកំណត់លេខសម្ងាត់កាន់តែមានសុវត្ថិភាព ដើម្បីការពារគណនីរបស់អ្នកប្រើប្រាស់ និង ៣).វិធីស្វែងយល់ពីទង្វើនានារបស់អ្នកប្រម៉ាញ់តាមប្រព័ន្ធអ៊ិនធឺណិត។ បន្ថែមលើនេះទៀត សិស្ស និងគ្រូបង្រៀនបង្ហាញពីតម្រូវការចង់ឲ្យឪពុកម្តាយយល់ដឹងកាន់តែច្បាស់អំពីបរិយាកាស និងការចំណាយពេលវេលាយ៉ាងច្រើនក្នុងការប្រើប្រាស់អ៊ិនធឺណិតរបស់កូនៗពួកគាត់។ ស្របពេលដែលគ្រូបង្រៀនយល់ឃើញថាសុវត្ថិភាពរបស់កុមារលើប្រព័ន្ធអ៊ិនធឺណិតជាបញ្ហាចចាំបាច់ កុមារនៅក្នុងសិក្ខាសាលារៀនសូត្រក៏បានបង្ហាញពីការស្វាគមន៍ចំពោះពីការចូលរួមដោយវិជ្ជមានរបស់ឪពុកម្តាយនៅក្នុងបរិយាកាសអ៊ិនធឺណិតរបស់ពួកគេដែរ។

ការស្រាវជ្រាវនេះបានផ្តល់អនុសាសន៍ឲ្យមានការបង្កើត "អង្គភាពពហុវិស័យថ្នាក់ជាតិ" ដើម្បីទទួលខុសត្រូវលើកិច្ចការពារកុមារនៅក្នុងបរិយាកាសអ៊ិនធឺណិត ដោយរាប់បញ្ចូលទាំងសង្គមស៊ីវិល និងឧស្សាហកម្មឯកជន។ អ្វីដែលល្អបំផុតនោះគឺ "អង្គភាពពហុវិស័យថ្នាក់ជាតិ" គួរតែដឹកនាំដោយថ្នាក់ដឹកនាំជាន់ខ្ពស់របស់រដ្ឋាភិបាល និងមន្ត្រីអនុវត្តច្បាប់។ លើសពីនេះ ការស្រាវជ្រាវ ក៏បានផ្តល់នូវកម្រងអនុសាសន៍ទាក់ទងនឹងសមត្ថភាពការពារកុមារនៅប្រទេសកម្ពុជា រាប់បញ្ចូលទាំងការបង្កើតនិងជំនាញឯកទេសនៃអង្គភាពប្រឆាំងបទល្មើសបច្ចេកវិទ្យា ដើម្បីឲ្យកិច្ចសហការជាមួយនគរបាល សង្គមស៊ីវិល ការិយាល័យសន្តិសុខមាតុភូមិសហរដ្ឋអាមេរិក និងដៃគូពាក់ព័ន្ធផ្សេងទៀតកាន់តែមានប្រសិទ្ធភាពខ្ពស់ ក្នុងគោលបំណងដោះស្រាយករណីបទល្មើស ដំណើរការករណីកសាងសមត្ថភាពការងារចារកម្ម និងការស៊ើបអង្កេតជាក់ស្តែង ជាពិសេសផ្តោតលើករណីដែលមានស្រាប់ដែលបានបញ្ជូនពីNCMEC ទៅកាន់HSI អាមេរិក។

នៅក្នុងបរិបទនេះ ការស្រាវជ្រាវបានកំណត់រកឃើញតម្រូវការបន្ទាន់មួយ ក្នុងការបង្កើតឲ្យមានការភ្ជាប់ទំនាក់ទំនងជាប្រចាំរវាងការិយាល័យកណ្តាល(NCB) និងនគរបាលអន្តរជាតិ (Interpol) ដែលនឹងជួយសម្រួលឲ្យមានការឯកភាពលើដំណើរការនៃការដោះស្រាយ CSAM ដើម្បីធានាថារូបភាពទាំងអស់ត្រូវបានចំរាញ់ទុក និងរៀបចំជាបញ្ជី ហើយអនុញ្ញាតឲ្យមន្ត្រីអនុវត្តច្បាប់អន្តរជាតិអាចចូលមើលបាន។ លើសពីនេះ គួរធ្វើការខិតខំប្រឹងប្រែងបន្ថែមទៀតដើម្បីឲ្យអង្គភាពអនុវត្តច្បាប់កម្ពុជា ឈានដល់កម្រិតបទដ្ឋានពេញលេញដែលអនុញ្ញាតឲ្យមានការភ្ជាប់ទំនាក់ទំនងជាផ្លូវការជាមួយនឹងទិន្នន័យមូលដ្ឋាននៃការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ(ICSE)របស់នគរបាលអន្តរជាតិដែលនឹងពង្រឹងសមត្ថភាពប្រតិបត្តិការរបស់អង្គភាពអនុវត្តច្បាប់កម្ពុជា នៅក្នុងដំណើរការកំណត់រកជនរងគ្រោះ និងជនល្មើសនៅទូទាំងប្រទេស និងផ្តល់ឧបករណ៍ និងធនធានអន្តរជាតិយ៉ាងច្រើនសន្ធឹកសន្ធាប់សម្រាប់ឆ្លើយតបបានកាន់តែប្រសើរចំពោះបញ្ហា OCSE។

# វគ្គទី១: សេចក្តីផ្តើម

ការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ គឺជាទម្រង់ថ្មីដែលកំពុងលេចឡើងសម្រាប់ការកេងប្រវ័ញ្ចនិងការរំលោភបំពានផ្លូវភេទលើកុមារ តាមប្រព័ន្ធអ៊ិនធឺណិត ដោយប្រើប្រាស់គេហទំព័រ បណ្តាញទំនាក់ទំនងសង្គម និងកម្មវិធីសូហ្វវែរនានា។ ក្នុងនោះរួមមាន ការផលិត ការកាន់កាប់ និងការចែកចាយសម្ភារពាក់ព័ន្ធនឹងការរំលោភបំពានផ្លូវភេទកុមារតាមប្រព័ន្ធអ៊ិនធឺណិត រាប់បញ្ចូលទាំងការផ្សាយផ្ទាល់នូវការកេងប្រវ័ញ្ចនិងការរំលោភបំពានផ្លូវភេទលើកុមារ[11]។ ជាសកល ការទទួលបានសេវាអ៊ិនធឺណិត កុំព្យូទ័រផ្ទាល់ខ្លួន និងទូរស័ព្ទដៃវៃឆ្លាតតម្លៃសមរម្យកំពុងកើនឡើងយ៉ាងឆាប់រហ័សនៅក្នុងសហគមន៍ក្រីក្រ និងងាយរងគ្រោះ។ ក្នុងតំបន់អាស៊ីអាគ្នេយ៍ មានប្រជាជន៧៥% មានទូរស័ព្ទដៃវៃឆ្លាត និងមានលើសពី២ភាគ៣នៃអ្នកប្រើប្រាស់អ៊ិនធឺណិតកំពុងប្រើប្រាស់គេហទំព័របណ្តាញសង្គម និងកម្មវិធីសូហ្វវែរ តាមរយៈឧបករណ៍ចល័ត។[12] យ៉ាងហោចណាស់ មានអ្នកប្រើប្រាស់បណ្តាញទំនាក់ទំនងសង្គមចំនួន៧៥០លាននាក់នៅទូទាំងតំបន់។[13]

ការភ្ជាប់ប្រព័ន្ធអ៊ិនធឺណិតចល័ត បណ្តាញទំនាក់ទំនងសង្គម និងការប្រើប្រាស់បច្ចេកវិទ្យា បានពង្រីកខ្លួនយ៉ាងខ្លាំងនៅក្នុងប្រទេសកម្ពុជាក្នុងកំឡុងពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ហើយនិន្នាការនេះ ត្រូវបានព្យាករណ៍ថានឹងបន្តកើនឡើង។ យ៉ាងហោចណាស់ មានអ្នកប្រើប្រាស់ប្រមាណជាង១៩,៥លានលេខទូរស័ព្ទ ត្រូវបានចុះបញ្ជីនៅក្នុងប្រទេសកម្ពុជា ឬ១១៩% នៃប្រជាជនសរុប[14]។ ទិន្នន័យដែលត្រូវប្រមូលនៅឆ្នាំ២០១៦ តាមរយៈការសម្ភាសជាមួយអ្នកចូលរួម២.០៦១នាក់ អាយុចន្លោះពី១៥ឆ្នាំ និង៦៥ឆ្នាំ នៅទូទាំងប្រទេសកម្ពុជាបង្ហាញថា មានប្រជាជន៤៨% និយាយថា ពួកគេប្រើប្រាស់ ឬធ្លាប់បានប្រើប្រាស់Facebook។ ក្នុងនោះ៣៤%ក្នុងឆ្នាំ២០១៥ ២៣%ក្នុងឆ្នាំ២០១៤ និង១៦%ក្នុងឆ្នាំ២០១៣។ ទិន្នន័យនេះ បើធៀបជាមួយឆ្នាំ២០១៥ មានការកើនឡើង៣៩% ស្របពេលមានការកើនឡើង១០៦%បើធៀបជាមួយឆ្នាំ២០១៤ និងកើនឡើង២០០%បើធៀបជាមួយឆ្នាំ២០១៣។ អ្នកប្រើប្រាស់Facebookជាបុរសមានចំនួនច្រើនជាងស្ត្រី គឺ៥៥%ទល់នឹង៤១%។[15] ទន្ទឹមនឹងនេះ ក្នុងឆ្នាំ២០១៩ មានអ្នកប្រើប្រាស់ Facebook ជាបុរស៥៩% និងស្ត្រី៤១%។[16] មានការយល់ដឹងតិចតួចនៅក្នុងប្រទេសកម្ពុជា អំពីការគំរាមកំហែងតាមអ៊ិនធឺណិតជាក់លាក់ចំពោះកុមារ ប៉ុន្តែOCSEគឺជាក្តីបារម្ភដែលកំពុងតែកើនឡើង ក្នុងនោះប្រភពជាសាកលបង្ហាញថា ការប៉ុនប៉ងនៅក្នុងអ៊ិនធឺណិត និងបច្ចេកវិទ្យាចល័ត រួមចំណែកយ៉ាងខ្លាំងចំពោះការកេងប្រវ័ញ្ចផ្លូវភេទកុមារនៅក្នុងការធ្វើដំណើរ និងក្នុងវិស័យទេសចរណ៍។

ការតភ្ជាប់ប្រព័ន្ធអ៊ិនធឺណិត កុំព្យូទ័រផ្ទាល់ខ្លួន និងទូរស័ព្ទដៃវៃឆ្លាត នៅតាមសហគមន៍មានចំណូលទាបមានអត្ថប្រយោជន៍ផ្នែកសង្គម និងសេដ្ឋកិច្ចជាច្រើន។ ទោះបីជាយ៉ាងណា វាក៏បង្កនូវហានិភ័យគួរឲ្យកត់សម្គាល់ផងដែរចំពោះកុមារនិងមនុស្សវ័យក្មេង ដែលអាចជាអ្នកប្រើប្រាស់អ៊ិនធឺណិតល្បឿនលឿន និងចូលរួមសកម្មក្នុងបណ្តាញទំនាក់ទំនងសង្គម។ ការរីករាលដាលនៃការតភ្ជាប់ប្រព័ន្ធអ៊ិនធឺណិតនេះ បានបង្កលក្ខណៈកាន់តែងាយស្រួល និងឆាប់រហ័សដល់អ្នកប្រើប្រាស់អ៊ិនធឺណិត អាចទទួលបានសម្ភារពាក់ព័ន្ធនឹងការរំលោភបំពានផ្លូវភេទកុមារ និងធ្វើឲ្យមានការផ្សព្វផ្សាយសម្ភារ គាំទ្រអ្នកនិយមផ្លូវភេទកុមារក្នុងចំណោមភេទទីបី និងអ្នកដែលមានចំណាប់អារម្មណ៍ផ្លូវ

---

[11] WePROTECT. (2016).

[12] We are Social. (2017).

[13] *Ibid.*

[14] ប្រភព៖ TRC 2018.

[15] ប្រភព៖ វិទ្យាស្ថានបើកទូលាយ (Open Institute)-2016.

[16] ប្រភព៖ Geeks in Cambodia-2019.

ភេទជាមួយកុមារ[17]។ ដោយភាពធូរថ្លៃនៃសេវាអ៊ិនធឺណិត និងល្បឿននៃការតភ្ជាប់ទំនាក់ទំនងកាន់តែកើនឡើង ដូច្នេះការផ្ទេរទិន្នន័យទំហំធំអាចធ្វើបានរវាងនិងក្នុងចំណោមអ្នកប្រើប្រាស់។ ការពង្រីកការប្រើប្រាស់ប្រព័ន្ធអ៊ិនធឺណិត ជាការបង្ករបរិយាកាសក៏ងាយស្រួលដល់ជនខិលខូចនៅទូទាំងព្រំដែនតំបន់និងព្រំដែនអន្តរជាតិ[18] ដោយហេតុនេះ វាជាការនាំឲ្យយល់ខុសអំពីភាពស្របច្បាប់ចំពោះអ្នកដែលមានចំណាប់អារម្មណ៍ផ្លូវភេទជាមួយកុមារ[19]។ ស្របពេលដែលមិនដឹងអំពីចំនួនជនរងគ្រោះនៃOCSEជាសាកល ចំនួនគេហទំព័រដែលមានសម្ភារពាក់ព័ន្ធនឹងការរំលោភបំពានផ្លូវភេទលើកុមារ ត្រូវបានដកស្រង់ថាបានកើនឡើងចំនួន១៤៧% នៅរវាងឆ្នាំ២០១២ និង២០១៤ប៉ុណ្ណោះ ហើយការប៉ាន់ស្មាននាពេលបច្ចុប្បន្នបង្ហាញឲ្យឃើញថា វាគឺជាបញ្ហាគួរឲ្យកត់សម្គាល់ដែលកំពុងកើនឡើងយ៉ាងឆាប់រហ័ស[20]។

## ១.១. ទម្រង់ផ្សេងៗនៃ OCSE

### ១.១.១. សម្ភារពាក់ព័ន្ធនឹងការរំលោភបំពានកុមារ (CSAM) តាមប្រព័ន្ធអនឡាញ

ភាគច្រើននៃសំណេរអក្សរសាស្រ្តក្នុងតំបន់ដែលមាននិយាយអំពីOCSE មាននិន្នាការផ្តោតលើការផលិត និងការចែកចាយសម្ភារពាក់ព័ន្ធនឹងការរំលោភបំពានផ្លូវភេទលើកុមារ(CSAM) ឬម្យ៉ាងទៀតត្រូវគេស្គាល់ថាជា "រូបអាសអាភាសកុមារ"។ មានអង្គការអន្តរជាតិមួយចំនួន ដូចជា មូលនិធិឃ្លាំមើលតាមប្រព័ន្ធអ៊ិនធឺណិត(INHOPE) និងមជ្ឈមណ្ឌលជាតិការពារកុមារបាត់ខ្លួននិងរងគ្រោះដោយការកេងប្រវ័ញ្ច(NCMEC) ធ្វើការងារដោយសហការគ្នាជាមួយនគរបាលអន្តរជាតិ ទីភ្នាក់ងារឬស្ថាប័នអនុវត្តច្បាប់ និងក្រុមហ៊ុនផ្តល់សេវាកម្មអ៊ិនធឺណិត ដើម្បីដកយក CSAM ចេញពីអ៊ិនធឺណិត និងផ្តន្ទាទោសជនខិលខូច[21]។ ជាញឹកញាប់ CSAM តាមអ៊ិនធឺណិតទាមទារនូវការឆ្លើយតបដោយសហការគ្នា ដើម្បីដកយកសម្ភារទាំងនេះចេញនិងផ្តន្ទាទោសជនខិលខូច ដោយហេតុថា បាតុភូតនេះមានចរិតលក្ខណៈឆ្លងដែន។ កុមារអាចត្រូវរំលោភបំពាននៅក្នុងប្រទេសមួយ ប៉ុន្តែត្រូវចែកចាយនិងបង្ហោះនៅក្នុងServer ដែលមានទីតាំងនៅបណ្តាប្រទេសផ្សេងទៀត ហេតុនេះជាញឹកញាប់ បញ្ហានេះពាក់ព័ន្ធនឹងបទល្មើសជាច្រើនដែលកើតឡើងនៅក្នុងប្រទេសជាច្រើន។ បញ្ហានេះ អាចមានការស្មុគស្មាញបន្ថែមទៀត បើកាលណាផលិតករ និង/ឬ អ្នកចែកចាយCSAM នៅក្នុងប្រទេសម្ចាស់ផ្ទះគឺជាជនបរទេស។

សហគមន៍ជនខិលខូចតាមប្រព័ន្ធអនឡាញ នៅតែជាក្តីកង្វល់ចម្បងក្នុងវិស័យOCSEនេះ។ សហគមន៍បែបនេះ ប្រតិបត្តិការពីគេហទំព័រងងឹតដែលផ្តល់នូវបរិយាកាសកាន់តែមានសុវត្ថិភាព និងប្រកបដោយអនាមិកភាពសម្រាប់ជនខិលខូច ដើម្បីចែករំលែកCSAM ជាមួយជនខិលខូចផ្សេងទៀត និងដើម្បីបង្កើតទំនាក់ទំនងសង្គមមនុស្សដែលមានចំណាប់អារម្មណ៍ស្រដៀងគ្នា ដែលបង្កើតនូវការយល់ខុសអំពីភាពស្របច្បាប់ចំពោះអាកប្បកិរិយារបស់ពួកគេ[22]។ បន្ថែមលើនេះ ការផលិតCSAMយ៉ាងច្រើន គឺត្រូវបានធ្វើឡើងសម្រាប់គោលបំណងចែកចាយ ផ្ទុយពីសម្រាប់ការប្រើប្រាស់ផ្ទាល់ខ្លួនរបស់អ្នករំលោភបំពាន។ ពលរដ្ឋអឺរ៉ុបមួយចំនួន ត្រូវបានគេរាយការណ៍ថា មាននិន្នាការកើនឡើងឆ្ពោះទៅរកការផលិតCSAM ជាមធ្យោបាយរកប្រាក់ចំណូលសម្រាប់ផលិតករ ប៉ុន្តែមិនទាន់មានការយល់ដឹងពេញលេញអំពីមុខជំនួញទាំងនេះនៅឡើយទេ[23]។

[17]Elliott &Ashfield. (2011); Kierkegaard. (2008).
[18]ក្រសួងយុត្តិធម៌សហរដ្ឋអាមេរិក(ឆ្នាំ២០១៨) នគរបាលអន្តរជាតិ(ឆ្នាំ២០១៨)
[19]Kloss, et al. (2014).
[20]UNICEF. (2016).
[21]Net Clean. (2017).
[22]Europol. (2017).
[23] *Ibid.*

### ១.១.២. ការផ្សាយផ្ទាល់

ការផ្សាយផ្ទាល់អំពីការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ គឺជាទម្រង់ដែលកំពុងលេចឡើងនូវការកេងប្រវ័ញ្ចផ្លូវភេទកុមារតាមប្រព័ន្ធអនឡាញ(OCSE) ដែលពាក់ព័ន្ធនឹងការមើល និងការផ្សាយផ្ទាល់វីឌីអូអំពីកុមារសម្តែងសកម្មភាពផ្លូវភេទនៅមុខវ៉ែបខែម ឬម៉ាស៊ីនថតរបស់ទូរស័ព្ទដៃសម្រាប់មនុស្សពេញវ័យ ដើម្បីផ្តោះប្តូរនឹងលាភការជាមួយកុមារ ឪពុកឬម្តាយ ឬឈ្មួញកណ្តាល[24]។ លើកលែងប្រទេសហ្វីលីពីនចេញ គឺមានការពិភាក្សាគ្នាតិចតួចអំពីភាពងាយរងគ្រោះរបស់កុមារនៅក្នុងតំបន់អាស៊ាន ពាក់ព័ន្ធនឹងការប្រើប្រាស់សេវាកម្មផ្សាយផ្ទាល់សម្រាប់ការរំលោភបំពាន និងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ។ ការឆ្លើយតបជាច្រើនចំពោះOCSE នៅក្នុងរដ្ឋាភិបាល និងវិស័យ CSO បានផ្តោតការយកចិត្តទុកដាក់លើការកំណត់រក CSAM និងសម្ភារពាក់ព័ន្ធ ប៉ុន្តែបានមើលរំលងការរីកចម្រើនយ៉ាងឆាប់រហ័សនៃកម្មវិធីផ្សាយផ្ទាល់ ដូចជា Bigo Live, Cube TV, Magic Video, Blued, Live Chat, App Live ក្នុងចំណោមកម្មវិធីផ្សេងទៀត។ កម្មវិធីទាំងនេះ ភាគច្រើនមានជាកម្មវិធីបណ្តាញទំនាក់ទំនងសង្គម ដែលអ្នកប្រើប្រាស់ អាចផ្សាយផ្ទាល់អំពីផ្នែកមួយចំនួននៃជីវិតប្រចាំថ្ងៃរបស់ខ្លួន។ ទោះបីជាយ៉ាងណា កម្មវិធីទាំងនេះភាគច្រើន ត្រូវបានប្រើប្រាស់កាន់តែច្រើនឡើង សម្រាប់ជាមធ្យោបាយសម្រាប់ទំនាក់ទំនងជាមួយជនរងគ្រោះ និងចែករំលែកសម្ភារជាលក្ខណៈកេងប្រវ័ញ្ច[25]។ នៅពេលបានទំនាក់ទំនងគ្នាហើយ អ្នកប្រើប្រាស់មានជម្រើសក្នុងការឈានទៅដល់ការជជែកគ្នាជាលក្ខណៈឯកជន ឬប្រើប្រាស់សេវាកម្មទំនាក់ទំនងសង្គមផ្សេងទៀត ដែលសេវាកម្មជាច្រើនផ្តល់ការការពារសន្តិសុខសម្រាប់ការទំនាក់ទំនងគ្នា ហើយការកេងប្រវ័ញ្ចនិងការរំលោភបំពាន អាចកើតមានឡើង និងមានការថតរូប សម្លេងទុក ក្នុងពេលនៅជាមួយគ្នានោះផងដែរ។

### ១.១.៣. ការលួងលោមក្នុងគោលបំណងប៉ុនប៉ងផ្លូវភេទ

ដោយសារតែការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញគឺជាវិស័យថ្មី ដូច្នេះមានសំណេរអក្សរសាស្ត្រភាគច្រើន ធ្វើការស្រាវជ្រាវតែអំពីដំណើរការនៃការលួងលោម ក្នុងគោលបំណងរំលោភបំពារបំពានតាមប្រភពក្រៅអនឡាញដោយផ្ទាល់ ដោយមិនបានបង្ហាញជាក់លាក់អំពីការលួងលោមតាមប្រព័ន្ធអនឡាញឡើយ[26]។ បច្ចុប្បន្ននេះ កុមារបានចូលរួមពាក់ព័ន្ធជាលក្ខណៈបុគ្គល តាមរយៈការលួងលោមតាមប្រព័ន្ធអនឡាញ ឬតាមរយៈការចូលរួមក្នុង "មុខរបរជំនួញ" កាន់តែធំ ដែលដំណើរការដោយគ្រួសារ ឬអ្នកជិតខាង។

ការលួងលោមក្នុងគោលបំណងប៉ុនប៉ងផ្លូវភេទត្រូវបានគេយល់ថា ជាដំណើរការដែលជនខិលខូចប្រើប្រាស់ដើម្បីត្រៀមកុមារសម្រាប់ការរំលោភបំពានផ្លូវភេទ[27] និងពាក់ព័ន្ធជាមួយនឹងការរៀបចំ និងការប្រើប្រាស់ឱកាសនានាដែលមានគោលបំណងទទួលបាននូវការជឿទុកចិត្តពីកុមារ[28]។ ដំណើរការនេះ អាចជាកលល្បិចដ៏ប៉ិនប្រសប់ និងជាញឹកញាប់ពាក់ព័ន្ធនឹងសកម្មភាពដដែលៗ ដែលត្រូវកំណត់ចរិតលក្ខណៈតាមការបង្កើតទំនាក់ទំនងប្រកបដោយការជឿទុកចិត្ត និងនៅទីបំផុតរំលោភបំពានលើជំនឿទុកចិត្តរបស់កុមារ[29]។ ចាំបាច់គឺត្រូវទទួលស្គាល់ថា នៅក្នុងការរៀបចំដំណើរការលួងលោម ភាគច្រើនមិនកំណត់ត្រឹមតែកុមារប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងមានឪពុកម្តាយ អ្នកថែទាំគ្រួសារ

[24]Terre des Hommes-Netherlands. (2018).

[25]Europol. (2017).

[26]Kloss et al. (2014).

[27]Craven, et al. (2006).

[28]McAlinden. (2006).

[29]Finkelhor, D., & Wolak, J. (2004).

និងអ្នកផ្សេងទៀតផងដែរដែលជាមនុស្សគេទុកចិត្ត និងអ្នកដែលអាចជាឧបសគ្គចំពោះជនដែលអាចជាជនខិលខូច និងចំពោះការសម្របសម្រួលដំណើរការនេះ។

## ១.១.៤. រូបភាពផ្លូវភេទ ដែលត្រូវបានបង្កើតឡើងដោយខ្លួនឯង

ការផ្ញើរូបភាពផ្លូវភេទ ឬ"ការបញ្ជូនរូបភាពផ្លូវភេទ" គឺជានិន្នាការកំពុងកើនឡើង ក្នុងចំណោមកុមារ និងមនុស្សពេញវ័យក្មេងៗ។ ក្នុងបរិបទជាច្រើន ការផ្ញើបែបនេះហាក់ដូចជាមិនបង្កការខូចខាត ឈឺចាប់អ្វីទេ ប៉ុន្តែការវិភាគដោយមូលនិធិ INHOPE កត់សម្គាល់ថា មានការកើនឡើងនូវបទល្មើសឌីជីថល ដូចជា ការបង្ខិតបង្ខំ និងការគំរាមកំហែងដែលបង្កឲ្យមានការថតរូបភាពផ្លូវភេទរបស់ខ្លួនឯងកាន់តែច្រើនឡើង[30]។ នេះគឺជានិន្នាការមួយដែលគួរទទួលបានការយកចិត្តទុកដាក់ខ្ពស់ ដោយសារថារូបភាពទាំងនេះ អាចត្រូវគេយកទៅប្រើប្រាស់ដើម្បីគ្រប់គ្រង និងកេងប្រវ័ញ្ចយុវវ័យឲ្យផ្តល់ប្រាក់លស់ ឬអាចគេបង្ហាញរូបភាពច្បាស់ៗជាចំហ ដើម្បីប្តូរជាមួយនឹងកិច្ចការពារឯកជនភាពរបស់យុវវ័យ។

## ១.១.៥. CSEA តាមប្រព័ន្ធអនឡាញ និងក្រៅអនឡាញ

ជាញឹកញាប់ និយមន័យរវាង CSEA តាមប្រព័ន្ធអនឡាញ និងបុគ្គលផ្ទាល់ គឺមានភាពមិនច្បាស់លាស់ជាពិសេស ជាមួយនឹងការវិវឌ្ឍន៍យ៉ាងរហ័សនៃកម្មវិធីអនឡាញនិងឧបករណ៍នានា។ ដោយសារបញ្ហានេះCSEA ជាមួយនឹងសមាសធាតុតាមប្រព័ន្ធអនឡាញមួយចំនួនមានលក្ខណៈកាន់តែទូលំទូលាយ។ គោលការណ៍ណែនាំវាក្យស័ព្ទអន្តរជាតិសម្រាប់កិច្ចការពារកុមារពីការកេងប្រវ័ញ្ចផ្លូវភេទនិងការរំលោភបំពានផ្លូវភេទ ក៏ទទួលស្គាល់នូវភាពមិនច្បាស់លាស់នេះផងដែរ និងដកស្រង់ថា ជាជាងមើលឃើញការកេងប្រវ័ញ្ចតាមអនឡាញ ជាប្រភេទខុសគ្នានៃការកេងប្រវ័ញ្ច វាជាការសំខាន់ដែលអនឡាញត្រូវបានមើលឃើញយ៉ាងទូលំទូលាយថា ជាមធ្យោបាយដ៏មានសក្តានុពលនៅក្នុងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ[31]។

មានវិស័យមួយក្នុងចំណោមវិស័យទាំងនេះ ដែលជាទូទៅអាចត្រូវបានមើលរំលង គឺការប្រើប្រាស់កាន់តែច្រើនឡើងនូវកម្មវិធីទូរស័ព្ទ ដែលមានលក្ខណៈ "ភ្ជាប់ទំនាក់ទំនង" ដូចជា Grindr, Badoo, OkCupid, Jack'd ជាដើម និងកម្មវិធីផ្សេងទៀត ដែលកុមារនិងយុវវ័យអាចទទួលបានយ៉ាងងាយស្រួល។ ស្របពេលដែលកម្មវិធី ដូចជាកម្មវិធីទាំងនេះ មានគោលនយោបាយប្រឆាំងនឹងគណនីអ្នកប្រើប្រាស់សម្រាប់មនុស្សអាយុក្រោម១៨ឆ្នាំ គឺកុមារអាចបង្កើតគណនីបានយ៉ាងងាយស្រួល តាមរយៈការបង្ហាញថា ពួកគេមានអាយុលើសពី១៨ឆ្នាំ។ នៅលើកម្មវិធីទាំងនេះ កុមារអាចជួបជាមួយនឹងមនុស្សពេញវ័យនៅក្នុងកម្មវិធីនេះ ស្របពេលដែលការលួងលោមក្នុងគោលបំណងប៉ុនប៉ងផ្លូវភេទ និងការផ្លោះប្តូររូបភាពបង្ហាញផ្លូវភេទច្បាស់ អាចកើតឡើង ហើយបន្ទាប់មក អាចមានរៀបចំឲ្យមានការជួបគ្នាជាក់ស្តែង ក្រោយមកការរំលោភបំពានជាច្រើនអាចកើតឡើងបាន។

នគរបាលអឺរ៉ុបបានកំណត់ការបង្ខិតបង្ខំ និងការគំរាមកំហែងផ្លូវភេទកុមារ(SCE)ថា ជាក្តីបារម្ភដ៏សំខាន់មួយនៅក្នុងបរិបទនេះ។ ជាទូទៅ ជនខិលខូចផ្តួចផ្តើមទំនាក់ទំនងជាមួយកុមារ ដោយប្រើប្រាស់ព័ត៌មានប្រវត្តិរូប (Profile)ក្លែងក្លាយ ដោយអះអាងថា ខ្លួនពួកគេគឺជាអនីតិជនផ្សេងទៀត និងតែងតែទំនាក់ទំនងជាមួយកុមារជាច្រើននាក់ក្នុងពេលជាមួយគ្នា ជាញឹកញាប់ រក្សាព័ត៌មានប្រវត្តិរូបច្រើននៅទូទាំងកម្មវិធីបណ្តាញទំនាក់ទំនងសង្គមជាច្រើន ដោយអនុញ្ញាតឲ្យពួកគេផ្តោតគោលដៅលើកុមារផ្សេងៗគ្នាជាមួយនឹងចរិតលក្ខណៈខុសៗគ្នា[32]។

---

[31]Terre des Hommes. (2018); ECPAT International. (2016).

[32]Europol. (2017).

## ១.២. ការឆ្លើយតប

នៅក្នុងការឆ្លើយតបចំពោះ CSAM នៅប្រទេសកម្ពុជា អង្គការក្នុងប្រទេស និងអង្គការអន្តរជាតិមួយចំនួនកំពុងធ្វើការងារ ដើម្បីធ្វើឲ្យកុមារមានសុវត្ថិភាពនៅតាមប្រព័ន្ធអនឡាញ តាមរយៈការឆ្លើយតបចំពោះការគំរាមកំហែងនៃ OCSE។ ការឆ្លើយតបនេះ រួមមាន ការតាមដានត្រួតពិនិត្យជាសាកល និងអង្គការបណ្តាញរាយការណ៍បន្ទាន់ដោយសម្ងាត់ ដែលធ្វើការងារ ដើម្បីកំណត់និងដកយក CSEA ចេញពីអនឡាញ ផ្តល់នូវវេទិកាសម្រាប់សេចក្តីរាយការណ៍ វិភាគខ្លឹមសារ និងបញ្ជូនករណី CSAM ទៅកាន់រដ្ឋាភិបាលក្នុងប្រទេសសមស្រប ដើម្បីស៊ើបអង្កេត និងផ្តន្ទាទោស។ ក្រសួង ស្ថាប័នសំខាន់ៗមួយចំនួនដែលកំពុងធ្វើការងារដើម្បីឆ្លើយតបនឹង OCSE រួមមាន ៖

- **ក្រសួងមហាផ្ទៃ** មានអង្គភាពជំនាញបាននិងកំពុងដំណើរការ និងបំពេញភារកិច្ចក្នុងការទប់ស្កាត់ ការពារកុមារពីការរំលោភបំពានផ្លូវភេទតាមប្រព័ន្ធអនឡាញ ក្នុងនោះដែរបាននិងកំពុងដំណើរការនូវយន្តការ និងបង្កើតនូវគោលនយោបាយ បទដ្ឋានគតិយុត្តិក្នុងការចូលរួមឆ្លើយតប និងដោះស្រាយបញ្ហានេះផងដែរ។

- **ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍** មានអង្គភាពជំនាញបាននិងកំពុងធ្វើការ និងបំពេញភារកិច្ចគាំទ្រក្នុងការទប់ស្កាត់ ការពារកុមារពីការរំលោភបំពានផ្លូវភេទតាមប្រព័ន្ធអនឡាញ តាមរយៈការធ្វើនិយ័តកម្មក្នុងវិស័យទូរគមនាគមន៍ រួមទាំងបង្កើតនូវគោលនយោបាយ បទដ្ឋានគតិយុត្តិ និងបទដ្ឋានបច្ចេកទេសក្នុងការចូលរួមឆ្លើយតប និងដោះស្រាយបញ្ហានេះផងដែរ។

- **ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ (ក.ជ.ក.)** ជាយន្តការសម្របសម្រួលអន្តរក្រសួង ដែលដើរតួនាទីក្នុងការបញ្ជ្រាបការយល់ដឹងអំពី OCSE រៀបចំគោលនយោបាយ បទដ្ឋានគតិយុត្តិ និងផែនការសកម្មភាព។ ជាមួយគ្នានេះដែរ ក.ជ.ក. ជំរុញ និងលើកកម្ពស់ការចូលរួមជាពហុវិស័យក្នុងកិច្ចការពារកុមារពីOCSE ដើម្បីឧត្តមប្រយោជន៍កុមារ។

- **អង្គការដែនដីមនុស្ស-ហូឡង់ប្រចាំកម្ពុជា (TdH NL in Cambodia)** បានត្រួសត្រាយអភិក្រមនានាប្រកបដោយការច្នៃប្រឌិត ដើម្បីដោះស្រាយការងារ OCSE ជាមួយនឹង 'Sweetie' ការស្រាវជ្រាវ និងយុទ្ធនាការសាកល ហើយនិងដោយសារមានការទទួលស្គាល់ច្រើន អង្គការនេះក៏ត្រូវបានគេចាត់ទុកថាជាអ្នកដឹកនាំមួយក្នុងពិភពលោកលើវិស័យនេះ។

- **អង្គការសកម្មភាពដើម្បីកុមារ (APLE)៖** អង្គភាពនេះ បានរួមចំណែកគួរឲ្យកត់សម្គាល់ក្នុងការទប់ស្កាត់ និងការពារកុមារនៅទូទាំងប្រទេសអស់រយៈពេលជាង១ទសវត្សរ៍មកហើយ និងបានដឹកនាំគំនិតផ្តួចផ្តើមថ្នាក់ជាតិ ដើម្បីឆ្លើយតបនឹងការរំលោភបំពាននិងការកេងប្រវ័ញ្ចតាមប្រព័ន្ធអ៊ិនធឺណិត រាប់បញ្ចូលទាំងការបង្កើតបណ្តាញទូរស័ព្ទបន្ទាន់តាមប្រព័ន្ធអ៊ិនធឺណិត សហការជាមួយសមាគមអន្តរជាតិនៃបណ្តាញរាយការណ៍បន្ទាន់តាមប្រព័ន្ធអ៊ិនធឺណិត និងមូលនិធិ INHOPE។ ពួកគេមានទំនាក់ទំនងយ៉ាងល្អជាមួយគ្នា និងទទួលបានការកោតសសើរយ៉ាងខ្លាំងនៅក្នុងជួររដ្ឋាភិបាល និងអាចផ្សព្វផ្សាយសាររបស់ពួកគេបានទៅកាន់ថ្នាក់ដឹកនាំកម្រិតខ្ពស់បំផុតក្នុងជួររដ្ឋាភិបាល។

- **មូលនិធិអន្តរជាតិនៃបណ្តាញរាយការណ៍បន្ទាន់តាមប្រព័ន្ធអ៊ិនធឺណិត (INHOPE)**[33] គឺជាអង្គការជំមួយមានមូលដ្ឋាននៅក្នុងប្រទេសហូឡង់ ដែលជាបណ្តាញសហការសាកលនៃប្រព័ន្ធរាយការណ៍បន្ទាន់ចំនួន៤៥ ក្នុង៤០ប្រទេស។ INHOPE ទទួលរបាយការណ៍ពីសមាជិករបស់ខ្លួននៅទូទាំងពិភពលោកអំពី

---

[33] INHOPE Foundation. *At A Glance.* Accessed 20 Nov 2018 from, http://www.inhope.org/gns/who-we-are/at-a-glance.aspx

CSAM តាមប្រព័ន្ធអនឡាញដែលគេមានការសង្ស័យ រាប់បញ្ចូលទាំងសម្ភារពាក់ព័ន្ធនឹងការរំលោភបំពានផ្លូវភេទលើកុមារ។ បណ្តាញរាយការណ៍បន្ទាន់នឹងធ្វើការស៊ើបអង្កេត ហើយនិងបញ្ជូនទៅកាន់ទីភ្នាក់ងារអនុវត្តច្បាប់ ព្រមទាំងក្រុមហ៊ុនផ្តល់សេវាកម្មអ៊ិនធឺណិត ដែលកំពុងបង្ហោះខ្លឹមសារនោះ ប្រសិនបើរកឃើញថាខុសច្បាប់។

- មជ្ឈមណ្ឌលជាតិការពារកុមារបាត់ខ្លួន និងរងគ្រោះដោយការកេងប្រវ័ញ្ច(NCMEC)[34]៖ គឺជាអង្គការមិនមែនរដ្ឋាភិបាល មានមូលដ្ឋាននៅសហរដ្ឋអាមេរិក និងបានទទួលមូលនិធិពីក្រសួងយុត្តិធម៌សហរដ្ឋអាមេរិកតាំងពីឆ្នាំ១៩៨៤។ NCMEC ផ្តល់ទិន្នន័យ និងធ្វើវិភាគអំពីការផលិត និងការចែកចាយ CSAM តាមរយៈបណ្តាញរាយការណ៍បន្ទាន់ដោយសម្ងាត់ពាក់ព័ន្ធនឹងបច្ចេកវិទ្យារបស់ខ្លួន និងដើរតួនាទីជាធនធានសម្រាប់កុមារកំពុងបាត់ខ្លួននិងកុមារទទួលរងការកេងប្រវ័ញ្ច ជាជនបង្គោលក្នុងការផ្តល់ជំនួយដើម្បីលើកកម្ពស់ការយល់ដឹងអំពីការចាប់ពង្រត់ ការធ្វើបាប ការកេងប្រវ័ញ្ចផ្លូវភេទកុមារ និងការទទួលបានមកវិញ កុមារដែលកំពុងបាត់ខ្លួន។ NCMEC រួមជាមួយនឹងមជ្ឈមណ្ឌលដើម្បីកុមារបាត់ខ្លួន និងកុមារទទួលរងការកេងប្រវ័ញ្ច (CMEC) និងមជ្ឈមណ្ឌលអន្តរជាតិដើម្បីកុមារកំពុងបាត់ខ្លួន និងកុមារទទួលរងការកេងប្រវ័ញ្ច (ICMEC) អនុវត្តបណ្តាញកុមារកំពុងបាត់ខ្លួនក្នុងចំនួន២២ប្រទេស និងបណ្តុះបណ្តាលមន្ត្រីអនុវត្តច្បាប់ ធ្វើការងារជាមួយអង្គភាពអនុវត្តច្បាប់ និងអង្គនីតិបញ្ញត្តិ ដើម្បីអនុម័តច្បាប់ថ្មីៗ ដែលប្រយុទ្ធប្រឆាំងនឹងរូបភាពអាសអាភាសកុមារនៅក្នុងជាង១០០ប្រទេស។
- មូលនិធិឃ្លាំមើលតាមប្រព័ន្ធអ៊ិនធឺណិត (IWF)[35]៖ គឺជាអង្គការមិនមែនរដ្ឋាភិបាល មានមូលដ្ឋាននៅចក្រភពអង់គ្លេស បង្កើតនៅឆ្នាំ១៩៩៦ ដែលផ្តល់បណ្តាញរាយការណ៍បន្ទាន់តាមប្រព័ន្ធអនឡាញដល់សាធារណជន សម្រាប់រាយការណ៍ខ្លឹមសារដែលអាចជាបទល្មើសតាមប្រព័ន្ធអនឡាញ ដើម្បីជាការជូនដំណឹង និងដកចេញ។ IWF ត្រូវបានទទួលស្គាល់ជាទីភ្នាក់ងារសម្រាប់រាយការណ៍ ដោះស្រាយ និងប្រយុទ្ធប្រឆាំងរូបភាពរំលោភបំពានផ្លូវភេទកុមារតាមប្រព័ន្ធអ៊ិនធឺណិត។ IWF មានការងារស្នូលក្នុងការដកហូតចេញនូវរូបភាព និងវីឌីអូរំលោភបំពានផ្លូវភេទកុមារតាមប្រព័ន្ធអ៊ិនធឺណិត ជាមួយនឹងវិស័យទទួលខុសត្រូវរបស់ IWF ក្នុងការជូនដំណឹងដល់ក្រុមហ៊ុនផ្តល់សេវាកម្មបង្ហោះ និងក្រុមហ៊ុនផ្តល់សេវាកម្មអ៊ិនធឺណិតឲ្យដកហូតចេញ ឬបិទលទ្ធភាពទទួលបាន/ចូលខ្លឹមសារបទល្មើសដែលអាចមាននោះជាបន្ទាន់។ IWF គឺជាសមាជិកស្ថាបនិកនៃ INHOPE និងសមាគមនៃបណ្តាញរាយការណ៍បន្ទាន់ ដើម្បីរួមចំណែកដល់កិច្ចការពារកុមារតាមអ៊ិនធឺណិត និងធ្វើការងារក្នុងភាពជាដៃគូជាមួយនគរបាល និងក្រុមហ៊ុនបង្ហោះគេហទំព័រ ដើម្បីដកហូតចេញខ្លឹមសារពាក់ព័ន្ធ និងស៊ើបអង្កេតអ្នកផ្សព្វផ្សាយខ្លឹមសារនោះ។
- Cybertip.ca[36]៖ គឺជាអង្គការមិនមែនរដ្ឋាភិបាល មានមូលដ្ឋាននៅប្រទេសកាណាដា តាំងពីឆ្នាំ២០០២។ គោលដៅនៃ Cybertip.ca គឺដើម្បីកាត់បន្ថយភាពរងគ្រោះរបស់កុមារ តាមរយៈការផ្តល់កម្មវិធីជាតិ និងសេវាដល់សាធារណជន។ Cybertip.ca ប្រតិបត្តិការជាច្រកទ្វារមុខ ដើម្បីឲ្យសាធារណជនរាយការណ៍អំពីព័ត៌មាន ឬខ្លឹមសារ ពាក់ព័ន្ធនឹងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ ហើយ Server នៃគេហទំព័រ Cybertip.ca ទទួលបានព័ត៌មានតាមលក្ខណៈមានសុវត្ថិភាព និងកំណត់អាទិភាពលើ

[34] NSVRC. Accessed 20 Nov, 2018 from, https://www.nsvrc.org/organizations/60

[35] Internet World Foundation. Who We Are. Accessed 20 Nov, 2018 from, https://www.iwf.org.uk/what-we-do/who-we-are

[36] Cybertip.ca. *About us.* Accessed 17 Nov, 2018 from, https://www.cybertip.ca/app/en/about

ដំណើរការចំណាត់ថ្នាក់ដោយផ្អែកលើលេខកូដបទល្មើស (ប្រទេសកាណាដា) សម្រាប់អ្នកវិភាគ។ របាយការណ៍ ត្រូវបានបញ្ជូនទៅកាន់ទីភ្នាក់ងារសមស្របអនុវត្តច្បាប់ និង/ឬ បណ្តាញរាយការណ៍បន្ទាន់ជាដៃគូរបស់ INHOPE និងទីភ្នាក់ងារពាក់ព័ន្ធ ប្រសិនបើព័ត៌មាននោះទំនងជាឧប្បត្តិហេតុខុសច្បាប់។

## ១.៣. បរិបទនៅក្នុងប្រទេសកម្ពុជា

បច្ចុប្បន្ននេះ នៅក្នុងប្រទេសកម្ពុជាមានការយល់ដឹងតិចតួចអំពីវត្តមាន និងទំហំនៃOCSE[37] ហើយការយល់ដឹងរបស់សហគមន៍ក៏នៅមានកម្រិតដែរ[38]។ ផែនការសកម្មភាពដើម្បីទប់ស្កាត់ និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារ (ឆ្នាំ២០១៧-២០២១) បានកំណត់ភាពខ្វះចន្លោះយ៉ាងច្បាស់នៅក្នុងច្បាប់ សមត្ថភាពអនុវត្តច្បាប់ ការយល់ដឹងរបស់សហគមន៍ និងឧស្សាហកម្មឯកជនក្នុងការឆ្លើយតបទៅនឹងបញ្ហាOCSE។ ជាមួយនឹងបរិបទនេះ គឺអ្នកពាក់ព័ន្ធដែលកំពុងធ្វើការងារវិស័យកិច្ចការពារកុមារនៅក្នុងប្រទេស កម្ពុជាមានកង្វល់កាន់តែច្រើនឡើងថា ត្រូវការរៀបចំយន្តការប្រយុទ្ធប្រឆាំងសម្រាប់ឆ្លើយតបនឹងបញ្ហានេះឲ្យបានទាប់នាពេលខាងមុខនេះ ព្រោះជាកិច្ចការមួយដែលប្រឈម និងជាការងារដែលទាមទារឲ្យមានការប្តេជ្ញាចិត្តរួមគ្នាជាពហុវិស័យ[39]។ ស្របពេលដែលមិនទាន់មានតួលេខផ្លូវការអំពីOCSE ផែនការសកម្មភាពជាតិដើម្បីទប់ស្កាត់អំពើហិង្សាចំពោះស្ត្រី(ឆ្នាំ២០១៤-២០១៨) បង្ហាញថា មានការកើនឡើងការផលិត ការកាន់កាប់ និងការចែកចាយ CSAM តាមប្រព័ន្ធអនឡាញ ការលួងលោមជនដែលងាយរងគ្រោះជាកុមារ តាមប្រព័ន្ធអនឡាញ និងការផ្សាយផ្ទាល់នូវការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទកុមារ (CSEA)[40]។

រាជរដ្ឋាភិបាលកម្ពុជា គឺជាភាគីហត្ថលេខីនៃសេចក្តីថ្លែងការណ៍សកម្មភាព WePROTECT ដែលត្រូវបានចុះហត្ថលេខានៅឯកិច្ចប្រជុំកំពូលសាកល នៅទីក្រុងអាប៊ុយដាប៊ី ឆ្នាំ២០១៥។ គំរូនៃការឆ្លើយតបជាតិ(MNR) នៃ WePROTECT សង្កត់ធ្ងន់លើសារៈសំខាន់នៃការចូលរួមរបស់អ្នកពាក់ព័ន្ធផ្សេងៗ និងកំណត់នូវឧស្សាហកម្ម អ្នកពាក់ព័ន្ធសំខាន់ៗក្នុងកិច្ចការពារកុមារតាមប្រព័ន្ធអ៊ិនធឺណិត។ ដោយឡែក VAC បានផ្តល់អនុសាសន៍ឲ្យមានការកែសម្រួលសេចក្តីព្រាងច្បាប់ប្រឆាំងបទល្មើសបច្ចេកវិទ្យា ដើម្បីធានាកិច្ចការពារយ៉ាងពេញលេញពី OCSE រាប់បញ្ចូលទាំងការគំរាមកំហែងដើម្បីគោលបំណងផ្លូវភេទ ការបញ្ជូនរូបភាពពាក់ព័ន្ធនឹងផ្លូវភេទ ការផ្សាយផ្ទាល់ និងការលួងលោមតាមប្រព័ន្ធអនឡាញ។ ផែនការសកម្មភាពនេះ បានអំពាវនាវឲ្យមានការផ្តល់សិទ្ធិអំណាចជូនមន្ត្រីអនុវត្តច្បាប់ថ្នាក់មូលដ្ឋាន ក្នុងការស៊ើបអង្កេត រឹបអូសឧបករណ៍បរិក្ខារ និងបិទចោលខ្លឹមសារ **"កម្មវិធីអនឡាញដែលកំពុងរួមចំណែកលើកកម្ពស់ និងសម្របសម្រួល"** OCSE។ ទន្ទឹមនេះដែរ ផែនការសកម្មភាពនេះ ផ្តល់អនុសាសន៍ឲ្យធ្វើវិសោធនកម្មច្បាប់ស្តីពីទូរគមនាគមន៍ជាធរមាន ដើម្បីបញ្ចូលពិធីសារការពារកុមារសម្រាប់កម្មវិធីអនឡាញ និងកម្មវិធីឧបករណ៍ចល័ត[41]។

### ១.៣.១. កិច្ចការពារថ្នាក់គោលនយោបាយ

បច្ចុប្បន្ននេះ មានភាពខ្វះចន្លោះគួរឲ្យកត់សម្គាល់នៅក្នុងច្បាប់ជុំវិញ OCSE នៅប្រទេសកម្ពុជា។ នៅឆ្នាំ ២០០៨ រាជរដ្ឋាភិបាលកម្ពុជា បានអនុម័តច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងការកេងប្រវ័ញ្ចផ្លូវភេទ។

[37] អង្គការសកម្មភាពដើម្បីកុមារ (ឆ្នាំ២០១៦)

[38] ក្រសួងកិច្ចការនារី (ឆ្នាំ២០១៤)

[39] អង្គការសកម្មភាពដើម្បីកុមារ (ឆ្នាំ២០១៦)

[40] ក្រសួងកិច្ចការនារី (ឆ្នាំ២០១៤)

[41] UNICEF (2017)

ស្របពេលដែលច្បាប់នេះកំណត់ជាទោសព្រហ្មទណ្ឌចំពោះ "រូបភាពអាសអាភាសកុមារ" ច្បាប់នេះមិនកំណត់ជាទោសព្រហ្មទណ្ឌ ឬមិនមានបទបញ្ញត្តិច្បាស់ ដែលកំណត់ជាទោសព្រហ្មទណ្ឌ ចំពោះការចូលមើល ឬការទាញយករូបភាពអាសអាភាសកុមារ ឬការមានជាកម្មសិទ្ធិនូវ CSAM ដោយគ្មានចេតនាចែកចាយនោះឡើយ។ បន្ថែមលើនេះ ការចែកចាយ និងការផ្សព្វផ្សាយ ត្រូវបានកំណត់ជាទោសព្រហ្មទណ្ឌនៅ "កន្លែងសាធារណៈ" ដែលមិនរាប់បញ្ចូលការលក់ដូរ ឬការចែកចាយ CSAM នៅកន្លែងអសាធារណៈឡើយ។ ច្បាប់នេះក៏គ្មានបញ្ញត្តិសម្រាប់ការចូលមើល ឬការទាញយក CSAM សម្រាប់ការល្បួងលោមក្នុងគោលបំណងផ្លូវភេទនោះដែរ។ បន្ថែមលើនេះ គ្មានបញ្ញត្តិដែលទាមទារឲ្យក្រុមហ៊ុនផ្តល់សេវាកម្មអ៊ិនធឺណិត រាយការណ៍អំពី CSAM ទៅមន្ត្រីអនុវត្តច្បាប់ ឬអាជ្ញាធរផ្សេងទៀតឡើយ[42] ដែលក្នុងនោះ ភាពខ្វះចន្លោះមួយចំនួន គឺត្រូវយកទៅបំពេញនៅក្នុងសេចក្តីព្រាងច្បាប់ប្រឆាំងបទល្មើសបច្ចេកវិទ្យា ប៉ុន្តែសេចក្តីព្រាងច្បាប់នេះ បានរៀបចំតាំងពីឆ្នាំ២០១២មក និងមិនទាន់ត្រូវបានអនុម័តនៅឡើយទេ។

## ១.៣.២. ទូរស័ព្ទដៃវៃឆ្លាត ការប្រើប្រាស់អ៊ិនធឺណិត និងលទ្ធភាពទទួលបាននៅកម្ពុជា

មានការអង្កេតមួយនៅឆ្នាំ២០១៨ ដោយ LIRNE asia ដែលជាក្រុមផ្តល់យោបល់អំពីទីផ្សារអាស៊ីប៉ាស៊ីហ្វិករកឃើញថា មាន៩១% ក្នុងចំណោមគ្រួសារកម្ពុជា មានទូរស័ព្ទដៃវៃឆ្លាតយ៉ាងហោចណាស់១គ្រឿង ហើយអ្នកនៅតាមទីជនបទចំនួន២១% មិនទំនងជាមានទូរស័ព្ទដៃវៃឆ្លាតប្រើប្រាស់ឡើយ បើប្រៀបធៀបទៅនឹងអ្នកដែលរស់នៅតាមទីក្រុង[43]។ ការវាយលុកទីផ្សារខ្ពស់នៃទូរស័ព្ទដៃវៃឆ្លាត ក្នុងចំណោមអ្នករស់នៅទីប្រជុំជន ធៀបនឹងអ្នករស់នៅជនបទ (៦០% ទល់នឹង៤៤%) និងមានលក្ខណៈទូទៅបំផុតក្នុងចំណោមប្រជាជនកម្ពុជា វ័យក្មេងៗ៖ មាន៧៨% ក្នុងចំណោមអ្នកមានអាយុពី២០ទៅ២៤ឆ្នាំ មាន៧០% ក្នុងចំណោមអ្នកមានអាយុពី១៥ ទៅ២៥ឆ្នាំ និងមាន៥៩% ក្នុងចំណោមអ្នកមានអាយុពី១៥ ទៅ១៩ឆ្នាំ។ ក្នុងចំណោមអ្នកដែលមិនកំពុងប្រើប្រាស់ទូរស័ព្ទភ្ជាប់អ៊ិនធឺណិត មានឧបសគ្គចម្បងធំសម្រាប់ប្រើប្រាស់ទូរស័ព្ទបែបនេះ គឺលទ្ធភាពអាចរកទិញបាន(៥០%) កង្វះជំនាញផ្នែកឌីជីថល (៤១%) និងមានអារម្មណ៍ថា វាមានភាពស្មុគស្មាញពេកសម្រាប់ការប្រើប្រាស់(៣០%)[44]។

យោងតាមទិន្នន័យរបស់TRC នៅឆ្នាំ២០១៨ មានក្រុមហ៊ុនចំនួន៣៦ ដែលបានផ្តល់សេវាអ៊ិនធឺណិត នៅកម្ពុជា។ ក្នុងនោះដែរ ក្រុមហ៊ុនទូរគមនាគមន៍ដែលផ្តល់អ៊ិនធឺណិតចល័តដល់អ្នកប្រើប្រាស់ គឺស្មាតអាហ្សាតា៤២% មិត្តហ្វូន៤០% សែលកាត១៤% និងក្រុមហ៊ុនផ្សេងៗ៤%។ ជាមួយគ្នានេះ ការផ្តល់អ៊ិនធឺណិតអចល័តដល់អ្នកប្រើប្រាស់គឺមិត្តហ្វូន៤៩% ស្មាតអាហ្សាតា១២% ក្រុមហ៊ុនស៊ីងម៉េងកម្ពុជា១០% ក្រុមហ៊ុនកូជីតែល៨% ក្រុមហ៊ុនស៊ីនវ៉ៃ៧% ក្រុមហ៊ុនតែលកូតិច៥% និងក្រុមហ៊ុនផ្សេងៗទៀត៩%។[45] ទន្ទឹមនេះដែរ យោងតាមរបាយការណ៍ឆ្នាំ២០១៤ នៃកម្មវិធីUNDP មានក្រុមហ៊ុនចំនួនជាង៣០ ដែលផ្តល់សេវាកម្មអ៊ិនធឺណិត។ បន្ថែមលើនេះ បណ្តាញ4G មានភាពអាក់រអួលតិច(គឺល្អ) បើធៀបនឹងប្រជាជាតិអាស៊ីអាគ្នេយ៍ផ្សេងទៀត[46]។ នៅកម្ពុជាក្រុមហ៊ុនទូរគមនាគមន៍ដែលត្រូវបានប្រើប្រាស់ច្រើនជាងគេគឺ **មិត្តហ្វូន** ត្រូវបានប្រើប្រាស់ដោយសំណាកគំរូចំនួន៤៥% បន្ទាប់មកគឺ **ស្មាត** (៤០%) និង**សែលកាត** (១៤%)។ យុវវ័យចំនួនលើសពី២នាក់ ក្នុងចំណោម៣នាក់ ឬស្មើនិង៦៨% ប្រើប្រាស់**មិត្តហ្វូន** បន្ទាប់មក**ស្មាត**អាហ្សាតា (៤១%)។ អ្នករស់នៅតាមជនបទ ទំនងជាប្រើប្រាស់**មិត្តហ្វូន**ច្រើនជាង ស្របពេល

---

[42] ធនាគារពិភពលោក (2015).

[43] LIRNE asia. (2018).

[44] *Ibid.*, 22.

[45] ប្រភព៖ TRC 2018

[46] គំរូពី IMDA សីង្ហបុរី 300 ms សម្រាប់ Server អន្តរជាតិ និង100 ms លើ 4G/LTE

ដែលអ្នកទៅតាមទីក្រុង ទំនងជាប្រើប្រាស់**ស្មាត**អាហ្វាតាច្រើនជាង។ យោងតាម LIRNE asia គឺអ្នកប្រើប្រាស់អ៊ិនធឺណិតតាមទូរស័ព្ទ (3G, 4G, LTE) នៅប្រទេសកម្ពុជា ចំណាយប្រហែល២,៦ដុល្លារ និងពាក់កណ្តាលនៃមនុស្សវ័យក្មេង ចំណាយ២ដុល្លារ ឬតិចជាងនេះក្នុងមួយខែ លើសេវាកម្មអ៊ិនធឺណិត។

យោងតាមកម្មវិធីUNDP ប្រជាជនកម្ពុជាប្រើប្រាស់ទូរស័ព្ទដៃវៃឆ្លាតសម្រាប់ហៅចេញ និងទទួលទូរស័ព្ទ (៩៨%) ស្តាប់វិទ្យុ(៤៣%) ផ្ញើនិងទទួលសារ(៣២%) លេង/ទាញយកហ្គេម(២៧%) និងថតរូប(២២%)[47]។ អ្នកប្រើប្រាស់បណ្តាញទំនាក់ទំនងសង្គមកម្ពុជា មិនសូវមានបំណងចែករំលែកព័ត៌មានផ្ទាល់ខ្លួន ដូចជា ភេទ ឈ្មោះពិត អាយុ ស្ថានភាពអាពាហ៍ពិពាហ៍ លេខទូរស័ព្ទដៃវៃឆ្លាត អាសយដ្ឋានអ៊ីម៉េល សាសនា ទស្សនៈនយោបាយ អត្តសញ្ញាណផ្លូវភេទ រូបភាព ឬ វីឌីអូអំពីគ្រួសារ និងមិត្តភក្តិរបស់ពួកគេឡើយ[48]។ អ្នកប្រើប្រាស់អ៊ិនធឺណិតកម្ពុជាចំនួនលើសពី១នាក់ ក្នុងចំណោម៤នាក់ ឬ២៦% ធ្លាប់ជួបប្រទះនឹងការរំខានតាមអ៊ិនធឺណិត ដោយមានការបង្ហាញអំពីការរំខានដល់អ្នកប្រើប្រាស់ជាស្ត្រី ច្រើនជាងអ្នកប្រើប្រាស់ជាបុរស (២៩% ទល់នឹង ២៣%)។ ២ភាគ៣នៃអ្នកប្រើប្រាស់អ៊ិនធឺណិត ឬ៦៥% បង្ហាញនូវការព្រួយបារម្ភអំពីព័ត៌មានឯកជនភាពរបស់ពួកគេ ៦៣% ជឿជាក់ថា មនុស្សអាចញៀននឹងទូរស័ព្ទដៃវៃឆ្លាត និងអ៊ិនធឺណិត៤៧% បង្ហាញការព្រួយបារម្ភថា កូនរបស់ពួកគេនឹងមើលឃើញខ្លឹមសារមិនសមស្រប និង២៤% រៀបរាប់ថាអ៊ិនធឺណិត ជះឥទ្ធិពលលើការបែងចែកសង្គម និង២០% រៀបរាប់អំពីការថយចុះនូវពេលវេលាជាមួយគ្រួសារ ឬមិត្តភក្តិ ដោយសារតែចំណាយពេលលើបណ្តាញទំនាក់ទំនងសង្គម។

### ១.៣.៣. យន្តការជាតិសម្រាប់រាយការណ៍

អគ្គស្នងការនគរបាលជាតិមានលេខទូរស័ព្ទទាន់ហេតុការណ៍ (Hotline) ១១៧ សម្រាប់ទទួលព័ត៌មានដើម្បីដោះស្រាយរាល់ហេតុការណ៍កើតឡើងពាក់ព័ន្ធនឹងបទល្មើស។ ទន្ទឹមនឹងនេះដែរ ក៏មានលេខទូរស័ព្ទដោយឡែកមួយខ្សែទៀតគឺ១២៨៨ សម្រាប់ទទួលព័ត៌មាននិងដោះស្រាយហេតុការណ៍ពាក់ព័ន្ធនឹងការជួញដូរមនុស្ស និងការពារអនីតិជន។ ជាមួយគ្នានេះដែរ អគ្គស្នងការដ្ឋាននគរបាលជាតិ បាននិងកំពុងសហការសម្របសម្រួល ជាមួយអង្គការជាតិ និងអន្តរជាតិមួយចំនួនដែលធ្វើការងារលើOCSE ក្នុងការទប់ស្កាត់ ការពារ និងឆ្លើយតបការរំលោភបំពានលើកុមារតាមប្រព័ន្ធអនឡាញ។

បណ្តាញកម្ពុជា រាយការណ៍បន្ទាន់តាមប្រព័ន្ធអ៊ិនធឺណិត (**IHC**)[49]- នៅឆ្នាំ២០១៥ បណ្តាញទូរស័ព្ទបន្ទាន់តាមប្រព័ន្ធអ៊ិនធឺណិតរបស់អង្គការAPLE ត្រូវបានបង្កើតឡើងដោយមានការគាំទ្រពីមូលនិធិ INHOPE និងដំណើរការដោយអង្គការAPLE កម្ពុជាដែលផ្តល់ជូនសាធារណៈជនក្នុងការរាយការណ៍បែបអនាមិកអំពីCSAM។ សម្របសម្រួលជាមួយនាយកដ្ឋានប្រឆាំងបទល្មើសបច្ចេកវិទ្យានៃក្រសួងមហាផ្ទៃ និងបណ្តាញរាយការណ៍បន្ទាន់ផ្សេងទៀតនៃINHOPE និងឧស្សាហកម្មអ៊ិនធឺណិត ដើម្បីដកចេញនូវខ្លឹមសារនានា និងវិធានការសមស្របចំពោះខ្លឹមសារខុសច្បាប់ និងករណីទាក់ទងនឹងOCSEទាំងអស់។ បន្ថែមលើនេះ IHC បានធ្វើយុទ្ធនាការលើកកម្ពស់ការយល់ដឹងអំពីហានិភ័យតាមប្រព័ន្ធអ៊ិនធឺណិត និងការយល់ដឹងអំពីសុវត្ថិភាពអ៊ិនធឺណិតចំពោះកុមារ ឪពុកម្តាយ/អ្នកអាណាព្យាបាល អ្នកវិជ្ជាជីវៈ និងសហគមន៍មូលដ្ឋាន។ IHC ធ្វើការជាមួយដៃគូ អ្នកពាក់ព័ន្ធ ធ្វើការស្រាវជ្រាវ ដើម្បីទទួលបានចំណេះដឹងនិងព័ត៌មាន ផ្តោតលើភស្តុតាងសម្រាប់បង្កើតមជ្ឈមណ្ឌលសម្រាប់ការរៀនសូត្រ/ធនធានតាមអ៊ិនធឺណិត ឆ្ពោះទៅរកការលុបបំបាត់ OCSE ។

---

[47]UNDP. (2014).

[48]LIRNEasia. (2018).

[49]បណ្តាញរាយការណ៍បន្ទាន់តាមអ៊ិនធឺណិត។ ចូលមើលនៅថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១៨ ពីhttps://www.internethotlinecambodia.org/

**បណ្តាញសុវត្ថិភាពកុមារ**[50]: គឺជាចលនានៃភ្នាក់ងារការពារកុមារដោយស្ម័គ្រចិត្តនៅទូទាំងសហគមន៍កម្ពុជា ដើរតួនាទីសំខាន់សម្រាប់បណ្តាញនៃអង្គការការពារកុមារនៅទូទាំងប្រទេសកម្ពុជា។ ភ្នាក់ងារជាច្រើនបានទទួលវគ្គបណ្តុះបណ្តាលដើម្បីឲ្យយល់អំពីស្ថានភាពគ្រោះថ្នាក់ចំពោះកុមារ និងចាត់វិធានការដើម្បីការពារពួកគេ។ កម្មវិធីសុវត្ថិភាពកុមារធ្វើការងារដើម្បីការពារកុមារនិងយុវវ័យ ដែលជួបប្រទះការរំលោភបំពានជាច្រើន ចាប់ពីអំពើហិង្សាលើរាងកាយនិងផ្លូវចិត្ត រហូតដល់ការកេងប្រវ័ញ្ចផ្លូវភេទ ពលកម្មដោយបង្ខំ និងកង្វះលទ្ធភាពទទួលបានការអប់រំ និងការថែទាំសុខភាព។ កុមារនិងយុវវ័យដែលទទួលសេវានេះ រួមមានជនរងគ្រោះដោយសារការរំលោភបំពានអំពើហិង្សាក្នុងគ្រួសារពាក់ព័ន្ធនឹងអាជីវកម្មផ្លូវភេទ បោះបង់ការសិក្សា ឬអត់ការងារធ្វើ ប្រើប្រាស់សារធាតុញៀន ផលប៉ះពាល់ពីមេរោគអេដស៍ ជនទេសន្តរប្រវេសន៍ ឬជនជាប់ឃុំជនឬជនប្រព្រឹត្តបទល្មើស និងជនដែលរស់នៅដោយផ្សងព្រេង។

**បណ្តាញទូរស័ព្ទជំនួយកុមារកម្ពុជា(CHC)**[51]: បណ្តាញទូរស័ព្ទជំនួយកុមារកម្ពុជា (១២៨០) លើកស្ទួយសិទ្ធិកុមារ និងបង្កើតឱកាសសម្រាប់កិច្ចការពារកុមារនិងយុវវ័យ តាមរយៈការពិគ្រោះយោបល់តាមទូរស័ព្ទប្រកបដោយវិជ្ជាជីវៈ និងសេវាផ្តល់ព័ត៌មានអំពីដៃគូសមស្រប តាមរយៈការពិគ្រោះយោបល់ និងការផ្តល់ព័ត៌មានដើម្បីឲ្យ CHC ផ្តល់ភាពអង់អាចដល់អតិថិជនក្នុងការធ្វើសេចក្តីសម្រេចចិត្តនានា ហើយCHC ធ្វើអន្តរាគមន៍តែនៅពេលដែលអតិថិជនស្នើសុំជំនួយ និងនៅពេលដែលមានករណីចាំបាច់ប៉ុណ្ណោះ ដូចជាក្នុងគ្រាដែលអាយុជីវិតរបស់នរណាម្នាក់កំពុងស្ថិតក្នុងហានិភ័យ។ CHC មិនផ្តោតជាក់លាក់លើការរំលោភបំពានផ្លូវភេទកុមារឡើយ ប៉ុន្តែផ្តល់ការហៅចូលដោយឥតគិតថ្លៃក្នុងរយៈពេល២៤ម៉ោង និងឲ្យកុមារនិយាយជាមួយអ្នកផ្តល់ប្រឹក្សាយោបល់អំពីបញ្ហាទាំងឡាយជាច្រើន។ ស្របពេលដែលអាណត្តិនៃបណ្តាញទូរស័ព្ទនេះមានលក្ខណៈទូលំទូលាយ ជាទូទៅអ្នកផ្តល់ប្រឹក្សាយោបល់ក៏ទទួលបានការរាយការណ៍អំពីការកេងប្រវ័ញ្ចអំពើផ្លូវភេទកុមារ និងអាចផ្តល់ប្រឹក្សាយោបល់ និងការបញ្ជូនទៅរកសេវាខាងក្រៅនៅពេលចាំបាច់ផងដែរ។

[50]បណ្តាញសុវត្ថិភាពកុមារ ។ *មនុស្ស*។ ចូលមើលនៅថ្ងៃទី ១៧ ខែវិច្ឆិកា ឆ្នាំ២០១៨ ពី https://thinkchildsafe.org/the-people/

[51]បណ្តាញទូរស័ព្ទជំនួយកុមារកម្ពុជា៖ *អំពីបណ្តាញទូរស័ព្ទជំនួយ* ។ចូលមើលនៅថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១៨ http://childhelpline.org.kh/about/organisational-overview/

## វគ្គទី២: វិធីសាស្ត្រនៃការវិភាគស្ថានភាពដំបូងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ

ការសិក្សានេះ ប៉ាន់ប្រមាណនូវការគំរាមកំហែងនាពេលបច្ចុប្បន្ននៃ OCSE នៅប្រទេសកម្ពុជា ជាវិធីដែលបង្ហាញច្បាស់នៅក្នុងសហគមន៍កម្ពុជា ទីកន្លែង និងវិធីដែលកុមារស្ថិតក្នុងហានិភ័យ ព្រមទាំងសមត្ថភាព និងភាពខ្វះចន្លោះក្នុងគោលនយោបាយ ច្បាប់ យុត្តិធម៌ព្រហ្មទណ្ឌ សេវាសង្គម និងវិស័យឯកជន ដើម្បីកំណត់អនុសាសន៍ផ្អែកលើភស្តុតាងដែលអាចស្តែងចេញជាវិធានការសម្រាប់ អន្តរាគមន៍ជាក់លាក់ចំពោះប្រទេសកម្ពុជា។ ការប៉ាន់ប្រមាណនេះ នឹងត្រូវផ្តល់ជាភស្តុតាងដោយគំរូនៃការឆ្លើយតបថ្នាក់ជាតិ (MNR) នៃWePROTECT ផ្អែកលើការរៀនសូត្រពីការអនុវត្តល្អៗនៅក្នុងប្រទេស និងថ្នាក់អន្តរជាតិ។

សកម្មភាពរៀនសូត្រ និងកំណត់ទីតាំង ព្រមទាំងទិន្នន័យនៅក្នុងសំណេរអក្សរសាស្ត្រថ្នាក់តំបន់ និងថ្នាក់អន្តរជាតិ បង្ហាញភាពខ្វះចន្លោះគួរឲ្យកត់សម្គាល់ក្នុងទិន្នន័យពីកុមារនិងសហគមន៍។ ភាគច្រើនបំផុតនៃរបាយការណ៍ ទិន្នន័យ និងករណីនានា ហាក់ដូចជាចេញមកពីការអនុវត្តន៍ច្បាប់ថ្នាក់តំបន់និងថ្នាក់អន្តរជាតិ ជាញឹកញាប់ ផ្អែកលើរបាយការណ៍នៃមជ្ឈមណ្ឌលជាតិការពារកុមារបាត់ខ្លួន និងរងគ្រោះដោយការកេងប្រវ័ញ្ច(NCMEC)។ ភាគច្រើននៃរបាយការណ៍ទាំងនេះ មានដើមកំណើតចេញពីសម្ភារពាក់ព័ន្ធនឹងការរំលោភបំពានផ្លូវភេទកុមារ(CSAM) ពីក្រុមហ៊ុនផ្តល់សេវាកម្មអេឡិចត្រូនិក ដូចជា Facebook, Google និង Microsoft ។ ស្របពេលដែលរបាយការណ៍ទាំងនេះជាប្រភពទិន្នន័យដ៏មានសារៈសំខាន់ ដែលអាចស្តែងចេញជាវិធានការបាននោះ របាយការណ៍ទាំងនេះមិនបានផ្តល់រូបភាពពេញលេញនៃបញ្ហា OCSE នៅប្រទេសកម្ពុជា និងមិនបង្ហាញច្បាស់អំពីទម្រង់ផ្សេងទៀតនៃការកេងប្រវ័ញ្ចដែលត្រូវសម្របសម្រួលតាមប្រព័ន្ធអ៊ិនធឺណិត ដែលអាចរាលដាលខ្លាំងនៅសហគមន៍ ដូចជា មានការលួងលោមការគំរាមកំហែងក្នុងគោលបំណងផ្លូវភេទ និងការផ្សាយផ្ទាល់អំពីការរំលោភបំពាន និងការកេងប្រវ័ញ្ចផ្លូវភេទឡើយ។ ជាការសំខាន់ដែលកុមារចូលរួមជួយយើងឲ្យយល់អំពីរូបភាពទូលំទូលាយនៃហានិភ័យនៅថ្នាក់មូលដ្ឋាន និងនៅកម្រិតថ្នាក់អ្នកប្រើប្រាស់។ ហេតុនេះ ការសិក្សានេះបានសង្កត់ធ្ងន់ ជាពិសេសលើការបង្កើតទិន្នន័យសំខាន់ៗពីកុមារ និងសហគមន៍របស់ពួកគេ តាមរយៈសិក្ខាសាលារៀនសូត្រ ដែលកសាងបន្ថែមលើគុណតម្លៃនៃការរចនាដោយគិតគូរអំពីមនុស្ស។

គោលបំណងសំខាន់នៃការសិក្សានេះ គឺដើម្បីបង្កើតឲ្យមានការចូលរួមជាមួយសហគមន៍ និងភ្នាក់ងារសំខាន់ៗ ដែលធ្វើការងារការពារកុមារ នៅទូទាំងប្រទេសកម្ពុជា និងតំបន់ ក្នុងគោលបំណងដើម្បី៖

- បង្កើតការយល់ដឹងគ្រប់ជ្រុងជ្រោយនិងប្លែកៗគ្នាអំពីចរិត និងទំហំនៃ OCSE នៅប្រទេសកម្ពុជា នៅកម្រិតថ្នាក់សហគមន៍ រាប់បញ្ចូលទាំងទិដ្ឋភាពទូទៅនៃក្រុមកំពុងមានហានិភ័យ និងទីកន្លែង និងកម្មវិធីសំខាន់ៗដែលកំពុងសម្របសម្រួល OCSE។
- ប៉ាន់ប្រមាណ និងវាយតម្លៃសមត្ថភាពនានា ការពារកុមារ ដែលទទួលខុសត្រូវចំពោះកុមារ នៅតាមសហគមន៍ រាប់បញ្ចូលទាំងគោលនយោបាយ និងអភិបាលកិច្ច ក្រុមហ៊ុនផ្តល់សេវាកម្មអ៊ិនធឺណិត យុត្តិធម៌ព្រហ្មទណ្ឌ និងប្រព័ន្ធផ្សព្វផ្សាយ និងការប្រាស្រ័យទំនាក់ទំនង។
- កំណត់អនុសាសន៍ផ្អែកលើភស្តុតាង ដែលអាចស្តែងចេញជាវិធានការបានសម្រាប់អន្តរាគមន៍ជាក់លាក់ចំពោះប្រទេសកម្ពុជា ផ្អែកលើគំរូនៃការឆ្លើយតបថ្នាក់ជាតិ(MNR) នៃWePROTECT ដែលនឹងផ្តល់ព័ត៌មានទៅក្នុងការរៀបចំបង្កើតផែនការសកម្មភាពសម្រាប់ដោះស្រាយបញ្ហា OCSE នៅក្នុងប្រទេសកម្ពុជា។

- កសាងសមត្ថភាពរបស់ភ្នាក់ងារសំខាន់ៗ ការពារកុមារនៅក្នុងវិស័យនានារបស់រដ្ឋាភិបាល និងវិស័យមិនមែនរដ្ឋាភិបាល ដើម្បីស្វែងយល់និងដោះស្រាយ OCSE នៅកម្រិតថ្នាក់សហគមន៍។

ការសិក្សានេះមិនមានបំណងប៉ុនប៉ងផ្តល់សំណាកតំណាងឲ្យកុមារនៅទូទាំងប្រទេសកម្ពុជាឡើយ ប៉ុន្តែមានបំណងត្រឹមតែផ្តល់នូវរូបភាពដំបូង និងមានគុណភាពសម្បូរបែបអំពីOCSEនៅប្រទេសកម្ពុជា ខ្លឹមសារៈសំខាន់ៗ និងទម្រង់នៃហានិភ័យ ព្រមទាំងការប៉ាន់ប្រមាណអំពីចេនាសម្ព័ន្ធរបស់រដ្ឋាភិបាល ដែលមានសម្រាប់រាយការណ៍ និងការឆ្លើយតបចំពោះករណី និងការបិទ/ដកយកខ្លឹមសារទាក់ទងនឹងOCSE ចេញពីអ៊ិនធឺណិតប៉ុណ្ណោះ។

## ២.១. ការកំណត់សំណាកគំរូ

គម្រោងនេះ នឹងផ្តោតការយកចិត្តទុកដាក់លើការប្រមូលទិន្នន័យពីវិស័យសំខាន់ៗចំនួនពីរ (សូមមើលគំនូស១)៖

**កុមារនិងសហគមន៍របស់កុមារ៖** ផ្តោតការយកចិត្តទុកដាក់លើ ការយល់ដឹងអំពីបទពិសោធន៍ និងហានិភ័យតាមការយល់ឃើញរបស់កុមារ គ្រួសាររបស់កុមារ គ្រូបង្រៀន និងបុគ្គលិកសង្គម ក្នុងសហគមន៍មូលដ្ឋាន និងមន្ត្រីអនុវត្តច្បាប់។ ការប្រមូលទិន្នន័យ ត្រូវធ្វើឡើងតាមរយៈកម្រងនៃសិក្ខាសាលា រៀនសូត្រ ដែលផ្តោតលើការកសាងទម្លាប់ ដែលត្រូវបានបង្កើតឡើងរួមគ្នា ដោយបុគ្គលិកសង្គមកម្ពុជា អ្នកជំនាញផ្នែកកិច្ចការពារកុមារ និងអ្នករចនាគម្រោងដោយគិតគូរអំពីមនុស្ស។ បន្ថែមលើនេះ ការសម្ភាសស៊ីជម្រៅ ត្រូវបានធ្វើឡើងនៅកម្រិតថ្នាក់សហគមន៍ជាមួយមន្ត្រីរដ្ឋាភិបាល មន្ត្រីអនុវត្តច្បាប់ បុគ្គលិកសង្គម អ្នកស្វែងរកការគាំទ្រមតិសំខាន់ៗ មកពីអង្គការមានមូលដ្ឋានក្នុងសហគមន៍ ដើម្បីបន្ថែមបរិបទថែមទៀតសម្រាប់ទិន្នន័យ ដែលត្រូវប្រមូលបានពីសិក្ខាសាលារៀនសូត្រ។

**សមត្ថភាពការពារកុមារ៖** ផ្តោតការយកចិត្តទុកដាក់លើការកសាងការយល់ដឹងអំពីសមត្ថភាពផ្សេងៗនៃរដ្ឋាភិបាលថ្នាក់ជាតិ ឧស្សាហកម្មឯកជនក្នុងប្រទេស (ក្រុមហ៊ុនផ្តល់សេវាកម្មអ៊ិនធឺណិត) គំនិតផ្តួចផ្តើមថ្នាក់តំបន់ និងយន្តការការពារកុមារថ្នាក់អន្តរជាតិ ក្នុងការការពារកុមារនៅតាមបណ្តាសហគមន៍កម្ពុជា ពីហានិភ័យនៃ OCSE។ ជាពិសេស ការសិក្សានេះ ពិចារណាលើវិធីនានាដែលយន្តការទាំងនេះធ្វើការងារ ឬអាចធ្វើការងាររួមគ្នា ដើម្បីបង្កើតបណ្តាញសុវត្ថិភាព មានលក្ខណៈរួមបញ្ចូលគ្នា បណ្តាញសុវត្ថិភាពបែបឆ្លើយតប និងយន្តការឆ្លើយតប ដើម្បីការពារកុមារនៅតាមប្រព័ន្ធអ៊ិនធឺណិត។ សកម្មភាពនេះរួមមាន ការសម្ភាសស៊ីជម្រៅជាមួយមន្ត្រីរដ្ឋាភិបាលសំខាន់ៗ និងអ្នកតំណាងក្រុមហ៊ុនផ្តល់សេវាកម្មអ៊ិនធឺណិត បន្ថែមលើការពិនិត្យជាប្រព័ន្ធលើច្បាប់ការពារកុមារក្នុងប្រទេស និងក្នុងតំបន់ ដែលទាក់ទងនឹង OCSE ការដក CSAM ចេញពីអ៊ិនធឺណិត និងគោលនយោបាយការពារកុមាររបស់ក្រុមហ៊ុនផ្តល់សេវាកម្មអ៊ិនធឺណិតកម្ពុជា។




**រូបភាព១ ៖** គំរូដែលបង្ហាញវិស័យពីរសម្រាប់ប្រមូលទិន្នន័យពីការសិក្សានេះ - កុមារ និងសហគមន៍ និងសមត្ថភាពការពារកុមារ។

## ២.២. ការរៀនសូត្រពីកុមារនៅក្នុងសហគមន៍

សិក្ខាសាលារៀនសូត្រ ផ្តល់ព័ត៌មានសម្រាប់សំណួរស្នូលនៃការសិក្សានេះ អំពីចរិតនៃOCSE នៅក្នុងសហគមន៍កម្ពុជា និងស្វែងរកទម្រង់ផ្សេងៗនៃOCSE ដែលកុមារនៅក្នុងប្រទេសកម្ពុជាជួបប្រទះ។ សិក្ខាសាលាទាំងនេះ បានផ្តល់បរិយាកាសប្រកបដោយសុវត្ថិភាព មានអន្តរទំនាក់ទំនងគ្នា និងភាពច្នៃប្រឌិតសម្រាប់កុមារគិតអំពីវិធីដែលពួកគេប្រើប្រាស់អ៊ិនធឺណិត និងហានិភ័យតាមប្រព័ន្ធអ៊ិនធឺណិត ដែលទំនងជាមានសម្រាប់កុមារកម្ពុជា។ ជាពិសេស សិក្ខាសាលាទាំងនេះ បានរិះរកទម្រង់ផ្សេងៗ ដែលជាទូទៅOCSE បង្ហាញយ៉ាងច្បាស់នៅក្នុងបរិយាកាសអ៊ិនធឺណិតរបស់កុមារនៅប្រទេសកម្ពុជា។ វិស័យនៃការស្រាវជ្រាវរក រួមមាន ការផលិត និងការចែកចាយសម្ភារទាក់ទងនឹងការរំលោភបំពានផ្លូវភេទលើកុមារ(CSAM) ការផ្សាយផ្ទាល់នូវការកេងប្រវ័ញ្ចផ្លូវភេទ(LCSE) ព្រមទាំងទម្រង់ក្រៅអ៊ិនធឺណិតមួយចំនួននៃការកេងប្រវ័ញ្ច ដែលអាចទាក់ទងនឹងធាតុផ្សំតាមអ៊ិនធឺណិត និងក្រៅអ៊ិនធឺណិត ដូចជា ការប្រើប្រាស់កម្មវិធីទូរស័ព្ទ ឬកម្មវិធី ICT ផ្សេងទៀត ដើម្បីជួបកុមារតាមក្រៅអ៊ិនធឺណិត និងរំលោភបំពាន ឬការកេងប្រវ័ញ្ច។

គុណតម្លៃនៃការរៀបចំបង្កើតគម្រោងដោយគិតគូរអំពីមនុស្ស បានដឹកនាំរៀបចំនិងប្រតិបត្តិសិក្ខាសាលាទាំងនេះ។ សិក្ខាសាលារៀនសូត្រចំនួន១៣ ត្រូវបានរៀបចំឡើងជាមួយកុមារចំនួន២២០នាក់ មានអាយុពី៨ ទៅដល់១៧ឆ្នាំ និងគ្រូបង្រៀនចំនួន៤៥នាក់ មកពីសាលារៀនរដ្ឋ សាលារៀនឯកជន និងមណ្ឌលសាលារៀននៃអង្គការមិនមែនរដ្ឋាភិបាល នៅក្នុងតំបន់ចំនួន៣នៃប្រទេសកម្ពុជា៖ ខេត្តព្រះសីហនុ ខេត្តសៀមរាប និងរាជធានីភ្នំពេញ (រាប់បញ្ចូលទាំងតំបន់នានាក្នុងក្រុងតាខ្មៅនិងខេត្តកណ្តាល)ផងដែរ។ តំបន់ទាំងបីនេះ ត្រូវបានជ្រើសរើសដោយសារតំបន់ទាំងនេះគឺជាតំបន់ទីក្រុងធំៗនិងជាតំបន់ដែលមានភាគរយអ្នកប្រើប្រាស់អ៊ិនធឺណិតខ្ពស់បំផុតនៅក្នុងប្រទេស។ នេះដោយយោងតាមការសិក្សាថ្នាក់ជាតិរបស់LINRE asia[52]។ បន្ថែមលើនេះ វត្តមានអង្គការមិនមែនរដ្ឋាភិបាលជាដៃគូ និងបណ្តាញផ្សេងៗទៀតដែលមានស្រាប់ បានជួយសម្របសម្រួលយ៉ាងច្រើនដល់សកម្មភាពគម្រោងនេះ។ សិក្ខាសាលារៀនសូត្រនេះ ត្រូវបានរៀបចំធ្វើឡើងជាមួយកុមារមកពីសាលារៀនបំពេញវិជ្ជា (អង្គការមិនមែនរដ្ឋាភិបាល) សាលារៀនរដ្ឋ និងសាលារៀនឯកជននៅក្នុងតំបន់មូលដ្ឋាននីមួយៗ។ ក្រុមទាំងនេះត្រូវបានបំបែក ដើម្បីឲ្យមានការបំបែកក្នុងលក្ខណៈប្រហាក់ប្រហែលទៅតាមក្រុមសេដ្ឋកិច្ចសង្គមនៅប្រទេសកម្ពុជា។ ជាចុងក្រោយ សិក្ខាសាលារៀនសូត្រចំនួន៣ ជាមួយគ្រូបង្រៀនចំនួន៤៥នាក់ នៅទូទាំងតំបន់ទាំង៣ត្រូវបានរៀបចំឡើង ដើម្បីបង្កើតរូបភាពអំពីការយល់ដឹងរបស់គ្រូបង្រៀន និងអន្តរទំនាក់ទំនងជាមួយកិច្ចការពារកុមារនៅក្នុងបរិយាកាសអ៊ិនធឺណិត។

បន្ថែមលើការរៀនសូត្រដែលប្រមូលបានពីសិក្ខាសាលាជាមួយកុមារ និងគ្រូបង្រៀននៅក្នុងសហគមន៍ទាំងនេះ គេបានធ្វើសម្ភាសស៊ីជម្រៅនៅក្នុងតំបន់មូលដ្ឋាននីមួយៗជាមួយមន្ត្រីរដ្ឋាភិបាល អ្នកតំណាងមកពីក្រុមហ៊ុនផ្តល់សេវាកម្មអ៊ិនធឺណិតនិងអ្នកប្រតិបត្តិការងារសង្គម មកពីអង្គការមិនមែនរដ្ឋាភិបាល ដែលមានមូលដ្ឋាននៅក្នុងសហគមន៍។

គោលដៅស្នូលសម្រាប់សិក្ខាសាលារៀនសូត្រគឺ៖

- ដើម្បីយល់ដឹងយ៉ាងទូលំទូលាយ និងប្លែកៗគ្នាអំពីចរិត និងទំហំនៃ OCSE នៅក្នុងសហគមន៍កម្ពុជា។
- ដើម្បីបង្កើតការយល់ដឹងអំពីអ្នកដែលជាក្រុមប្រជាជនមានហានិភ័យសំខាន់ៗ និងមូលហេតុដែលធ្វើឲ្យពួកគេមានហានិភ័យ។
- ដើម្បីកំណត់ទីកន្លែង ក្រុម និងកម្មវិធី ដែលសម្របសម្រួលភាពងាយរងគ្រោះរបស់កុមារ ចំពោះការកេងប្រវ័ញ្ចតាមប្រព័ន្ធអ៊ិនធឺណិត។

[52] LINRE asia. (2018).

- ដើម្បីកំណត់អនុសាសន៍ផ្អែកលើភស្តុតាង និងដែលអាចស្វែងចេញជាវិធានការបានសម្រាប់អន្តរាគមន៍ជាក់លាក់ចំពោះប្រទេសកម្ពុជា។

ការស្រាវជ្រាវនេះបានចាប់ដៃគូគ្នាជាមួយអង្គការ មានមូលដ្ឋាននៅក្នុងសហគមន៍ចំនួន៤ មកពីរាជធានីភ្នំពេញ ខេត្តសៀមរាប និងខេត្តព្រះសីហនុ។ នៅរាជធានីភ្នំពេញ ការស្រាវជ្រាវនេះ បានចាប់ដៃគូគ្នាជាមួយអង្គការ The Hard Places Community (HPC) និងអង្គការជំហានដំបូងកម្ពុជា (FSC)។ អង្គការ HPC គឺជាអង្គការផ្តល់សេវាសង្គម ដែលធ្វើការងារជាមួយកុមារមកពីសហគមន៍ងាយរងគ្រោះនៅរាជធានីភ្នំពេញ ដោយផ្តោតការយកចិត្តទុកដាក់ជាក់លាក់លើការដោះស្រាយបញ្ហានៃការរំលោភបំពាននិងការកេងប្រវ័ញ្ចផ្លូវភេទកុមារនៅសហគមន៍។ អង្គការ FSC គឺជាគម្រោងអង្គការឯកទេសមួយ មានមូលដ្ឋាននៅរាជធានីភ្នំពេញ ដែលផ្តល់សេវាគាំទ្រជាច្រើនដល់កុមារា និងបុរសវ័យក្មេង ដែលជាអ្នករួចផុតពីការរំលោភបំពាននិងការកេងប្រវ័ញ្ចផ្លូវភេទ។ នៅខេត្តព្រះសីហនុ ការស្រាវជ្រាវនេះ បានចាប់ដៃគូគ្នាជាមួយអង្គការម្លប់តាប៉ាង ជាអង្គការផ្តល់សេវាសង្គមដែលផ្តល់ការថែទាំ និងការគាំទ្រយ៉ាងច្រើនដល់កុមារមកពីសហគមន៍ងាយរងគ្រោះ នៅខេត្តព្រះសីហនុ រួមមានការអប់រំ សមាហរណកម្មទៅក្នុងគ្រួសារ ការបណ្តុះបណ្តាលបំណិនជីវិត សកម្មភាពប្រកបដោយភាពច្នៃប្រឌិតនិងសកម្មភាពកំសាន្តនានា ព្រមទាំងការឆ្លើយតប និងកិច្ចការពារពីគ្រប់ទម្រង់នៃការរំលោភបំពាន។ នៅខេត្តសៀមរាប ការស្រាវជ្រាវនេះ បានចាប់ដៃគូគ្នាជាមួយបុគ្គលិកសង្គមក្នុងស្រុក មកពីអង្គការដែនដីមនុស្ស-ប្រទេសហូឡង់(TdH-NL) ដែលជាអង្គការអភិវឌ្ឍន៍អន្តរជាតិជាមួយនឹងការិយាល័យគម្រោង និងក្រុមបុគ្គលិកសង្គមក្នុងស្រុកនៅខេត្តសៀមរាប ដែលផ្តោតការយកចិត្តទុកដាក់លើការឆ្លើយតបនឹងការកេងប្រវ័ញ្ចផ្លូវភេទក្នុងការធ្វើដំណើរនិងវិស័យទេសចរណ៍ (SECTT) តាមរយៈការធ្វើការងារជាមួយភ្នាក់ងារអនុវត្តច្បាប់ ផ្តល់ការស្វែងរកការគាំទ្រមតិចំពោះកុមារ និងកិច្ចការពារសម្រាប់អ្នករួចផុតពីការកេងប្រវ័ញ្ច។

## ២.២.១. ការស្រាវជ្រាវដោយគិតគូរអំពីមនុស្ស និងពិធីសារក្រមសីលធម៌

ការបណ្តុះបណ្តាលប្រកបដោយការចូលរួមរយៈពេល៤ថ្ងៃ ត្រូវបានរៀបចំធ្វើជូនបុគ្គលិកសង្គម និងបុគ្គលិកដែលមានទំនាក់ទំនងជាមួយកុមារ។ ការបណ្តុះបណ្តាលនេះគ្របដណ្តប់លើទស្សនៈវិជ្ជា និងគុណតម្លៃស្នូលនៃការរៀបចំបង្កើតគម្រោងដោយគិតគូរអំពីមនុស្ស និងពិធីសារក្រមសីលធម៌សម្រាប់ធ្វើការស្រាវជ្រាវជាមួយកុមារ។ ការបណ្តុះបណ្តាលនេះ រួមមានការអភិវឌ្ឍន៍យ៉ាងទូលំទូលាយ និងដាក់ស្នែងនូវជំនាញ ដូចជា ភាពចេះយល់ចិត្ត ការយកចិត្តទុកដាក់ស្តាប់ និងការរៀបចំបរិស្ថានប្រកបដោយសុវត្ថិភាពនិងភាពរីករាយ ដែលកុមារមានអារម្មណ៍ថា ពួកគេមានសារៈសំខាន់ មានគេយកចិត្តទុកដាក់ស្តាប់ និងអាចនិយាយដោយមានសុវត្ថិភាពអំពី "ពិភពអ៊ិនធឺណិត" របស់ពួកគេ និងហានិភ័យនានា ដែលពួកគេអាចប្រឈមមុខនៅទីនោះ។ ជ្រុងដ៏សំខាន់មួយនៃការបណ្តុះបណ្តាលនេះ គឺការពង្រឹងការយល់ដឹងថា "កុមារគឺជាអ្នកឯកទេសអំពីការពិតផ្ទាល់ខ្លួនរបស់ពួកគេ" ហើយក្រុមដែលជាអ្នកស្រាវជ្រាវ ត្រូវទទួលភារកិច្ចរៀបចំបរិយាកាសដែលផ្តល់ឲ្យកុមារនូវវេទិកាមួយសម្រាប់ប្រាស្រ័យទាក់ទងគ្នា តាមរយៈសិល្បៈពាក្យពេជន៍នានា និងចលនា។

នៅក្នុងសប្តាហ៍នៃការបណ្តុះបណ្តាលនេះ បានបញ្ចូលការតម្រង់ទិសយ៉ាងសង្ខេបអំពីបញ្ហាOCSE ព្រមទាំងការណែនាំអំពីទស្សនៈវិជ្ជា និងអភិក្រមនៃការស្រាវជ្រាវដោយគិតគូរអំពីមនុស្ស។ បន្ទាប់មក ក្រុមនេះបានផ្តោតការយកចិត្តទុកដាក់លើការកសាងជំនាញជាក់លាក់ទាក់ទងនឹងការស្រាវជ្រាវដោយគិតគូរអំពីមនុស្ស ជាពិសេស ក្រមសីលធម៌ ភាពចេះយល់ចិត្ត ការស្តាប់ ការប្រាស្រ័យទាក់ទងគ្នា និងការកសាងទំនាក់ទំនង។ បន្ទាប់មកទៀត គេបាន

ចំណាយពេលវេលាពេញមួយថ្ងៃ បង្កើតឲ្យមានការយល់ដឹងអំពី និងដោះស្រាយភាពចន្លោះប្រហោងផ្នែកជំនាញរបស់អ្នកចូលរួមម្នាក់ៗ និងផ្តោតការយកចិត្តទុកដាក់លើការកសាងសមត្ថភាពក្រុម ដើម្បីធ្វើការងារជាមួយគ្នាទៅវិញទៅមកទាំងស្រុង ក្នុងការរិះរកដំណោះស្រាយសម្រាប់បញ្ហាប្រឈមនានាដែលមានលក្ខណៈស្មុគស្មាញ។ ខណៈពេលឈានឆ្ពោះទៅកការបញ្ចប់វគ្គបណ្តុះបណ្តាលនេះ បុគ្គលិកសង្គមកិច្ច បានធ្វើការងារជាមួយមិត្តរួមក្រុមរបស់ខ្លួន រៀបចំសិក្ខាសាលារយៈពេលមួយថ្ងៃពេញ ដែលនឹងដំណើរការប្រព្រឹត្តទៅល្វេនសម្រាប់បរិបទរបស់ពួកគេផ្ទាល់។ បន្ទាប់មកទៀត ក្រុមស្រាវជ្រាវនេះ បានប្រើប្រាស់ទស្សនៈទានដោយឡែកទាំងនោះ រៀបចំវគ្គសិក្ខាសាលារៀនសូត្រឯកភាពគ្នាមួយ មានរយៈពេលមួយថ្ងៃពេញសម្រាប់យកទៅអនុវត្តជាមួយកុមារ និងគ្រូបង្រៀន នៅរាជធានីភ្នំពេញ ខេត្តសៀមរាប និងខេត្តព្រះសីហនុ។

## ២.២.២. ការពិនិត្យទិន្នន័យអំពីប្រទេសកម្ពុជាសម្រាប់រាយការណ៍ក្នុងប្រទេស និងអន្តរជាតិ

ការស្រាវជ្រាវនេះ បានធ្វើសម្ភាសន៍ស៊ីជម្រៅជាមួយយន្តការរាយការណ៍អំពីOCSE ក្នុងប្រទេស និងអន្តរជាតិ មានដូចជា បណ្តាញរាយការណ៍បន្ទាន់តាមប្រព័ន្ធអ៊ិនធឺណិតនៃអង្គការAPLE(កម្ពុជា) បណ្តាញទូរស័ព្ទជំនួយកុមារកម្ពុជា មជ្ឈមណ្ឌលជាតិការពារកុមារបាត់ខ្លួន និងរងគ្រោះដោយការកេងប្រវ័ញ្ច(NCMECសហរដ្ឋអាមេរិក) និងមូលដ្ឋានទិន្នន័យ ICSE នៃនគរបាលអន្តរជាតិ(អន្តរជាតិ)។ អ្វីដែលគេអាចធ្វើបាន គឺការស្រាវជ្រាវនេះបានប្រមូល និងវិភាគទិន្នន័យបច្ចុប្បន្ននិងទិន្នន័យពីមុនអំពី OCSE ពីប្រភពទាំងនេះ។ ទិន្នន័យដែលពេញលេញ គឺមានតែពីបណ្តាញរាយការណ៍បន្ទាន់តាមប្រព័ន្ធអ៊ិនធឺណិតនៃអង្គការAPLE និងពីបណ្តាញទូរស័ព្ទជំនួយកុមារកម្ពុជាប៉ុណ្ណោះ។ បណ្តាញទូរស័ព្ទបន្ទាន់តាមប្រព័ន្ធអ៊ិនធឺណិតនៃអង្គការ APLE បានផ្តល់ទិន្នន័យពីករណីទាក់ទងនឹង OCSE ដែលមានចំនួនសរុប២០៤ករណី ក្នុងកំឡុងពេលបីឆ្នាំមុន ហើយបណ្តាញទូរស័ព្ទជំនួយកុមារកម្ពុជា បានទិន្នន័យករណីសរុបចំនួន៧ក្នុងកំឡុងពេលដូចគ្នានេះ។ NCMEC បានផ្តល់ទិន្នន័យដែលពណ៌នាអំពីទិន្នន័យជាមូលដ្ឋានផ្សេងទៀតសម្រាប់របាយការណ៍ទាក់ទងនឹងប្រទេសកម្ពុជាចំនួនជាង ២០០.០០០ របាយការណ៍ស្តីពី CSAM ដែលត្រូវបានបញ្ជូនមកការិយាល័យសន្តិសុខមាតុភូមិនៃសហរដ្ឋអាមេរិកក្នុងកំឡុងពេល៥ឆ្នាំមុន។ នគរបាលអន្តរជាតិមិនអាចផ្តល់ទិន្នន័យពាក់ព័ន្ធនឹងប្រទេសកម្ពុជាជាក់លាក់អំពីករណី OCSE បានឡើយ។

## ២.២.៣. ការអង្កេតតាមប្រព័ន្ធអនឡាញជាមួយយុវសិស្សសាលារដ្ឋ

ការអង្កេតតាមប្រព័ន្ធអនឡាញ ត្រូវបានធ្វើឡើងជាមួយសិស្ស មកពីសាលារៀនរដ្ឋចំនួន១៣៩នាក់ ដែលមានទំនាក់ទំនងជាមួយកម្មវិធី ការថែទាំកុមារក្នុងគ្រួសារ ជាអាទិភាពចម្បងនៅក្នុងតំបន់ខេត្តបាត់ដំបង។ ការអង្កេតនេះ មាន៣០សំណួរ ដែលប៉ាន់ប្រមាណអំពីវិធីដែលយុវវ័យភ្ជាប់អ៊ិនធឺណិត និងគំនិត និងបទពិសោធន៍របស់ពួកគេទាក់ទងនឹងសុវត្ថិភាព និងហានិភ័យតាមប្រព័ន្ធអ៊ិនធឺណិត។

ស្របពេលដែលចេតនាដំបូងនៃការស្រាវជ្រាវនេះ គឺដើម្បីប្រមូលសំណាកតំណាងជាតិពីយុវវ័យកម្ពុជា នៅតាមសាលារៀនរដ្ឋ សាលារៀនឯកជន និងសាលារៀនបំពេញវិជ្ជា និងដោយសារពេលវេលា មានកំណត់ដូច្នោះ ទំហំនៃការអង្កេតនេះគឺមានកម្រិត។ ទិន្នន័យដែលត្រូវបង្ហាញនៅក្នុងការអង្កេតនេះ មិនអាចធ្វើជាតំណាងជាតិទាំងមូលបានឡើយ ទោះបីជាយ៉ាងណា វាផ្តល់នូវបណ្តុំនៃការរៀនសូត្រដ៏មានសារៈសំខាន់អំពីការប្រើប្រាស់អ៊ិនធឺណិត ក្នុងចំណោមក្រុមយុវវ័យជាក់លាក់ និងផ្តល់ការប្រៀបធៀបដ៏មានសារៈសំខាន់ជាសក្តានុពលជាមួយនឹងការរៀនសូត្រផ្សេងទៀត ដែលត្រូវរៀបចំពេញមួយកំឡុងពេលនៃការសិក្សាស្រាវជ្រាវនេះ។ របកគំហើញនៃការសិក្សានេះ ត្រូវបាន

បញ្ចូលជាឧបសម្ព័ន្ធនៅក្នុងរបាយការណ៍នេះ និងឆ្លុះបញ្ចាំងនៅក្នុងការពិភាក្សា និងអនុសាសន៍សំខាន់ៗនៃការសិក្សានេះ។ យើងមានចេតនាថា គំនិតផ្តួចផ្តើមសម្រាប់ការស្រាវជ្រាវនាពេលអនាគត នឹងធ្វើការងារជាមួយរាជរដ្ឋាភិបាលកម្ពុជា ដើម្បីកសាងបន្ថែមលើរបកគំហើញនៅមានកម្រិតនេះ នឹងបង្កើតសំណាកតំណាងថ្នាក់ជាតិនៃយុវវ័យកម្ពុជានៅក្នុងកម្មវិធីអប់រំសាធារណៈ ឯកជន និងកម្មវិធីអប់រំបំពេញវិជ្ជា។

## ២.៣. ការរៀនសូត្រអំពីសមត្ថភាពការពារកុមារពី OCSE

ការសម្ភាសស៊ីជម្រៅត្រូវបានរៀបចំធ្វើឡើងជាមួយអ្នកតំណាងសំខាន់ៗ មកពីទីភ្នាក់អនុវត្តច្បាប់ជាតិ តំបន់ និងអន្តរជាតិ ទីភ្នាក់ងារ ឬស្ថាប័នរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាល ព្រមទាំងសមាជិកពាក់ព័ន្ធនៃវិស័យឯកជនកម្ពុជា។ ការសម្ភាសទាំងនេះ ប៉ាន់ប្រមាណមើលការយល់ដឹងទូទៅអំពីOCSE និងសមត្ថភាពផ្សេងៗ ដើម្បីឆ្លើយតបចំពោះតម្រូវការរបស់កុមារ និងដើម្បីសហការជាមួយដៃគូពាក់ព័ន្ធ និងទីភ្នាក់ងារនានា ដើម្បីទប់ស្កាត់ការរំលោភបំពាន និងការកេងប្រវ័ញ្ចកុមារតាមប្រព័ន្ធអ៊ិនធឺណិតនៅក្នុងប្រទេសកម្ពុជា។

### ២.៣.១. យុត្តិធម៌ព្រហ្មទណ្ឌ

ទិន្នន័យយុត្តិធម៌ព្រហ្មទណ្ឌ ត្រូវបានទាញយកពីអ្នកតំណាងមកពីទីភ្នាក់ងារអនុវត្តច្បាប់ជាតិ តំបន់ និងអន្តរជាតិចំនួន៩នាក់។ នៅក្នុងប្រទេសកម្ពុជា អ្នកតំណាងទាំងនេះ រួមមាន សមាជិកបួននាក់នៃទីភ្នាក់ងារអនុវត្តច្បាប់កម្ពុជាក្នុងនោះមាននាយកដ្ឋានប្រឆាំងអំពើជួញដូរមនុស្សនិងការពារអនីតិជន និងនាយកដ្ឋានប្រឆាំងបទល្មើសបច្ចេកវិទ្យាចំណុះក្រសួងមហាផ្ទៃ។ នៅប្រទេសថៃ ការស្រាវជ្រាវនេះ ទាញយកទិន្នន័យពីអ្នកតំណាងសំខាន់ម្នាក់នៃនាយកដ្ឋានស៊ើបអង្កេតពិសេសនៃប្រទេសថៃ និងអ្នកតំណាងសំខាន់ពីរនាក់នៃទីភ្នាក់ងារអនុវត្តច្បាប់អន្តរជាតិ។ បន្ថែមលើនេះ ការស្រាវជ្រាវនេះ បានទាញយកទិន្នន័យបន្ថែមពីអ្នកតំណាងសំខាន់ពីរនាក់ មកពីការិយាល័យស៊ើបអង្កេតសហព័ន្ធ (FBI) និងក្រសួងសន្តិសុខមាតុភូមិ (HSI) នៃសហរដ្ឋអាមេរិក។

ស្របពេលដែលការស្រាវជ្រាវនេះ បានអនុវត្តតាមកម្រងសំណួរខុសៗគ្នា អាស្រ័យលើទីភ្នាក់ងារ និងសមត្ថភាព និងមុខងាររបស់ទីភ្នាក់ងារ ក្នុងការឆ្លើយតបទៅនឹង OCSE នៅប្រទេសកម្ពុជា ភាគច្រើន ការសម្ភាសទាំងនេះបានអនុវត្តតាមវិស័យនៃសំណួរទូលំទូលាយដូចតទៅ៖

១- តើទីភ្នាក់ងារអនុវត្តច្បាប់នៅប្រទេសកម្ពុជាមានការអនុវត្ត និងបញ្ហាប្រឈមអ្វីខ្លះ បច្ចុប្បន្ននេះដែលទាក់ទងទៅនឹងOCSE?

២-តើតុលាការនៅប្រទេសកម្ពុជាមានការអនុវត្ត និងបញ្ហាប្រឈមអ្វីខ្លះ បច្ចុប្បន្ននេះដែលទាក់ទងទៅនឹង OCSE?

៣-បច្ចុប្បន្ននេះ តើមានតម្រូវការការកសាងសមត្ថភាព និងការបណ្តុះបណ្តាលអ្វីខ្លះទាក់ទងទៅនឹងបទល្មើសបច្ចេកវិទ្យា និងកិច្ចការពារកុមារ?

ក្នុងអំឡុងពេលនៃដំណើរការនេះ ការស្រាវជ្រាវនេះ ក៏បានស្វែងរកករណី OCSE មានស្រាប់ផងដែរ ដែលត្រូវរាយការណ៍ពីចំណោមនគរបាល។

### ២.៣.២. គោលនយោបាយ និងអភិបាលកិច្ច

ទិន្នន័យបឋមស្តីពីគោលនយោបាយ និងអភិបាលកិច្ច ត្រូវបានទាញយកពីអ្នកតំណាងចំនួន១០នាក់ មកពីអង្គការអភិបាលកិច្ច និងនិយ័តករជាតិ និងអន្តរជាតិ។ នៅថ្នាក់ជាតិ អ្នកតំណាងទាំងនេះ រួមមាន អ្នកតំណាងចំនួន៧នាក់ មកពីរដ្ឋាភិបាលកម្ពុជា រួមមាន ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ និយ័តករទូរគមនាគមន៍កម្ពុជា និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។ ថ្នាក់អន្តរជាតិ អ្នកតំណាងទាំងនេះ រួមមាន អ្នកតំណាងផ្នែកកិច្ចការពារសំខាន់ចំនួន២នាក់ មកពីមូលនិធិអង្គការសហប្រជាជាតិដើម្បីកុមារ (អង្គការយូនីសេហ្វ) និងអ្នកតំណាងម្នាក់ មកពីការិយាល័យអង្គការសហប្រជាជាតិទទួលបន្ទុកគ្រឿងញៀន និងឧក្រិដ្ឋកម្ម (UNODC)។ សំណួរសំខាន់មួយចំនួន ដើម្បីដឹកនាំការសម្ភាសនេះគឺ៖

១-តើអ្វីទៅដែលជាចរិត ទំហំ និងប្រសិទ្ធភាពច្បាប់ និងគោលនយោបាយតំបន់(អាស៊ាន) និងជាតិ?

២-តើមានឱកាសអ្វីខ្លះក្នុងបរិបទនេះ ដើម្បីប្រតិបត្តិតាមគំនិតផ្តួចផ្តើមថ្នាក់តំបន់ដែលមានស្រាប់ទាក់ទងទៅនឹងអំពើហិង្សាលើកុមារ និងការរំលោភបំពាន និងការកេងប្រវ័ញ្ចតាមប្រព័ន្ធអ៊ិនធឺណិត?

៣-តើមានសារគន្លឹះៗអ្វីខ្លះក្នុងបរិបទនេះ ដើម្បីបង្កើតសម្ភារអប់រំ លើកកម្ពស់ការយល់ដឹង និងស្វែងរកការគាំទ្រមតិ?

### ២.៣.៣. ទីភ្នាក់ងារ ឬ ស្ថាប័ន ការពារកុមារ

កម្រងសំណួរជាមួយទីភ្នាក់ងារការពារកុមារ មានភាពខុសៗគ្នាយ៉ាងច្រើន អាស្រ័យលើសមត្ថភាព និងអាណត្តិរបស់អង្គការដែលត្រូវបានសម្ភាស។ ឧទាហរណ៍ ការសម្ភាសជាមួយអង្គការនានា ដូចជាមជ្ឈមណ្ឌលជាតិការពារកុមារបាត់ខ្លួន និងរងគ្រោះដោយការកេងប្រវ័ញ្ច (NCMEC) និងគម្រោង NetClean បានផ្តោតការយកចិត្តទុកដាក់ច្រើនលើយន្តការរាយការណ៍ជាក្រុម និងយន្តការបញ្ជូន ដែលត្រូវបានបង្កើតឡើងជាមួយរដ្ឋាភិបាលក្នុងប្រទេស និងទីភ្នាក់ងារអនុវត្តច្បាប់អន្តរជាតិ ស្របពេលដែលការសម្ភាសជាមួយទីភ្នាក់ងារការពារកុមារក្នុងប្រទេសផ្តោតការយកចិត្តទុកដាក់ច្រើនលើបញ្ហា OCSE នៅក្នុងប្រទេសកម្ពុជា ការកំណត់អត្តសញ្ញាណជនរងគ្រោះ និងភាពខ្វះចន្លោះក្នុងការផ្តល់សេវា។

ទិន្នន័យត្រូវបានទាញយកពីអ្នកតំណាងចំនួន ២៥ នាក់ មកពីទីភ្នាក់ងារជាតិការពារកុមារតំបន់ និងអន្តរជាតិ។ ក្នុងចំណោមអ្នកតំណាងទាំងនេះ មាន១២នាក់ មកពីទីភ្នាក់ងារកម្ពុជា រួមមាន បណ្តាញសុវត្ថិភាពកុមារ អង្គការសង្គ្រោះទារក អង្គការកល្យាណមិត្ត អង្គការម្លប់តាប៉ាង មជ្ឈមណ្ឌលធនធានស្ត្រី មន្ទីរពេទ្យកុមារអង្គរ បណ្តាញទូរស័ព្ទជំនួយកុមារកម្ពុជា និងអង្គការសកម្មភាពដើម្បីកុមារ (APLE)។

### ២.៣.៤. ឧស្សាហកម្មឯកជន

ការស្រាវជ្រាវនេះ ក៏បានធ្វើសម្ភាសស៊ីជម្រៅជាមួយអ្នកតំណាងពីរនាក់ មកពីក្រុមហ៊ុនផ្តល់សេវាកម្មអ៊ិនធឺណិតកម្ពុជា ចំនួនពីរក្រុមហ៊ុន ដែលត្រូវបានសួរសំណួរយ៉ាងទូលំទូលាយ ដូចខាងក្រោមនេះផងដែរ៖

១- តើក្រុមហ៊ុនផ្តល់សេវាកម្មអ៊ិនធឺណិត មានយន្តការ ឥរិយាបថ ការប្តេជ្ញាចិត្ត ការជំរុញទឹកចិត្ត និងសមត្ថភាពអ្វីខ្លះ បច្ចុប្បន្ននេះ ដើម្បីការពារកុមារឲ្យបានកាន់តែល្អពី OCSE?

២- តើមានការឆ្លើយតប អ្វីខ្លះ នៅក្នុងប្រព័ន្ធអេកូ ICT បច្ចុប្បន្ននេះ រួមមាន ការភ្ជាប់ទំនាក់ទំនងក្រុមហ៊ុនផ្តល់សេវាកម្មអ៊ិនធឺណិត ជាមួយនឹងបណ្តាញរាយការណ៍បន្ទាន់តាមប្រព័ន្ធអ៊ិនធឺណិតរបស់អង្គការ APLE ការបិទ និងការដកចេញលទ្ធភាពចូលមើលខ្លឹមសារ OCSE និងការចូលរួមរបស់ឧស្សាហកម្មនេះ

៣- តើមានសារគន្លឹះៗអ្វីខ្លះ ដែលចាំបាច់សម្រាប់បង្កើតសម្ភារៈរាយការណ៍ អប់រំ លើកកម្ពស់ការយល់ដឹង និងស្វែងរកការគាំទ្រមតិប្រកបដោយប្រសិទ្ធភាព?

# ជំពូកទី៣៖ បទពិសោធន៍របស់កុមារតាមប្រព័ន្ធអនឡាញ

## ៣.១. សិក្ខាសាលារៀនសូត្រ

### ៣.១.១. ការយល់ដឹងអំពីបរិយាកាសតាមប្រព័ន្ធអនឡាញរបស់យុវវ័យកម្ពុជា

យុវវ័យទទួលបានការលើកទឹកចិត្តឱ្យគិតទូលំទូលាយអំពីបទពិសោធន៍របស់ខ្លួនតាមប្រព័ន្ធអនឡាញ រាប់បញ្ចូលទាំងវិធីភ្ជាប់ ទីកន្លែងភ្ជាប់ និងអ្វីដែលពួកគេចង់ឃើញនៅក្នុងពិភពអ៊ិនធឺណិត។ ប្រសិនបើពួកគេអាច "ចូលទៅក្នុងនោះ" និងចូលមើលនៅក្នុងនោះបាន។ ជាមធ្យោបាយនៅក្នុងការធ្វើកិច្ចការនេះ កុមារចូលរួមនៅក្នុងសិក្ខាសាលារៀនសូត្រនីមួយៗ បានចំណាយពេលកន្លះថ្ងៃធ្វើការងារជាក្រុមតូចៗមានគ្នាពី ៤ ទៅ ៥នាក់ ដើម្បីបង្កើតផែនទីអន្តរទំនាក់ទំនងគ្នាយ៉ាងធំអំពី "ពិភពអ៊ិនធឺណិត"។ អ្នកសម្របសម្រួល បានចូលរួមជាមួយក្រុមយុវវ័យនីមួយៗ និងសួរសំណួរបន្ថែម ដើម្បីធ្វើឱ្យការគិតគូរអំពីពិភពអ៊ិនធឺណិតរបស់ពួកគេមានលក្ខណៈប្រកបដោយអន្តរទំនាក់ទំនង ការស្វែងរក និងភាពរីករាយ។ ផែនទីអ៊ិនធឺណិតរបស់កុមារបានរួមបញ្ចូលទីកន្លែងទាំងអស់នៅតាមប្រព័ន្ធអ៊ិនធឺណិតដែលពួកគេចង់ចំណាយពេល ប្រើប្រាស់ និងប្រភេទនៃមនុស្សដែលពួកគេនឹងជួបនៅតាមប្រព័ន្ធអ៊ិនធឺណិត ព្រមទាំងសកម្មភាពដែលពួកគេចង់ធ្វើនៅទីកន្លែងនីមួយៗ។

យុវវ័យបានរាយការណ៍ថា ពួកគេបានចំណាយពេលយ៉ាងច្រើននៅតាមប្រព័ន្ធអ៊ិនធឺណិត និងបានរៀបរាប់អំពីឧបករណ៍ផ្តល់លទ្ធភាពប្រើប្រាស់អ៊ិនធឺណិតយ៉ាងច្រើនចម្រុះគ្នាលើសពីការរំពឹងទុក។ កុមារមកពីសហគមន៍ងាយរងគ្រោះ ក៏បានបង្ហាញនូវការយល់ដឹងលម្អិត ជាពិសេសអំពី ឧបករណ៍ផ្តល់លទ្ធភាពប្រើប្រាស់អ៊ិនធឺណិតដែលគ្មានសុវត្ថិភាពសម្រាប់វ៉ាយហ្វាយ (Wifi) ឥតបង់ថ្លៃនៅក្នុងសហគមន៍របស់ពួកគេ រួមទាំងនៅលើរ៉ឺម៉កម៉ូតូ សណ្ឋាគារ ហាងកាត់សក់ និងរថយន្តក្រុង។ ពេលវេលាដែលចំណាយលើអ៊ិនធឺណិតមានភាពខុសគ្នាច្រើន ក្នុងចំណោមកុមារដែលបានមកចូលរួមក្នុងសិក្ខាសាលារៀនសូត្រទាំងនេះ ដោយកុមារបាននិយាយថា ពួកគេចំណាយពេលពី១៥នាទី ក្នុងមួយថ្ងៃ រហូតស្ទើរតែគ្រប់ពេលក្រោយពេលដែលពួកគេភ្ញាក់ពីដំណេកសម្រាប់កុមារចំនួន៥នាក់។ យុវវ័យមកពីសាលារៀនរដ្ឋ និងសាលារៀនឯកជន បានបង្ហាញអំពីការប្រើប្រាស់អ៊ិនធឺណិត ជាមធ្យម ច្រើនម៉ោងបន្តិចជាងយុវវ័យមកពីសហគមន៍ក្រីក្រ (៥,៨ម៉ោង ធៀបនឹង៤,៨ ម៉ោងក្នុងមួយថ្ងៃ)។ ជារួម ក្នុងចំណោមកុមារ ១៤៨ នាក់ ដែលបានផ្តល់ចម្លើយ មានកុមារ៦០នាក់ ឬ ៤០% បង្ហាញថា ពួកគេចំណាយពេលពី ១ ទៅ ២ម៉ោង លើអ៊ិនធឺណិត មាន៣៨នាក់ ឬ២៥% ចំណាយពេលពី២ ទៅ ៤ ម៉ោង លើអ៊ិនធឺណិត មាន ២៨ នាក់ ឬ ១៩%

៥១.៩១

ចំណាយពេលពី ៤ ទៅ ៦ម៉ោង មាន ១២ នាក់ ឬ ៨% ចំណាយពេលពី ៦ ទៅ ៨ ម៉ោង និងមានកុមារ ១០ នាក់ ឬ ៧% ចំណាយពេលលើសពី ៨ ម៉ោង ក្នុងមួយថ្ងៃ លើអ៊ីនធឺណិត។

### ៣.១.១.១. សម្ភារពាក់ព័ន្ធនឹងការរំលោភបំពានផ្លូវភេទលើកុមារ

មានជាងមួយក្រុម គឺមានមួយក្នុងចំណោមបួនក្រុម ឬ ១៦ ក្រុម ក្នុងចំណោមក្រុមកុមារ និងគ្រូបង្រៀនសរុបចំនួន ៥៨ក្រុម (២៧%) រៀបរាប់អំពីការទាក់ទាញ ការចែកចាយឬការផលិតសម្ភារទាក់ទងនឹងការរំលោភបំពានផ្លូវភេទកុមារ (CSAM) ថាជាហានិភ័យសំខាន់ នៅក្នុងបរិយាកាសអ៊ីនធឺណិតរបស់ពួកគេ។ ស្របពេលដែលគ្មានគ្រូបង្រៀនណាម្នាក់បានដឹងថា CSAM ជាហានិភ័យសំខាន់ វាគឺជាវិស័យទូទៅមួយនៃការពិភាក្សា ក្នុងចំណោមកុមារនៅគ្រប់វិស័យ ដែលត្រូវយកមកពិភាក្សានៅក្នុងសិក្ខាសាលាទាំងនេះ។ ការពិភាក្សាជាចម្បងបានបង្ហាញថា CSAM ត្រូវបញ្ជូន ឬ ទទួលតាមរយៈ Facebook (៥០%) ឬ តាមរយៈ Messenger ដែលជាផ្នែកមួយនៃ Facebook (៤០%)។ ហានិភ័យតាមការយល់ឃើញនៃ CSAM ហាក់ដូចជាមានភាពចម្រុះគ្នា ហើយជាញឹកញាប់ ទាក់ទងនឹងទម្រង់ផ្សេងទៀតនៃ OCSE ផងដែរ ដូចជា ការគំរាមកំហែង និងការផ្សាយផ្ទាល់នូវខ្លឹមសារផ្លូវភេទ។ កុមារម្នាក់មកពីសាលារៀនរបស់អង្គការមិនមែនរដ្ឋាភិបាល នៅក្រុងតាខ្មៅ កត់សម្គាល់ថា "មិត្តភក្តិមួយចំនួនលើបណ្តាញ Facebook បានផ្ញើរូបថតអាក្រាត វីឌីអូអាសអាភាស នៅក្នុង Messenger។ ក្មេងស្រីមួយចំនួនដែលចង់មានប្រជាប្រិយភាពតាមប្រព័ន្ធអ៊ីនធឺណិត បានព្យាយាមផ្សាយវីឌីអូផ្ទាល់ ដើម្បីបង្ហាញខ្លួនប្រាណរបស់ខ្លួន"។ បន្ថែមលើនេះ មានការបង្ហាញមួយចំនួនអំពីការលួងលោមដែលអាចកើតមានចំពោះយុវវ័យឲ្យផលិត CSAM ដើម្បីផ្លោះប្តូរនឹងលុយកាក់។ កុមារម្នាក់មកពីសាលារៀនរដ្ឋក្នុងខេត្តសៀមរាប រៀបរាប់ថា"ជនខិលខូចប្រើប្រាស់ Facebook ដើម្បីលួងលោមមនុស្សវ័យក្មេង ដោយសន្យាផ្តល់លុយកាក់ សម្ភារ (របស់របរផ្សេងៗ) ហើយមនុស្សវ័យក្មេងៗអាចធ្វើអ្វីៗគ្រប់បែបយ៉ាងទៅតាមតែអ្វីដែលពពួកមនុស្សអាក្រក់បានប្រាប់ឲ្យគេធ្វើ"។

### ៣.១.១.២. ការផ្សាយផ្ទាល់អំពីខ្លឹមសារផ្លូវភេទ

មានមួយក្រុម ក្នុងចំណោមបួនក្រុម ឬ ១៤ ក្រុម (២៤.១%) យល់ឃើញថា ការផ្សាយផ្ទាល់អំពីខ្លឹមសារផ្លូវភេទ គឺជាហានិភ័យសំខាន់សម្រាប់កុមារ។ ភាគច្រើននៃការយល់ដឹងអំពីហានិភ័យទាក់ទងនឹងយុវវ័យ ដែលកំពុងប្រើប្រាស់កម្មវិធី Bigo Live (៥៧%) រួមទាំង Facebook និង Messenger។ ជាញឹកញាប់ យុវវ័យបានរៀបរាប់ថា ការផ្សាយផ្ទាល់ដែលបង្ហាញរូបភាពផ្លូវភេទ ខ្លឹមសារដែលបង្កភាពស្រើបស្រាលផ្លូវភេទ គឺត្រូវធ្វើឡើងទៅតាមការស្នើសុំរបស់អ្នកប្រើប្រាស់ផ្សេងទៀត។ ក្នុងករណីផ្សេងទៀត យុវវ័យត្រូវបានគេដកស្រង់ថា បានប្រើប្រាស់សកម្មភាពទាក់ទងនឹងផ្លូវភេទ ដើម្បីផ្សព្វផ្សាយលក់ផលិតផលតាមរយៈកម្មវិធីអ៊ីនធឺណិត។ កុមារីម្នាក់នៅខេត្តសៀមរាប បានរៀបរាប់ថា "កុមារី និងស្ត្រីជាច្រើននាក់ បានប្រើប្រាស់ Bigo Live ដើម្បីលក់ផលិតផលសំអាងរបស់ពួកគេ។ ពួកគេតែងតែផ្សាយផ្ទាល់ និងបង្ហាញខ្លួនប្រាណរបស់ខ្លួន ដើម្បីឲ្យយុវជនមានអារម្មណ៍ស្រើបស្រាល"។ យុវជនមួយចំនួនបង្ហាញថា ការធ្វើបែបនេះ គឺជាវិធីសាស្ត្រដើម្បីរកលុយកាក់ និងដើម្បីទទួលបានអ្នកគាំទ្រតាមបណ្តាញទំនាក់ទំនងសង្គមកាន់តែច្រើន ស្របពេលដែលករណីផ្សេងទៀតបង្ហាញថា កុមារកំពុងត្រូវបានគេលួងលោមឲ្យចូលរួមនៅក្នុងខ្លឹមសារបែបនេះ។ សិស្សសាលារៀនរដ្ឋម្នាក់មកពីខេត្តសៀមរាប បានរៀបរាប់ថា "ជនខិលខូចបានប្រើប្រាស់កម្មវិធីទាំងពីរ (Facebook និង Messenger) ដើម្បីលួងលោមមនុស្ស (វ័យក្មេង) និងសុំឲ្យពួកគេផ្ញើរូបថតអាក្រាតផ្សាយវីឌីអូផ្ទាល់។ ពេលខ្លះ ពួកគេ(នឹង)ធ្វើការណាត់ជួបហើយ ត្រូវបានគេចាប់រំលោភសេពសន្ថវៈ"។

### ៣.១.១.៣. ការលួងលោមដើម្បីរំលោភបំពារបំពាន និងកេងប្រវ័ញ្ចផ្លូវភេទកុមារ CSEA

មានជាងមួយភាគបួននៃក្រុម ឬ ១៦ ក្រុម (២៨%) រៀបរាប់ថា ការលួងលោម គឺជាហានិភ័យគួរឲ្យកត់សម្គាល់តាមអ៊ីនធឺណិត។ ភាគច្រើននៃយុវវ័យនិងគ្រូបង្រៀនដែលយល់ឃើញថា ការលួងលោម គឺជាហានិភ័យហាក់ដូចជាមកពីតំបន់ខេត្តព្រះសីហនុ។ ទោះបីជាយ៉ាងណា ការលួងលោម ជារឿយៗគឺជាផ្នែកមួយ (និងអាចមិនត្រូវបានរៀបរាប់យ៉ាងពេញលេញឡើយ) នៅក្នុងបទល្មើសទាក់ទងនឹង OCSE ផ្សេងទៀតជាច្រើនដែលត្រូវ បានរៀបរាប់នៅក្នុងវិស័យផ្សេងទៀតផងដែរ។ ឧទាហរណ៍ កុមារជាច្រើនបានរៀបរាប់អំពីហានិភ័យដែលមនុស្ស ពេញវ័យចែករំលែករូបភាពអាសអាភាសឲ្យពួកគេ ដែលក៏អាចមិនមែនជាទម្រង់មួយ នៃការលួងលោមឡើយ។ ការលួងលោមត្រូវបានរៀបរាប់ថា កើតឡើងតាមវិធី និងចំនួនបរិបទចម្រុះគ្នាមួយចំនួន។ ពួកគេបានរៀបរាប់ថា ការលួងលោមភាគច្រើនបំផុតកើតឡើងនៅតាម Messenger ប៉ុន្តែកម្មវិធីផ្សេងទៀតដូចជា Bigo Live, Instagram និង WeChat ក៏ត្រូវបានរៀបរាប់ផងដែរ។ សិស្សសាលារៀនរដ្ឋម្នាក់ មកពីខេត្តសៀមរាប បានរៀបរាប់ថា "ជន ខិលខូចបានប្រើប្រាស់ Facebook ដើម្បីលួងលោមមនុស្សវ័យក្មេង (ដោយសន្យាថា) ផ្តល់លុយកាក់ និងសម្ភារ (របស់របរផ្សេងៗទៀត) ក្នុងបំណងឲ្យមនុស្សវ័យក្មេងៗ ធ្វើតាមគ្រប់បែបយ៉ាង ដែលពួកគេបានប្រាប់ (ឲ្យធ្វើ)"។

### ៣.១.១.៤. ការចែកចាយរូបភាពអាសអាភាសទៅឲ្យកុមារ

ការចែកចាយសម្ភារអាសអាភាស ពីមនុស្សពេញវ័យទៅឲ្យកុមារ (និងមានក្នុងចំណោមកុមារគ្នាឯងផងដែរ) ហាក់ដូចជាក្លាយទៅជារឿងទូទៅៗហើយ ហើយមានក្រុមភាគច្រើន (៣៥ ក្រុម ឬ ៦០.៣%) បានរៀបរាប់ថា វាគឺជាហានិភ័យដែលត្រូវបានដឹងច្បាស់។ កុមារមួយចំនួនបាននិយាយអំពីការទទួលបានសម្ភារអាសអាភាសពីមនុស្សពេញវ័យ ដែលផ្តោតទិសដៅដាក់លាក់លើពួកគេ ដែលច្បាស់ណាស់ថា មានគោលបំណងលួងលោម ឬទទួលបានរូបភាពផ្លូវភេទពីកុមារត្រលប់វិញ។ ក្នុងករណីផ្សេងទៀត កុមារបានរៀបរាប់អំពីការបញ្ចូលទៅក្នុងក្រុម Facebook និង Messenger ដែលមានការបង្ហោះ និងការផ្ដោះប្ដូររូបភាពអាសអាភាសជាប្រចាំ។ កុមារម្នាក់បានអធិប្បាយថា "មានមនុស្សផ្ញើរូបថតអាក្រាតបីសន្លឹកមកឲ្យខ្ញុំ តាមរយៈ Messenger។ ខ្ញុំខឹងនឹងមនុស្ស (បែបនេះ) ណាស់។ ខ្ញុំគ្រាន់តែជាក្មេងស្រីតូចម្នាក់ប្រហែលជាពួកគេគិតថា ខ្ញុំជាស្ត្រីពេស្យាហើយ"។ ស្របពេលដែលកុមារមួយចំនួនបង្ហាញការបដិសេធ និងលុបចោលរូបភាពទាំងនោះនិងប្លុក (Block) អ្នកផ្ញើនោះចោល កុមារនោះបាននិយាយអំពីយុវវ័យផ្សេងទៀត ដែលបានចែកចាយរូបភាពបន្ថែមទៀត ឬ រួមចំណែកទាំងរូបភាពរបស់ពួកគេផ្ទាល់ផងដែរ។

បន្ថែមលើការទទួលបានរូបភាពអាសអាភាសដោយផ្ទាល់ កុមារក៏រៀបរាប់ជាទូទៅអំពីការមើលឃើញរូបភាពអាសអាភាស តាមរយៈការផ្សាយពាណិជ្ជកម្មរបស់ភាគីទីបីនៅក្នុងកម្មវិធីផ្សេងមានដូចជា Facebook, Youtube និងហ្គេមអ៊ិនធឺណិតផងដែរ។ មានកុមារម្នាក់បាននិយាយថា "នៅពេលខ្ញុំរំកិលទំព័រ ឆ្លងកាត់ទំព័រ Facebook ខ្ញុំបានឃើញវីឌីអូផ្សាយផ្ទាល់អំពី ក្មេងស្រីម្នាក់កំពុងដោះសម្លៀកបំពាក់ (របស់នាង) និងប្រកាសលក់ខ្លួនរបស់នាង"។ កុមារម្នាក់ទៀតបានរៀបរាប់ថា ជាញឹកញាប់គាត់ឃើញវីឌីអូ និងរូបភាពអាសអាភាសលេចឡើងនៅក្នុងកញ្ចក់ទូរស័ព្ទឬកុំព្យូទ័រពីអ្នកផ្សាយពាណិជ្ជកម្ម ជាភាគីទីបីនៅពេលដែលគាត់មើលភាពយន្តគំនូរជីវចល។

### ៣.១.១.៥. ការគំរាមកំហែង

ការគំរាមកំហែងជាទម្រង់ផ្សេងៗតាមរយៈ Facebook, Messenger និងកម្មវិធីផ្សេងទៀត ត្រូវបានរៀបរាប់ថា ជាហានិភ័យសំខាន់នៅក្នុងក្រុមដែលមានជាងមួយភាគបួន ឬ ១៥ ក្រុមនៃ ៥៨ ក្រុមកុមារ និងគ្រូបង្រៀន

(២៦%)។ ឧទាហរណ៍អំពីការគំរាមកំហែង គឺមានលក្ខណៈចម្រុះគ្នា និងហាក់ដូចជាត្រូវបានប្រព្រឹត្តដោយតួអង្គជាច្រើនផ្សេងៗគ្នា និងមានគោលបំណងជាច្រើនខុសៗគ្នា។ ក្នុងករណីខ្លះ ជនខិលខូចលួងលោមជនរងគ្រោះឲ្យចែករំលែករូបភាពផ្លូវភេទអំពីខ្លួនប្រាណរបស់ពួកខ្លួន ហើយបន្ទាប់មកប្រើប្រាស់រូបភាពទាំងនោះសម្រាប់សម្លុតដើម្បីគំរាមកំហែងយកលុយកាក់ពីជនរងគ្រោះនិងមានកុមារផ្សេងទៀតបានរៀបរាប់អំពី អ្នកប្រើប្រាស់ដែលលួចជ្រៀតចូលដោយគ្មានការអនុញ្ញាត (Hack) ទៅក្នុងគណនីបណ្ដាញទំនាក់ទំនងសង្គមរបស់ពួកខ្លួនដើម្បីធ្វើជាសមាជិកគ្រួសាររបស់ជនរងគ្រោះនិងសុំលុយកាក់។ ក្នុងករណីខ្លះ ជនល្មើសបានប្រើប្រាស់រូបភាពជាសាធារណៈ ឬមិនមែនអាសអាភាសរបស់កុមារ និងកែរូបទាំងនោះដើម្បីឲ្យបង្ហាញថា កុមារកំពុងធ្វើអ្វីមួយដែលមានលក្ខណៈផ្លូវភេទ។ បន្ទាប់មក រូបភាពទាំងនោះត្រូវបានប្រើប្រាស់ជាមទម្រង់មួយនៃការសម្លុតដើម្បីគំរាមកំហែងយកលុយកាក់ពីកុមារ ឬ ឲ្យកុមារសម្តែងឈុតផ្សេងទៀត ទៅតាមការប្រាប់របស់ជនខិលខូច។ សិស្សសាលារៀនរដ្ឋម្នាក់ មកពីខេត្តសៀមរាបបានកត់សម្គាល់ថា "មនុស្សខ្លះប្រើប្រាស់គណនី Facebook របស់ពួកគេដើម្បីស្វែងរកមិត្តភក្តិតាមប្រព័ន្ធអ៊ិនធឺណិត និងលួងលោមពួកគេឲ្យធ្វើ (ការហៅទូរស័ព្ទជាវីឌីអូបែបផ្លូវភេទ) ហើយបន្ទាប់មកថតរូបពីលើកញ្ចក់ទូរស័ព្ទ។ ក្រោយមក ពួកគេផ្ញើសារគំរាមកំហែងជនរងគ្រោះឲ្យបង់លុយ"។

## ៣.១.២. ការប៉ាន់ប្រមាណកម្មវិធី ដែលមានហានិភ័យខ្ពស់

### ៣.១.២.១. កម្មវិធីបណ្ដាញទំនាក់ទំនងសង្គម

Facebook ត្រូវបានក្រុមកុមារ និងគ្រូបង្រៀនចំនួន ៤៧ ក្រុម ក្នុងចំណោមក្រុមសរុបចំនួន ៥៨ ក្រុម (៨១.0%) លើកឡើងថា ជាកម្មវិធីមានហានិភ័យខ្ពស់។ ហានិភ័យទូទៅមួយចំនួន រួមមានការមើលឃើញ និងការទទួលបានរូបភាពអាសអាភាសរបស់មនុស្សពេញវ័យ ដែលមិនបានស្នើសុំ (៤៧%) ការទទួលបានរូបភាពផ្លូវភេទរបស់កុមារ ឬកុមារត្រូវបានស្នើសុំឲ្យផ្ញើរូបភាពផ្លូវភេទ(២១%) ព្រមទាំងទម្រង់ផ្សេងទៀតនៃការគំរាមកំហែង ឬគំរាម(២១%) ជាញឹកញាប់តាមរយៈការប្រើប្រាស់រូបភាពផ្លូវភេទដ៏គួរឲ្យខ្មាស់អៀន ឬដែលមានរូបរាងដូចកុមារបន្ថែមលើហានិភ័យផ្សេងទៀត។

**រូបភាព ឬ វីឌីអូអាសអាភាស**: ការបង្ហោះ ឬការចែករំលែករូបភាពអាសអាភាស គឺជាហានិភ័យដែលត្រូវបានលើកឡើងជាទូទៅនៅតាម Facebook ដោយក្រុមចំនួន២២ ក្រុមនៃក្រុមសរុបចំនួន ៤៧ក្រុម បានរៀបរាប់ថាជាហានិភ័យ។ កុមារម្នាក់បានលើកឡើងថា "ខ្ញុំបានឃើញរូបភាពអាសអាភាសជាច្រើន ត្រូវបានបង្ហោះតាម Facebook ។ ខ្ញុំគិតថា មនុស្សពេញវ័យបានផ្ញើរូបភាពទាំងអស់នេះ ហើយពួកគេបានផ្ញើរូបនោះទៅឲ្យមនុស្ស (ផ្សេងទៀត) ជាច្រើនផងដែរ"។ នៅក្នុងករណីឯទៀតខ្លះ មានមនុស្សពេញវ័យបានរៀបរាប់ថា គេមានរូបភាពអាសអាភាសពិសេស ដែលគេសំដៅដល់រូបអាសអាភាស របស់កុមារ។

CSAM: ការផលិត និងការចែកចាយសម្ភារពាក់ព័ន្ធនឹងការរំលោភបំពានផ្លូវភេទលើកុមារ ក៏ជាហានិភ័យទូទៅ ដែលត្រូវបានក្រុមចំនួនលើសពីមួយ ក្នុងចំណោមប្រាំក្រុម (១០ក្រុមនៃក្រុមសរុបចំនួន ៤៧ ក្រុម) បានពិភាក្សាដែលបានកំណត់ថា Facebook គឺជាកម្មវិធីមានហានិភ័យ។ ហានិភ័យនេះរួមមាន ការចែករំលែករូបភាពផ្លូវភេទកុមារ មនុស្សពេញវ័យ និងកុមារ ស្នើសុំឲ្យកុមារផ្សេងទៀតផ្ញើរូបភាព និងខ្លឹមសារផ្លូវភេទ ព្រមទាំង "ការផ្សាយផ្ទាល់" នូវការសម្តែងទាក់ទងនឹងផ្លូវភេទ។ មានកុមារាម្នាក់មកពីខេត្តសៀមរាប បានលើកឡើងថា "(Facebook ត្រូវបាន) ប្រើប្រាស់ដោយជនខិលខូច ដើម្បីលួងលោមមនុស្សមួយចំនួន (យុវវ័យ) និងស្នើសុំឲ្យពួកគេផ្ញើរូបភាពអាក្រាតឲ្យ ផ្សាយផ្ទាល់នូវវីឌីអូ(ផ្លូវភេទ)។ ពេលខ្លះ(អ្នកប្រើប្រាស់) បានរៀបចំការណាត់ជួប និងចាប់រំលោភសេព

សន្ទរៈ (អ្នកផ្សេងទៀត)”។ បន្ថែមលើនេះ មានទម្រង់ផ្សេងៗនៃការគំរាមកំហែងដោយប្រើប្រាស់រូបភាពផ្លូវភេទរបស់កុមារ ត្រូវបានបង្ហាញឡើង ដែលនឹងត្រូវពិភាក្សាបន្ថែមទៀតនៅខាងក្រោម។

**ការគំរាមកំហែង**: ១០ ក្រុម ក្នុងចំណោមក្រុមសរុបចំនួន ៤៧ ក្រុម ក៏បានទទួលស្គាល់ផងដែរថា ទម្រង់ផ្សេងៗនៃការគំរាមកំហែង ជាហានិភ័យទូទៅនៅក្នុង Facebook ផងដែរ ដែលបានកំណត់ថា Facebook គឺជាកម្មវិធីមានហានិភ័យ។ ខ្លឹមសារនេះមានលក្ខណៈចម្រុះគ្នា ប៉ុន្តែជាទូទៅ ទាក់ទងនឹង “អ្នកលួចជ្រៀតចូល” ឬបុគ្គលដែលអាចចូលទៅក្នុងគណនី Facebook របស់កុមារ ដើម្បីគំរាមកំហែងយកលុយពីមិត្តភក្តិ និងគ្រួសាររបស់កុមារ។ កុមារម្នាក់រៀបរាប់អំពី អ្នកលួចជ្រៀតចូល ដែលអាចធ្វើឲ្យសាច់ញាតិរបស់កុមារជឿជាក់ថា ម្ដាយរបស់កុមារធ្លាក់ខ្លួនឈឺ និងបោកប្រាស់ពួកគេឲ្យផ្ញើលុយឲ្យ។ ក្នុងករណីជាច្រើន ការគំរាមកំហែងនេះ មិនពាក់ព័ន្ធនឹងការលួចជ្រៀតចូលក្នុងគណនីរបស់កុមារឡើយ ប៉ុន្តែ ដោយប្រើប្រាស់កម្មវិធីកែរូបភាពរបស់កុមារ ដើម្បីផ្លាស់ប្ដូររូបភាពមានលក្ខណៈសាធារណៈរបស់កុមារឲ្យមើលទៅដូចជាកុមារអាក្រាតកាយ ឬកំពុងសម្ដែងសកម្មភាពផ្លូវភេទ។ ក្នុងករណីផ្សេងទៀត ពួកគេទទួលបានរូបភាពអាក្រាត ឬផ្លូវភេទពិតប្រាកដរបស់កុមារ ហើយបន្ទាប់មកប្រើប្រាស់វា ដើម្បីគំរាមកំហែងកុមារឲ្យផ្ដល់សេវាកម្មនានា ផ្ដល់រូបភាពច្រើនថែមទៀត ឬលុយកាក់ ទៅឲ្យបុគ្គលដែលធ្វើការគំរាមកំហែង។

Instagram ត្រូវបានក្រុមកុមារ និងគ្រូបង្រៀនចំនួន១០ក្រុម ក្នុងចំណោមក្រុមសរុបចំនួន៥៨ក្រុម (១៧.២៤%) លើកឡើងថា ជាកម្មវិធីមានហានិភ័យ ភាគច្រើនដោយសារជាទូទៅ ខ្លឹមសារផ្លូវភេទ ឬអាសអាភាស ត្រូវបានចែករំលែកតាមរយៈកម្មវិធីនេះ។ ក្រុមមួយចំនួនបានរៀបរាប់ អំពីខ្លឹមសារផ្លូវភេទ ពីកម្មវិធីផ្សាយផ្ទាល់ផ្សេងទៀត (មានរៀបរាប់ខាងក្រោម) ដែលត្រូវបានបង្ហោះបញ្ចូលក្នុង Instagram ឬ កម្មវិធីបណ្ដាញទំនាក់ទំនងសង្គមស្រដៀងគ្នានេះផ្សេងទៀត ដែលអ្នកផលិតខ្លឹមសារ ឬរូបភាពផ្លូវភេទ អាចចែករំលែកទៅឲ្យអ្នកមើលកាន់តែច្រើន ដោយពួកគេមិនបានដឹង។ ក្រុមមួយទៀត លើកឡើងថា Instagram មានហានិភ័យច្រើនដូចគ្នានឹង Facebook ដែរ ដោយសារកម្មវិធីនេះផ្ដល់ទីកន្លែងសម្រាប់ឲ្យអ្នកប្រើប្រាស់បង្ហាញព័ត៌មានផ្ទាល់ខ្លួនជាមួយសារកម្មវិធីផ្ញើសារសម្រាប់ឲ្យអ្នកប្រើប្រាស់ធ្វើការសន្ទនាគ្នាជាលក្ខណៈឯកជនជាមួយអ្នកប្រើប្រាស់ផ្សេងទៀត។

## ៣.១.២.២. កម្មវិធីប្រាស្រ័យទាក់ទងគ្នា

Messenger ត្រូវបានក្រុមចំនួន៤២ក្រុម ក្នុងចំណោមក្រុមកុមារ និងគ្រូបង្រៀនសរុបចំនួន៥៨ក្រុម (៧២.៤%) លើកឡើងថា ជាកម្មវិធីមានហានិភ័យខ្ពស់។ កុមាររៀបរាប់ប្រកបដោយសង្កតភាពអំពី ក្ដីបារម្ភផ្នែកសុវត្ថិភាពសំខាន់មួយនៅតាម Messenger ដែលជនចម្លែកពួកគេបានបន្ថែមជាមិត្តនៅក្នុង Facebookអាចបញ្ជូនឲ្យពួកគេនូវរូបសញ្ញា “ការបក់ដៃ” (Wave) នៅពេលដែលអ្នកប្រើប្រាស់ ដែលមិនត្រូវបានភ្ជាប់ទំនាក់ទំនងតាម Facebook ជាទូទៅ មិនអាចផ្ញើរូបភាព ឬវីឌីអូដែលមិនត្រូវបានស្នើសុំទៅកាន់អ្នកផ្សេងទៀតបាន។ ប្រសិនបើកុមារឆ្លើយតបចំពោះសញ្ញាបក់ដៃ សមត្ថភាពក្នុងការផ្ញើរូបថត វីឌីអូ ឬចាប់ផ្ដើមការហៅទូរស័ព្ទដោយសម្លេង ឬវីឌីអូត្រូវបានបើកដោយស្វ័យប្រវត្តិ ដែលអនុញ្ញាតឲ្យជនចម្លែកអាចផ្ញើខ្លឹមសារទាក់ទងនឹងផ្លូវភេទ ភ្ជាប់ទំនាក់ទំនងជាមួយកុមារតាមរយៈ វ៉េបខៃម ឬផ្ញើតំណភ្ជាប់ទៅកាន់ខ្លឹមសារទាក់ទងនឹងផ្លូវភេទ ឬខ្លឹមសារដែលមានលក្ខណៈព្យាបាទ បាន។ លើសនេះទៀត គឺជនណាដែលបានភ្ជាប់ទំនាក់ទំនងជាមួយកុមាររួចហើយ នៅតាម Facebook ក៏អាចបញ្ចូលកុមារទៅក្នុងក្រុម Messenger ដែលមានស្រាប់ បានដែរ ដោយពុំចាំបាច់មានការយល់ព្រមពីកុមារឡើយ។ អ្នកប្រើប្រាស់ Facebook ទាំងឡាយ នៅក្នុងបណ្ដាញមិត្តភក្តិរបស់កុមារ អាចបញ្ចូលកុមារទៅក្នុងក្រុម Messenger

បាន ដែលមានការផ្ដោះប្ដូរសម្ភារ ទាក់ទងនឹងផ្លូវភេទ នៅក្នុងក្រុមនោះ ដោយអនុញ្ញាតឲ្យជន ដែលអាចជាជនខិលខូច (ដែលក៏អាចនៅក្នុងក្រុមដែរ) មានទំនាក់ទំនងដោយផ្ទាល់ជាមួយកុមារតាមអ៊ិនធឺណិត។

ហានិភ័យទូទៅបំផុតមួយចំនួន រួមមាន ការមើលឃើញ ឬការទទួលរូបភាព ឬវីឌីអូអាសអាភាសរបស់មនុស្សពេញវ័យដោយមិនមានការស្នើសុំ (៤៥%) និងការលួងលោមកុមារក្នុងគោលបំណងរំលោភបំពានផ្លូវភេទ ដែលមានដូចជា ការផ្ញើរូបភាពផ្លូវភេទអំពីខ្លួនប្រាណរបស់ពួកគេ (២៦%)។ ទាក់ទងនឹងការលួងលោម មានករណីផ្សេងៗដែលកុមារត្រូវបានលើកទឹកចិត្ត ឬស្នើសុំឲ្យចែករំលែករូបភាពផ្លូវភេទអំពីខ្លួនពួកគេ (CSAM) ដែលត្រូវបានក្រុមចំនួនប្រាំបីក្រុម ឬ ១៩% រៀបរាប់ថា Messenger ជាកម្មវិធីមានហានិភ័យ។ មានការលើកឡើងថា Messenger ត្រូវបានប្រើប្រាស់ជាឧបករណ៍សម្រាប់គំរាមកំហែង ឬគ្រោងការទុច្ចរិត នៅក្នុងករណីចំនួនប្រាំមួយ ឬ ១៤%។ ការបង្ហាញអំពីភាពខុសគ្នា រវាងប្រភេទហានិភ័យនានានៅទីនេះ គឺជាការលំបាក ដោយសារប្រភេទនៃហានិភ័យទាំងនេះមានភាពជាន់គ្នា ឬមានអន្តរទំនាក់ទំនងគ្នាទៅវិញទៅមក។ ឧទាហរណ៍ ស្របពេលដែលក្រុមចំនួន ១៩ក្រុម លើកឡើងអំពីហានិភ័យនៃការទទួលសម្ភារអាសអាភាសដែលមិនបានស្នើសុំ ករណីជាច្រើននៃការលួងលោម ដែលកុមារបានរៀបរាប់នៅតាម Messenger ក៏ពាក់ព័ន្ធនឹងការផ្ដោះប្ដូរខ្លឹមសារផ្លូវភេទ ដែលមិនចង់បានផងដែរ ដែលអាចមិនចាំបាច់ត្រូវចាត់ទុកថាជាអំពើអាសអាភាសឡើយ។ បន្ថែមលើនេះ មានករណីមួយចំនួននៃ CSAM ក៏ពាក់ព័ន្ធនឹងជនខិលខូច ដែលដំបូងឡើយផ្ញើរូបភាពមានលក្ខណៈស្រើបស្រាលពីខ្លួនឯង ដើម្បីអូសទាញរូបភាពផ្លូវភេទពីកុមារត្រលប់វិញ ដែលអាចជាទម្រង់មួយនៃការលួងលោម ឬអំពើអាសអាភាស។ ក្នុងន័យនេះ វាគួរត្រូវបានចាត់ទុកថា មានខ្លឹមសារជាន់គ្នាមួយចំនួននៅក្នុងប្រភេទនានា ដែលត្រូវបានកំណត់ខាងក្រោម។

**រូបភាព ឬ វីឌីអូអាសអាភាស**: មានក្រុមចំនួន ១៩ ក្នុងចំណោមក្រុមដែលបានបង្ហាញថា Messenger "មានហានិភ័យ" (៤៥%) បង្ហាញនូវករណីផ្សេងៗ ដែលកុមារ ឬមិត្តភក្តិរបស់កុមារ បានទទួលរូបភាព ឬ វីឌីអូអាសអាភាសភាគច្រើន មកពីជនចម្លែក នៅតាមប្រព័ន្ធអ៊ិនធឺណិត។ កុមារលើកឡើងថា ជនចម្លែកមួយចំនួននឹងបញ្ចូល (Add) ពួកគេ ទៅជាមិត្តភក្តិតាម Facebook ស្របពេលដែលអ្នកផ្សេងទៀត នឹងបញ្ចូលកុមារទៅក្នុងក្រុម Messenger ដែលមានស្រាប់ (ជាមួយនឹងអ្នកប្រើប្រាស់ជាច្រើននាក់ផ្សេងទៀត) ដែលអ្នកប្រើប្រាស់ទាំងឡាយនោះនឹងផ្ញើ ហើយនិងចែករំលែកខ្លឹមសារផ្លូវភេទនៅក្នុងក្រុម Messenger ជាលក្ខណៈឯកជន និងដែលត្រូវបានដាក់ព័ត៌មានបញ្ចូលជាលេខកូដសម្ងាត់។ កុមារម្នាក់បានរៀបរាប់អំពីបញ្ហាសារក្លែងក្លាយ ដែលមានអ្នកប្រើប្រាស់ម្នាក់មានរូបភាពស្ត្រីវ័យក្មេងម្នាក់នៅក្នុងរូបភាព ប្រូហ្វាល និងផ្ញើរូបភាពផ្លូវភេទ បន្ទាប់មកជជែកនិងសុំឲ្យហៅទូរស័ព្ទជាវីឌីអូផ្ទាល់ ហើយអ្នកប្រើប្រាស់នោះនឹងឃើញបុរសម្នាក់ នៅចុងម្ខាងទៀតនៃការហៅទូរស័ព្ទនេះ។ ជាពិសេសកុមារមួយចំនួនបានរៀបរាប់ថា បញ្ហានេះកើតឡើងជាមួយជនខិលខូច "ជាជនជាតិឥណ្ឌា" ដែលមិនអាចចង្អុលបង្ហាញជាក់លាក់អំពីនរណាម្នាក់មកពីប្រទេសឥណ្ឌាឡើយ ប៉ុន្តែអាចសំដៅដល់មនុស្សជាច្រើន ដែលមានដើមកំណើតមកពីតំបន់មជ្ឈិមបូព៌ា ឬអាស៊ីខាងត្បូង។

**ការលួងលោម**: មានដប់មួយក្រុម (២៦.១៩%) បានរៀបរាប់អំពីសេណារីយ៉ូនានា នៅលើ Messenger ដែលជនចម្លែកអាចប៉ុនប៉ងបង្កើតទំនាក់ទំនងជាមួយកុមារ ដើម្បីផ្ដោះប្ដូររូបភាពផ្លូវភេទគ្នាឬធ្វើសកម្មភាពខុសច្បាប់ផ្សេងទៀត។ កុមារមួយចំនួនបានរៀបរាប់ថា មនុស្សពេញវ័យដែលពួកគេមិនធ្លាប់ស្គាល់បានបញ្ចូលពួកគេនៅក្នុង Messenger និងមានបំណងធ្វើជាមិត្តភក្តិរបស់ពួកគេ។ ក្នុងករណីខ្លះ មនុស្សពេញវ័យមានព័ត៌មានប្រូហ្វាល រួមទាំងរូបថត ដែលធ្វើឲ្យពួកគេមើលទៅនៅក្មេង ឬ ធ្វើដូចជាខ្លួនឯងជាកុមារដែរ។ មានករណីជាច្រើនដែលមនុស្សពេញវ័យព្យាយាមចាប់ផ្ដើមកិច្ចសន្ទនា ជាមួយកុមារដែលជាញឹកញាប់មានផ្ញើរូបភាពអាសអាភាស ឬផ្លូវភេទរបស់

កុមារផ្សេងទៀត ក្នុងគោលបំណងឲ្យកុមារចូលរួមតាមរយៈការផ្ញើរូបភាពផ្លូវភេទរបស់ពួកគេផ្ទាល់ត្រលប់វិញ។ មានករណីភាគច្រើន ដែលយើងមិនច្បាស់ត្រង់ថា តើជនខិលខូចគឺជាជនបរទេស ឬជាជនជាតិកម្ពុជា ប៉ុន្តែនៅមានករណីចំនួនបី ដែលការទំនាក់ទំនងគ្នាតាមវីឌីអូ ត្រូវបានធ្វើឡើងរវាងកុមារ និងជនខិលខូច។ កុមារបានរំលឹកថា គេបានឃើញជនបរទេសពេញវ័យនៅចុងម្ខាងទៀតនៃការទំនាក់ទំនងគ្នានោះ។ កុមារម្នាក់បានរៀបរាប់ថា "មានជនបរទេសម្នាក់ បានផ្ញើរូបថតអាក្រាតមក បន្ទាប់ពីការហៅទូរស័ព្ទជាវីឌីអូមកខ្ញុំ។ ប៉ុន្តែ ខ្ញុំបានប្លុកគណនីរបស់គាត់ចោល។ បន្ទាប់ពីនោះ គាត់បានបញ្ជូនសំណើស្នើសុំធ្វើជាមិត្តមកឲ្យខ្ញុំម្តងទៀត ប៉ុន្តែខ្ញុំមិនទទួលគាត់ឡើយ" ហើយបន្ថែមលើនេះទៀត កុមារបានលើកឡើងថា គណនីដដែលនោះបានប៉ុនប៉ងធ្វើការទំនាក់ទំនងស្រដៀងគ្នាជាមួយមិត្តភក្តិរបស់ខ្លួនគឺរបស់កុមារនោះ។

CSAM: មានប្រាំបីក្រុម (១៩%)បានរៀបរាប់ថា Messenger គឺជាកម្មវិធីដែលសម្ភារទាក់ទងនឹងការរំលោភបំពានផ្លូវភេទកុមារត្រូវបានគេផលិតនិងចែកចាយ។ មានករណីមួយចំនួន ជនខិលខូចហាក់ដូចជាទាញយករូបភាពផ្លូវភេទរបស់កុមារ ដើម្បីគំរាមកំហែងយកលុយកាក់ពីកុមារ តាមរយៈ ការគំរាមបង្ហោះរូបភាពទាំងនោះជាសាធារណៈ (ការគំរាមកំហែងទាក់ទងនឹងផ្លូវភេទ)។ សិស្សសាលារៀនរដ្ឋម្នាក់ នៅក្នុងខេត្តសៀមរាបបានរៀបរាប់ថា "មនុស្សខ្លះប្រើប្រាស់គណនី Facebook របស់គាត់ ដើម្បីស្វែងរកមិត្តភក្តិតាមអ៊ិនធឺណិត និងលួងលោមពួកគេឲ្យធ្វើ (ការហៅទូរស័ព្ទជាវីឌីអូទាក់ទងនឹងផ្លូវភេទ) ហើយបន្ទាប់មកគេបានថតរូបចេញពីលើកញ្ចក់ទូរស័ព្ទ។ ក្រោយមកទៀតពួកគេផ្ញើសារដើម្បីគំរាមកំហែងឲ្យជនរងគ្រោះបង់លុយ"។ ក្នុងករណីខ្លះ មានរូបភាពនានាត្រូវបានទាញយកដើម្បីបំពេញចំណាប់អារម្មណ៍ផ្លូវភេទ ប៉ុន្តែមិនមានព័ត៌មានលម្អិតច្បាស់ពីសេចក្តីអធិប្បាយរបស់កុមារ ដែលត្រូវផ្តល់នៅក្នុងសកម្មភាពនេះឡើយ។ យើងនឹងមានការពន្យល់លម្អិតបង្ហាញនៅក្នុងផ្នែកខាងក្រោម។

ការគំរាមទាក់ទងនឹងផ្លូវភេទ និងគ្រោងការទុច្ចរិត៖ មានមួយក្រុមក្នុងចំណោមប្រាំមួយក្រុម(១៦.៦៦%) បានរៀបរាប់ថា Messenger គឺជាកម្មវិធីមានហានិភ័យ ដោយសារគ្រោងការទុច្ចរិត និងការគំរាមកំហែងប្រភេទផ្សេងៗរាប់បញ្ចូលទាំងការប្រើប្រាស់រូបភាពផ្លូវភេទរបស់កុមារ ដើម្បីគំរាមយកលុយ ឬសកម្មភាពខុសច្បាប់ផ្សេងទៀតពីអ្នកប្រើប្រាស់ផងដែរ។ ជាពិសេសមានកុមារមួយចំនួនបានរៀបរាប់ថា មានមនុស្សកែរូបភាពសាធារណៈរបស់ពួកគេពី Facebook ដើម្បីឲ្យមើលទៅឃើញថា កុមារអាក្រាត ឬកំពុងប្រព្រឹត្តសកម្មភាពផ្លូវភេទ។ បន្ទាប់មកជនខិលខូចនឹងទាមទារឲ្យកុមារផ្តល់លុយ ឬធ្វើសកម្មភាពផ្សេងទៀត ដើម្បីជាការផ្តោះប្តូរនឹងការមិនបញ្ចេញរូបភាពទាំងនេះ។ ទាក់ទងនឹងគ្រោងការទុច្ចរិតបែបនេះ មានជនខិលខូចមួយចំនួនសន្យាផ្ញើកញ្ចប់មួយឬលុយឲ្យ ប៉ុន្តែអ្នកប្រើប្រាស់ត្រូវចំណាយលើសោហ៊ុយ ដើម្បីទទួលលុយ ឬកញ្ចប់នោះ ហើយក៏មានករណីផ្សេងៗទៀតដែរ។

ឡាញ (Line) ត្រូវបានក្រុមកុមារ និងគ្រូបង្រៀនចំនួន ១៤ក្រុម ក្នុងចំណោមក្រុមសរុបចំនួន ៥៨ក្រុម (២៤.១៣%) លើកឡើងថា ជាកម្មវិធីប្រកបដោយហានិភ័យ។ កុមារនៅក្នុងសិក្ខាសាលារៀនសូត្រនេះ បានផ្តល់ព័ត៌មានជាក់លាក់តិចតួចអំពីអ្វីដែលធ្វើឲ្យ Line គឺជាកម្មវិធីមានហានិភ័យ ប៉ុន្តែចំពោះក្រុមវាហាក់ដូចជាថា Line មានហានិភ័យដូចគ្នាច្រើនទៅនឹងកម្មវិធីប្រាស្រ័យទាក់ទងគ្នាផ្សេងទៀតដែរ។ កុមារបានបង្ហាញថា Line គឺជាផ្លូវមួយដែលពួកគេអាចទទួលបានរូបភាពផ្លូវភេទ និងការទំនាក់ទំនងមានលក្ខណៈបែបឯកជនជាមួយជនចម្លែក ដែលពួកគេបានជួបនៅក្នុងកម្មវិធីតាមប្រព័ន្ធអ៊ិនធឺណិតផ្សេងទៀត ដូចជា Facebook, Rules of Survival និង TikTok។

Skype ត្រូវបានក្រុមកុមារ និងគ្រូបង្រៀនចំនួនប្រាំមួយក្រុម (១០.៣%) លើកឡើងថា ជាកម្មវិធីមានហានិភ័យ។ ស្រដៀងគ្នានឹង Line ដែរ គឺមានការផ្តល់ព័ត៌មានជាក់លាក់តិចតួចទាក់ទងនឹងអ្វីដែលធ្វើឲ្យ Skype មានហានិភ័យ ប៉ុន្តែការពិភាក្សាកាន់តែច្រើនជុំវិញកម្មវិធីនេះ និងកម្មវិធីដូចគ្នានេះ បានបង្ហាញថា Skype មានហានិ

ភ័យដូចគ្នាច្រើន រាប់បញ្ចូលទាំងថាវាជាផ្លូវមួយដែលពួកគេអាចទទួលបានរូបភាពផ្លូវភេទ និងការទំនាក់ទំនងមានលក្ខណៈជាឯកជនជាមួយជនចម្លែក ដែលពួក គេបានជួបនៅក្នុងកម្មវិធីតាមប្រព័ន្ធអ៊ិនធឺណិតផ្សេងទៀត។

### ៣.១.២.៣. កម្មវិធីហ្គេម

ជាទូទៅ កម្មវិធីហ្គេមជាច្រើន ត្រូវបានកំណត់ថា ជាបរិយាកាសអ៊ិនធឺណិត ដែលមានហានិភ័យខ្ពស់។ ថ្វីបើបែបនេះក៏ដោយ ក៏មានការបង្ហាញថា មានហានិភ័យតែមួយចំនួនតូចប៉ុណ្ណោះ ដែលទាក់ទងផ្ទាល់ទៅនឹង OCSE នៅលើកម្មវិធីទាំងនេះ ហើយទោះជាយ៉ាងណា ការសន្ទនាគ្នាទូលំទូលាយអំពីហានិភ័យតាមអ៊ិនធឺណិត បានបង្ហាញថា កម្មវិធីលេងហ្គេមតាមប្រព័ន្ធអ៊ិនធឺណិត គឺជាសហគមន៍សំខាន់ ដែលក្នុងនោះមានជនខិលខូចអាចជា OCSE ហើយធ្វើទំនាក់ទំនងដំបូងជាមួយកុមារ។ បន្ទាប់មក ជនខិលខូចអាចរកកុមារនៅតាម Facebook ឬកម្មវិធីផ្សេងទៀត តាមរយៈការស្នើសុំព័ត៌មានរបស់កុមារនៅក្នុងហ្គេម ឬតាមរយៈការប្រើប្រាស់ឈ្មោះលើស្រ្គីន(កញ្ចក់) ជាសាធារណៈរបស់កុមារនៅក្នុងហ្គេម ដើម្បីស្វែងរកកុមារនៅក្នុងកម្មវិធីតាមប្រព័ន្ធអ៊ិនធឺណិតមួយផ្សេងទៀត ដែលទំនាក់ទំនងគ្នាអាចធ្វើឡើងបាន។ ហានិភ័យគួរឲ្យកត់សម្គាល់មួយចំនួនទាក់ទងនឹងការលេងហ្គេម ដែលកុមារបានពិភាក្សា នឹងត្រូវយកទៅបង្ហាញនៅខាងក្រោម។

Rules of Survival គឺជាហ្គេមមានលក្ខណៈសមរភូមិតាមប្រព័ន្ធអ៊ិនធឺណិត លេងដោយអ្នកលេងច្រើន និងមិនបង់ថ្លៃ ដែលអនុញ្ញាតឲ្យអ្នកប្រើប្រាស់ចំនួន១៥០លាននាក់ ដែលបានចុះឈ្មោះពីទូទាំងពិភពលោក ប្រកួតប្រជែងគ្នា។ មានក្រុមចំនួន ២៩ ក្រុម (៥០%) បានរៀបរាប់ថា ហ្គេមនេះ គឺជាហ្គេមដែលមានហានិភ័យខ្ពស់។ មានបីក្រុម (ក្នុងនោះមានពីរក្រុមជាកុមារ និងមួយក្រុមជាគ្រូបង្រៀន) បានរៀបរាប់អំពី ក្ដីបារម្ភជាឯកជនភាពជាច្រើន ដោយលើកឡើងថា ជនខិលខូចអាចជួបកុមារតាមរយៈហ្គេមនេះ ឬទទួលបានព័ត៌មានអំពី Facebook របស់កុមារ ដែលផ្ដល់ឱកាសឲ្យពួកគេទំនាក់ទំនងជាមួយកុមារនៅតាមកម្មវិធីផ្សេងទៀត។ មានកុមារម្នាក់បានលើកឡើងថា "Rule of Survivor គឺជាកម្មវិធីតាមប្រព័ន្ធអ៊ិនធឺណិត ដែលអនុញ្ញាតឲ្យយើងលេងជាមួយក្រុមអ្នកលេងផ្សេងទៀត។ យើងអាចនិយាយ (ទៅកាន់ពួកគេ) តាមប្រព័ន្ធអ៊ិនធឺណិត ហើយជួនកាលសមាជិកក្រុមស្នើសុំលេខទូរស័ព្ទ ឬគណនី Facebook របស់យើង"។ ក្រៅពីនេះ ភាគច្រើននៃហានិភ័យដែលកុមារយល់ឃើញនៅក្នុងហ្គេមនេះ គឺទាក់ទងនឹងជម្លោះមានលក្ខណៈជាអន្តរបុគ្គលរវាងអ្នកលេង ដែលត្រូវបានលើកឡើងដោយក្រុមកុមារចំនួន១១ ក្រុម (៣៨%)។ លើសពីនេះទៀត កុមារ ជាពិសេសកុមារដែលមកពីសហគមន៍ងាយរងគ្រោះ បានលើកឡើងថា នេះគឺជាកម្មវិធីមានហានិភ័យ ដោយសារមានលក្ខណៈជាច្រើនរបស់ហ្គេមនេះ ទាមទារឲ្យអ្នកប្រើប្រាស់បង់លុយ (ពិភាក្សាដោយក្រុមចំនួនប្រាំមួយក្រុម ឬ ២១% នៃក្រុមដែលមើលឃើញកម្មវិធីនេះថា ជាកម្មវិធីមានហានិភ័យ)។ ដោយសារហេតុនេះ អ្នកប្រើប្រាស់ត្រូវចំណាយលុយតាមរយៈការខ្ចីលុយពីកុមារផ្សេងទៀត ឬ ការយកលុយពីឪពុកម្ដាយរបស់ខ្លួន។

AK2 ហៅម្យ៉ាងទៀតថា "Mission Against Terror" គឺជាហ្គេមបាញ់សត្រូវ លេងបានច្រើននាក់ និងឥតបង់ថ្លៃ ដែលស្រដៀងគ្នាទៅនឹងហ្គេមអាជីវកម្មនានា ដូចជា Counter-Strike ឬ Call of Duty ដែរ។ មានក្រុមចំនួន ១៥ ក្រុម (២៥.៨៦%) បានរៀបរាប់ថា ហ្គេមនេះ គឺជាហ្គេមដែលមានហានិភ័យខ្ពស់។ មានតែក្រុមកុមារមួយប៉ុណ្ណោះដែលបានបង្ហាញពីក្ដីបារម្ភចំពោះឯកជនភាពរបស់ពួកគេ។ មានកុមារម្នាក់បានលើកឡើងថា "ពេលខ្លះ នៅពេលយើងកំពុងលេងហ្គេម (អ្នកប្រើប្រាស់ផ្សេងទៀត) អាចថតរូបរបស់យើង និងចែករំលែកឲ្យអ្នកផ្សេង"។ មានក្រុមមួយផ្សេងទៀតបានលើកឡើងថា ក្រៅពីទាំងនេះ ក៏នៅមានហានិភ័យតិចតួចដែលមានទំនាក់ទំនងផ្ទាល់ទៅ

នឹង OCSE ប៉ុន្តែទាក់ទងជាមួយបញ្ហាផ្សេងៗជាង ដែលមានដូចជា តម្លៃហ្គេម និងទំនាស់អន្តរបុគ្គលរវាងអ្នកលេងដូចគ្នា ឬជាមួយគ្នា។

PUBG ហៅម្យ៉ាងទៀតថា "Player Unknown's Battlegrounds" គឺជាហ្គេមសមរភូមិ ដែលលេងបានច្រើននាក់ តាមប្រព័ន្ធអ៊ិនធឺណិត ដំណើរការដោយសាជីវកម្ម PUBG ជាបុត្តសម្ព័ន្ធមួយរបស់ Blueholecited ដែលជាក្រុមហ៊ុនវីឌីអូហ្គេមមួយនៅប្រទេសកូរ៉េខាងត្បូង។ មានក្រុមចំនួន ១៥ ក្រុម (២៥.៨%) បានរៀបថា ហ្គេមនេះ មានហានិភ័យ។ ហានិភ័យចម្បងដែលត្រូវបានកុមារកំណត់បាន គឺទំនាស់អន្តរបុគ្គលរវាងអ្នកលេង និងអ្នកលេង ដែលមានមួយចំនួនបានជេរ ឬប្រមាថកុមារ ខណៈដែលពួកគេនៅលើអ៊ិនធឺណិត ព្រមទាំងវាយតប់គ្នានៅក្នុងជីវិតពិត ជាមួយយុវវ័យផ្សេងទៀត ដោយសារការលេងហ្គេមនេះ។ ក្តីបារម្ភមួយទៀតដែលត្រូវបានពិភាក្សា គឺសមត្ថភាពរបស់អ្នកលេងអនាមិក ក្នុងការជជែកជាមួយកុមារខណៈកំពុងលេងហ្គេម។ មានក្រុមចំនួនពីរបានពិភាក្សាអំពីបទពិសោធន៍ផ្ទាល់ខ្លួនលើ ការជួបជាមួយបុគ្គលអនាមិកដែលពួកគេបានជួបនៅក្នុងហ្គេមក្នុងជីវិតពិត។ មានកុមារម្នាក់រំលឹកថា "PubG បានណែនាំយើងឲ្យស្គាល់មិត្តភក្តិជាច្រើន តាមប្រព័ន្ធអ៊ិនធឺណិត។ ពេលខ្លះមិត្តភក្តិទាំងនេះសុំជួបយើងនៅក្នុងជីវិតពិត និងព្យាយាមឲ្យយើងចូលរួមជាមួយក្រុមរបស់ពួកគេ"។

GTA 5 ហៅម្យ៉ាងទៀតថា Grand Theft Auto 5 គឺជាវីឌីអូហ្គេមផ្សងព្រេងបែបវាយតប់គ្នា ដែលអ្នកលេងគ្រប់គ្រងតួអង្គនាំមុខបីនាក់នៅទូទាំងបរិស្ថានទីក្រុង ដើម្បីបំពេញបេសកកម្មផ្សេងៗ ដែលជាញឹកញាប់ ទាក់ទងនឹងអំពើហិង្សា។ មានក្រុមចំនួន ៨ក្រុម (១៣.៨%) បានលើកឡើងថា ហ្គេមនេះគឺជាហ្គេមមានហានិភ័យ។ ភាគច្រើននៃកុមារ (មាន ៨នាក់ មកពីក្រុមចំនួនប្រាំ) ដែលកំពុងប្រើប្រាស់ហ្គេមនេះបានលើកឡើងថា វាមានហានិភ័យដោយសារខ្លឹមសារហិង្សា និងផ្លូវភេទ ដែលមានទូទាំងហ្គេមនេះ។ លើសពីនេះ មានក្រុមមួយបានលើកឡើងថា ហ្គេមនេះគឺជាហ្គេមមានហានិភ័យ ដោយសារគ្រោងការទុច្ចរិត ដោយលើកឡើងនូវករណីមួយ ដែលអ្នកលេងម្នាក់បានប៉ុនប៉ងយកព័ត៌មានហិរញ្ញវត្ថុពីអ្នកលេងផ្សេងទៀត។

## ៣.១.២.៤. កម្មវិធីផ្សាយផ្ទាល់

ការផ្សាយផ្ទាល់ គឺជាការផ្សាយបន្តដោយផ្ទាល់ទាន់ពេលវេលា ការផ្សាយផ្ទាល់ចេញពីកុំព្យូទ័រ ឬឧបករណ៍ចល័តទៅកាន់ទស្សនិកជន តាមប្រព័ន្ធអ៊ិនធឺណិត។ បាតុភូតនេះ បានកំពុងទាក់ទាញកុមារ និងមនុស្សពេញវ័យក្មេងៗនៅប៉ុន្មានឆ្នាំថ្មីៗនេះ ដោយសារវាផ្តល់ឱកាសដល់ពួកគេ ឲ្យក្លាយជាអ្នកបង្កើតនិងអ្នកបង្ហាញ ហើយទស្សនិកជនមើលឃើញជុំវិញទូទាំងពិភពលោក។ នរណាម្នាក់ដែលមានកម្មវិធីនេះ អាចជាអ្នកបង្ហាញផ្ទាល់និងអាចផ្សព្វផ្សាយអំពីអ្វីមួយនៅទូទាំងពិភពលោក ទាន់ពេលវេលាជាក់ស្តែង។ អន្តរទំនាក់ទំនងរបស់អ្នកប្រើប្រាស់ជាមួយទស្សនិកជនរបស់ពួកគេ គឺជាធាតុផ្សំចម្បងនៃកម្មវិធីទាំងនេះ។ ការផ្សាយផ្ទាល់នេះ កើតឡើងតាមរយៈការជជែកជាសាធារណៈដែលប្រតិបត្តិការនៅក្នុងឬជាមួយការផ្សាយវីឌីអូ។ ការផ្សាយផ្ទាល់នេះ ផ្តល់សមត្ថភាពរបស់អ្នកបង្ហាញ និងទស្សនិកជនរបស់ពួកគេក្នុងការនិយាយ ឬមានករណីខ្លះផ្ញើអំណោយមានលក្ខណៈជាឌីជីថល ដែលអាចផ្តោះប្តូរជាមួយឥណទានរូបិយវត្ថុបាន។ នៅក្នុងសិក្ខាសាលារៀនសូត្រ TikTok និង Bigo Live គឺកម្មវិធីផ្សាយផ្ទាល់ពីរ ដែលមានប្រជាប្រិយភាពបំផុត ហើយដែលអ្នកចូលរួមបានពិភាក្សា ហើយកម្មវិធីទាំងពីរត្រូវបានកំណត់ថា ជាកម្មវិធីមានហានិភ័យខ្ពស់។

TikTok (ពីដំបូងមក គេស្គាល់ថាជា musical.ly) គឺជាកម្មវិធីទំនាក់ទំនងសង្គម ដើម្បីបង្កើត ចែករំលែក និងរកវីឌីអូតន្ត្រីខ្លីៗ។ អ្នកប្រើប្រាស់អាចបង្កើតវីឌីអូតន្ត្រីខ្លីៗ ជាមួយនឹងឧបករណ៍នៅលើកម្មវិធីនេះ និងចែករំលែក

ខ.៨១

វីឌីអូទាំងនេះជាមួយអ្នកប្រើប្រាស់ TikTok ផ្សេងទៀត។ ក្រុមកុមារ និងគ្រូបង្រៀនចំនួន ២៥ក្រុម ក្នុងចំណោម ៥៨ ក្រុម (៤៣.១០%) បានរៀបរាប់ថា កម្មវិធីទាំងនេះ គឺជាកម្មវិធីមានហានិភ័យ។ ខ្លឹមសារផ្លូវភេទ គឺជាហានិភ័យដែលត្រូវបានកំណត់ជាទូទៅបំផុតនៅលើ TikTok (ប្រាំពីរក្រុម ឬ៣០%) ជាមួយនឹងក្រុមភាគច្រើន លើកឡើងអំពីខ្លឹមសារបង្ហាញបែបផ្លូវភេទ ត្រូវបានផលិតឡើងដោយផលិតករនៅលើកម្មវិធីនេះ (រាប់បញ្ចូលទាំងផលិតករដែលមានវ័យក្មេងខ្លាំង) ផងដែរ។ មានពីរក្រុម (៨.៦៩%) បានរៀបរាប់អំពី ខ្លឹមសារផ្លូវភេទច្រើនជ្រុលនៅក្នុងកម្មវិធីនេះ រាប់បញ្ចូលទាំងភាពអាក្រាត និងអ្នកប្រើប្រាស់ដែលប្រើប្រាស់កម្មវិធីនេះ ដើម្បីរកលុយពីខ្លឹមសារបែបនេះ។ មានក្រុមផ្សេងទៀត បានលើកឡើងអំពីហានិភ័យផ្សេងទៀត ដែលមាននៅលើកម្មវិធីនេះ រាប់បញ្ចូលទាំងយុវវ័យដែលរៀនអំពី ផ្លូវភេទ ឬភាសា និងអាកប្បកិរិយាមិនសមរម្យផ្សេងទៀត។

Bigo Live គឺជាកម្មវិធីផ្សាយផ្ទាល់ ដែលអនុញ្ញាតឲ្យអ្នកប្រើប្រាស់ផ្សាយផ្ទាល់វីឌីអូរបស់ពួកគេ រៀបចំការបង្ហាញ និងអន្តរទំនាក់ទំនងជាមួយអ្នកប្រើប្រាស់ផ្សេងទៀត។ ទ្រង់ទ្រាយដែលគួរឲ្យចាប់អារម្មណ៍នៃកម្មវិធីនេះ គឺសមត្ថភាពរបស់វាក្នុងការរកលុយ។ អ្នកប្រើប្រាស់ទិញកញ្ចប់ Bean ដើម្បីធ្វើជាអំណោយ ឬ ផ្តល់កម្រៃទឹកតែចំពោះ Vloggers ជាទីពេញចិត្តជាងគេរបស់ពួកគេ។ បន្ទាប់មក Vloggers អាចដកយករូបិយប័ណ្ណក្នុងកម្មវិធីចេញជាលុយក្នុងពិភពពិត។ មានក្រុមចំនួន ១៧ ក្រុម (២៩.៣%) បានរៀបរាប់ថា Bigo Live គឺជាកម្មវិធីមានហានិភ័យ។ ស្របពេលដែល Bigo Live ត្រូវបានពិភាក្សាដោយក្រុមចំនួនតិចជាង បើប្រៀបធៀបជាមួយនឹងTikTok ហានិភ័យនានាដែលត្រូវបានរៀបរាប់ដោយគ្រូបង្រៀន និងកុមារ គឺមានលក្ខណៈកាន់តែធ្ងន់ធ្ងរគួរឲ្យកត់សម្គាល់។ មានក្រុមចំនួនប្រាំបីក្រុមនៃក្រុមសរុបចំនួន ១៧ក្រុម (៤៧.០៥%) ដែលលើកឡើងថា Bigo Live ជាកម្មវិធីមានហានិភ័យ បានរៀបរាប់ថា គេបានឃើញការផ្សាយផ្ទាល់ខ្លឹមសារផ្លូវភេទរបស់កុមារ និងមនុស្សពេញវ័យក្មេងៗ រាប់បញ្ចូលទាំងមនុស្សជាច្រើន ដែលផ្តល់ខ្លឹមសារបែបនេះ ដើម្បីផ្តោះប្តូរនឹងការចំណាយហើយមាន មនុស្សមួយចំនួននឹងយល់ព្រមជួបជាលក្ខណៈឯកជនជាមួយសមាជិក នៃទស្សនិកជនរបស់ពួកគេនៅតាមកម្មវិធីផ្សេងទៀត។ សិស្សសាលារៀនរដ្ឋម្នាក់នៅក្នុងខេត្តព្រះសីហនុកត់សម្គាល់ថា "Bigo Live គឺត្រូវបានប្រើប្រាស់ច្រើនជាងគេដោយ (ក្មេងស្រីដែលលក់ផ្លូវភេទ)។ ពួកគេផ្សាយផ្ទាល់ (និងការបង្ហាញ) ខ្លួនប្រាណរបស់ពួកគេ និងនិយាយអំពីរឿងរាវផ្លូវភេទ និងផ្តល់ព័ត៌មានទំនាក់ទំនងរបស់ពួកគេ"។

ក្រុមកុមារ និងគ្រូបង្រៀនចំនួន ១៥ ក្រុម ក្នុងចំណោមក្រុមសរុបចំនួន ៥៨ ក្រុម (២៧.៦%) បានលើកឡើងថា YouTube គឺជាកម្មវិធីមានហានិភ័យ។ ភាគច្រើននៃក្រុមដែលពិភាក្សាអំពី YouTube (៦២.៥០%) កំណត់បាននូវការរីករាលដាលនៃវត្ថុមានរូបភាព ឬវីឌីអូអាសអាភាស ដែលជាហានិភ័យសំខាន់សម្រាប់កុមារ។ ក្រុមគ្រូបង្រៀន និងកុមារមួយចំនួន គូសបញ្ជាក់នូវទំនាក់ទំនងរវាងការទទួលបានសម្ភារអាសអាភាសយ៉ាងស្រួល និងអាកប្បកិរិយាបង្កការឈឺចាប់ផ្លូវភេទ ក្នុងចំណោមកុមារ និងយុវវ័យ។ សិស្សសាលារៀនរដ្ឋម្នាក់ នៅខេត្តសៀមរាប បានលើកឡើងថា "បន្ទាប់ពីនរណាម្នាក់មើលវីឌីអូអាសអាភាសតាម YouTube រួចហើយ ពួកគេតែងតែចង់អនុវត្តផ្ទាល់ (នូវអ្វីដែលពួកគេបានឃើញ) នៅក្នុងសង្គមជាក់ស្តែង"។ មានបុរសម្នាក់ទៀត មកពីសហគមន៍ងាយរងគ្រោះនៅក្នុងរាជធានីភ្នំពេញ បានរៀបរាប់អំពីផលប៉ះពាល់មួយចំនួន ដែលគាត់បានកត់សម្គាល់ឃើញនៅក្នុងស្ថានភាពរបស់គាត់ផ្ទាល់។ គាត់កត់សម្គាល់ថា "វីឌីអូផ្លូវភេទ បានជះឥទ្ធិពលលើកុមារ ឲ្យអនុវត្តការរំលោភបំពានផ្លូវភេទ លើកុមារផ្សេងទៀត។ ឧទាហរណ៍ វីឌីអូផ្លូវភេទ បានជះឥទ្ធិពលដល់កុមារ ឲ្យបេះរួមភេទ (ទាំងនៅវ័យក្មេង (និង) បេះទៅលួចមើលអ្នកផ្សេងទៀតកំពុងងូតទឹក ជាដើម។ វីឌីអូផ្លូវភេទ ជះលើឥទ្ធិពលលើខួរក្បាលរបស់កុមារ"។

### ៣.១.៣. ការរៀបចំរឿង អំពីហានិភ័យតាមប្រព័ន្ធអ៊ីនធឺណិត

បន្ទាប់ពីកំណត់បរិយាកាសអ៊ីនធឺណិត និងការចូលរួមរបស់ពួកគេនៅក្នុងសកម្មភាពផ្សេងទៀត ក្នុងគោលបំណងកំណត់ និងវិភាគអំពីហានិភ័យនៃ OCSE សំខាន់ៗមក កុមារត្រូវបានស្នើសុំឲ្យបង្កើតសាច់រឿងមួយថាតើមានអ្វីខ្លះដែលដូច OCSE ហើយបានកើតឡើង ឬអាចកើតឡើងនៅក្នុងបរិយាកាសតាមប្រព័ន្ធអ៊ីនធឺណិតរបស់ពួកគេដោយរបៀបណា។ ក្នុងចំណោមកុមារទាំង២២០នាក់ ដែលមកចូលរួមវគ្គសិក្ខាសាលាទាំង ១៣លើកមានកុមារចំនួន១១៧នាក់ បានចែករំលែកឧទាហរណ៍ជាក់លាក់អំពីហានិភ័យទាក់ទងនឹងអ៊ីនធឺណិតនៅក្នុងបរិយាកាសអ៊ីនធឺណិតរបស់ពួកគេ។ កុមារមួយចំនួនបានចែករំលែកនូវសេណារីយ៉ូបែបសម្មតិកម្ម ដោយផ្អែកលើចំណេះដឹង និងបទពិសោធន៍របស់ពួកគេ ជាមួយនឹងកម្មវិធីដែលពួកគេប្រើប្រាស់ច្រើនជាងគេស្របពេលដែលកុមារផ្សេងទៀតបង្កើតសាច់រឿងពិតពីឧប្បត្តិហេតុ ដែលបានកើតឡើងចំពោះពួកគេផ្ទាល់ ឬចំពោះមនុស្សដែលពួកគេស្គាល់។

កុមារចំនួន៧១នាក់ ក្នុងចំណោមកុមារ១១៧នាក់ (៦០%) បានចែករំលែកឧទាហរណ៍ នៃការកេងប្រវ័ញ្ចផ្លូវភេទកុមារតាមប្រព័ន្ធអ៊ីនធឺណិត[53] នៅក្នុងបរិយាកាសអ៊ីនធឺណិតរបស់ពួកគេ។ ភាគច្រើនបំផុត ឬមាន៥៩នាក់ក្នុងចំណោម៧១នាក់ (៨៣%) បានចែករំលែកបទពិសោធន៍ឬការរៀបរាប់អំពីសាច់រឿងរបស់អ្នកដទៃទៀតអំពី OCSE។ ចំនួនជាងពាក់កណ្តាលនៃកុមារទាំងនេះ ដែលមានកុមារចំនួន៣៧នាក់ ឬ៥៣% បានចែករំលែកបទពិសោធន៍ផ្ទាល់ខ្លួនអំពី OCSE និងជិតមួយភាគបី ដែលមានកុមារចំនួន២២នាក់ ឬ៣១% រៀបរាប់អំពី OCSE ដែលបានកើតឡើងលើនរណាម្នាក់ដែលពួកគេស្គាល់។ នេះមានន័យថា ក្នុងចំណោមកុមារទាំង ២២០នាក់ ដែលបានចូលរួមក្នុងសិក្ខាសាលារៀនសូត្រនេះមានកុមារ៣៧នាក់ ឬ១៧% (ប្រហែលមានកុមារម្នាក់ក្នុងចំណោម ប្រាំមួយនាក់) បានចែករំលែកបទពិសោធន៍ផ្ទាល់ខ្លួនអំពីហានិភ័យទាក់ទងនឹង OCSE នៅតាមអ៊ីនធឺណិត។ សេចក្តីអធិប្បាយចំនួន១៣ គឺជាសម្មតិកម្ម ឬការឆ្លុះបញ្ចាំងនូវអ្វីមួយ ដែលកុមារបានអាននៅក្នុងសារព័ត៌មានហើយសេចក្តីអធិប្បាយផ្សេងទៀត មិនមានលក្ខណៈច្បាស់ លាស់ឡើយ។

**ការលួងលោម:** ក្នុងចំណោមកុមារ១១៧នាក់ ដែលបានចែករំលែកអំពីហានិភ័យតាមប្រព័ន្ធអ៊ីនធឺណិតមាន កុមារ២៩នាក់ (២៥%) បានចែករំលែកបទពិសោធន៍ផ្ទាល់ខ្លួនផ្សេងៗ (១៨សេចក្តីអធិប្បាយ) ឬ បទពិសោធន៍របស់អ្នកដទៃ (១១សេចក្តីអធិប្បាយ) អំពីការលួងលោម ឬការប៉ុនប៉ងទាក់ទងនឹងផ្លូវភេទពីមនុស្សពេញវ័យតាមអ៊ីនធឺណិត។ កុមារភាគច្រើន ដែលជួបប្រទះនឹងការលួងលោមបានលើកឡើងថា វាកើតឡើងតាមរយៈ Facebook និងកម្មវិធី Messenger របស់ Facebook (២០សេចក្តីអធិប្បាយ) ព្រមទាំងកម្មវិធីផ្ញើសារផ្សេងទៀតដូចជា Line។ គោលដៅនៃការលួងលោម គឺទាំងបុរស (១១សេចក្តីអធិប្បាយ) និងស្រី (១៤សេចក្តីអធិប្បាយ) និងមានសេចក្តីអធិប្បាយចំនួនបួន មិនបានបញ្ជាក់អំពីភេទឡើយ។ ជនខិលខូចភាគច្រើនត្រូវបានរៀបរាប់ថា ជាមនុស្សពេញវ័យជាបុរស (២០សេចក្តីអធិប្បាយ) ហើយពួកគេមួយចំនួនត្រូវបានជឿជាក់ថា គឺជាជនបរទេស ជាពិសេសពួកឥណ្ឌា[54]។ នៅក្នុងសេចក្តីអធិប្បាយជាច្រើន កុមារបានរៀបរាប់អំពី ការទទួលបានសំណើធ្វើជាមិត្តឬ

---

[53]ឧទាហរណ៍ជាក់លាក់ទាក់ទងនឹងការកេងប្រវ័ញ្ចផ្លូវភេទកុមារតាមអ៊ីនធឺណិត។ កុមារជាច្រើនបង្ហាញនូវរឿងរ៉ាវនានា ដែលពាក់ព័ន្ធនឹងហានិភ័យក្រៅអ៊ីនធឺណិតផ្សេងៗ ចំពោះអំពើហិង្សា ឬការកេងប្រវ័ញ្ច រាប់បញ្ចូលទាំងគ្រោងការទុច្ចរិតតាមរយៈការហៅទូរស័ព្ទ និងការផ្ញើសារជាអក្សរ និងទម្រង់ផ្សេងទៀតនៃអំពើហិង្សា និងការកេងប្រវ័ញ្ច នៅតាមអ៊ីនធឺណិតកាហ្វេ (ជាពិសេស ក្នុងចំណោមកុមារ មកពីសហគមន៍ងាយរងគ្រោះ)។ ទោះបីជាយ៉ាងណា ឧទាហរណ៍ទាំងនេះ មិនត្រូវបានបញ្ចូលទៅក្នុងរបាយការណ៍នេះទេ ដោយសារតែឧទាហរណ៍ទាំងនេះ មិនទំនងជាទាក់ទងនឹង OCSE។

[54]ស្របពេលដែលកុមារបានរៀបរាប់អំពីជនខិលខូចមួយចំនួនថាជា "ជនជាតិឥណ្ឌា" ការពិតវាមិនច្បាស់អំពី សញ្ជាតិនៃបុគ្គលដែលកុមារបានរៀបរាប់ឡើយ។ គួរកត់សម្គាល់ថា "ជនជាតិឥណ្ឌា" អាចត្រូវបានប្រើប្រាស់ជាទូទៅ ជាពាក្យបញ្ជាក់អំពីជាតិពន្ធុ យ៉ាងទូលំទូលាយ សម្រាប់មនុស្សដែលមានដើមកំណើតនៅអាស៊ីខាងត្បូង និងមជ្ឈឹមបូព៌ា។

សារដោយផ្ទាល់ ពីបុគ្គលដែលពួកគេមិនស្គាល់នៅតាម Facebook ដែលពួកគេប៉ុនប៉ងចាប់ផ្តើមការសន្ទនាជាមួយកុមារ និងបង្កើតទំនុកចិត្ត។ មានករណីមួយចំនួន ជនដែលកុមារមិនធ្លាប់ស្គាល់បានចាប់ផ្តើមការហៅទូរស័ព្ទជាវីឌីអូបន្តផ្ទាល់ជាមួយកុមារ ឬដោយផ្ញើរូបភាពទាក់ទងនឹងផ្លូវភេទដោយផ្ទាល់ហើយមានករណីខ្លះ បានស្នើសុំរូបភាពទាក់ទងនឹងផ្លូវភាពពីកុមារវិញ។ មានកុមារីម្នាក់មកពីខេត្តព្រះសីហនុបានរៀបរាប់ថា មានបុរសម្នាក់បានបញ្ចូលនាងទៅក្នុង Messenger និងបានចាប់ផ្តើមជជែកជាមួយនាង។ នាងលើកឡើងថា "គាត់ (បានចាប់ផ្តើម) ផ្ញើរូបភាពអាសអាភាសមកខ្ញុំ ទាំងរូបភាពរបស់បុរស និងស្ត្រី។ ខ្ញុំបានចុចបើកមើលរូបភាពទាំងនោះ ហើយខ្ញុំបានខឹងគាត់ជាខ្លាំង ដោយសារគាត់ផ្ញើរូបភាពបែបនេះមកឲ្យខ្ញុំ។ ខ្ញុំគិតថា គាត់ចង់មានឱកាសផ្លូវភេទជាមួយខ្ញុំ។ ខ្ញុំបានប្លុកគាត់ពីគណនីរបស់ខ្ញុំ និងបានលុបរូបភាពទាំងអស់ដែលគាត់បានផ្ញើមកឲ្យខ្ញុំចោល"។ ករណីមួយទៀត មានកុមារីម្នាក់មកពីខេត្តព្រះសីហនុ បានរៀបរាប់អំពីឧប្បត្តិហេតុជាបន្តបន្ទាប់ពីមុន ថាមានបុរសជនជាតិចិនម្នាក់ដែលនាងមិនធ្លាប់ស្គាល់ និងមិនបានបញ្ចូលបុរសនោះជាមិត្តភក្តិនៅក្នុង Facebook សោះឡើយ។ នាងបានរៀបរាប់ថាបុរសនោះព្យាយាមទំនាក់ទំនងមកនាងជាប្រចាំនៅតាម Messenger ហើយគាត់បានផ្ញើរូបភាព និងវីឌីអូទាក់ទងនឹងផ្លូវភេទ និងស្នើសុំជួបនាង។ នាងបានលើកឡើងទៀតថា "បន្ទាប់ពីខ្ញុំបានឆែកមើលប្រូហ្វាលរបស់គាត់ (ខ្ញុំបានរកឃើញថា) គាត់គឺជាបុរសជនជាតិចិន ហើយគាត់បានបង្ហោះរូបភាព និងវីឌីអូអាសអាភាស ដែលបង្ហាញពីស្ត្រីអាក្រាតកាយ។ គាត់គឺជាជនខិលខូច ដែលចង់លួងលោមយើង ឲ្យធ្វើការងារបម្រើសេវាផ្លូវភេទ"។ បន្ទាប់ពីសិក្ខាសាលានេះទៅ កុមារទទួលបានធនធានចាំបាច់ ដើម្បីឲ្យពួកគេបន្តមានសុវត្ថិភាពនៅតាមប្រព័ន្ធអ៊ិនធឺណិត ហើយបុគ្គលិកសង្គមក្នុងមូលដ្ឋាន ដែលធ្វើការងារយ៉ាងជិតស្និទ្ធជាមួយគម្រោងនេះ បានបន្តដោះស្រាយករណីនេះ។

**ការទទួលបានរូបភាព ឬ វីឌីអូអាសអាភាស**: ជាទូទៅ កុមាររៀបរាប់អំពីស្ថានភាពនានា ដែលពួកគេទទួលបាន ឬឃើញវីឌីអូ និងខ្លឹមសារអាសអាភាស ដែលមិនស្របនឹងឆន្ទៈរបស់ពួកគេ។ មានកុមារម្នាក់ក្នុងចំណោមកុមារប្រាំនាក់ នៃកុមារសរុបចំនួន ១១៧នាក់ (២៣ ឬ២៣%) បានរៀបរាប់អំពី សេណារីយ៉ូចម្រុះគ្នាច្រើន ដែលមនុស្សពេញវ័យ កុមារផ្សេងទៀត និងការផ្សាយពាណិជ្ជកម្មតាមប្រព័ន្ធអ៊ិនធឺណិត ធ្វើឲ្យពួកគេមើលឃើញសម្ភារអាសអាភាសច្បាស់ៗជាច្រើនប្រភេទ នៅតាមប្រព័ន្ធអ៊ិនធឺណិត។ ក៏មានការរៀបរាប់ត្រួតគ្នាផងដែរ អំពីការលួងលោមដោយសារកុមារបានលើកឡើងជាទូទៅថា មនុស្សពេញវ័យប្រើប្រាស់រូបភាព និងវីឌីអូអាសអាភាសជាមធ្យោបាយសម្រាប់លួងលោមកុមារឲ្យចែករំលែក ឬចូលរួមក្នុងសកម្មភាព និងខ្លឹមសារផ្លូវភេទ។ ក្នុងសេចក្តីអធិប្បាយចំនួន ២៣ ដែលកុមារបានចែករំលែក មានសេចក្តីអធិប្បាយចំនួន១៦ ត្រូវបានលើកឡើងថា បានកើតឡើងនៅតាម Facebook និងតាមកម្មវិធីផ្ញើសាររបស់ Facebook មានសេចក្តីអធិប្បាយចំនួនពីរ ត្រូវបានលើកឡើងថា បានកើតឡើងនៅលើកម្មវិធីមិនស្គាល់ឈ្មោះផ្សេងទៀត មានសេចក្តីអធិប្បាយចំនួនមួយថា កើតឡើងនៅក្នុង Line (កម្មវិធីផ្ញើសារ) និងមួយទៀតកើតឡើងនៅក្នុង TikTok (កម្មវិធីបណ្តាញទំនាក់ទំនងសង្គម) ស្របពេលនឹងមានសេចក្តីអធិប្បាយចំនួនបី ដែលមិនបានបញ្ជាក់អំពី កម្មវិធីជាក់លាក់នោះឡើយ។ ភាគច្រើននៃសេចក្តីអធិប្បាយ (មាន១៧ ក្នុងចំណោម២៣) ត្រូវបានរៀបរាប់ថា ជាបទពិសោធន៍ផ្ទាល់ខ្លួនរបស់កុមារ ស្របពេលនឹងមានសេចក្តីអធិប្បាយចំនួនប្រាំមួយត្រូវបានរៀបរាប់ថា បានកើតឡើងចំពោះនរណាម្នាក់ ដែលកុមារស្គាល់។ មានកុមារមួយចំនួន បានរៀបរាប់អំពី ការដែលត្រូវបានបញ្ចូលជាមិត្តក្នុង Facebook ឬបញ្ចូលទៅក្នុងក្រុមផ្ញើសារដោយគ្មានការស្នើសុំ ឬការយល់ព្រមពីពួកគេ ហើយវាជាកន្លែងដែលរូបភាព ឬវីឌីអូអាសអាភាសត្រូវបានចែករំលែកជាទូទៅជាមួយអ្នកប្រើប្រាស់។ ក្នុងករណីផ្សេងទៀត មានកុមារលើកឡើងជាទូទៅអំពីការបញ្ចូលទៅក្នុងក្រុមផ្ញើសារដោយគ្មានការយល់ព្រមពីពួកគេ និងការទទួលបានវីឌីអូ និងរូបភាពអាសអាភាស។ នេះក៏ជាខ្លឹមសារគួរឲ្យកត់សម្គាល់ ដែលលេចឡើងពីសកម្មភាពកំណត់ទីតាំងបែបបរិស្ថានវិទ្យាផងដែរ។ មានកុមារម្នាក់បានរំលឹកថា "នៅពេលមួយខ្ញុំបានចូលរួមក្នុងការជជែកជា

ក្រុមមួយ ហើយមានសមាជិកក្រុមម្នាក់បានផ្ញើរូបភាពអាសអាភាសរបស់បុរសម្នាក់ និងស្ត្រីម្នាក់។ បន្ទាប់ពីខ្ញុំបានឃើញ ខ្ញុំក៏បានចាកចេញពីក្រុមនោះ។ ខ្ញុំគិតថា រូបភាពនោះមិនល្អ (សម្រាប់មើល) ឡើយ"។

**ការផ្សាយផ្ទាល់**: មានសេចក្តីអធិប្បាយចំនួនប្រាំពីររបស់កុមារ បានរៀបរាប់ករណីផ្សេងៗ ដែលស្របគ្នានឹងការផ្សាយផ្ទាល់ អំពីការរំលោភបំពានផ្លូវភេទលើកុមារតាមប្រព័ន្ធអ៊ិនធឺណិត។ មានបីករណីនៃករណីទាំងនេះ ត្រូវបានរៀបរាប់ថា បានកើតឡើងនៅតាម Facebook ឬកម្មវិធីផ្ញើសាររបស់ Facebook មានសេចក្តីអធិប្បាយចំនួនមួយត្រូវបានលើកឡើងថា បានកើតឡើងតាមរយៈកម្មវិធី Tik Tok និងមានសេចក្តីអធិប្បាយមួយផ្សេងទៀតមិនបានផ្តល់ព័ត៌មានលម្អិតអំពីកម្មវិធីតាមប្រព័ន្ធអ៊ិនធឺណិតឡើយ។ មានសេចក្តីអធិប្បាយចំនួនបី ទាក់ទងនឹងកុមារដែលជាគោលដៅផ្ទាល់សម្រាប់សកម្មភាពផ្លូវភេទរបស់មនុស្សពេញវ័យ ដោយប្រើប្រាស់វ៉ែបខែម។ ក្នុងករណីមួយផ្សេងទៀត មានកុមារាអាយុ ១៤ឆ្នាំម្នាក់ មកពីខេត្តសៀមរាប បានរៀបរាប់អំពីការក្លាយខ្លួនជាគោលដៅរបស់បុរសបរទេសម្នាក់ នៅពេលកំពុងប្រើប្រាស់កម្មវិធីផ្ញើសាររបស់ Facebook។ កុមារនេះបានលើកឡើងថា "មានបុរសឥណ្ឌាម្នាក់បានបញ្ចូលខ្ញុំទៅក្នុង Messenger និងបានចាប់ផ្តើមហៅទូរស័ព្ទជាវីឌីអូ។ គាត់បានបង្ហាញ(ខ្ញុំ) ដោយគាត់បានដោះសម្លៀកបំពាក់របស់គាត់ចេញ ស្របពេលដែលគាត់កំពុងជជែកជាមួយខ្ញុំ។ ពេលខ្លះ គាត់ផ្ញើសារជាភាសាអង់គ្លេស និងជាភាសាខ្មែរមកខ្ញុំផងដែរ។ ខ្ញុំបានប្លុកគាត់នៅក្នុង Messenger របស់ខ្ញុំ ប៉ុន្តែក្រោយមក គាត់លេចមុខឡើងម្តងទៀត ដើម្បីជជែកជាមួយខ្ញុំ។ ខ្ញុំគិតថា គាត់ប្រហែលចង់ឲ្យខ្ញុំធ្វើដូចគាត់ដែរ"។

ក្នុងករណីមួយ មានកុមារម្នាក់ និងមិត្តភក្តិរបស់កុមារ ត្រូវបានគេសួរនាំនៅតាមផ្លូវ ដើម្បីឲ្យថតវីឌីអូ អំពីសកម្មភាពផ្លូវភេទ ដែលនឹងត្រូវផ្សាយផ្ទាល់នៅតាមប្រព័ន្ធអ៊ិនធឺណិត។ មានកុមារីម្នាក់ មកពីខេត្តសៀមរាប បានលើកឡើងថា "នៅជិតក្លឹបរាត្រី និងខារ៉ាអូខេ មានជនចម្លែកម្នាក់ដើរមកកាន់យើងនិងសួរថា តើយើងអាចពាក់អាវនិងខោខ្លីបែបស្រើបស្រាល និងរាំសម្រាប់ថតវីឌីអូផ្សាយផ្ទាល់ឬទេ?" នាងលើកឡើងថា ជនចម្លែកនោះបន្តសួរនាំអំពី ព័ត៌មានផ្ទាល់ខ្លួនរបស់នាង របស់មិត្តភក្តិនាង និងរបស់គ្រួសារនាង។

CSAM: មានកុមារប្រាំមួយនាក់ (៥%) បានរៀបរាប់អំពី ករណីដែលពួកគេ (ឬ កុមារផ្សេងទៀត ដែលពួកគេស្គាល់) បានថតរូបភាពផ្លូវភេទរបស់ខ្លួនឯង និង/ឬ បានចែកចាយនៅតាមប្រព័ន្ធអ៊ិនធឺណិត។ មានសេចក្តីអធិប្បាយចំនួនបួន ក្នុងចំណោមសេចក្តីអធិប្បាយចំនួនប្រាំមួយ ទាក់ទងនឹងការផលិត CSAM នៅក្នុងបរិយាកាសក្រៅអ៊ិនធឺណិត ហើយរូបភាពទាំងនោះ ត្រូវបានយកទៅបង្ហោះចូលក្នុងកម្មវិធីតាមប្រព័ន្ធអ៊ិនធឺណិត ស្របពេលដែលសេចក្តីអធិប្បាយពីរផ្សេងទៀត ទាក់ទងនឹងការចែកចាយរូបភាព ដែលមានស្រាប់ ពាក់ព័ន្ធនឹងផ្លូវភេទរបស់កុមារនៅក្នុងការជជែកគ្នាតាមប្រព័ន្ធអ៊ិនធឺណិត។ មានសេចក្តីអធិប្បាយបី ត្រូវបានរៀបរាប់ថា កើតឡើងនៅតាម Facebook និង/ឬ តាមកម្មវិធីផ្ញើសារ ហើយមានសេចក្តីអធិប្បាយបីផ្សេងទៀតមិនបានបញ្ជាក់អំពី កម្មវិធីតាមអ៊ិនធឺណិតឡើយ។ ក្នុងសេចក្តីអធិប្បាយពីរនៃសេចក្តីអធិប្បាយទាំងនេះ (មានមួយជាបទពិសោធន៍ផ្ទាល់ខ្លួន និងមួយទៀតជាសេចក្តីអធិប្បាយអំពីបទពិសោធន៍របស់អ្នកដទៃទៀត) គឺមានមនុស្សពេញវ័យបានផ្តល់លុយកាក់ដល់កុមារជាថ្នូរនឹងការថតរូបរបស់ពួកគេ។ មានបុរសម្នាក់ មកពីសហគមន៍ងាយរងគ្រោះនៅរាជធានីភ្នំពេញ បានរៀបរាប់ថា "ខ្ញុំបានជួបបុរសម្នាក់ (នៅទីតាំងជាក់លាក់មួយ) ស្របពេលដែលមិត្តភក្តិរបស់ខ្ញុំ និងខ្ញុំកំពុងលេងហ្គេមតាមប្រព័ន្ធអ៊ិនធឺណិត។ គាត់មានម៉ាស៊ីនថតពណ៌ខ្មៅធំមួយ និងសុំឲ្យពួកយើងថតរូបអាក្រាត(ដើម្បីប្តូរនឹង) លុយប្រាំពាន់រៀល។ មិត្តភក្តិរបស់ខ្ញុំម្នាក់បានយល់ព្រមថតរូប ប៉ុន្តែពីរនាក់ទៀតមិនបានយល់ព្រមឡើយ"។ មានសេចក្តីអធិប្បាយមួយទាក់ទងនឹងធាតុផ្សំនៃការចំអក និងអាកប្បកិរិយាផ្លូវភេទ ប្រកបដោយការឈឺចាប់។ នៅក្នុងសេចក្តីអធិប្បាយនេះ មានយុវវ័យម្នាក់ (អាយុ ១៩ឆ្នាំ) ត្រូវបានរៀបរាប់ថា បានសើចចំអកចំពោះកុមារវ័យក្មេងជាងម្នាក់

អំពី ទំហំខ្លួនរបស់កុមារនោះ និងបន្តទៅបង្ខំកុមារនោះ ឈរឲ្យគេថតដោយគ្មានសម្លៀកបំពាក់។ បន្ទាប់មករូបភាពទាំងនេះត្រូវបានចែកចាយនៅតាម Facebook ក្នុងគោលបំណងបន្ទុះបង្អាប់កុមារនោះ។ ស្របពេលដែលសេចក្តីអធិប្បាយនេះ ហាក់ដូចជាមិនមានចរិតផ្លូវភេទច្បាស់លាស់ មានការរំលោភបំពាន និងមានភាពពាក់ព័ន្ធដ៏អន្តរាយសម្រាប់កុមារ មានលក្ខណៈគួរឲ្យកត់សម្គាល់។

មានសេចក្តីអធិប្បាយអំពីការផលិត និងការចែកចាយ CSAM ត្រូវបានបង្ហាញនៅគ្រប់តំបន់ (រាជធានីភ្នំពេញ ខេត្តសៀមរាប និងខេត្តព្រះសីហនុ) និងត្រូវបានរៀបរាប់ដោយកុមារមកពីសហគមន៍ងាយរងគ្រោះប៉ុណ្ណោះ។ ទោះបីជាយ៉ាងណា គួរកត់សម្គាល់ថា ស្របពេលដែលសិស្សានុសិស្សមកពីសាលារៀនរដ្ឋ និងឯកជន មិនបានបរិយាយអំពីការផលិត និងការចែកចាយ CSAM ក្រុមកុមារទាំងអស់បានបង្ហាញហានិភ័យគួរឲ្យកត់សម្គាល់ ហើយមិនត្រូវសន្មត់ថា សិស្សានុសិស្សមកពីសាលារៀនរដ្ឋ និងឯកជន មានហានិភ័យតិចជាងឡើយ។ មានសេចក្តីអធិប្បាយប្រាំ ក្នុងចំណោមសេចក្តីអធិប្បាយប្រាំមួយ គឺជាការរៀបរាប់អំពីបទពិសោធន៍របស់អ្នកដទៃទៀត និងត្រូវបានលើកឡើងថា គឺជាអ្វីម្យ៉ាងដែលបានកើតឡើងចំពោះកុមារម្នាក់ផ្សេងទៀតដែល ពួកគេបានស្គាល់។ មានសេចក្តីអធិប្បាយមួយត្រូវបានរៀបរាប់ថា ជាបទពិសោធន៍ផ្ទាល់ខ្លួន។

***រូបភាពផ្លូវភេទដែលបង្កើតឡើងដោយយុវវ័យ***: នៅក្នុងសេចក្តីអធិប្បាយចំនួនបួន មានកុមារផ្តល់សេចក្តីអធិប្បាយអំពីមិត្តប្រុស ឬមិត្តស្រី ដែលរក្សាទុករូបភាពបង្ហាញអំពីការរួមភេទ ឬផ្លូវភេទរបស់មិត្តស្រី ឬមិត្តប្រុស។ នៅក្នុងសេចក្តីអធិប្បាយចំនួនពីរ បានរៀបរាប់ថា មានរូបភាពផ្លូវភេទរបស់កុមារ ត្រូវបានគេបង្ហោះជាសាធារណៈនៅតាម Facebook ដែលជាមធ្យោបាយមួយនៃការសងសឹក បន្ទាប់ពីគូសង្សារទាំងពីរមានទំនាស់ ឬ បែកបាក់គ្នា។ នៅក្នុងសេចក្តីអធិប្បាយមួយទៀត មានកុមារីម្នាក់ត្រូវបានគេលើកឡើងថា បានជួបជាមួយកុមារាម្នាក់ទៀត នៅតាមអ៊ិនធឺណិត និងបានបង្កើតទំនាក់ទំនងមនោសញ្ចេតនាជាមួយគ្នា។ នៅទីបំផុត កុមារីត្រូវបានបញ្ចុះបញ្ចូលឲ្យចែករំលែករូបភាពផ្លូវភេទអំពីខ្លួននាង ជាមួយកុមារម្នាក់ផ្សេងទៀត ដែលកុមារម្នាក់នោះគំរាមអំពីការបង្ហោះរូបភាពទាំងនោះលុះត្រាតែកុមារនោះអាចចំណាយលុយ ៥០.០០០ រៀល (១២.៥ដុល្លារ) ឲ្យកុមារនោះ ទើបរួចខ្លួន។

### ៣.១.៤. ការពិចារណាផ្នែកសេដ្ឋកិច្ចសង្គម

ស្របពេលដែលកុមារបានរៀបរាប់អំពី បទពិសោធន៍ទាក់ទងនឹង OCSE នៅគ្រប់ទីតាំង និងក្នុងចំណោមក្រុមសេដ្ឋកិច្ចទាំងអស់ (មានសាលារៀនរដ្ឋ សាលារៀនឯកជន និងកុមារ មកពីសហគមន៍ងាយរងគ្រោះ) មានភាពងាយរងគ្រោះដោយឡែកមួយចំនួន ដែលហាក់ដូចជាកើតឡើងក្នុង ចំណោមកុមារមកពីសហគមន៍ងាយរងគ្រោះ។ ខណៈដែលក្រុមទាំងនេះ តំណាងឲ្យកុមារភាគច្រើន នៅក្នុងសិក្ខាសាលារៀនសូត្រនេះ ពួកគេហាក់ដូចជាបង្ហាញនូវភាពងាយរងគ្រោះជាច្រើនកាន់តែទូលំទូលាយ ចំពោះ OCSE ហើយបទពិសោធន៍ទាក់ទងនឹង OCSE ត្រូវបានបង្ហាញកាន់តែទូទៅ ក្នុងចំណោមក្រុមទាំងនេះ បើប្រៀបធៀបជាមួយកុមារមកពីសាលារៀនរដ្ឋ និងសាលារៀនឯកជន។ ទោះបីជាយ៉ាងណា គួរកត់សម្គាល់ថា សិក្ខាសាលារៀនសូត្រ មានចេតនាផ្តល់នូវទស្សនៈបែបគុណវិស័យអំពីខ្លឹមសារ និងគំរូនៃហានិភ័យទាក់ទងនឹង OCSE ក្នុងចំណោមកុមារនិងគ្មានផ្លូវធ្វើជាមធ្យោបាយនៃការប៉ាន់ប្រមាណភាពកើតឡើងជាទូទៅឡើយ។ តែទោះជាយ៉ាងណាក៏ដោយ មានយុវវ័យលើសបន្តិចពីម្នាក់ក្នុងចំណោមយុវវ័យបួននាក់ មកពីសហគមន៍ងាយរងគ្រោះ ២៣នាក់ ឬ ២៦% បានរៀបរាប់អំពីបទពិសោធន៍ផ្សេងៗនៃការលួងលោមតាមប្រព័ន្ធអ៊ិនធឺណិត។ បញ្ហានេះ មានភាពទូទៅជាងអ្វីដែលត្រូវបានរកឃើញក្នុងចំណោមកុមារមកពីសាលារៀនរដ្ឋ និងសាលារៀនឯកជន ដែលមានកុមារចំនួនតិចតួច លើសពីម្នាក់ ក្នុងចំណោមកុមារ ០៦ នាក់ បាន

រៀបរាប់ដូចគ្នា។ ការទទួលបានរូបភាពអាសអាភាសពីមនុស្សពេញវ័យ ដែលពួកគេមិនធ្លាប់ស្គាល់ ក៏មានលក្ខណៈទូទៅផងដែរ ដែលត្រូវរៀបរាប់ដោយកុមារម្នាក់ ក្នុងចំណោមកុមារប្រាំនាក់មកពីសហគមន៍ងាយរងគ្រោះ។

បន្ថែមលើហានិភ័យជាក់លាក់តាមប្រព័ន្ធអ៊ិនធឺណិត កុមារមកពីសហគមន៍ងាយរងគ្រោះក៏បានបង្ហាញដែរនូវការយល់ដឹង និងបទពិសោធន៍ ច្រើនជាងអំពីហានិភ័យផ្នែកបរិស្ថាន នៅពេលដែលពួកគេប្រើប្រាស់អ៊ិនធឺណិត។ បញ្ហានេះមានលក្ខណៈគួរឲ្យកត់សម្គាល់ ក្នុងចំណោមកុមារនៅតាមចញ្ចើមថ្នល់ ដែលជាទូទៅ បានប្រើប្រាស់កាហ្វេអ៊ិនធឺណិត ដើម្បីទទួលបានអ៊ិនធឺណិត។ ហានិភ័យផ្នែកបរិស្ថាន មានដូចជា អំពើហិង្សាពីអ្នកប្រើប្រាស់ផ្សេងទៀត ការមើលឃើញរូបភាព ឬវីឌីអូអាសអាភាស និងសកម្មភាពផ្លូវភេទរបស់មនុស្សពេញវ័យផ្សេងទៀត នៅក្នុងហាងកាហ្វេផ្ទាល់ការប្លន់ដោយកុមារផ្សេងទៀត ព្រមទាំងអំពើហិង្សាលើរាងកាយពីម្ចាស់ហាង និងយុវវ័យផ្សេងទៀត។ ស្របពេលដែលបញ្ហានេះមិនជាប់ទាក់ទងជាក់លាក់ជាមួយនឹង OCSE បញ្ហានេះគឺជាការពិភាក្សាជាទូទៅ ក្នុងចំណោមក្រុមបែបនេះ និងបង្ហាញហានិភ័យដែលមានសក្តានុពលខ្លាំងចំពោះកុមារ និងមនុស្សវ័យក្មេង។

ស្របពេលដែលកុមារមកពីសាលារៀនរដ្ឋ និងសាលារៀនឯកជន ផ្តល់សេចក្តីអធិប្បាយទាក់ទងនឹង OCSE ជាក់លាក់ តិចជាងពួកគេបានដឹងច្បាស់អំពីវត្តមាននៃហានិភ័យទាក់ទងនឹង OCSE នៅក្នុងបរិយាកាសអ៊ិនធឺណិតរបស់ពួកគេ រាប់បញ្ចូលទាំងមនុស្សពេញវ័យ ដែលប៉ុនប៉ងលួងលោមកុមារ ដើម្បីរំលោភបំពានផ្លូវភេទ ផ្សាយផ្ទាល់អំពីការកេងប្រវ័ញ្ចផ្លូវភេទ ការគំរាមកំហែង និងហានិភ័យផ្សេងទៀត។ មានកុមារត្រឹមតែ ១០នាក់ប៉ុណ្ណោះ ក្នុងចំណោមកុមារ២៣នាក់ មកពីសាលារៀនរដ្ឋ និងសាលារៀនឯកជន បានផ្តល់សេចក្តីអធិប្បាយជាក់លាក់ទាក់ទងនឹង OCSE អំពីហានិភ័យនៅតាមប្រព័ន្ធអ៊ិនធឺណិត។ ក្នុងចំណោមសេចក្តីអធិប្បាយទាំងដប់នេះ មានសេចក្តីអធិប្បាយចំនួនបួន (១៧% នៃកុមារមកពីសាលារៀនរដ្ឋ ឬ សាលារៀនឯកជនទាំងអស់) បានបង្ហាញបទពិសោធន៍ផ្សេងៗអំពីការលួងលោមតាមប្រព័ន្ធអ៊ិនធឺណិត។ មានសេចក្តីអធិប្បាយបី ក្នុងចំណោមសេចក្តីអធិប្បាយទាំងបួននេះ ជាបទពិសោធន៍ផ្ទាល់ខ្លួន និងពីរទៀត ជាបទពិសោធន៍របស់អ្នកដទៃទៀត។ មានយុវវ័យបីនាក់ (១៣% នៃកុមារមកពីសាលារៀនរដ្ឋ ឬសាលារៀនឯកជន) បានរៀបរាប់អំពីករណីផ្សេងៗនៃការទទួលបានរូបភាព ឬវីឌីអូអាសអាភាសពីមនុស្សពេញវ័យ។ មានកុមារម្នាក់បានបរិយាយអំពី រឿងរ៉ាវមួយរបស់មិត្តរួមថ្នាក់របស់គាត់ ដែលបានទទួលសារពីមនុស្សម្នាក់ ពីប្រទេសផ្សេងទៀត។ បុគ្គលនេះបានសុំព័ត៌មានផ្ទាល់ខ្លួនរបស់កុមារនោះ ប៉ុន្តែកុមារនោះបានបដិសេធ។ ក្រោយមកទៀត បុគ្គលនោះចាប់ផ្តើមផ្ញើរូបភាពអាសអាភាសមកកុមារនោះតាមរយៈ Messenger ដែលវាជាហេតុបង្កឲ្យកុមារនោះប្តូកគណនីរបស់អ្នកប្រើប្រាស់នោះចោល។ មានកុមារពីរនាក់ ក្នុងចំណោមកុមារ១០នាក់ មកពីសាលារៀនរដ្ឋ ឬសាលារៀនឯកជន បានរៀបរាប់អំពីរូបភាពផ្លូវភេទ បង្កើតដោយយុវវ័យ ជាមួយនឹងសេចក្តីអធិប្បាយពីរ អំពីការគំរាមកំហែងតាមរយៈរូបភាពផ្លូវភេទ ដែលទទួលបានពីអ្នកប្រើប្រាស់។

## ៣.១.៨. អ្វីដែលត្រូវការសម្រាប់ធ្វើឲ្យអ៊ិនធឺណិតកាន់តែមានសុវត្ថិភាព

នៅចុងបញ្ចប់នៃសិក្ខាសាលារៀនសូត្រនីមួយៗ សិស្ស និងគ្រូបង្រៀនត្រូវបានស្នើសុំឲ្យវិលត្រលប់ទៅកាន់ក្រុមតូចៗរបស់ខ្លួនវិញ និងគិតគូរអំពី វិធីនានាដែលពួកគេធ្វើឲ្យអ៊ិនធឺណិតមានសុវត្ថិភាព ១០០% សម្រាប់មនុស្សវ័យក្មេងនៅក្នុងប្រទេសកម្ពុជា ប្រសិនបើពួកគេទទួលបានថាមពលដោយគ្មានដែនកំណត់។ ក្រុមគ្រូបង្រៀនចំនួនដប់ក្រុម និងក្រុមកុមារចំនួន៤៧ក្រុម បានបំផុសគំនិតរកដំណោះស្រាយផ្សេងៗ ដែលពួកគេគិតថា នឹងធ្វើឲ្យពិភពអ៊ិនធឺណិតកាន់តែមានសុវត្ថិភាព។ ជារួម គ្រូបង្រៀនមាននិន្នាការពិភាក្សាអំពីអ៊ិនធឺណិត មានលក្ខណៈទំលូទំលាយជាងទាក់ទងនឹងគ្រោះថ្នាក់ ការញៀន និងភាពឯកោពីគ្រួសារ ចំណែកឯកុមារវិញទំនងជាមើលឃើញអ៊ិនធឺណិត ថា

ជាបរិយាកាសវិជ្ជមានច្រើនជាង ដែលរួមមានទាំងគ្រោះថ្នាក់ពិតប្រាកដ ដែលត្រូវដោះស្រាយផងដែរ។ គ្រូបង្រៀនទំនងជាស្នើអំពីការបិទលទ្ធភាពទទួលបានអ៊ិនធឺណិត និងផ្តល់សៀវភៅជំនួសវិញ ចំណែកឯកុមារវិញ មាននិន្នាការឲ្យមានការអនុវត្តន៍អភិក្រមប្លែកៗគ្នាច្រើនជាង មើលឃើញដំណោះស្រាយក្នុងការស្វែងរកការគាំទ្រមតិ ការយល់ដឹង និងការបិទខ្លឹមសារជាក់លាក់ និងសេចក្តីអធិប្បាយ ដែលបង្កហានិភ័យចំពោះសុវត្ថិភាពរបស់ពួកគេ។

### ៣.១.៥.១. ការយល់ឃើញរបស់គ្រូបង្រៀន

គ្រូបង្រៀនមាននិន្នាការមើលឃើញអ៊ិនធឺណិតថា ជាអ្វីម្យ៉ាងដែលមានឥទ្ធិពលអវិជ្ជមានលើកុមារទាក់ទងនឹងការគេចសាលា មករៀនយឺត និងមិនសូវយកចិត្តទុកដាក់ចំពោះការសិក្សារបស់ពួកគេ។ គ្រូបង្រៀនជាច្រើនបានប្រើប្រាស់ភាសាញៀន នៅក្នុងការរៀបរាប់អំពី ការប្រើប្រាស់បណ្តាញទំនាក់ទំនងសង្គម និងឧបករណ៍ចល័តរបស់សិស្សខ្លួន។ ក្រុមគ្រូបង្រៀនមានទិន្នាការចំណាយពេលច្រើនក្នុងការពិចារណាអំពីផលប៉ះពាល់អវិជ្ជមាន ដែលការប្រើប្រាស់អ៊ិនធឺណិត មានចំពោះសុខភាព និងសុខុមាលភាពរបស់សិស្សពួកខ្លួន ដោយលើកឡើងអំពី ការផ្លាស់ប្តូរ អាកប្បកិរិយា និងភាពឯកោ និងកង្វះទំនាក់ទំនងសង្គម ក្នុងចំណោមកុមារដែលបានញៀនហ្គេម និងបណ្តាញទំនាក់ទំនងសង្គម។ ស្របពេលដែលគ្រូបង្រៀនផ្តោតការយកចិត្តទុកដាក់ច្រើនលើអ៊ិនធឺណិត និងឧបករណ៍ ICT កុមារផ្តោតការយកចិត្តទុកដាក់ច្រើនជាង ទៅលើក្តីបារម្ភអំពីគ្រោះថ្នាក់ជាក់លាក់តាមអ៊ិនធឺណិត និងបញ្ហាកេងប្រវ័ញ្ចនៅក្នុងបរិយាកាសអ៊ិនធឺណិតរបស់ពួកគេ។ ស្របពេលដែលគ្រូបង្រៀនលើកឡើងថា ការញៀនអ៊ិនធឺណិត គឺជាក្តីបារម្ភសំខាន់ ពួកគេបានប៉ាន់ស្មានថា កុមារចំណាយពេលប្រើអ៊ិនធឺណិតតិចជាងការប៉ាន់ស្មានរបស់កុមារខ្លួនឯង។

នៅក្នុងការពិចារណាលើដំណោះស្រាយ ដើម្បីធ្វើឲ្យអ៊ិនធឺណិតកាន់តែមានសុវត្ថិភាពចំពោះកុមារ គ្រូបង្រៀនទំនងជាស្នើឡើងនូវវិធីនានានៃការបិទលទ្ធភាពទទួលអ៊ិនធឺណិត និងការផ្តល់សៀវភៅជំនួសវិញ ចំណែកឯកុមារវិញផ្តោតលើអភិក្រមប្លែកៗគ្នា មើលឃើញដំណោះស្រាយនៅក្នុងការបិទខ្លឹមសារជាក់លាក់ និងសេចក្តីអធិប្បាយដែលបង្កហានិភ័យចំពោះសុវត្ថិភាពដល់ពួកគេ។ ដំណោះស្រាយរបស់ពួកគេ រួមមាន៖

**ការយល់ដឹងរបស់អ្នកប្រើប្រាស់:** គ្រូបង្រៀនជឿជាក់ថា កុមារត្រូវទទួលបានការយល់ដឹងអំពីគ្រោះថ្នាក់តាមប្រព័ន្ធអ៊ិនធឺណិត និងការបណ្តុះបណ្តាលអំពីវិធីនានានៃការធ្វើឲ្យមានសុវត្ថិភាព។ ពួកគេលើកឡើងថាការបណ្តុះបណ្តាលនេះ គួររួមមានការបណ្តុះបណ្តាលអំពីរបៀបប្រើប្រាស់ការកំណត់ឯកជនភាព នៅក្នុងបណ្តាញទំនាក់ទំនងសង្គម ដើម្បីធ្វើឲ្យរូបភាព និងព័ត៌មានផ្ទាល់ខ្លួនមានសុវត្ថិភាព វិធីបង្កើត និង ប្រើលេខសម្ងាត់ដែលខ្លាំង ដើម្បីការពារគណនីរបស់អ្នកប្រើប្រាស់ និងរបៀបដែលត្រូវយល់ដឹង ព្រមទាំងចៀសវាងបានពីទង្វើសកម្មភាពរបស់អ្នកប្រម៉ាញ់តាមប្រព័ន្ធអ៊ិនធឺណិត។ ការលើកកម្ពស់ការយល់ដឹងក៏ត្រូវធ្វើឡើងជាមួយគ្រួសារ និងសហគមន៍មូលដ្ឋានផងដែរ រាប់បញ្ចូលទាំងសិស្សានុសិស្ស គ្រូបង្រៀន ឪពុកម្តាយ/អ្នកអាណាព្យាបាល បុគ្គលិកសង្គមកិច្ច គ្រួសារ នគរបាល អាជ្ញាធរមូលដ្ឋាន អង្គការមិនមែនរដ្ឋាភិបាល និងស្ថាប័ននានា ដែលធ្វើការងារជាមួយកុមារ។ ក្រុមទាំងអស់នេះ ត្រូវដឹងអំពីវិធីរាយការណ៍ អំពីបញ្ហាការពារកុមារ តាមរយៈបណ្តាញទូរស័ព្ទជំនួយនានាដូចជា បណ្តាញសុវត្ថិភាពកុមារ បណ្តាញទូរស័ព្ទជំនួយកុមារកម្ពុជា បណ្តាញរាយការណ៍បន្ទាន់តាមប្រព័ន្ធអ៊ិនធឺណិតរបស់អង្គការ APLE។

**ការចូលរួម និងការគ្រប់គ្រងកាន់តែខ្លាំងពីឪពុកម្តាយ:** គ្រូបង្រៀនបង្ហាញថា ឪពុកម្តាយត្រូវដើរតួនាទីសកម្មថែមទៀត ក្នុងការពិនិត្យតាមដានលើការប្រើប្រាស់ឧបករណ៍ភ្ជាប់អ៊ិនធឺណិតរបស់កូនៗពួកគេ។ ឪពុកម្តាយត្រូវដឹងអំពីវិធីចូលរួមក្នុង "របៀបធ្វើឲ្យការស្វែងរកមានសុវត្ថិភាព" នៅក្នុង YouTube និងកម្មវិធីស្រាវជ្រាវក្នុងអ៊ិនធឺណិតនានា ហើយឪពុកម្តាយត្រូវកំណត់ព្រំដែន និងពេលវេលាចំពោះការប្រើប្រាស់អ៊ិនធឺណិតរបស់កុមារ ដើម្បីកុមារមាន

៥១

ពេលវេលាកាន់តែច្រើនសម្រាប់ការសិក្សារបស់ពួកគេ។ គ្រូបង្រៀនជឿជាក់ថា អ៊ិនធឺណិតមានផលប៉ះពាល់អវិជ្ជមានលើទំនាក់ទំនងសង្គមរបស់កុមារ ដោយលើកឡើងអំពីការមិនគោរពមនុស្សពេញវ័យ និងការប្រើប្រាស់ភាសាមិនល្អជាដើម។ គ្រូបង្រៀនម្នាក់នៅខេត្តសៀមរាប បានលើកឡើងថា "អ្នកលេងហ្គេមមួយចំនួន បាននិយាយសំដីមិនល្អ (ទាក់ទងនឹងផ្លូវភេទ) នៅក្នុងវីឌីអូ"។ មានគ្រូបង្រៀនម្នាក់ទៀត នៅខេត្តព្រះសីហនុ បានថ្លែងថា "កុមារបានញៀននឹង Tik Tok (ហើយនិង) មិនបានអើពើជាមួយមនុស្សពេញវ័យ ព្រមទាំងប្រើប្រាស់ពាក្យពេជន៍មិនល្អដូចដែលពួកគេបានប្រើប្រាស់នៅលើ(កម្មវិធី)"។ បន្ថែមលើនេះ ពួកគេលើកឡើងថា មិនគួរអនុញ្ញាតិឲ្យកុមារអាយុក្រោម ១៧ ឆ្នាំ មានឧបករណ៍ភ្ជាប់អ៊ិនធឺណិតផ្ទាល់ខ្លួនឡើយ។

**គោលនយោបាយទាក់ទងនឹងអ៊ិនធឺណិតនៅសាលារៀន**: គ្រូបង្រៀនជឿជាក់ថា កុមារមានភាពងាយស្រួលពេកក្នុងការទទួលបានអ៊ិនធឺណិត ហើយអ៊ិនធឺណិតមានផលប៉ះពាល់អវិជ្ជមាន លើការសិក្សារបស់ពួកគេ។ ជាពិសេសគ្រូបង្រៀនលើកឡើងអំពីបញ្ហានានា ជាមួយនឹងការប្រើប្រាស់ទូរស័ព្ទដៃវៃឆ្លាតក្នុងថ្នាក់រៀន ដែលធ្វើឲ្យកុមារមិនចាប់អារម្មណ៍នឹងកម្មវិធីសិក្សា។ បន្ថែមលើនេះ គ្រូបង្រៀនលើកឡើងនូវក្តីបារម្ភចំពោះការមានហាងអ៊ិនធឺណិតនៅជិតសាលារៀន ដោយបញ្ជាក់ថា សិស្សានុសិស្សនឹងដើរទៅហាងនៅជិតៗនោះ ហើយនិងមិនបានចូលរៀន។ គ្រូបង្រៀនស្នើថា ក្រសួងអប់រំយុវជន និងកីឡា គួរចេញសារណែនាំមួយ ដើម្បីដាក់កំហិតចំពោះការប្រើប្រាស់អ៊ិនធឺណិត នៅក្នុងសាលារៀន និងការហាមបើកហាងអ៊ិនធឺណិតនៅក្នុងរយៈចម្ងាយ៥០០ម៉ែត្រ ពីសាលារៀន។ បន្ថែមពីនេះ គ្រូបង្រៀនស្នើឲ្យមានការដាក់កំហិតអាយុ សម្រាប់ការចូលហាងអ៊ិនធឺណិត ដើម្បីទប់ស្កាត់កុមារពីការលេងហ្គេម និងការប្រើប្រាស់អ៊ិនធឺណិត ដោយគ្មានការគ្រប់គ្រងត្រឹមត្រូវ។

**បណ្ណាល័យជាជម្រើសជំនួស**: ទាក់ទងនឹងឧបករណ៍ ICT ក្រុមគ្រូបង្រៀនមួយចំនួនស្នើថា គួរផ្តល់បណ្ណាល័យសាធារណៈ និងបណ្ណាល័យតាមសាលារៀន ដើម្បីលើកទឹកចិត្តកុមារជាសិស្សានុសិស្ស ឲ្យសិក្សាតាមរយៈការអានសៀវភៅ ដើម្បីឲ្យកុមារចំណាយពេលប្រើអ៊ិនធឺណិតកាន់តែតិច។

### ៣.១.៥.២. ការយល់ឃើញរបស់សិស្ស

កុមារអាចចូលរួមបានច្រើនជាង ជាមួយនឹងប្រធានបទស្តីពីហានិភ័យ និងគ្រោះថ្នាក់តាមប្រព័ន្ធអ៊ិនធឺណិតជាក់លាក់ និងអាចផ្តល់ដំណោះស្រាយប្លែកៗគ្នាចំពោះបញ្ហា OCSE បើប្រៀបធៀបនឹងគ្រូបង្រៀន។ ជាពិសេសកុមារអាចពិភាក្សាអំពីហានិភ័យដែលមានសក្តានុពលជាក់លាក់ ហើយដែលពួកគេប្រឈមមុខពីមនុស្សពេញវ័យដែលផ្ញើខ្លឹមសារអាសអាភាស/ផ្លូវភេទ ការលួងលោម ការចំអក តាមប្រព័ន្ធបច្ចេកវិទ្យាពីកុមារមានវ័យស្របាលគ្នានឹងពួកគេ ការគំរាមកំហែងតាមអ៊ិនធឺណិត និងឥទ្ធិពលនៃខ្លឹមសារសម្រាប់មនុស្សពេញវ័យលើកុមារ។ កុមារក៏លើកឡើងនូវក្តីបារម្ភទាក់ទងនឹងឯកជនភាពតាមប្រព័ន្ធអ៊ិនធឺណិត និងការចែករំលែកទិន្នន័យផ្ទាល់ខ្លួនរបស់ពួកគេជាមួយជនចម្លែក ជាពិសេសគឺតាមបរិយាកាសហ្គេមអ៊ិនធឺណិត។ កុមារបង្ហាញនូវការយល់ដឹងទូលំទូលាយ និងប្លែកៗគ្នា អំពីឧបករណ៍អ៊ិនធឺណិត ក្រុមហ៊ុនផ្តល់សេវាកម្មអ៊ិនធឺណែត កម្មវិធីនានា និងកម្មវិធីអ៊ិនធឺណិត ច្រើនជាងគ្រូបង្រៀនរបស់ពួកគេ។ កុមារបង្ហាញនូវការយល់ដឹងជ្រៅជាង អំពីសុវត្ថិភាពតាមអ៊ិនធឺណិត រាប់បញ្ចូលទាំងការដឹងអំពីវិធីប្លុកមិត្តភក្តិ និងលុប ឬប្លុកខ្លឹមសារជាក់លាក់។

ស្របពេលដែលគ្រូបង្រៀនមានទិន្នាការមើលឃើញថា អ៊ិនធឺណិត និងឧបករណ៍ ICT មិនបានបង្កផលល្អសម្រាប់សាលារៀន និងជាការប្រកួតប្រជែងសម្រាប់ការយកចិត្តទុកដាក់របស់សិស្សានុសិស្ស កុមារបង្ហាញនូវការប្រើប្រាស់អ៊ិនធឺណិតជាប្រចាំ ដើម្បីកិច្ចការសាលា ការស្រាវ ជ្រាវ និងទម្រង់ផ្សេងទៀតនៃការផលិត រាប់បញ្ចូលទាំង

ការរៀនសូត្រអំពីជំនាញថ្មីៗ ការស្រាវជ្រាវផ្ទាល់ខ្លួន និងការដាក់ពាក្យសុំអាហារូបករណ៍។ ផ្ទុយទៅវិញ គ្រូបង្រៀនមិនបានបង្ហាញខ្លាំងអំពីសមត្ថភាពវិជ្ជមាននៃអ៊ិនធឺណិត ឬបង្ហាញថាការប្រើប្រាស់អ៊ិនធឺណិតសម្រាប់ផលិតភាព ឬការអភិវឌ្ឍន៍ខ្លួនឡើយ ក្រៅពីការប្រើប្រាស់បណ្តាញទំនាក់ទំនងសង្គម ដើម្បីអានព័ត៌មាន និងស្វែងរកព័ត៌មានជាមូលដ្ឋាន។

## ដំណោះស្រាយដែលអាចកើតមាន

**ការយល់ដឹងរបស់អ្នកប្រើប្រាស់:** កុមារគូសបញ្ជាក់នូវសារៈសំខាន់នៃកុមារផ្សេងទៀត និងសមាជិកគ្រួសាររបស់ពួកគេ ក្នុងការរៀនសូត្រអំពីបរិយាកាសអ៊ិនធឺណិតរបស់កុមារ។ ពួកគេបង្ហាញនូវតម្រូវការដាក់លាក់ចំពោះការលើកកម្ពស់ការយល់ដឹង អំពីការប្រើប្រាស់អ៊ិនធឺណិត និងសុវត្ថិភាពនៅក្នុងសហគមន៍របស់ពួកគេ រាប់បញ្ចូលទាំងអ្នកដែលនៅក្នុងចំណោមសមាជិកគ្រួសារ អ្នកជិតខាង និងកុមារផ្សេងទៀត និងតម្រូវការការបណ្តុះបណ្តាលអំពីកម្មវិធី និងហ្គេមខុសៗគ្នា កន្លែងដែលមានគ្រោះថ្នាក់ និង វិធីធ្វើឲ្យកុមារមានសុវត្ថិភាពតាមអ៊ិនធឺណិត។ ជាពិសេសកុមាររៀបរាប់អំពីតម្រូវការរបស់កុមារ និងគ្រួសារ ក្នុងការយល់ដឹងអំពីវិធីការពារកាន់តែប្រសើរ ចំពោះព័ត៌មានផ្ទាល់ខ្លួនរបស់ពួកគេតាមអ៊ិនធឺណិត របៀបបង្កើតលេខសម្ងាត់ដែលខ្លាំង និងការប្រើប្រាស់ការកំណត់ឯកជនភាពនៅលើកម្មវិធីកាន់តែល្អ។ កុមារស្នើឡើងថា ការបង្កើតយុទ្ធនាការផ្តល់ការយល់ដឹងជាសាធារណៈតាមទូរទស្សន៍ និងនៅក្នុងសាលារៀន គឺចាំបាច់សម្រាប់ការបញ្ជូនព័ត៌មានអំពីគ្រោះថ្នាក់ដែលអាចកើតមាននៅតាមអ៊ិនធឺណិត និងវិធីដែលមនុស្សអាចការពារខ្លួន ពីអ្នកលួចជ្រៀតចូលដោយគ្មានការអនុញ្ញាត (Hacker) និងអ្នកប្រម៉ាញ់ផ្សេងទៀត ខណៈដែលនៅប្រើប្រាស់អ៊ិនធឺណិត។

**ការស្វែងរកការគាំទ្រមតិ និងការអប់រំលើកកម្ពស់ការយល់ដឹងអំពីសុវត្ថិភាពតាមប្រព័ន្ធអ៊ិនធឺណិត:** កុមារក៏សង្កត់ធ្ងន់លើសារៈសំខាន់នៃការយល់ដឹងអំពី វិធីចៀសវាងជនចម្លែក នៅតាមប្រព័ន្ធអ៊ិនធឺណិតផងដែរ។ កុមារកត់សម្គាល់ថា កុមារផ្សេងទៀតត្រូវការការយល់ដឹងកាន់តែល្អអំពីសុវត្ថិភាពតាមប្រព័ន្ធអ៊ិនធឺណិត រាប់បញ្ចូលទាំងសារនានាអំពីការមិនបញ្ចូលព័ត៌មានទំនាក់ទំនង ឬទទួលសំណើសុំធ្វើមិត្តភក្តិ ពីមនុស្សដែលពួកគេមិនធ្លាប់ស្គាល់ និងមិនឆ្លើយតបនឹងសារនានា ការបង្ហោះ ឬរូបភាពនានា ដែលធ្វើដោយជនណាម្នាក់ដែលពួកគេមិនស្គាល់។ កុមារសង្កត់ធ្ងន់លើតម្រូវការឲ្យកុមារផ្សេងទៀតយល់អំពីសារៈសំខាន់នៃការមិនទុកចិត្តមនុស្ស ដែលពួកគេជួបនៅតាមអ៊ិនធឺណិត សូម្បីតែពួកគេមានមិត្តភក្តិជាមួយគ្នាតាម Facebook ហើយក៏ដោយ។ ពួកគេលើកឡើងនូវសារៈសំខាន់នៃការពិនិត្យព័ត៌មានប្រូហ្វាលយ៉ាងប្រុងប្រយ័ត្ន ដើម្បីឲ្យប្រាកដច្បាស់ថា គណនីនោះពិតជារបស់ម្ចាស់រូប និងមិនមែនជាជនបន្លំខ្លួន។ បន្ថែមលើនេះ កុមារសង្កត់ធ្ងន់ថា កុមារផ្សេងទៀតត្រូវការយល់អំពីគ្រោះថ្នាក់នៃការបង្ហោះ "រូបថតដែលធ្វើឲ្យស្រើបស្រាល" និងជៀសវាងគេហទំព័រ ឬកម្មវិធីផ្សាយផ្ទាល់ (វីឌីអូ) ព្រមទាំងគេហទំព័រ ដែលមានវីឌីអូ និងរូបភាពអាសអាភាស។

**សេចក្តីរាយការណ៍អំពី ខ្លឹមសារ/ស្ថានភាព ដែលប្រកបដោយគ្រោះថ្នាក់:** កុមារ និងឪពុកម្តាយរបស់ពួកគេគួរដឹងនូវវិធីរាយការណ៍អំពីខ្លឹមសារដែលមានហានិភ័យ និងការរំលោភបំពានទៅកាន់កម្មវិធីបណ្តាញទំនាក់ទំនងសង្គម ដើម្បីឲ្យមានវិធានការសមស្របប្រឆាំងនឹងគណនី ដែលប្រើប្រាស់បណ្តាញទំនាក់ទំនងសង្គមក្នុងផ្លូវខុស។ កុមារបានស្នើឲ្យ ក្រុមហ៊ុនបណ្តាញទំនាក់ទំនងសង្គម និងក្រុមហ៊ុនហ្គេម (ជាពិសេស Facebook) គួរមានសកម្មភាពសកម្មជាងនេះ ក្នុងការពិនិត្យមើលអ្នកប្រើប្រាស់ និងឆ្លើយតបចំពោះខ្លឹមសារដែលត្រូវបានរាយការណ៍ ដើម្បីឲ្យប្រាកដថា កុមារមានសុវត្ថិភាព នៅពេលដែលពួកគេប្រើប្រាស់អ៊ិនធឺណិត។ បន្ថែមលើនេះ កុមារបានលើកឡើងនូវសារៈសំខាន់នៃការយល់ដឹងអំពីធនធានក្នុងមូលដ្ឋាន ដើម្បីរាយការណ៍ អំពីការរំលោភបំពាន ដូចជាបណ្តាញ

ទូរស័ព្ទជំនួយកុមារកម្ពុជា (លេខ១២៨០)។ ពួកគេបង្ហាញថា សេវានានាបែបនេះមានសារៈសំខាន់ ដោយសារសេវាទាំងនេះផ្តល់ដោយបុគ្គលិកសង្គម ដែលអាចជឿទុកចិត្តបាន ក្នុងកិច្ចការពារឯកជនភាពរបស់ពួកគេ និងរកដំណោះស្រាយតាមរយៈការពិភាក្សានានា ជាមួយអ្នកដែលអាចជួយបាន។

**ការបន្ធូរបន្ថយហានិភ័យខាងបរិយាកាស:** កុមារក៏ទទួលស្គាល់ផងដែរនូវហានិភ័យ ដែលគួរឲ្យកត់សម្គាល់ខាងបរិយាកាសពាក់ព័ន្ធនឹងការទទួលបានអ៊ិនធឺណិត តាមរយៈកាហ្វេអ៊ិនធឺណិតសាធារណៈ និងបានលើកឡើងថា កាហ្វេអ៊ិនធឺណិតសាធារណៈ មិនគួរនៅជិតសាលារៀនឡើយ។ ស្របពេលដែលគ្រូបង្រៀន ហាក់ដូចជាបានលើកឡើងអំពី បញ្ហានានាពាក់ព័ន្ធនឹងកុមារគេចសាលារៀន ដើម្បីចូលទៅក្នុងកាហ្វេអ៊ិនធឺណិត កុមារបានទទួលស្គាល់ថា មិនត្រឹមតែហានិភ័យនេះប៉ុណ្ណោះទេ គឺមានថែមទាំងហានិភ័យដែលគួរឲ្យកត់សម្គាល់ខាងបរិយាកាសនៅក្នុងកាហ្វេអ៊ិនធឺណិត មានដូចជាអំពើហិង្សា និងការជួបជាមួយនឹងមនុស្សពេញវ័យ ដែលមើលខ្លឹមសារអាសអាភាសតាមកុំព្យូទ័រសាធារណៈ និងមានករណីខ្លះ គេបានធ្វើសកម្មភាពមិនសមរម្យនៅកន្លែងដែលមានកុមារនៅក្បែរៗនោះផងដែរ។

### ៣.១.៥.៣. ការវាយតម្លៃទស្សនៈ

សិក្ខាសាលារៀនសូត្រនេះ បានបង្ហាញឲ្យឃើញនូវការបែងចែកយ៉ាងខ្លាំង តាមជំនាន់ រវាងគ្រូបង្រៀន និងសិស្ស ដែលការបែងចែកនេះ មិនត្រឹមតែទាក់ទងនឹងសមត្ថភាពរបស់ពួកគេ ក្នុងប្រើប្រាស់អ៊ិនធឺណិតប៉ុណ្ណោះនោះទេ គឺមានថែមទាំងទាក់ទងនឹងការយល់ឃើញរបស់ពួកគេ អំពីពិភពលោកនេះ និងហានិភ័យ ដែលពិភពលោកនេះចូលរួមបង្កឲ្យមាននោះ ផងដែរ។ ទន្ទឹមគ្នានឹងពេលដែលគ្រូបង្រៀន ហាក់ដូចជាបាននិយាយថា អ៊ិនធឺណិតគឺជាកម្មវិធី ឬ ឧបករណ៍ បង្កការបែកអារម្មណ៍ ពីជីវិតពិតនោះ យុវវ័យបានពិភាក្សាគ្នាថា បរិយាកាសអ៊ិនធឺណិតរបស់ពួកខ្លួនគឺជាពិភពអ៊ិនធឺណិតផ្ទាល់របស់ពួកគេ។ ភាពចន្លោះប្រហោងក្នុងការយល់ឃើញបែបនេះ ហាក់ដូចជាមានភាពពាក់ព័ន្ធទៅនឹងប្រភេទនៃហានិភ័យ ដែលក្រុមនីមួយៗបានយល់ឃើញ។ ស្របពេលដែលគ្រូបង្រៀន ពិតជាបានទទួលស្គាល់នូវហានិភ័យជាមូលដ្ឋានមួយចំនួន ដូចជា គ្រោងការទុច្ចរិតតាមអ៊ិនធឺណិត និងអ៊ិនធឺណិតជាការរំខានដល់ការសិក្សារបស់សិស្សនោះ ពួកគេមិនបានបង្ហាញនូវការយល់ដឹងខ្លាំង អំពីប្រភេទកម្មវិធី ដែលកុមារកំពុងប្រើប្រាស់ ឬកន្លែងជាក់លាក់ ដែលពួកគេជួបប្រទះហានិភ័យតាមប្រព័ន្ធអ៊ិនធឺណិតឡើយ។ ស្របពេលដែលគ្រូបង្រៀន ហាក់ដូចជាបានដឹងអំពីហានិភ័យមានកំណត់មួយចំនួន(ដូចជា រូបភាពឬវីឌីអូអាសអាភាស និងគ្រោងការទុច្ចរិតតាមអ៊ិនធឺណិត) តាមរយៈបណ្តាញទំនាក់ទំនងសង្គម កុមារបានកំណត់វិស័យនៃហានិភ័យដែលមានភាពប្លែកៗគ្នា ច្រើនជាង មានដូចជា កម្មវិធីហ្គេម ដែលត្រូវបានប្រើប្រាស់ជាកន្លែងសម្រាប់ការជួបជុំកុមារ និងសេចក្តីអធិប្បាយលម្អិតអំពីការលួងលោមតាមកម្មវិធីបណ្តាញ ទំនាក់ទំនងសង្គម ព្រមទាំងមានការកេងប្រវ័ញ្ចផ្លូវភេទ ដែលផ្សាយផ្ទាល់ ផងដែរ។

កុមារ និងគ្រូបង្រៀនបានស្នើឡើងនូវដំណោះស្រាយស្រដៀងគ្នា ដូចជាការយល់ដឹងរបស់អ្នកប្រើប្រាស់ ការគ្រប់គ្រងពេលវេលាប្រើប្រាស់អ៊ិនធឺណិត ការមានបណ្ណាល័យ និងតម្រូវការសេសម្រាប់រាយការណ៍ និងការដកយកខ្លឹមសារនានាមួយចំនួនចេញ។ ទោះបីជាយ៉ាងណាកុមារបានបង្ហាញទស្សនៈប្លែកៗគ្នា ច្រើនជាងអំពីហានិភ័យ និងបានស្នើឡើងនូវគោលនយោបាយអនុវត្តជាក់ស្តែងនៃការលើកទឹកចិត្តកុមារ ឲ្យរាយការណ៍អំពីខ្លឹមសារទាក់ទងនឹង OCSE និងធ្វើការងារជាមួយកម្មវិធីបណ្តាញទំនាក់ទំនងសង្គម ដើម្បីផ្តល់ការឆ្លើយតបឲ្យបានគ្រប់គ្រាន់ចំពោះសេចក្តីរាយការណ៍ ទាក់ទងនឹងកិច្ចការពារកុមារ។ បន្ថែមលើនេះ ដំណោះស្រាយពីគ្រូបង្រៀន ទំនងជាផ្តោតលើវិធានការនានាដែលចាំបាច់ត្រូវធ្វើនៅក្នុងពិភពក្រៅអ៊ិនធឺណិត ស្របពេលដែលកុមារទំនងជាផ្តោតលើវិធានការ ដែលចាំបាច់ត្រូវធ្វើនៅក្នុងបរិយាកាសអ៊ិនធឺណិតរបស់ពួកគេ។ គ្រូបង្រៀនមើលឃើញដំណោះស្រាយនៅក្នុងការបង្កើនការអនុវត្តច្បាប់

និងការទប់ស្កាត់កុមារពីការប្រើប្រាស់អ៊ិនធឺណិត និងលើកឡើងនូវតម្រូវការឲ្យមានសេចក្តីរាយការណ៍កាន់តែខ្លាំង និងការដកចេញខ្លឹមសារនានាដែលមានលក្ខណៈរំលោភបំពានចេញ ចំណែកឯកុមារវិញទំនងជាបានលើកឡើងច្រើនជាង នូវតម្រូវការឲ្យមានការយល់ដឹងរបស់អ្នកប្រើប្រាស់ ការរាយការណ៍ ការពិនិត្យតាមដាន និងកិច្ចសហការជាមួយឪពុកម្តាយ និងគ្រូបង្រៀន ដើម្បីឲ្យកុមារមានសុវត្ថិភាព។ កុមារហាក់ដូចជាផ្តល់តម្លៃលើអន្តរទំនាក់ទំនងវិជ្ជមាននៅទូទាំងពិភពលោក ដែលអាចមាននៅក្នុងបរិយាកាសអ៊ិនធឺណិតរបស់ពួកគេ ប៉ុន្តែក៏ទទួលស្គាល់នូវតម្រូវការបន្ទាន់ក្នុងការបន្ធូរបន្ថយហានិភ័យសម្រាប់ពួកគេ និងកុមារផ្សេងទៀត តាមរយៈការអប់រំកាន់តែល្អអំពីអ៊ិនធឺណិត ការស្វែងរកការគាំទ្រមតិ និងការឆ្លើយតបកាន់តែប្រសើរចំពោះសេចក្តីរាយការណ៍ទាក់ទងនឹងកិច្ចការពារកុមារ និងយន្តការឆ្លើយតបផងដែរ។

# ចំណុចទី៤: យន្តការជាតិ និងអន្តរជាតិ សម្រាប់រាយការណ៍អំពី OCSE

## ៤.១. អង្គភាពជំនាញរបស់រាជរដ្ឋាភិបាល

រាជរដ្ឋាភិបាល បានបង្កើតគណៈកម្មាធិការជាតិប្រឆាំងអំពើជួញដូរមនុស្ស(គ.ជ.ប.ជ) ហើយបានដំណើរការយ៉ាងសកម្ម ដើម្បីចូលរួមបង្ការ ទប់ស្កាត់ និងឆ្លើយតបនឹងការរំលោភបំពានពាក់ព័ន្ធនឹងការជួញដូរមនុស្ស និងការកេងប្រវ័ញ្ចកុមារ ដែលមានសមាសភាពមកពីអន្តរក្រសួង និងស្ថាប័នជាច្រើន ជាមួយគ្នានេះដែរ មាន គ.ជ.ប.ខ នៅទូទាំងរាជធានី ខេត្ត។

ជាមួយគ្នានេះដែរ ក្រសួងមហាផ្ទៃបានបង្កើត និងជំរុញឲ្យដំណើរការនូវនាយកដ្ឋានជំនាញ២ចំណុះឲ្យអគ្គស្នងការដ្ឋាននគរបាលជាតិ រួមមាន នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន និងនាយកដ្ឋានប្រឆាំងបទល្មើសបច្ចេកវិទ្យា ដែលបានដើរតួរយ៉ាងសំខាន់ក្នុងកិច្ចសហការ អន្តរាគមន៍ និងឆ្លើយតបទាន់ពេលវេលា និងដោយផ្ទាល់ជាមួយអង្គការជាតិ និងអន្តរជាតិ ដើម្បីដោះស្រាយបញ្ហាពាក់ព័ន្ធនឹងការកេងប្រវ័ញ្ចផ្លូវភេទកុមារតាមប្រព័ន្ធអនឡាញ។ ទន្ទឹមនឹងនេះ និយត័ករទូរគមនាគមន៍នៃក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ក៏ជាយន្តការមួយដែលមានសមត្ថកិច្ចក្នុងការគ្រប់គ្រងក្រុមហ៊ុនផ្តល់សេវាអ៊ិនធឺណិត និងអន្តរាគមន៍ក្នុងក្របខណ្ឌបច្ចេកទេសនៅពេលដែលមានសំណើសុំឲ្យមានការណែនាំ ទប់ស្កាត់ និងឈានទៅដល់ការបិទគេហទំព័រដែលមានមាតិកាប៉ះពាល់ដល់ការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ។

## ៤.២. មជ្ឈមណ្ឌលជាតិការពារកុមារបាត់ខ្លួន និងរងគ្រោះដោយការកេងប្រវ័ញ្ច (NCMEC)

មជ្ឈមណ្ឌលជាតិការពារកុមារបាត់ខ្លួន និងរងគ្រោះដោយការកេងប្រវ័ញ្ច (NCMEC) គឺជាយន្តការរាយការណ៍ពីកុមារបាត់ខ្លួន និងកេងប្រវ័ញ្ចដែលមានទីតាំងនៅសហរដ្ឋអាមេរិក ហើយយន្តការនេះមានបណ្តាញនៅតាមបណ្តាប្រទេសជាច្រើននៅលើពិភពលោក ក្នុងនោះក៏មានប្រទេសកម្ពុជាផងដែរ។

នៅសហរដ្ឋអាមេរិក គ្រប់ក្រុមហ៊ុនផ្តល់សេវាកម្មអេឡិចត្រូនិកទាំងអស់(ESP) ចាំបាច់ត្រូវបញ្ជូនករណីស្តីពីកិច្ចការពារកុមារទៅកាន់បណ្តាញរាយការណ៍តាមប្រព័ន្ធអ៊ីនធឺណិត ដែលប្រតិបត្តិការដោយមជ្ឈមណ្ឌលជាតិការពារកុមារបាត់ខ្លួន និងរងគ្រោះដោយការកេងប្រវ័ញ្ច (NCMEC)។ អាណត្តិនេះបានរួមបញ្ចូលនូវក្រុមហ៊ុនដែលផ្តល់សេវាកម្មអ៊ីនធឺណិត និងក្រុមហ៊ុនបច្ចេកវិទ្យាទាំងអស់ ដែលមានមូលដ្ឋាននៅសហរដ្ឋអាមេរិក (Facebook, Microsoft, Google, Twitter) និងក្រុមហ៊ុនបរទេស ដែលប្រើប្រាស់ Server មានមូលដ្ឋាននៅសហរដ្ឋអាមេរិក ដើម្បីរក្សាទុកទិន្នន័យរបស់ពួកគេ។ ដោយសារក្រុមហ៊ុនបច្ចេកវិទ្យាអាមេរិក ផ្តល់ហេដ្ឋារចនាសម្ព័ន្ធយ៉ាងធំសម្រាប់អ៊ីនធឺណិតនៅក្នុងពិភពលោក NCMEC ទទួលបានរបាយការណ៍ជាច្រើនអំពី OCSE (ជាពិសេស CSAM) និងដើរតួនាទីជាការិយាល័យកណ្តាលសម្រាប់របាយការណ៍ទាំងនេះ ដោយផ្តល់ការវិភាគជាមូលដ្ឋាន ការប្រមូលផ្តុំព័ត៌មានស៊ើបអង្កេតសំខាន់ៗ និងការបញ្ជូនរបាយការណ៍ ទៅកាន់ទីភ្នាក់ងារអនុវត្តច្បាប់នៅជុំវិញពិភពលោក។

នៅពេលអ្នកប្រើប្រាស់រាយការណ៍អំពីសម្ភារ ទាក់ទងនឹងការរំលោភបំពានផ្លូវភេទតាមកម្មវិធីអ៊ីនធឺណិត ដូចជា Facebook សម្ភារនោះត្រូវពិនិត្យមើលដោយកម្មវិធីនោះ និងដកចេញ/រាយការណ៍ ប្រសិនបើរកឃើញថាបានរំលោភបទដ្ឋានការពារកុមារ របស់កម្មវិធី។ ប្រសិនបើរូបភាពនេះ បង្ហាញអំពីការរំលោភបំពាន ឬការកេងប្រវ័ញ្ចកុមាររូបភាពនោះ គណនីរបស់អ្នកប្រើប្រាស់និងអាសយដ្ឋាន IP នឹងត្រូវកត់ត្រាទុកជាមួយនឹងព័ត៌មានសំខាន់ផ្សេងៗទៀត និងត្រូវបានបញ្ចូលទៅក្នុងរបាយការណ៍ ដែលនឹងត្រូវបញ្ជូនទៅកាន់ NCMEC។ អាសយដ្ឋាន IP របស់អ្នកប្រើប្រាស់ ផ្តល់ព័ត៌មានអំពីទីតាំងភូមិសាស្ត្រដែលជាដើមកំណើតនៃ CSAM ព្រមទាំងក្រុមហ៊ុនផ្តល់សេវាកម្មអ៊ីនធឺណិតក្នុងប្រទេស ដែលសម្ភារទាំងនេះបានឆ្លងកាត់ នៅពេលសម្ភារនោះត្រូវបានបង្ហោះចេញពី ឬទាញយកដោយឧបករណ៍ ICT របស់បុគ្គលដែលអាចជាជនខិលខូច។

នៅប្រទេសកម្ពុជា របាយការណ៍ស្តីពី CSAM ពាក់ព័ន្ធនឹងកម្ពុជា ត្រូវបានបញ្ជូនដោយស្វ័យប្រវត្តិទៅកាន់ភ្នាក់ងារស៊ើបអង្កេតសន្តិសុខមាតុភូមិ (HSI) របស់សហរដ្ឋអាមេរិក ដែលមានទីតាំងនៅក្នុងស្ថានទូតសហរដ្ឋអាមេរិកក្នុងរាជធានីភ្នំពេញ។ បន្ទាប់មក ភ្នាក់ងារ HSI នៅក្នុងរាជធានីភ្នំពេញ ទទួលខុសត្រូវលើការទាញយករបាយការណ៍ទាំងនេះ និងកំណត់ថា តើករណីណាដែលមានលក្ខណៈបន្ទាន់បំផុត និងអាចចាត់វិធានការបាននៅថ្នាក់ប្រទេស។ ក្នុងរយៈពេលប្រាំមួយឆ្នាំកន្លងទៅ មានការកើនឡើងជាលំដាប់នូវចំនួនរបាយការណ៍ ទាំងនេះទៅកាន់ HSI នៅរាជធានីភ្នំពេញ ជាពិសេសគឺនៅឆ្នាំ២០១៨។ ស្របពេលដែលមិនទាន់មានចំនួនពេញលេញសម្រាប់ឆ្នាំ២០១៨ នៅឡើយ សេចក្តីរាយការណ៍អំពី CSAM សម្រាប់ប្រទេសកម្ពុជា ចាប់ពីខែមករា ដល់ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៩ បានបង្ហាញនូវការកើនឡើងចំនួន៤៩០% ពីឆ្នាំ២០១៧។ មានន័យថា ក្នុងកំឡុងពេល១១ខែ ដើមឆ្នាំ២០១៩ NCMEC បានបញ្ជូនរបាយការណ៍ករណី CSAM ចំនួន១២៣.៨៩៦ ទៅកាន់ HSI នៅរាជធានីភ្នំពេញ ច្រើនជាងចំនួនរបាយការណ៍ដែលត្រូវបញ្ជូនក្នុងកំឡុងពេល៦ឆ្នាំ បូកបញ្ចូលគ្នាទៀត (សូមមើលតារាងខាងក្រោម)។

| ឆ្នាំ | របាយការណ៍ VPN | របាយការណ៍ជាព័ត៌មាន | សរុប |
|---|---|---|---|
| ២០១៣ | ៣៧០ | មិនពាក់ព័ន្ធ | ៣៧០ |
| ២០១៤ | ៤.៧៥៩ | មិនពាក់ព័ន្ធ | ៤.៧៥៩ |
| ២០១៥ | ៥.២៩២ | ២៤.១៣៣ | ២៩.៤២៥ |

| | | | |
|---|---|---|---|
| ២០១៦ | ៩.២២១ | ២១.០៨៣ | ៣០.៣០៤ |
| ២០១៧ | ៤.៨៣២ | ២០.៥០០ | ២៥.៣៣២ |
| ២០១៨* | ៣៥.៩១៣ | ៨៧.៩៨៣ | ១២៣.៨៩៦ |

*ឆ្នាំ ២០១៨ – ត្រឹមថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៨

មិនមែនគ្រប់រូបភាព ដែលត្រូវបានបញ្ជូនទៅកាន់ HSI អាចបញ្ជាក់ថាជា CSAM ឡើយ ប៉ុន្តែអាចរួមមានភាពអាក្រាតរបស់កុមារ ទម្រង់ផ្សេងទៀតនៃអំពើហិង្សាលើកុមារ ឬរូបភាពមានសញ្ញាសម្គាល់ផ្សេងទៀត ដែលរំលោភបទដ្ឋានខ្លឹមសាររបស់អ្នកផ្តល់សេវាកម្ម។ ហេតុនេះ មុនពេលបញ្ជូន CSAM ទៅរាជធានីភ្នំពេញ រូបភាពទាំងឡាយត្រូវបានបញ្ជូនទៅធ្វើវិភាគកោសល្យវិច្ច័យជាមូលដ្ឋានសិន ដើម្បីកំណត់ជាក្រុម និងផ្តល់ចំណាត់ថ្នាក់អាទិភាព ដែលអនុញ្ញាតឲ្យភ្នាក់ងារ HSI កំណត់នូវរបាយការណ៍បន្ទាន់បំផុត និងស្តែងចេញជាវិធានការបានដែលនឹងត្រូវស៊ើបអង្កេតជាមួយគ្នានឹងមន្ត្រីអនុវត្តច្បាប់មូលដ្ឋាន(កម្ពុជា)។ ការពន្យល់អំពីដំណើរការនេះ នឹងត្រូវធ្វើឡើងនៅផ្នែកខាងក្រោមនេះ។

**NCMEC កំណត់របាយការណ៍ CSAM ដែលអាចមានពីរប្រភេទ**: ជាព័ត៌មាន និង VPN។ របាយការណ៍ជាព័ត៌មាន សំដៅដល់រូបភាពដែលត្រូវបាន "រាលដាល" ឬបានលេចឡើងនៅគណនីបណ្តាញទំនាក់ទំនងសង្គមជាច្រើនតាមរយៈការចែករំលែក។ ជាទូទៅ របាយការណ៍ជាព័ត៌មានផ្តល់ "ព័ត៌មាន" បន្ថែមអំពីការរីករាលដាលនៃសម្ភារ CSAM ដែលអាចមានជាក់លាក់ ឬបើមិនដូច្នេះទេ គឺជាសម្ភារដែលពុំសមរម្យ។ ជាទូទៅ របាយការណ៍ជាព័ត៌មាន គឺជារបាយការណ៍ស្តីពីសម្ភារដែលអាចរីករាលដាល និងមិនមែនជាករណីថ្មីនៃ CSAM ដែលអាចស្តែងចេញជាវិធានការបាននោះឡើយ។ ចំណែកឯជាទូទៅវិញនោះ គឺជារបាយការណ៍ VPN ដែលសំដៅដល់អ្វីម្យ៉ាងដែលហាក់ដូចជាថ្មី មិនចាំបាច់មានការផ្សព្វផ្សាយបន្តគ្នាតាមប្រព័ន្ធអ៊ិនធឺណិតឡើយនិងត្រូវជឿជាក់ថា ជា CSAM នៅពេលនោះតែម្តង។ របាយការណ៍ទាំងឡាយ ដូចជារបាយការណ៍ទាំងនេះអាចជាភស្តុតាងដ៏មានសក្តានុពល ដែលអាចស្តែងចេញជាវិធានការបាន សម្រាប់ភ្នាក់ងារអនុវត្តច្បាប់ប្រសិន បើមានភស្តុតាងពាក់ព័ន្ធគ្រប់គ្រាន់។

ក្នុងកំឡុងពេលប្រាំមួយឆ្នាំមុននេះ ក្នុងចំណោមរបាយការណ៍ស្តីពី CSAM ទាំងអស់ ដែលត្រូវបញ្ជូនពី NCMEC មានតែ ៤៣% ប៉ុណ្ណោះ ដែលជារបាយការណ៍ VPN។ ប៉ុន្តែរបាយការណ៍ VPN បានកើនឡើងគួរឲ្យកត់សម្គាល់ ក្នុងឆ្នាំ ២០១៨។ របាយការណ៍ VPN ចំនួន ៣២.៩១៣ ដែលត្រូវបានបញ្ជូនទៅប្រទេសកម្ពុជា ពីខែមករាដល់ខែវិច្ឆិកា ឆ្នាំ២០១៨ គឺមានចំនួនច្រើនជាងរបាយការណ៍ដែលត្រូវបញ្ជូនទៅប្រទេសកម្ពុជា ក្នុងកំឡុងពេលប្រាំឆ្នាំមុនរួមគ្នាជិត១,៥ដង។ នេះបង្ហាញថាមានការកើនឡើងគួរឲ្យកត់សម្គាល់នូវចំនួនរបាយការណ៍ CSAM ថ្មី និងដែលអាចស្តែងចេញជាវិធានការបាន ដែលនឹងទាមទារនូវធនធាន សមត្ថភាព និងការគាំទ្រជាក់ស្តែងកាន់តែច្រើនពីទីភ្នាក់ងារអនុវត្តច្បាប់មូលដ្ឋាននៅទូទាំងប្រទេស។

NCMEC បង្ហាញថា ការកើនឡើងយ៉ាងខ្លាំងនៃរបាយការណ៍នេះ អាចដោយសារកត្តាជាសក្តានុពលមួយចំនួនមានដូចជា ការពិនិត្យតាមដានដោយប្រុងប្រយ័ត្ន និងមានលក្ខណៈត្រៀមទប់ទល់ជាមុន ដែលធ្វើឡើងដោយគេហទំព័របណ្តាញទំនាក់ទំនងសង្គម ក្រុមហ៊ុនផ្តល់សេវាកម្មអ៊ិនធឺណិត ដើម្បីសម្អាតរបាយការណ៍ CSAM ចេញពី Server របស់ពួកគេ និង/ឬការកើនឡើងជាក់ស្តែងនូវការផលិត CSAM ដោយអ្នកប្រើប្រាស់ ឬជនខិលខូច។ អ្នកតំណាង NCMEC បានបង្ហាញថា សេចក្តីរាយការណ៍អំពី CSAM ពី NCMEC គឺមានលក្ខណៈជាក់លាក់ចំពោះអ្នកប្រើប្រាស់ដែលមានន័យថា ប្រសិនបើអ្នកប្រើប្រាស់ម្នាក់មានរូបភាព CSAM មួយ NCMEC នឹងបញ្ជូនរបាយការណ៍មួយអំពីរូបភាពនោះ។ ម្យ៉ាងទៀត ប្រសិនបើអ្នកប្រើប្រាស់បានរក្សាទុកដោយសម្ងាត់ ដែលមានរូបភាព ២៥សន្លឹក របាយការណ៍មួយនឹងត្រូវបញ្ជូនទៅ HSI នៅប្រទេសកម្ពុជា ដោយមានលេខយោងទៅកាន់រូបភាព ដែលកំពុងរាយការណ៍ទាំងអស់ ក្នុងឈ្មោះគណនីរបស់អ្នកប្រើប្រាស់។




## ៤.៣. បណ្តាញរាយការណ៍បន្ទាន់ តាមប្រព័ន្ធអ៊ិនធឺណិតនៃអង្គការ APLE

ក្នុងកំឡុងពេលបីឆ្នាំមុន ករណីទាក់ទងនឹង OCSE ចំនួន២០៤ករណី ត្រូវបានរាយការណ៍ទៅកាន់បណ្តាញរាយការណ៍បន្ទាន់តាមអ៊ិនធឺណិតនៃអង្គការ APLE ដែលជាផ្នែកមួយនៃបណ្តាញ INHOPE។ ស្របពេលដែលរបាយការណ៍ បង្កើតឡើងដោយអ្នកប្រើប្រាស់អាចចាប់យកវិសាលគមន៍ចម្រុះគ្នាកាន់តែច្រើននៃខ្លឹមសារ OCSE ជាញឹកញាប់ វាចាប់យកតែចំណែកតូចមួយប៉ុណ្ណោះនៃករណីនានា ដែលអាចមើលឃើញនៅលើគេហទំព័របើកចំហរ។ ករណីពីបណ្តាញរាយការណ៍បន្ទាន់តាមប្រព័ន្ធអ៊ិនធឺណិត ពឹងផ្អែកលើភាពយកចិត្តទុកដាក់ នៃអ្នកប្រើប្រាស់អ៊ិនធឺណិតតែមួយប៉ុណ្ណោះ នៅពេញទូទាំងអ៊ិនធឺណិត ដែលពួកគេដឹងអំពីបណ្តាញរាយការណ៍បន្ទាន់នេះ និងមានបំណងដាក់របាយការណ៍ពីក្តីបារម្ភទាក់ទងនឹងកិច្ចការពារកុមារ ដែលពួកគេឃើញ។ ជានិច្ចកាល បុគ្គលដែលរាយការណ៍អំពីករណីទាំងនេះ នៅបន្តជាអនាមិកជន លុះត្រាតែអ្នកប្រើប្រាស់ជ្រើសរើសថា ត្រូវបង្ហាញអត្តសញ្ញាណរបស់ខ្លួន ប៉ុន្តែកម្រនឹងមានករណីបែបនេះណាស់។ ក្នុងចំណោមករណីទាំង២០៤ដែលត្រូវបានរាយការណ៍ទៅកាន់បណ្តាញរាយការណ៍បន្ទាន់តាមអ៊ិនធឺណិតនៃអង្គការ APLE មាន ២០០ ករណី ឬ ៩៨% ត្រូវបានរាយការណ៍មានលក្ខណៈជាអនាមិក។



ក្នុងចំណោមករណីទាំង២០៤ករណី មាន៩៣ករណី ត្រូវបានបញ្ជាក់ថា ជាករណីសម្ភារទាក់ទងនឹងការរំលោភបំពានផ្លូវភេទកុមារ (CSAM) ពាក់ព័ន្ធនឹងកុមារកម្ពុជា។ បន្ថែមលើនេះ មាន២៧ករណី ឬ១២.៧% មិនត្រូវបានបញ្ជាក់ថា ជា CSAM ឬសម្ភារ ដែលទំនងជាខ្លឹមសាររំលោភបំពានផ្លូវភាពកុមារឡើយ ប៉ុន្តែមិនអាចបញ្ជាក់អំពីអាយុរបស់បុគ្គល នៅក្នុងខ្លឹមសារនោះបានឡើយ។ ជាញឹកញាប់ គឺដោយសារតែខ្លឹមសារ ដែលមានលក្ខណៈព្រាលៗ មិនពេញលេញ ឬបង្ហាញតែផ្នែកជាក់លាក់នៃរាងកាយប៉ុណ្ណោះ។ បន្ថែមលើនេះ មានមួយករណី ក្នុងចំណោមបីករណី នៃករណីទាំង២០៤ ឬ២៨.៤% ត្រូវបានកំណត់ថាជាខ្លឹមសារផ្លូវភេទ របស់បុគ្គលមានអាយុលើសពី១៨ឆ្នាំ។ ខ្លឹមសារនេះ អាចរួមបញ្ចូលទាំងសម្ភារដែលត្រូវបានថតជាលក្ខណៈឯកជន ឬផ្សាយផ្ទាល់នៅក្នុងការរៀបចំជាឯកជនដែលបន្ទាប់មកត្រូវបានបង្ហោះជាសាធារណៈ ជាទូទៅការបង្ហោះនេះ គឺប្រឆាំងនឹងបំណងប្រាថ្នារបស់បុគ្គល ដែលមាននៅក្នុងខ្លឹមសារផ្លូវភេទនោះ។ បណ្ដាញរាយការណ៍បន្ទាន់តាមអ៊ិនធឺណិតនៃអង្គការ APLE នៅតែឆ្លើយតបនឹងរបាយការណ៍ ទាក់ទងនឹងមនុស្សពេញវ័យដូចករណីទាំងនេះ តាមរយៈការដកយកខ្លឹមសារនោះចេញ ដើម្បីការពារជនរងគ្រោះ ដែលរូបភាព ឬវីឌីអូឯកជនរបស់ពួកគេត្រូវបង្ហោះជាសាធារណៈ។

ភាគច្រើននៃខ្លឹមសារ ដែលត្រូវបានរាយការណ៍ទៅកាន់បណ្ដាញរាយការណ៍បន្ទាន់តាមប្រព័ន្ធអ៊ិនធឺណិតនៃអង្គការ APLE មាន ១២២ ករណី ៥៩.៨% គឺស្ថិតក្នុងទម្រង់រូបភាពនៃការរំលោភបំពានផ្លូវភេទលើកុមារ។ ជិតមួយភាគបីនៃករណី មាន ៦២ ករណី ឬ ៣០.៤% គឺស្ថិតក្នុងជាទម្រង់ឯកសារវីឌីអូ។ ភាគតិចនៃករណីទាំងនេះ មាន ១៨ ករណី ឬ ៨.៨% ត្រូវបានកំណត់ចំណាត់ថ្នាក់ថា "ផ្សេងទៀត"។ ខ្លឹមសារនេះ អាចរួមបញ្ចូលនូវសម្ភារផ្សេងៗ ដែលបង្កឲ្យមានការខូចខាត ប៉ះពាល់ ឬជាការរំលោភបំពាន រាប់បញ្ចូលទាំងកុមារដែលទទួលរងនូវការរំលោភបំពានរូបរាងកាយ ឬជាករណីនៃរូបភាពសាធារណៈ/មិនទាក់ទងនឹងផ្លូវភេទរបស់កុមារ ដែលអាចត្រូវគេកាត់ត ឬកែ ដើម្បីមើលទៅដូចកុមារនោះអាក្រាត ឬនៅក្នុងស្ថានភាពមានលក្ខណៈផ្លូវភេទមួយផ្សេងទៀត។ ជាចុងក្រោយ មានពីរករណីដែលត្រូវបានរាយការណ៍ គឺក្នុងទម្រង់ជាសារអក្សរ។ មានតែ៤៤ករណី ឬ២១.៦%ប៉ុណ្ណោះ ដែលអាចកំណត់ថាជាការរំលោភបំពានកុមារ បានកើតឡើងនៅប្រទេសកម្ពុជា ស្របពេលដែលមានករណីភាគច្រើន (៧៧.៩%) មិនអាចកំណត់បានទីតាំងនៃការរំលោភបំពានឡើយ។ ស្រដៀងគ្នានេះដែរ គឺអាយុ និងភេទរបស់ជនរងគ្រោះ មិនអាចកំណត់បានឡើយ ចំពោះករណីភាគច្រើន។ ក្នុងចំណោមករណីដែលអាចកំណត់ភេទបាន មាន៣២ករណី ឬ ៦៨% គឺជាស្រី មាន ៦ ករណី ឬ ១២.៧% គឺជាប្រុស និង មាន ៩ ករណី ឬ ១៩.១% ទាក់ទងទាំងប្រុស និងស្រី។ ក្នុងករណីចំនួន១៥៧ភាពខុសគ្នានៃភេទ គឺបានបាត់ ឬមិនអាចកំណត់បាននៅក្នុងរបាយការណ៍នេះ។ ក្នុងចំណោមរបាយការណ៍ចំនួន ៤៣ ដែលអាចកំណត់ប្រភេទអាយុបាន មាន ១៨ របាយការណ៍ ឬ ៤១.៨% ត្រូវបានកំណត់ថាជា "មនុស្សវ័យជំទង់" មាន ១០ របាយការណ៍ ឬ ២៣.២% គឺជាកុមារជិតពេញវ័យ មាន ៤របាយការណ៍ ឬ ៩.៣% គឺជាកុមារអាយុពីពីរទៅបីឆ្នាំ និង មាន ១ របាយការណ៍ ឬ ២% គឺជាទារក។ ជាចុងក្រោយមាន ១០ របាយការណ៍ ត្រូវបានកំណត់ថា ជាមនុស្សអាយុលើសពី ១៨ ឆ្នាំ ភាគច្រើនជាអ្នកដែលមាននៅក្នុងខ្លឹមសារផ្លូវភេទប្រឆាំងនឹងបំណងប្រាថ្នារបស់ពួកគេ។ ក្នុងចំណោម ៤១ករណី (២០%) ជាតិពន្ធុនៃជនរងគ្រោះ មិនអាចកំណត់បានឡើយ។ ក្នុងចំណោម ៤១ ករណី ៣៤ ករណី ឬ ៨២.៩% គឺជាជនជាតិអាស៊ី ១២.១% គឺជាជនជាតិស្បែកស មួយករណីគឺជាជនជាតិអាហ្វ្រិក និងមួយករណីទៀត ហាក់ដូចជាមានសាវតាជាតិពន្ធចម្រុះ។ សញ្ជាតិ អាចត្រូវបានកំណត់បានតែចំពោះ ២០ ករណីប៉ុណ្ណោះ មាន ១៩ ករណី គឺមានសញ្ជាតិខ្មែរ និងមួយករណី គឺសញ្ជាតិថៃ តួលេខដែលនៅសេសសល់ផ្សេងទៀត គឺបានបាត់បង់ ឬមិនអាចកំណត់បាន។

ភាគច្រើននៃករណី មាន១២៥ករណី ឬ៦១.៣% ត្រូវបានបញ្ជូនទៅកាន់ក្រុមហ៊ុនបង្ហោះអ៊ីនធឺណិត(ដែលជាម្ចាស់ Server ដែលរក្សាទុក CSAM នោះ) ដើម្បីឲ្យដកចេញ។ ក្រុមហ៊ុនបង្ហោះ អាចជាក្រុមហ៊ុនមានឈ្មោះល្បីដូចជា Facebook ឬ Youtube ឬជាគេហទំព័រដែលមិនសូវល្បី ឬកម្មវិធីបណ្ដាញទំនាក់ទំនងសង្គម ដែល CSAM ត្រូវបានរកឃើញដំបូង និងរាយការណ៍។ ក្នុងករណីភាគច្រើន មាន១១០ករណី ក្នុងចំណោម១២៥ករណី (៨៨%) ដែលត្រូវបានរាយការណ៍ទៅកាន់ក្រុមហ៊ុនបង្ហោះ ឬ Domain នៃគេហទំព័រទាំងនោះCSAM ត្រូវបានដកចេញ។ មួយសប្ដាហ៍បន្ទាប់ពីបានរាយការណ៍ឲ្យដក CSAM ចេញ អ្នកវិភាគបណ្ដាញរាយការណ៍បន្ទាន់នៃអង្គការ APLE នឹងពិនិត្យឡើងវិញករណី និងវាយតម្លៃថា សម្ភារនោះត្រូវបានដកចេញ ប៉ុន្តែ មាន១៥ ករណីក្នុងចំណោម ១២៥ករណី (១២%) ក្រុមហ៊ុនបង្ហោះមិនបានចាត់វិធានការឡើយ។ បន្ថែមលើនេះ ក្នុងចំណោមប្រាំមួយករណី (២.៩%) ដោយសាររបាយការណ៍របស់បណ្ដាញរាយការណ៍បន្ទាន់តាមអ៊ីនធឺណិតនៃអង្គការ APLE គេហទំព័រទាំងមូលត្រូវបានបិទចោល។

ក្នុងកំឡុងពេលបីឆ្នាំមុន មានករណីចំនួន ១៦ ឬ ៧.៨% ដែលត្រូវបានរាយការណ៍តាមរយៈបណ្ដាញរាយការណ៍បន្ទាន់តាមប្រព័ន្ធអ៊ីនធឺណិតនៃអង្គការ APLE ត្រូវបានបញ្ជូនទៅកាន់ទីភ្នាក់ងារអនុវត្តច្បាប់ ដែលគេបានបើកការស៊ើបអង្កេតចំពោះតែ ៤ករណី ឬ ២% ប៉ុណ្ណោះ។ ករណី ត្រូវបានបញ្ជូនទៅកាន់នគរបាល តែក្នុងពេលដែលអាចកំណត់អត្តសញ្ញាណជនរងគ្រោះបាន និងមានភស្តុតាងគ្រប់គ្រាន់នៅក្នុងរបាយការណ៍ សម្រាប់បើកករណីប៉ុណ្ណោះ។ ក្នុងករណីជាច្រើន មានរបាយការណ៍ស្តីពី CSAM ដែលត្រូវបានកំណត់ឃើញថា មិនត្រូវការការតាមដានពីនគរបាលឡើយ ឬ ក្នុងករណីដែលចាំបាច់ ត្រូវធ្វើការតាមដាន ករណីទាំងនោះ មានភស្តុតាងមិនគ្រប់គ្រាន់សម្រាប់ធ្វើកិច្ចការនេះឡើយ។

មាន ៣០ ករណីនៃករណីដែលត្រូវបានរាយការណ៍ ឬ ១៤.៧% មានខ្លឹមសារ CSAM ត្រូវបានកំណត់ឃើញ និងបញ្ជូនទៅកាន់បណ្ដាញរាយការណ៍បន្ទាន់តាមប្រព័ន្ធអ៊ីនធឺណិតនៃ INHOPE។ ករណីទាំងឡាយត្រូវបានបញ្ជូនទៅកាន់បណ្ដាញ INHOPE ក្នុងស្ថានភាពដែលខ្លឹមសារ CSAM ត្រូវបានរក្សាទុកនៅក្នុងប្រទេសមួយផ្សេងទៀត ដែលជាដៃគូរបស់ INHOPE ឬជនរងគ្រោះនៅក្នុងខ្លឹមសារនោះ គឺជាពលរដ្ឋមកពីប្រទេសមួយដែលជាដៃគូរបស់ INHOPE ។




នៅឆ្នាំ២០១៥ ដែលជាឆ្នាំបង្កើតបណ្ដាញរាយការណ៍បន្ទាន់នេះ មានចំនួនរបាយការណ៍ស្តីពី CSAM តិចតួចបំផុតបានរាយការណ៍ទៅកាន់បណ្ដាញរាយការណ៍នេះ។ នៅឆ្នាំ ២០១៦ ការរាយការណ៍អំពី CSAM មកកាន់បណ្ដាញរាយការណ៍នេះហាក់ដូចជាឡើងខ្ពស់បំផុតដល់ទៅ ៧១ករណី CSAM នៅក្នុងឆ្នាំនោះ។ នៅឆ្នាំបន្តបន្ទាប់ទៀត ការរាយការណ៍អំពី CSAM ហាក់ដូចជាថយចុះមកនៅត្រឹម៥៨ ក្នុងឆ្នាំ២០១៧ និង៤៣ នៅត្រឹមពេលនៃការរៀបចំរបាយការណ៍នេះ។ ការថយចុះនៃការរាយការណ៍នេះ ទំនងជាដោយសារកង្វះអន្តរទំនាក់ទំនងរបស់អ្នកប្រើប្រាស់ ជាមួយបណ្ដាញរាយការណ៍បន្ទាន់នេះ ជាជាងដោយសារការថយចុះនូវការកើតឡើង OCSE។ តាមពិត

យោងតាមការរាយការណ៍ពី NCMEC មានសេចក្តីរាយការណ៍អំពី CSAM បានកើនឡើងជិត ៣៧០% នៅឆ្នាំមុន (ឆ្នាំ២០១៧-២០១៨)។

## ៤.៤. បណ្តាញទូរស័ព្ទជំនួយកុមារកម្ពុជា

ថ្វីបើបណ្តាញទូរស័ព្ទនេះទទួលការហៅទូរស័ព្ទចូលយ៉ាងច្រើនជារៀងរាល់ខែក៏ដោយ ក៏មានតែករណី ទាក់ទងនឹង OCSE ចំនួនប្រាំពីរប៉ុណ្ណោះ ដែលត្រូវបានរាយការណ៍ទៅកាន់បណ្តាញទូរស័ព្ទជំនួយកុមារកម្ពុជា ក្នុងកំឡុងពេលបីឆ្នាំចុងក្រោយនេះ។ ភាគច្រើននៃករណីទាំងនេះ (ឬ ប្រាំករណី ក្នុងចំណោមប្រាំពីរករណី) ទាក់ទងនឹងរូបភាពផ្លូវភេទនៃបុគ្គលវ័យក្មេងម្នាក់ ដែលត្រូវបានបង្ហោះតាមបណ្តាញទំនាក់ទំនងសង្គម ដោយគ្មានការយល់ព្រមពីពួកគេ ឬការគំរាមបង្ហោះរូបភាពទាំងនេះ ប្រសិនបើបុគ្គលវ័យក្មេងនោះមិនធ្វើតាមសំណើរបស់បុគ្គលដែលកាន់កាប់រូបភាពទាំងនោះ។ មានករណីមួយ បុគ្គលដែលកំពុងកាន់កាប់រូបភាពផ្លូវភេទរបស់ជនរងគ្រោះ ទាមទារការចំណាយ ដើម្បីកុំឲ្យមានការបញ្ចេញរូបភាពផ្លូវភេទទាំងនោះ ហើយក្នុងករណីមួយទៀត រូបភាពបែបនេះ ត្រូវបានគេរក្សាទុកធ្វើជាការគំរាម ដើម្បីឲ្យជនរងគ្រោះបន្តទំនាក់ទំនងជាមួយជនខិលខូច។ នៅក្នុងករណីមួយ មានជនរងគ្រោះ និងជនខិលខូចធ្លាប់បានជួបគ្នាពីមុនមក ដើម្បីមានទំនាក់ទំនងផ្លូវភេទ ហើយមានការថតរូបភាពផ្លូវភេទរបស់បុគ្គលវ័យក្មេងនោះ ដោយគ្មានការយល់ព្រមពីម្ចាស់ខ្លួន ជនរងគ្រោះលើកឡើងថា គាត់ព្រួយបារម្ភខ្លាចក្រែងរូបភាពទាំងនោះនឹងលេចចេញជាសាធារណៈតាមប្រព័ន្ធអ៊ិនធឺណិត។ មានករណីមួយហាក់ដូចជាពាក់ព័ន្ធនឹងការលួងលោម ដែលជនរងគ្រោះបានលើកឡើងថា មានបុគ្គលដែលពុំធ្លាប់ស្គាល់គ្នាម្នាក់ (ដែលត្រូវបានបញ្ចូលធ្វើជាមិត្តភក្តិនៅក្នុង Facebook) បានចាប់ផ្តើមផ្ញើរូបភាពផ្លូវភេទ និងចង់បានការឆ្លើយតប មានលក្ខណៈដូចគ្នាពីជនរងគ្រោះ។ នៅពេលជនរងគ្រោះបដិសេធ ជននោះបានធ្វើការគំរាមបង្ហោះរូបភាពរបស់ជនរងគ្រោះ (ដែលត្រូវបានកាត់តបង្ហាញពីផ្លូវភេទ) ជាសាធារណៈ នៅក្នុងគេហទំព័របណ្តាញទំនាក់ទំនងសង្គម។

បុគ្គលវ័យក្មេងទាំងអស់ ដែលរាយការណ៍អំពីករណីទាំងនេះ គឺជាពលរដ្ឋកម្ពុជា ហើយមានប្រាំមួយនាក់ក្នុងចំណោមពួកគេទាំងប្រាំពីរនាក់ គឺជាស្ត្រី។ ដោយសារបណ្តាញទូរស័ព្ទជំនួយកុមារកម្ពុជាទទួលការហៅទូរស័ព្ទចូលពីមនុស្សដែលមានអាយុរហូតដល់ ២៥ឆ្នាំ ដូច្នេះមានករណីចំនួនបី គឺជាបុគ្គលវ័យក្មេង ដែលមានអាយុ ១៨ឆ្នាំ ហើយករណីក្រៅពីនោះ គឺជាបុគ្គលដែលមានអាយុលើសពី១៨ឆ្នាំឡើងទៅ។ មានបីករណីដែលពុំមានចាត់វិធានការឡើយ ដោយសារមិនអាចទំនាក់ទំនងជាមួយជនរងគ្រោះបាន ដើម្បីពិភាក្សាអំពីវិធានការបន្តបន្ទ។ មានពីរករណីដែលជនរងគ្រោះបានទទួលព័ត៌មានអំពីការប្តឹកខ្លឹមសារ និងការបញ្ជូនទៅរកសេវា។ មានពីរករណីដែលបានចាត់វិធានការផ្លូវច្បាប់គឺមួយនៅក្នុងប្រទេសកម្ពុជា និងមួយទៀតនៅក្នុងប្រទេសក្រៅមួយ ដែលជនល្មើសកំពុងស្នាក់នៅ។

ទោះបីជាមានសេចក្តីរាយការណ៍ចំនួនតិចក៏ដោយ ក៏ភាពស្រដៀងគ្នានៅក្នុងខ្លឹមសារ មានលក្ខណៈគួរឲ្យកត់សម្គាល់ដែរ រវាងករណី OCSE ដែលត្រូវបានពិភាក្សានៅក្នុងសិក្ខាសាលារៀនសូត្រ និងករណីដែលត្រូវបានរាយការណ៍ទៅកាន់បណ្តាញទូរស័ព្ទជំនួយនេះ។ ទម្រង់ទាំងនេះ នឹងត្រូវឆ្លើយតបនៅផ្នែកក្រោយៗទៀតនៃរបាយការណ៍នេះ។

## ៤.៥. ការស៊ើបអង្កេតលើសេចក្តីរាយការណ៍ស្តីពី OCSE

ធ្លាប់មានការផ្តួចផ្តើមស៊ើបអង្កេតករណីOCSEដែលត្រូវបានរាយការណ៍ដោយបុគ្គលផ្ទាល់ ទៅកាន់នគរបាល។ ភាគច្រើន មានប្រភពចេញពីការបញ្ជូនរបស់ទីភ្នាក់ងារអនុវត្តច្បាប់ទាក់ទងនឹងរូបភាព CSAM ដែលត្រូវបានរក

ឃើញនៅតាមឧបករណ៍អេឡិចត្រូនិករបស់ជនល្មើសបំពារបំពានផ្លូវភេទកុមារ ការប្រមូលបានពីវេទិកានានាក្នុងគេហទំព័រងងឹត និងពី Server ចែករំលែកឯកសារគ្នា និងសេចក្តីរាយការណ៍អំពី CSAM ពីអង្គការនានា ដូចជា NCMEC ដែលរបាយការណ៍ ត្រូវបានបង្កើតឡើងតាមរយៈសេចក្តីរាយការណ៍ទាក់ទងនឹងកិច្ចការពារតាមកម្មវិធីអ៊ិនធឺណិត ដូចជា Facebook ឬ Google។ ដើម្បីពិភាក្សាអំពី ដំណើរការស៊ើបអង្កេតករណីទាក់ទងនឹង OCSE នៅក្នុងប្រទេសកម្ពុជា ដំបូងចាំបាច់គឺត្រូវពន្យល់អំពី វិធីបង្កើតរបាយការណ៍ និងធនធានដែលមានជាទូទៅក្នុងការងារស៊ើបអង្កេត។

### ៤.៤.១. របាយការណ៍ពីមជ្ឈមណ្ឌលជាតិការពារកុមារបាត់ខ្លួន និងរងគ្រោះដោយការកេងប្រវ័ញ្ច (NCMEC)

ប្រសិនបើមានសកម្មភាពធ្ងន់ធ្ងរជាក់លាក់ ឬប្រសិនបើមានរបាយការណ៍មួយ ជាផ្នែកមួយនៃករណីដែលកំពុងដំណើរការរបាយការណ៍នៃ NCMEC នឹងត្រូវបញ្ជូនដោយឯករាជ្យទៅកាន់ FBI។ ទោះបីជាយ៉ាងណារបាយការណ៍/ព័ត៌មានរបស់ NCMEC ត្រូវបញ្ជូនទៅ HSI ដោយផ្ទាល់តាមរយៈ Portal អ៊ិនធឺណិត។ យោងតាមភ្នាក់ងារក្នុងមូលដ្ឋាននៃ HSI ភាគច្រើននៃព័ត៌មាននៅក្នុងប្រទេសកម្ពុជា មានប្រភពមកពី Facebook និង Google។ ជាទូទៅ របាយការណ៍ទាំងឡាយ ដែលលេចចេញពី Portal មានអាយុតិចជាងមួយសប្តាហ៍ នៅពេលរបាយការណ៍នេះ ទៅដល់ភ្នាក់ងារក្នុងប្រទេសកម្ពុជា និងរួមមានភស្តុតាងជារូបភាព/វីឌីអូ អាសយដ្ឋាន IP ពាក់ព័ន្ធ និងចំណាត់ថ្នាក់ជាមូលដ្ឋាននូវភាពធ្ងន់ធ្ងរនៃCSAMពាក់ព័ន្ធនៅនឹងករណី។ ការវិភាគរូបភាពត្រូវធ្វើឡើងជាបន្ទាន់ ប៉ុន្តែចំណាត់ថ្នាក់រូបភាពជាមូលដ្ឋាន ត្រូវបានផ្តល់នៅក្នុងរបាយការណ៍ទៅកាន់ HSI ដែលត្រូវផ្តល់បន្ត ដល់ភ្នាក់ងារអនុវត្តច្បាប់ក្នុងប្រទេស។ ចំណាត់ថ្នាក់សម្រាប់ខ្លឹមសាររូបភាព មានដូចតទៅ ៖

‘A’ -អនីតិជន មានវ័យមិនទាន់គ្រប់ការ

‘B’ -អនីតិជនពេញវ័យគ្រប់ការ

‘1’ -សកម្មភាពផ្លូវភេទ រូបភាព/វីឌីអូ ស្តីពីការប្រព្រឹត្តផ្លូវភេទ

‘2’ -ការបង្ហាញចំណង់ផ្លូវភេទ រូបភាព/វីឌីអូ ដែលបង្ហាញភាពអាក្រាត និងមានអាកប្បកិរិយា ស្ថិតក្រោមការគ្រប់គ្រង ការឈរ ឬអង្គុយបែបបង្កភាពស្រើបស្រាល ការប៉ះពាល់មិនសមរម្យចំនួនម្តង ឬច្រើនដង។ល។

ការរួមបញ្ចូលគ្នាអាចត្រូវបានបង្កើតឡើងដោយប្រើប្រាស់ចំណាត់ថ្នាក់ខាងលើ។ ឧទាហរណ៍រូបភាពមួយអាចត្រូវកំណត់ជាប្រភេទ A1 ឬ B2 ឬ A2 ឬ B1។ ទិន្នន័យដែលបានមកតាមរយៈ Portal របស់ HSI ពី NCMEC គឺពិតជាមានកម្រិតខ្ពស់ រាប់បញ្ចូលទាំងអាសយដ្ឋាន និងសញ្ញាសម្គាល់នៃឧបករណ៍ដែលទាក់ទងនឹងការចែកចាយ CSAM។ HSI លើកឡើងអំពី ការទទួលចំនួនរបាយការណ៍ រវាងពី៧០០ និង១.០០០ របាយការណ៍ តាមរយៈ Portal ក្នុងមួយខែ។

នៅពេល HSI ទទួលបានរបាយការណ៍ ភ្នាក់ងារនឹងបំបែករបាយការណ៍ទាំងនោះ ជាទូទៅ ដោយចាប់ផ្តើមពីប្រភេទ A ដែលទាក់ទងនឹងឧក្រិដ្ឋកម្ម មានទម្រង់អាក្រក់ចំពោះកុមារ។ ព័ត៌មានរបស់ NCMEC នឹងបង្ហាញអាសយដ្ឋាន IP ជាក់លាក់ ដែលបានទាញយក ឬចែកចាយសម្ភារ CSAM ជាក់លាក់។ បន្ទាប់មកភ្នាក់ងារនេះ នឹងត្រូវតាមដានរកអាសយដ្ឋាន IP នោះ។ កិច្ចការនេះ មានការលំបាកខ្លាំង នៅក្នុងបរិបទកម្ពុជា ដោយសារក្រុមហ៊ុនផ្តល់សេវាកម្មអ៊ិនធឺណិតគ្មានកម្រងបទដ្ឋានជាក់លាក់សម្រាប់រក្សាទិន្នន័យកំណត់ IP ហើយមានករណីជាច្រើនចាំបាច់ត្រូវការតាមដានបន្តចំពោះទិន្នន័យមូលដ្ឋាន នៅក្នុងរបាយការណ៍ ហើយការបើកការស៊ើបអង្កេត លែងអាចធ្វើបាននៅពេលដែលទទួលបានសំណើនេះ។

### ៤.៤.២. មូលដ្ឋានទិន្នន័យ ICSE នៃនគរបាលអន្តរជាតិ

មូលដ្ឋានទិន្នន័យស្តីពីការកេងប្រវ័ញ្ចផ្លូវភេទលើកុមារជាអន្តរជាតិ (ICSE) គឺជាឧបករណ៍ស៊ើបអង្កេតរបស់នគរបាលអន្តរជាតិ និងស្ថិតក្រោមការថែរក្សារបស់នគរបាលអន្តរជាតិ។ មូលដ្ឋានទិន្នន័យនេះ ត្រូវបានប្រើប្រាស់ដោយមន្ត្រីអនុវត្តច្បាប់ ដែលមានការបញ្ជាក់ត្រឹមត្រូវ ដើម្បីស៊ើបអង្កេត CSAM ក្នុងទម្រង់ជារូបភាពវីឌីអូ និងសញ្ញានានា ដោយប្រៀបធៀបរូបភាពវីឌីអូ និងសញ្ញាទាំងនេះជាមួយទិន្នន័យ និងភស្តុតាងផ្សេងទៀតដែលភ្នាក់ងារអនុវត្តច្បាប់រឹបអូសបាននៅទូទាំងពិភពលោក ដែលត្រូវបានរក្សាទុកនៅក្នុងមូលដ្ឋានទិន្នន័យនេះផងដែរ។ ការិយាល័យកណ្តាលជាតិនៃនគរបាលអន្តរជាតិ មានការគ្រប់គ្រងជាបឋមលើលទ្ធភាពចូលរបស់អ្នកប្រើប្រាស់ជាតិ ទៅក្នុងមូលដ្ឋានទិន្នន័យ ICSE នេះ។ គោលបំណងបឋមនៃទិន្នន័យនេះគឺ ដើម្បីសម្របសម្រួលការកំណត់អត្តសញ្ញាណកុមាររងគ្រោះ ដោយការរំលោភបំពានផ្លូវភេទ និងកាត់បន្ថយភាពមិនចាំបាច់ នៅក្នុងកិច្ចខិតខំប្រឹងប្រែងកំណត់អត្តសញ្ញាណ ដោយទីភ្នាក់ងារអនុវត្តច្បាប់។ ដើម្បីភ្ជាប់ជាមួយនឹងមូលដ្ឋានទិន្នន័យ ICSE ប្រទេសមួយត្រូវមានច្បាប់ជាក់លាក់ដែលហាមឃាត់ CSAM /CSEM អង្គភាពជាតិឯកទេសដែលធ្វើការងារជាមួយនឹងការកំណត់អត្តសញ្ញាណជនរងគ្រោះ និងកម្រិតបញ្ជូនទិន្នន័យលឿនគ្រប់គ្រាន់ ដើម្បីគាំទ្រដល់ប្រតិបត្តិការនៃការភ្ជាប់ទំនាក់ទំនងរបស់ពួកគេ ជា មួយនឹង មូលដ្ឋានទិន្នន័យនេះ។ បច្ចុប្បន្ននេះ មន្ត្រីអនុវត្តច្បាប់ និងមន្ត្រីពាក់ព័ន្ធសំខាន់ៗ មកពី ៥៤ប្រទេស ព្រមទាំងនគរបាលអន្តរជាតិ និងមន្ត្រីនគរបាលអឺរ៉ុប បានភ្ជាប់ទំនាក់ទំនងជាមួយមូលដ្ឋាន ទិន្នន័យនេះ និងប្រើប្រាស់វាដើម្បីចែករំលែក CSAM ដែលរឹបអូសបាន និងព័ត៌មានពាក់ព័ន្ធនឹងករណីផ្សេងទៀត[55]។

នៅពេលអ្នកប្រើប្រាស់អ៊ិនធឺណិត (ដែលជាទូទៅជាសមាជិកទីភ្នាក់ងារ ឬស្ថាប័នអនុវត្តច្បាប់ជាតិ) បញ្ចូលរូបភាពថ្មីមួយ បង្ហាញពីការរំលោភបំពានកុមារ (Hash) រូបភាពនោះនឹងត្រូវបានប្រើប្រាស់សម្រាប់ស្វែងរករូបភាពផ្សេងៗកំពុងមានស្រាប់ និងដើម្បីបញ្ជាក់ថា តើរូបភាពថ្មីនេះ មាននៅក្នុងប្រព័ន្ធនេះ រួចហើយឬនៅ។ រូបភាពទាំងនេះមានតួនាទីដូចជាប្រភេទខ្មៅដៃមួយ ដែលមានតែមួយគត់សម្រាប់រូបភាពឌីជីថល ដោយសារថាគ្រប់រូបភាពឌីជីថលសុទ្ធតែមានលក្ខណៈជាក់លាក់ ដូចជា ភីកសែល (សំណុំរូបភាពក្នុងកុំព្យូទ័រ) ពណ៌ និងទំហំ។ លក្ខណៈទាំងនេះអាចត្រូវកុំព្យូទ័របកប្រែទៅជាលេខកូដឌីជីថលដោយឡែក ដែលតំណាងយ៉ាងល្អសម្រាប់រូបភាពជាក់លាក់។ លេខកូដនេះ ត្រូវស្គាល់ថាជា "តម្លៃ Hash" នៃរូបភាព។ តម្លៃជាអក្សរនេះ អាចត្រូវបានប្រើប្រាស់ ដើម្បីស្វែងរកច្បាប់ចម្លងនៃរូបភាពដូចគ្នាបេះបិទ ពីក្នុងមូលដ្ឋានទិន្នន័យទាំងមូល។ ហេតុនេះ ទោះបីជារូបភាពដូចគ្នា ត្រូវបញ្ចូលដោយប្រទេសផ្សេងមួយ ដែលរូបភាពនោះមានទំនាក់ទំនងជាមួយករណីផ្សេង និងមានឈ្មោះឯកសារខុសគ្នាក៏ដោយ ក៏តម្លៃ Hash នៃរូបភាពនោះ នៅតែដូចគ្នាដដែល និងអាចត្រូវបានប្រើប្រាស់ជាអ្នកកំណត់អត្តសញ្ញាណដោយឡែក និងជាមធ្យោបាយកាត់បន្ថយរូបភាពជាន់គ្នា នៅក្នុងមូលដ្ឋានទិន្នន័យ។

ស្របពេលដែលមូលដ្ឋានទិន្នន័យ ICSE ទទួលបានទិន្នន័យ CSAM ពីមន្ត្រីអនុវត្តច្បាប់ នៅក្នុងប្រទេសជាសមាជិក ជាញឹកញាប់ NCMEC មានលទ្ធភាពធំទូលាយក្នុងការដែលអាចទទួលបាន CSAM ដោយសារពួកគេទទួលបានរបាយការណ៍ជាបន្តបន្ទាប់ និងដោយស្វ័យប្រវត្តិ ពីក្រុមហ៊ុនផ្តល់សេវាកម្មអ៊ិនធឺណិត និងក្រុមហ៊ុនបច្ចេកវិទ្យាធំៗ នៅសហរដ្ឋអាមេរិក (ដូចជា Facebook, Google និង Microsoft) ដែលក្រុមហ៊ុនទាំងនេះ ត្រូវរាយការណ៍អំពីខ្លឹមសារទាក់ទងនឹង OCSE ទាំងអស់ទៅកាន់ NCMEC ស្របតាមច្បាប់សហរដ្ឋអាមេរិក។ ហេតុនេះ មានកិច្ចព្រមព្រៀងសហការគ្នាមួយ រវាងបណ្តាញរាយការណ៍តាមប្រព័ន្ធអ៊ិនធឺណិតរបស់ NCMEC និងនគរបាលអន្តរជាតិ ដែលអនុញ្ញាតឲ្យនគរបាលអន្តរជាតិមានលទ្ធភាពទទួលបានតម្លៃ Hash នៃរូបភាពដែលប្រមូលបានដោយ

[55] ECPAT. (2017).

NCMEC។ ក្នុងករណីដែលអង្គភាពនគរបាលសហរដ្ឋអាមេរិក មិនទទួលខុសត្រូវដោយផ្ទាល់លើករណី CSAM (ដូចជារូបភាព CSAM នៃកុមារកម្ពុជា ដែលត្រូវបានបង្ហោះចូលក្នុង Facebook ដោយបុគ្គលជនជាតិចិននៅក្នុងប្រទេសកម្ពុជា) NCMEC មានសមត្ថភាពបញ្ចូលរូបភាព CSAM និងព័ត៌មានករណីពាក់ព័ន្ធដោយផ្ទាល់ទៅក្នុងមូលដ្ឋានទិន្នន័យ ICSE។ ការធ្វើបែបនេះ អនុញ្ញាតឲ្យទីភ្នាក់ងារអនុវត្តច្បាប់អន្តរជាតិ បន្តតាមរកបញ្ហាពាក់ព័ន្ធនឹងកិច្ចការពារកុមារ កំពុងដំណើរការ នៅក្រៅដែនសមត្ថកិច្ចសហរដ្ឋអាមេរិក។

មូលដ្ឋានទិន្នន័យ ICSE គឺជាឧបករណ៍ដែលគិតគូរអំពីជនរងគ្រោះ និងមានគោលបំណងគាំទ្រទីភ្នាក់ងារអនុវត្តច្បាប់ ក្នុងការកំណត់រកជនរងគ្រោះជាកុមារ។ ហេតុនេះ ព័ត៌មាននៅក្នុងមូលដ្ឋាននេះ ត្រូវបានកំណត់ជាប្រភេទ *ដែលអាចកំណត់អត្តសញ្ញាណបាន ឬមិនអាចកំណត់អត្តសញ្ញាណបាន*។ កុមារដែលត្រូវបានកំណត់អត្តសញ្ញាណឃើញ ត្រូវបានដាក់ស្លាកសញ្ញាដើម្បីកាត់បន្ថយលទ្ធភាពនៃភាពត្រួតជាន់គ្នាសម្រាប់កិច្ចខិតខំប្រឹងប្រែងទាក់ទងនឹងការកំណត់អត្តសញ្ញាណជនរងគ្រោះទាំងនោះ ហើយកុមារដែលមិនអាចកំណត់អត្តសញ្ញាណបាន ត្រូវបានដាក់ស្លាកសញ្ញា ក្នុងគោលបំណងកំណត់អត្តសញ្ញាណកុមារ។ មូលដ្ឋានទិន្នន័យ ICSE និងសមត្ថភាពរបស់មូលដ្ឋានទិន្នន័យនេះ ក្នុងការកំណត់អត្តសញ្ញាណកុមារប្រកបដោយប្រសិទ្ធភាព ពឹងផ្អែកលើម្ចាស់ករណីនៅកម្រិតប្រទេសក្នុងការធ្វើបច្ចុប្បន្នភាពស្ថានភាពករណីនានា បញ្ចូលព័ត៌មានអំពីករណីនិងប្រើប្រាស់ចំណេះដឹងនិងភស្តុតាងថ្នាក់ប្រទេស ដើម្បីកំណត់រូបភាពកុមារកម្ពុជា ដែលលេចឡើងនៅក្នុងមូលដ្ឋានទិន្នន័យនេះ។

ចរិតស្ម័គ្រចិត្តនៃការគ្រប់គ្រងមូលដ្ឋានទិន្នន័យនេះ មានន័យថា ចំនួននិងគុណភាពនៃព័ត៌មាន ដែលមូលដ្ឋានទិន្នន័យនេះមាន គឺអាស្រ័យទៅលើធនធានៈ និងធនធាននៃអ្នកប្រើប្រាស់ទាំងនេះ។ បច្ចុប្បន្ននេះ ការិយាល័យកណ្ដាលជាតិកម្ពុជា (ការិយាល័យសេនានុព័ន្ធនៃនគរបាលអន្តរជាតិនៅក្នុងប្រទេសកម្ពុជា) គ្មានលទ្ធភាពប្រើប្រាស់មូលដ្ឋានទិន្នន័យ ICSE ដោយផ្ទាល់ឡើយ។ ដោយសារ កង្វះកិច្ចសហការនេះ មានការលំបាកជាច្រើនក្នុងការប្រើប្រាស់មូលដ្ឋានទិន្នន័យ ICSE ឲ្យអស់សក្ដានុពលរបស់វានៅក្នុងប្រទេសកម្ពុជា។ ដោយគ្មានការភ្ជាប់ទំនាក់ទំនងកម្រិតថ្នាក់ជាតិ រវាងទីភ្នាក់ងារអនុវត្តច្បាប់កម្ពុជា និងមូលដ្ឋានទិន្នន័យនេះ ការអនុវត្តច្បាប់អន្តរជាតិ ប្រឈមមុខនឹងការលំបាកក្នុងការយល់អំពីខ្លឹមសារ និងទម្រង់នៃបទល្មើស OCSE នៅក្នុងប្រទេសកម្ពុជា ដែលនៅក្នុងនោះ ព័ត៌មាននៅក្នុងមូលដ្ឋានទិន្នន័យ ICSE ពឹងផ្អែកយ៉ាងខ្លាំងលើនគរបាលជាតិ និងសមត្ថភាពរបស់ពួកគេប្រើប្រាស់និងរួមចំណែកដល់មូលដ្ឋានទិន្នន័យនេះ។

មានតម្រូវការយ៉ាងច្បាស់មួយចំពោះកិច្ចសហប្រតិបត្តិការកាន់តែខ្លាំង និងចំពោះធាតុចូលពីអាស៊ាន និងប្រជាជាតិអាស៊ីខាងកើត ទៅក្នុងមូលដ្ឋានទិន្នន័យ ICSE។ ទីភ្នាក់ងារអនុវត្តច្បាប់អន្តរជាតិ ដឹងអំពីសម្ភារទាក់ទងនឹងការរំលោភបំពាន/ការកេងប្រវ័ញ្ចផ្លូវភេទកុមារ ដែលត្រូវបានផលិតនៅក្នុងប្រទេសកម្ពុជា ដោយជនខិលខូចកំពុងធ្វើដំណើរទៅពីប្រទេសកូរ៉េ ចិន ជប៉ុន និងប្រទេសផ្សេងទៀត ទោះបីជាយ៉ាងណាពួកគេមិនអាចកំណត់អត្តសញ្ញាណកុមារ និងធ្វើការស៊ើបអង្កេតជនខិលខូច ដោយគ្មានការចូលរួម និងមានកិច្ចសហការយ៉ាងសកម្មពីដៃគូថ្នាក់តំបន់ និងថ្នាក់មូលដ្ឋានបានឡើយ។ បច្ចុប្បន្ននេះ ប្រជាជាតិលោកខាងលិច (អឺរ៉ុប ចក្រភពអង់គ្លេស សហរដ្ឋអាមេរិក អូស្ត្រាលី) មានការវិវឌ្ឍន៍យ៉ាងខ្លាំង នៅក្នុងការដោះស្រាយបញ្ហាពលរដ្ឋរបស់ខ្លួនដែលធ្វើដំណើរទៅកាន់តំបន់អាស៊ាន ដើម្បីរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទកុមារ។ ទោះបីជាយ៉ាងណា សេនានុព័ន្ធនគរបាល មកពីប្រជាជាតិអាស៊ាន និងប្រជាជាតិអាស៊ីខាងកើត (រាប់បញ្ចូលទាំងប្រទេសកូរ៉េ ចិន និង ជប៉ុន ផង) ជាញឹកញាប់មិនបានកំណត់ជាអាទិភាពចំពោះបញ្ហាកិច្ចការពារកុមារឡើយ។ មន្ត្រីអនុវត្តច្បាប់អន្តរជាតិ រៀបរាប់អំពីការកើនឡើងជាក់លាក់នៃពលរដ្ឋចិនដែលពាក់ព័ន្ធនឹងការផលិតCSAM ប៉ុន្តែនៅពេលដែលករណីនេះត្រូវបានបញ្ជូនទៅសេនានុព័ន្ធ

៦៤/៩៨

នគរបាលចិន ជាញឹកញាប់ គឺការប្រាស្រ័យទាក់ទងគ្នានៅមានកម្រិត ឬគ្មានការប្រាស្រ័យទាក់ទងគ្នាសោះអំពីវិធានការដែលត្រូវអនុវត្ត ឬលទ្ធផលនៃករណីទាំងនោះ។

ជានិច្ចកាល និយាមសង្គម មិនថ្កោលទោសបទល្មើសផ្លូវភេទ លើកុមារឡើយនៅក្នុងប្រជាជាតិអាស៊ីខាងកើតមួយចំនួន។ នៅតំបន់ជាច្រើន កុមារអាចត្រូវបានមើលឃើញថា ជាឧបករណ៍ផ្លូវភេទ ដោយមានផលវិបាកផ្នែកសង្គមតិចតួច។ ការអនុវត្តច្បាប់ នៅក្នុងតំបន់ទាំងនេះ មិនមានលក្ខណៈត្រៀមទប់ទល់ជាមុនចំពោះករណីទាក់ទងនឹង OCSE ហើយកិច្ចសហការអន្តរជាតិនៅមានកម្រិតទាប ដោយមានការផ្តោតការយកចិត្តទុកដាក់ច្រើនជាងទៅការឆ្លើយតបចំពោះការបោកប្រាស់ ការសម្អាត លុយកខ្វក់ និងឧក្រិដ្ឋកម្ម ទាក់ទងនឹងហិរញ្ញវត្ថុផ្សេងទៀត។ ការផ្តោតការយកចិត្តទុកដាក់បែបនេះ បង្កើតនូវបញ្ហាប្រឈមដោយឡែក សម្រាប់ការយល់ដឹងនិងការដោះស្រាយជាមួយជនខិលខូចបំពារបំពាន ផ្លូវភេទកុមារនៅទូទាំងតំបន់ អាស៊ី និងអាស៊ាន។

បន្ថែមលើនេះ មានតម្រូវការក្នុងការធ្វើឯកភាពវូបនីយកម្ម ចំពោះដំណើរការដោះស្រាយ CSAM ដើម្បីធានាថា រូបភាពទាំងអស់ត្រូវបានដាក់សញ្ញាបញ្ចូលក្នុងបញ្ជី ហើយលទ្ធភាពចូលមើល ឬប្រើប្រាស់ត្រូវផ្តល់ជូនទីភ្នាក់ងារអនុវត្តច្បាប់អន្តរជាតិ។ បច្ចុប្បន្ននេះ នៅពេលនគរបាលក្នុងប្រទេសមួយរកឃើញ CSAM គឺសម្ភារទាំងនេះមិនត្រូវបានបញ្ជូនទៅកាន់នគរបាលអន្តរជាតិឡើយហើយគឺជាការចាំបាច់ ដែលត្រូវធ្វើឯកភាពវូបនីយកម្មចំពោះដំណើរការនិងបទដ្ឋាន សម្រាប់ឆ្លើយតបនឹងការរក្សាទុក CSAM ដោយសម្ងាត់ រវាងទីភ្នាក់ងារអនុវត្តច្បាប់អន្តរជាតិ និងជាតិ។ ការធ្វើបែបនេះ ទាមទារនូវការបង្កើតទំនាក់ទំនងប្រកបដោយសុវត្ថិភាពមួយរវាងការិយាល័យ NBC នៅរាជធានីភ្នំពេញ និងនគរបាលអន្តរជាតិ ដើម្បីសម្របសម្រួលដំណើរការនេះ។

ក៏មានតម្រូវការគួរឲ្យកត់សម្គាល់ផងដែរ ឲ្យមានមន្ត្រីក្នុងវិស័យយុត្តិធម៌ព្រហ្មទណ្ឌ ដែលអាចយល់ និងប្រើប្រាស់គេហទំព័រងងឹតដែលជាអ្នកសម្របសម្រួលការផ្សាយផ្ទាល់ តាមរយៈការភ្ជាប់ទំនាក់ទំនងជនខិលខូចជាមួយជនរងគ្រោះ។ បច្ចុប្បន្ននេះ ទីភ្នាក់ងារអនុវត្តច្បាប់ អនុវត្តការងារបែបឆ្លើយតប ចំពោះបទល្មើស ប៉ុន្តែមានតម្រូវការឲ្យមានការអនុវត្តន៍បែបត្រៀមទប់ទល់ជាមុនថែមទៀត ក្នុងការស៊ើបអង្កេតបញ្ហានានាទាក់ទងនឹងកិច្ចការពារកុមារដែលអាចកើតមានជាយថាហេតុ។ ស្របពេលដែលអ្នកបង្កើតច្បាប់ និងសមាជិកតុលាការមានសម្លេងខ្លាំងនៅក្នុងការបង្កើតច្បាប់ និងគោលនយោបាយសម្រាប់ផ្តន្ទាទោសបទល្មើសទាក់ទងនឹង OCSE ទីភ្នាក់ងារអនុវត្តច្បាប់អន្តរជាតិបានលើកឡើងថា អង្គភាពទាំងនេះមិនមែនជាអ្នកសង្កេតការជួរមុខដូចនគរបាល និងអ្នកឯកទេសការពារកុមារឡើយ។ ហេតុនេះ ជាការសំខាន់ គឺអ្នកប្រតិបត្តិការងារជួរមុខត្រូវទទួលបានការអនុញ្ញាតឲ្យមានតួនាទីសំខាន់ថែមទៀត ក្នុងការបង្កើតគោលនយោបាយ ដើម្បីគាំទ្រការងារជាបន្តបន្ទាប់របស់ពួកខ្លួន។

### ៥.៥.៣. អំពីក្រុមហ៊ុនផ្តល់សេវាកម្មអ៊ិនធឺណិត និងអាសយដ្ឋាន IP

ឧបករណ៍ ICT ដូចជា ទូរស័ព្ទដៃវៃឆ្លាត កុំព្យូទ័រ ថេបប្លេត ជាដើម មិនអាចភ្ជាប់អ៊ិនធឺណិតដោយផ្ទាល់បានឡើយ។ ដំបូង ឧបករណ៍ទាំងនេះត្រូវភ្ជាប់ជាមួយបណ្តាញក្នុងកន្លែងមួយ ឬ Router (ដូចជា បណ្តាញ Wifi ឬបង្គោលអង់តែនទូរស័ព្ទសិន ប្រសិនបើឧបករណ៍នេះប្រើប្រាស់អ៊ិនធឺណិតចល័ត) ហើយបន្ទាប់មក បណ្តាញនោះភ្ជាប់ទៅកាន់ក្រុមហ៊ុនផ្តល់សេវាកម្មអ៊ិនធឺណិត (ISP)។ ISP ភ្ជាប់អ៊ិនធឺណិតដោយផ្ទាល់ និងដើរតួនាទីជាផ្លូវចេញចូលសម្រាប់ឧបករណ៍នោះ (និងបណ្តាញក្នុងកន្លែងមួយ) ដើម្បីចូលទៅកាន់អ៊ិនធឺណិត។ អាចពេលណាមួយមានឧបករណ៍រាប់រយ ឬរាប់ពាន់បានភ្ជាប់ទៅកាន់បណ្តាញមួយ ហើយឧបករណ៍រាប់រយពាន់បានភ្ជាប់ទៅកាន់ ISP មួយ។ ដើម្បីធានានូវការបញ្ជូនព័ត៌មានទៅកាន់ឧបករណ៍ បានត្រឹមត្រូវនៅលើបណ្តាញដ៏ត្រឹមត្រូវនៅក្នុងទីក្រុងដ៏ត្រឹមត្រូវ

នៅក្នុងប្រទេសដ៏ត្រឹមត្រូវ ISP នឹងកំណត់អាសយដ្ឋានដោយឡែកសម្រាប់ឧបករណ៍នីមួយៗ ដើម្បីឲ្យកិច្ចការនេះដំណើរការរលូន។ គេហៅអាសយដ្ឋាននេះថា *អាសយដ្ឋាន IP*។

អាសយដ្ឋាន IP គឺជាលេខសេរីដោយឡែក ដែលត្រូវបានកំណត់ចំពោះឧបករណ៍មួយ (ដូចជាទូរស័ព្ទឆ្លាតវៃ ឬកុំព្យូទ័រ)។ ជាទូទៅ អាសយដ្ឋាននេះ គឺជាបណ្តុំនៃលេខបួនជុំ ដែលបែកចែកគ្នាដោយចំណុច "." ដូចជា ១៩២.១៦៨.០.១០០។ អាសយដ្ឋាននេះ ត្រូវកំណត់ចំពោះឧបករណ៍មួយដោយស្វ័យប្រវត្តិ ពី ISP សម្រាប់កំណត់អត្តសញ្ញាណឧបករណ៍ ដើម្បីឲ្យអាចបញ្ជូនព័ត៌មានយ៉ាងត្រឹមត្រូវពីឧបករណ៍មួយតាមរយៈ ISP ទៅកាន់អ៊ិនធឺណិត និងត្រលប់ទៅឧបករណ៍នោះវិញ។ ហេតុនេះ អ្វីគ្រប់យ៉ាងដែលអ្នកប្រើប្រាស់ធ្វើនៅលើអ៊ិនធឺណិតត្រូវបានភ្ជាប់ទៅកាន់អាសយដ្ឋាននេះដោយស្វ័យប្រវត្តិ និងអាចកំណត់អត្តសញ្ញាណបាន។

បណ្តាញ និង ISP ភាគច្រើន ប្រើប្រាស់អាសយដ្ឋាន IP "ថាមវន្ត"។ មានន័យថា អាសយដ្ឋាន IP ថ្មីត្រូវបានកំណត់សម្រាប់គ្រប់ឧបករណ៍ទាំងអស់ នៅពេលឧបករណ៍ទាំងនោះត្រូវបានបើក និងភ្ជាប់ទៅកាន់អ៊ិនធឺណិតម្តងៗ។ ដោយសារអាសយដ្ឋាន IP តែងតែផ្លាស់ប្តូរ ត្រូវមានកំណត់ត្រាលម្អិត ដើម្បីដឹងថា តើអាសយដ្ឋាន IPអ្វីខ្លះដែលត្រូវបានកំណត់សម្រាប់ឧបករណ៍ជាក់លាក់មួយ នៅពេលជាក់លាក់ណាមួយ។ កំណត់ត្រាទាំងនេះ គេហៅថា *"កំណត់ត្រាអំពីការកំណត់ IP"*។ ឧទាហរណ៍ ប្រសិនបើនរណាម្នាក់ផ្ញើសារពីកុំព្យូទ័រយួរដៃ តាមរយៈ Facebook នៅម៉ោង ៨:៣០ ព្រឹក ISP អាចកំណត់អាសយដ្ឋាន ០.០.០.១ សម្រាប់កុំព្យូទ័រនោះបាន។ ប្រសិន បើបុគ្គលនោះបិទកុំព្យូទ័រនោះ ហើយបន្ទាប់មកភ្ជាប់ម្តងទៀតនៅម៉ោង ១១:៣០ព្រឹក នោះ ISP អាចកំណត់ អាសយដ្ឋាន ០.០.០.២ សម្រាប់កុំព្យូទ័រនោះ ហើយអាសយដ្ឋានលើកមុន (០.០.០.១) អាចត្រូវបានកំណត់ចំពោះកុំព្យូទ័រយួរដៃមួយផ្សេងទៀត ដែលកំពុងភ្ជាប់អ៊ិនធឺណិតនៅម៉ោង ១១:៣០ព្រឹកដែរ។ *កំណត់ត្រាអំពីការកំណត់ IP"* នឹងរក្សាទុកជាននៃទីតាំងរបស់អាសយដ្ឋាន IP នៅពេលណាមួយ ប្រភេទកុំព្យូទ័រដែលទទួលបានអាសយដ្ឋាននេះ និងព័ត៌មានពាក់ព័ន្ធផ្សេងទៀតអំពី ឧបករណ៍ជាក់លាក់ និងការប្រើប្រាស់អ៊ិនធឺណិត។

នៅពេលទីភ្នាក់ងារ ឬស្ថាប័នការពារកុមារ ឬជាទីភ្នាក់ងារ ឬស្ថាប័នអនុវត្តច្បាប់ ដូចជា NCMEC នគរបាលអន្តរជាតិ ឬ អង្គការ APLE កំណត់បានករណី CSAM ថ្មី ដែលកំពុងត្រូវបានចែកចាយ ជាទូទៅ របាយការណ៍នេះមានអាសយដ្ឋាន IP នោះ។ ដើម្បីដឹងអំពីទីតាំងជាក់ស្តែង ដែលជាប្រភពដើមនៃសម្ភារនោះ និងបុគ្គលដែលកំពុងចែកចាយសម្ភារនេះ ទីភ្នាក់ងារ ឬ ស្ថាប័ន ចាំបាច់ត្រូវទទួលបាន "កំណត់ត្រាអំពីការកំណត់ IP" ដែលជាកម្មសិទ្ធិរបស់ ISP។ នៅសហរដ្ឋអាមេរិក ISP ទាំងអស់ ត្រូវរក្សាទុកកំណត់ត្រានេះ មានរយៈពេលយ៉ាងតិច ៦ ខែ ដើម្បីឲ្យទីភ្នាក់ងារ ឬ ស្ថាប័ន អនុវត្តច្បាប់ អាចស៊ើបអង្កេតករណី ដែលបទល្មើសត្រូវបានប្រព្រឹត្តតាមអ៊ិនធឺណិត។ នៅប្រទេសកម្ពុជា គ្មានបទដ្ឋានសម្រាប់រក្សាទុកកំណត់ត្រា អំពីការកំណត់ IP នេះទេ។ ISP មួយចំនួន អាចរក្សាទុកកំណត់ត្រានេះ មានរយៈពេលគិតជាសប្តាហ៍ ក្រុមហ៊ុនផ្សេងទៀត អាចរក្សាទុកបានមាន រយៈពេលគិតជាថ្ងៃ ហើយក្រុមហ៊ុនផ្សេងទៀត អាចរក្សាទុក មានរយៈពេលគិតជាម៉ោង ដែលការរក្សាទុកបែបនេះ ពិតជាធ្វើឲ្យការស៊ើបអង្កេតមិនអាចអនុវត្តទៅបាន។

សមាជិកក្រសួងសន្តិសុខមាតុភូមិសហរដ្ឋអាមេរិក ដែលមានមូលដ្ឋាននៅប្រទេសកម្ពុជា លើកឡើងថា នេះគឺជាបញ្ហាគួរឲ្យកត់សម្គាល់ ដែលរារាំងទីភ្នាក់ងារ ឬ ស្ថាប័ន អនុវត្តច្បាប់កម្ពុជា ពីការស៊ើបអង្កេតព័ត៌មាន ដែលពួកគេទទួលបានតាមរយៈ NCMEC។ ដោយសារ ជាទូទៅ OCSE ត្រូវបានកំណត់ឃើញដោយប្រើប្រាស់អាសយដ្ឋាន IP ការដឹងអំពីទីកន្លែងប្រព្រឹត្តបទល្មើស (ចែកចាយ CSAM) មិនអាចធ្វើបាន ដោយគ្មានកំណត់ត្រាទាំងនេះ ដែលអនុញ្ញាតឲ្យទីភ្នាក់ងារ ឬ ស្ថាប័ន អនុវត្តច្បាប់ កំណត់ទីតាំងឧបករណ៍ ដែលផលិត ឬចែកចាយ CSAM ឬ បើមិន

ដូច្នោះទេ អាចបង្កការខូចខាតដល់កុមារផ្សេងទៀត។ កិច្ចការនេះ មិនសំដៅដល់ការផលិត CSAM ទេ ដោយសារ ជាញឹកញាប់ វាត្រូវការការវិភាគកោសល្យវិច្ច័យច្រើនលើរូបភាព និងវីឌីអូ។




## ៤.៦. បញ្ហាប្រឈមចំពោះការស៊ើបអង្កេត

ស្របពេលដែលការត្រួតពិនិត្យតាមដាន តាមរយៈ NCMEC និងទីភ្នាក់ងារការពារកុមារផ្សេងទៀត មានសារៈប្រយោជន៍ ធនធានទាំងនេះពឹងផ្អែកលើសមត្ថភាពក្នុងការតាមដានអាសយដ្ឋាន IP ដើម្បីកំណត់បាននូវឈ្មោះ និងទីតាំងភូមិសាស្ត្រជាក់លាក់ ដើម្បីស៊ើបអង្កេតបទល្មើស។ ខណៈដែលការពង្រឹងការចុះបញ្ជីថ្នាក់ជាតិ និង ការកត់ត្រាអំពី អាសយដ្ឋាន IP ជួយបានយ៉ាងច្រើន នៅក្នុងការផ្តល់កិច្ចការពារកាន់តែប្រសើរ ដល់កុមារនៅទូទាំងប្រទេស នៅតែមានភាពងាយរងគ្រោះមួយចំនួនទៀត ដែលកំពុងទទួលរងការកេងប្រវ័ញ្ច និងដែលធ្វើឲ្យជនខិលខូច បន្តមានសុវត្ថិភាព ហើយកុមារបន្តមានហានិភ័យ។ បញ្ហាទាំងនេះ រួមមានការអនុវត្តន៍ច្បាប់ ទាក់ទងនឹងការចុះបញ្ជីស៊ីមកាត បណ្តាញ Peer-to-Peer (P2P) និង "គេហទំព័រងងឹត" សម្រាប់រក្សាអនាមិកភាព។

### ៤.៦.១. ស៊ីមកាតដែលមិនត្រូវបានចុះបញ្ជី

ស៊ីមកាតទូរស័ព្ទដៃវៃឆ្លាតជាច្រើន នៅក្នុងប្រទេសកម្ពុជា មិនត្រូវបានចុះបញ្ជីឡើយ ហេតុនេះ អាសយដ្ឋាន IP ទាក់ទងនឹងទូរស័ព្ទដៃវៃឆ្លាតទាំងនេះ មិនអាចភ្ជាប់ទំនាក់ទំនងជាមួយម្ចាស់ទូរស័ព្ទបានឡើយ ដែលធ្វើឲ្យការស៊ើបអង្កេតបទល្មើស ទាក់ទងនឹងការភ្ជាប់អ៊ិនធឺណិតរបស់ទូរស័ព្ទនោះ មានការលំបាក។ ពីមុនមក ក្រុមហ៊ុនទូរគមនាគមន៍ចល័តទាំងអស់ ចាំបាច់ត្រូវផ្តល់អត្តសញ្ញាណសម្គាល់ខ្លួន នៅពេលអតិថិជនជាវស៊ីមកាតថ្មី។ ថ្វីបើលក្ខខណ្ឌផ្លូវច្បាប់ តម្រូវឲ្យក្រុមហ៊ុនទូរគមនាគមន៍ទាំងអស់ ត្រូវចុះបញ្ជីអ្នកប្រើប្រាស់ស៊ីមកាតថ្មី ជាមួយអត្តសញ្ញាណសម្គាល់ខ្លួនក៏ដោយ ក៏បទបញ្ញានេះមិនត្រូវបានអនុវត្តជាទូទៅឡើយ។ លើសនេះទៀត ក្រុមហ៊ុនទូរគមនាគមន៍ជាច្រើនទៀត បានចាប់ផ្តើមចូលក្នុងទីផ្សារនេះ ហើយការប្រកួតប្រជែងគ្នា បានកើនឡើង ដែលមានក្រុមហ៊ុនថ្មីមួយចំនួន បានចាប់ផ្តើមចែកស៊ីមកាតឥតគិតថ្លៃ ដែលស៊ីមកាតភាគច្រើន មិនត្រូវចុះបញ្ជីឡើយ ជាហេតុធ្វើអ្នកប្រើប្រាស់ នៅតែមានអនាមិកភាព។

នៅឆ្នាំ២០១៥ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ និងអគ្គស្នងការដ្ឋាននគរបាលជាតិ បានចេញកាលបរិច្ឆេទកំណត់ដំបូងមួយ ឲ្យក្រុមហ៊ុនផ្តល់សេវាកម្មទូរស័ព្ទដៃវៃឆ្លាត ចុះបញ្ជីអ្នកប្រើប្រាស់ទាំងអស់របស់ខ្លួន។ កាលបរិច្ឆេទកំណត់នេះ ត្រូវបានពន្យាពេលជាច្រើនដង ចាប់តាំងពីពេលនោះមក បន្ទាប់ពីមានសំណើពីក្រុមហ៊ុនប្រតិបត្តិករទូរស័ព្ទចល័តធំៗ៣ នៅប្រទេសកម្ពុជា (Viettel សែលកាត និងស្មាតAxiata) ដែលស្នើសុំពេលបន្ថែមទៀត ដើម្បីអនុវត្តតាមបទបញ្ជានេះ។ កាលបរិច្ឆេទចុងក្រោយសម្រាប់ការចុះបញ្ជីនៅទូទាំងប្រទេស ត្រូវបានពន្យាពេលទៅដល់ថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៨។ បន្ទាប់ពីកាលបរិច្ឆេទនេះ ក្រុមហ៊ុនទូរគមនាគមន៍ទាំងអស់នៅប្រទេសកម្ពុជា ត្រូវធានាថា អ្នកប្រើប្រាស់ស៊ីមកាតទាំងអស់របស់ខ្លួន ត្រូវបានចុះបញ្ជី។[56]

និយ័តករទូរគមនាគមន៍កម្ពុជា លើកឡើងថា ប្រតិបត្តិករទូរស័ព្ទដៃវៃឆ្លាត បានបង្ហាញនូវការប្តេជ្ញាចិត្តល្អក្នុងការអនុវត្តន៍តាមបទបញ្ជាថ្មីនេះ ប៉ុន្តែភាពខ្វះចន្លោះ តែងតែនៅកើតមានជាមួយនឹងអ្នកចែកចាយក្នុងស្រុក ដែលលក់ស៊ីមកាតជំនួសមុខក្រុមហ៊ុនប្រតិបត្តិករទូរស័ព្ទដៃវៃឆ្លាត។ ស្របពេលដែលប្រតិបត្តិករទូរស័ព្ទ ទាមទារឲ្យអ្នកចែកចាយ ផ្តល់ព័ត៌មានចុះបញ្ជីរបស់អតិថិជន ជាញឹកញាប់ អ្នកចែកចាយត្រូវបានគេលើកឡើងថា បានផ្តល់ព័ត៌មានចុះបញ្ជីមិនត្រឹមត្រូវ ឬក្លែងក្លាយ ដែលជាវិធីកាត់បន្ថយពេលវេលា និងការចំណាយ។ ទោះជាបែបនេះក៏ដោយ ក៏និយ័តករទូរគមនាគមន៍កម្ពុជា បានប៉ាន់ស្មានឃើញដែរថា ស៊ីមកាតដែលមិនទាន់បានចុះបញ្ជី បច្ចុប្បន្ននេះមានចំនួនតិចជាង១០% ប៉ុន្តែនៅតែកំណត់ដដែលថា ត្រូវឲ្យបន្តអនុវត្តការចុះបញ្ជី ឲ្យបានទូទាំងប្រទេស។

## ៤.៤.២. គេហទំព័រងងឹត

គេហទំព័រងងឹត គឺជាផ្នែកមួយនៃបណ្តាញទូទាំងពិភពលោក (World Wide Web) ដែលខ្លឹមសាររបស់វាមិនត្រូវបានរៀបចំជាបញ្ជីដោយកម្មវិធីបើកអ៊ិនធឺណិតជាទូទៅ ដូចជា Chrome ឬ Firefox ឡើយ។ គេហទំព័រងងឹតមានគេហទំព័រដែលអាចមើលឃើញជាសាធារណៈបាន តែតាមរយៈការប្រើប្រាស់កម្មវិធីបើកអ៊ិន ធឺណិតពិសេសប៉ុណ្ណោះ (ដូចជា ToR ឬ Freenet) ដែលកម្មវិធីទាំងនេះពឹងផ្អែកលើបណ្តាញកុំព្យូទ័រ ដែលមានអន្តរទំនាក់ទំនងគ្នាដោយអនាមិកនៅជុំវិញពិភពលោក ដើម្បីបង្ហោះខ្លឹមសាររបស់វា។ បណ្តាញគេហទំព័រងងឹតនេះ មានចេតនាលាក់បាំងអាសយដ្ឋាន IP របស់អ្នកប្រើប្រាស់ ហើយដោយសារអាសយដ្ឋាន IP ត្រូវបានប្រើប្រាស់សម្រាប់កំណត់ទីតាំងរបស់អ្នកប្រើប្រាស់ និងServer ដែលកំពុងត្រូវបានប្រើប្រាស់ដើម្បីបង្ហោះគេហទំព័រ និងខ្លឹមសារដែលត្រូវបានអ្នកប្រើប្រាស់មើល[57] អ្នកប្រើប្រាស់អាចបន្តអនាមិកភាព ដោយគ្មានអ្នកណាម្នាក់ នៅក្នុងបណ្តាញស្គាល់ ឬឃើញឡើយ រាប់បញ្ចូលទាំងរដ្ឋាភិបាល និងទីភ្នាក់ងារ ឬស្ថាប័នអនុវត្តច្បាប់ផងដែរ។ ភាពផ្ទុយគ្នានៃគេហទំព័រងងឹតនេះ គឺផ្ទាំងខាងមុខនៃគេហទំព័រ ដែលមានជាស្រេចសម្រាប់សាធារណៈជនទូទៅ ប្រើប្រាស់ និងអាចស្រាវជ្រាវបាន ជាមួយនឹងឧបករណ៍ស្រាវជ្រាវលើគេហទំព័រជាបទដ្ឋាន ដូចជា Google។

ជាទូទៅ គេហទំព័រងងឹតត្រូវបានប្រើប្រាស់ដោយអ្នកសារព័ត៌មាន អ្នកស្រាវជ្រាវ និងអ្នកស្វែងរកការគាំទ្រមតិ ផ្នែកសិទ្ធិមនុស្ស ដើម្បីឲ្យពួកគេមានអនាមិកភាព និងមានការការពារ នៅពេលរៀបចំជាព័ត៌មានចារកម្ម និងនៅក្នុងតំបន់មានហានិភ័យ។ ប៉ុន្តែ នៅប៉ុន្មានឆ្នាំថ្មីៗនេះ គេហទំព័រងងឹតនេះ ត្រូវបានជ្រើសរើសយកទៅប្រើប្រាស់ដោយបុគ្គលដែលមានបំណងប្រើប្រាស់វា សម្រាប់ធ្វើសកម្មភាពខុសច្បាប់ មានដូចជា អំពើជួញដូរមនុស្ស និងការជួញដូរគ្រឿងញៀន អាវុធ ផលិតផល និងសេវាកម្មខុសច្បាប់ផ្សេងទៀត។ ជាទូទៅ ជននិយមរួមភេទជាមួយកុមារ

---

[56] Chan, S. "រដ្ឋាភិបាល បានចេញកាលបរិច្ឆេទកំណត់ សម្រាប់ការចុះបញ្ជីអ្នកប្រើប្រាស់ស៊ីមកាត" ចូលមើលនៅថ្ងៃទី១៥ ខែតុលា ឆ្នាំ ២០១៨ ពី https://www.khmertimeskh.com/50505669/government-issues-final-deadline-to-register-sim-card-users/

[57] Technopedia. (n.d.).

ប្រើប្រាស់គេហទំព័រងងឹតនេះ ជាធនធានមួយសម្រាប់ធ្វើទំនាក់ទំនងគ្នា ដោយអនាមិក បង្កើតបណ្តាញទំនាក់ទំនងសង្គម និងបណ្តាញធនធាន ព្រមទាំងចែករំលែក CSAM/CSEM។ NCMEC លើកឡើងអំពីការទទួលបានរបាយការណ៍សាធារណៈមួយចំនួន អំពីករណី CSAM/CSEM តាមគេហទំព័រងងឹត។ ប៉ុន្តែរបាយការណ៍ទាំងនេះ នៅមានកម្រិតណាស់ ដោយសារវាពឹងផ្អែកលើការផ្តួចផ្តើមរបស់សាធារណៈជន ក្នុងការរាយការណ៍ ដែលវាមិនមែនជាអ្វីម្យ៉ាង ក្រុមហ៊ុនផ្តល់សេវាកម្មអេឡិចត្រូនិក ចាប់យកបានជាទូទៅឡើយ។

### ៤.៤.៣. បណ្តាញ Peer-to-Peer (P2P)

បណ្តាញ Peer-to-Peer (P2P) គឺជាយន្តការមានប្រជាប្រិយបំផុតសម្រាប់ទទួលបាន និងចែកចាយ CSAM/CSEM[58]។ បណ្តាញទាំងនេះ ផ្តល់វិធីមួយសម្រាប់អ្នកប្រើប្រាស់ ចែករំលែកឯកសារដោយផ្ទាល់ រវាងមនុស្សពីរនាក់ ឬច្រើននាក់ ដោយមិនចាំបាច់រក្សាទុកឯកសារទាំងនោះនៅលើ Server កណ្តាល[59]។ បណ្តាញនេះអនុញ្ញាតឲ្យអ្នកប្រើប្រាស់ ផ្ទេរឯកសារពីអាសយដ្ឋាន IP មួយទៅអាសយដ្ឋាន IP មួយទៀត ដោយមិនបង្ហាញអត្តសញ្ញាណនៃបណ្តាញរបស់ពួកគេ ឬឧបករណ៍ដែលពួកគេកំពុងប្រើប្រាស់នោះឡើយ។ ការស្រាវជ្រាវអំពី CSAM/CSEM តាមបណ្តាញ P2P បានបង្ហាញចំនួនចរាចរណ៍យ៉ាងច្រើននៅលើបណ្តាញទាំងនេះ ដែលត្រូវបានបង្កើតឡើងសម្រាប់សម្ភារបែបនេះ។ ទោះបីជាយ៉ាងណា ស្របពេលដែល CSAM/CSEM តំណាងឲ្យចំនួនចរាចរណ៍យ៉ាងច្រើន វាមិនត្រូវបានជឿជាក់ថា ជាភាគច្រើននៃចរាចរណ៍នៅលើបណ្តាញទាំងនេះឡើយ ដោយសារមានការសាកសួរតែ១% ប៉ុណ្ណោះ ដែលត្រូវបានរកឃើញថា មានជាប់ទាក់ទងនឹងសម្ភារបែបនេះ ដែលវាមានសង្គតភាពជាមួយនឹងការស្រាវជ្រាវស្រដៀងគ្នានេះ នៅក្នុងវិស័យដូចគ្នានេះ[60]។ ចាំបាច់ត្រូវធ្វើការស្រាវជ្រាវ និងការងារការពារកុមារ ច្រើនថែមទៀត ដើម្បីឆ្លើយតបទៅនឹងការទទួលបាន ក៏ដូចជាការចែកចាយ CSAM/CSEM នៅក្នុងបរិបទទាំងនេះ។

---

[58] Hurley, R., et al. (2013).

[59] Netclean. (2017).

[60] Steel, C. M. S. (2009).

# ជំពូកទី៥: សមត្ថភាព និងបញ្ហាប្រឈមរបស់ប្រទេសកម្ពុជា

## ៥.១. យុត្តិធម៌ព្រហ្មទណ្ឌ

កង្វះទិន្នន័យអំពីករណីទាក់ទងនឹង OCSE ដែលត្រូវបានរាយការណ៍ពីភ្នាក់ងារ ឬស្ថាប័នអនុវត្តច្បាប់មូលដ្ឋាន ត្រូវបានលើកឡើងថា ជាបញ្ហាប្រឈម គួរឲ្យកត់សម្គាល់ ក្នុងកំឡុងពេល១០ឆ្នាំមកហើយ។ បញ្ហានេះ គឺជាបញ្ហាជាក់ស្តែង ជាពិសេសនៅអាស៊ី ដោយសារប្រទេសជាច្រើនគ្មានយន្តការរាយការណ៍ជាតិ គួរឲ្យជឿជាក់បាន ដែលមានលក្ខណៈរួមបញ្ចូលជាមួយនឹងទីភ្នាក់ងារ ឬស្ថាប័នជាតិ អនុវត្តច្បាប់។ យន្តការជាតិ ចាំបាច់ត្រូវឆ្លើយតបយ៉ាងសកម្ម ចំពោះបញ្ហា OCSE លើផ្នែកជាច្រើន មានដូចជា ការចាប់ដៃគូជាមួយផ្នែកហិរញ្ញវត្ថុ ការបង្កើនការយល់ដឹង ជុំវិញប្រព័ន្ធទូទាត់ការចំណាយផ្សេងៗ ដែលត្រូវបានប្រើប្រាស់ សម្រាប់បង់លុយដល់អ្នកផលិត CSAM រួមមាន Western Union, Wing, Cryptocurrency និង ទម្រង់អនាមិកផ្សេងទៀតនៃការផ្ញើ ឬ វេរលុយ។ ប្រព័ន្ធទាំងឡាយបែបនេះ ត្រូវបានបង្កើតឡើងយ៉ាងល្អ នៅទូទាំងតំបន់អាស៊ីអាគ្នេយ៍។

### ៥.១.១. ការយល់ដឹង និងសមត្ថភាពរបស់ទីភ្នាក់ងារ ឬស្ថាប័នជាតិ អនុវត្តច្បាប់

ប្រទេសកម្ពុជា បានបង្កើតនាយកដ្ឋានប្រឆាំងអំពើជួញដូរមនុស្ស និងការពារអនីតិជន (AHTJP) និងនាយកដ្ឋានប្រឆាំងបទល្មើសបច្ចេកវិទ្យា នៅក្រោមអគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ និងបានបង្កើតការិយាល័យប្រតិបត្តិការតាមបច្ចេកវិទ្យា នៃស្នងការស្រាវជ្រាវព័ត៌មានសន្តិសុខកងរាជអាវុធហត្ថលើផ្ទៃប្រទេស។ ស្របពេលដែលមានមន្ត្រីនគរបាលយុត្តិធម៌ និងមានអាណត្តិOCSE អង្គភាពជំនាញពាក់ព័ន្ធខាងលើ មិនទាន់បានកំណត់អាទិភាព ការទទួលខុសត្រូវ ឬយន្តការជាក់លាក់សម្រាប់ឆ្លើយតបចំពោះ OCSEឡើយ។ នៅក្នុងការអនុវត្តផ្ទាល់ ជាទូទៅនាយកដ្ឋានប្រឆាំងបទល្មើសបច្ចេកវិទ្យា មានការទទួលខុសត្រូវចំពោះបទល្មើសពាក់ព័ន្ធនឹងកុំព្យូទ័រ ហើយ AHTJP ឆ្លើយតបចំពោះបទល្មើសពាក់ព័ន្ធនឹងអំពើជួញដូរ និងការកេងប្រវ័ញ្ចកុមារ។ ហេតុនេះ ករណីកេងប្រវ័ញ្ចកុមារ តែងតែចាប់ផ្តើមជាមួយនឹង AHTJP ហើយប្រសិនបើករណីកេងប្រវ័ញ្ចកុមារពាក់ព័ន្ធនឹងបច្ចេកវិទ្យានោះ ករណីនេះ នឹងត្រូវបញ្ជូនទៅកាន់អង្គភាពប្រឆាំងបទល្មើសបច្ចេកវិទ្យា ដើម្បីពិនិត្យភស្តុតាង និងស៊ើបអង្កេត។

ស្របពេលដែលអង្គភាពប្រឆាំងបទល្មើសបច្ចេកវិទ្យា បានក្លាយជាអង្គភាពដែលផ្អែកលើភាពជាក់ស្តែង ដើម្បីទទួលខុសត្រូវលើការតាមដានបន្ត និងស៊ើបអង្កេតបទល្មើសទាក់ទងនឹង OCSE អង្គភាពនេះ គឺជាក្រុមតូចមួយ ដែលមានមន្ត្រីប្រហែល១០នាក់ ជាមួយធនធានមានកម្រិត និងអាណត្តិធំ គ្របដណ្តប់លើបទល្មើសទាក់ទងនឹងកុំព្យូទ័រជាច្រើន មានដូចជា ចោរលួចអត្តសញ្ញាណ ការជ្រៀតចូលដោយគ្មានការអនុញ្ញាត និងការសម្អាតលុយកខ្វក់។ ដោយសារអាណត្តិដ៏ធំនេះ អ្នកស្វែងរកការគាំទ្រមតិផ្នែកកិច្ចការពារកុមារអន្តរជាតិ បង្ហាញថា ក្រុមនេះខ្វះព័ត៌មានដែលអាចផ្តល់ ឬទទួលបានតាមប្រព័ន្ធអេឡិចត្រូនិក (Bandwidth) សម្រាប់ឆ្លើយតបចំពោះក្តីបារម្ភទាក់ទងនឹងកិច្ចការពារកុមារតាមប្រព័ន្ធអ៊ិនធឺណិត។

#### ៥.១.១.១ នគរបាលប្រឆាំងអំពើជួញដូរមនុស្ស និងការពារអនីតិជន (AHTJP)

**បទពិសោធន៍ និងការយល់ដឹងអំពីការកេងប្រវ័ញ្ចផ្លូវភេទកុមារ តាមប្រព័ន្ធអ៊ិនធឺណិត**

ការយល់ដឹងអំពី OCSE ក្នុងចំណោមនគរបាលជាតិ (រួមទាំង AHTJP) ហាក់ដូចជាមានកម្រិតត្រឹមតែទំនាក់ទំនងដោយផ្ទាល់រវាងមនុស្សពេញវ័យ និងកុមារ នៅក្រៅបរិយាកាសអ៊ិនធឺណិតប៉ុណ្ណោះ។ អ្នកដឹកនាំនៅក្នុង

ជួរនគរបាលជាតិ មិនបង្ហាញនូវការយល់ដឹងច្បាស់អំពី OCSE ជាទូទៅ ឬទំហំនៃតួនាទីរបស់អ៊ិនធឺណិត ជាកន្លែងសម្រាប់ការកេងប្រវ័ញ្ចផ្លូវភេទលើកុមារនៅក្នុងសហគមន៍កម្ពុជាឡើយ។ ភាគច្រើននៃការយល់ដឹង ហាក់ដូចជាប្រមូលផ្តុំលើករណីនៃការរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទកុមារតាមបែបប្រពៃណី ដែលជនខិលខូចប្រើប្រាស់កម្មវិធីតាមប្រព័ន្ធអ៊ិនធឺណិត (ជាពិសេសតាម Facebook) សម្រាប់រៀបចំការជួបជាមួយកុមារផ្ទាល់ ដើម្បីរំលោភបំពានកុមារ នៅក្រៅអ៊ិនធឺណិត។ ការយល់ដឹងនេះ ហាក់ដូចជាមាននៅជុំវិញករណីមានស្រាប់ ឬករណីពីមុនមកដែលត្រូវបានរាយការណ៍ដោយផ្ទាល់ទៅកាន់អង្គភាពរបស់ពួកគេ ដែលភាគច្រើន ពាក់ព័ន្ធនឹងករណីកេងប្រវ័ញ្ចផ្លូវភេទកុមារ តាមបែបប្រពៃណី។ មន្ត្រីមួយចំនួនមិនទាន់មានការយល់ដឹងច្បាស់លាស់អំពីការរំលោភបំពានតាមប្រព័ន្ធអ៊ិនធឺណិត ដោយជនខិលខូច ដែលស្ថិតនៅឯប្រទេស មួយទៀតនោះឡើយ។ ដោយឡែក នគរបាលជំនាញប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ជាពិសេសមន្ត្រីដែលធ្វើការស៊ើបអង្កេតលើករណីរំលោភបំពានផ្លូវភេទកុមារ និងការធ្វើអាជីវកម្មផ្លូវភេទលើកុមារ មានការយល់ដឹងអំពីជំនាញស៊ើបអង្កេត ប្រមូលព័ត៌មាន កំណត់អត្តសញ្ញាណជនរងគ្រោះនិងជនសង្ស័យ តែការយល់ដឹងអំពីការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាឆ្លើយតបទៅនឹងបទល្មើសរំលោភបំពានផ្លូវភេទតាមប្រព័ន្ធអនឡាញនៅមានកម្រិត។ ខណៈពេលនេះដែរមានការខ្វះខាតឧបករណ៍សម្ភារដែលបម្រើដល់ការស៊ើបអង្កេតចំពោះបទល្មើសនេះ។ បច្ចុប្បន្ន នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន បានស្នើអ្នកជំនាញឯកទេស ដើម្បីជួយបណ្តុះបណ្តាលមន្ត្រីជំនាញស៊ើបអង្កេតប្រឆាំងបទល្មើសរំលោភបំពានផ្លូវភេទកុមារតាមប្រព័ន្ធអនឡាញ ដើម្បីឆ្លើយតបនឹងបទល្មើសទាំងអស់ដែលកំពុងកើតមានឡើង។ (នៅមានការពិភាក្សាជាមួយជំនាញបន្ថែមទៀត)

នគរបាលបង្ហាញនូវការយល់ដឹងជាក់លាក់អំពីភាពរងគ្រោះរបស់កុមារក្នុងសហគមន៍ ដែលមានចំណូលទាប ហើយការសន្និដ្ឋានជាទូទៅ នៅក្នុងចំណោមទីភ្នាក់ងារ ឬស្ថាប័នអនុវត្តច្បាប់ គឺថា OCSE គឺជាបញ្ហាដែលប្រព្រឹត្តដោយជនបរទេស។ មន្ត្រីជាន់ខ្ពស់ម្នាក់ មកពីនគរបាលជាតិ បង្ហាញថា ករណីទាក់ទងនឹង OCSE តែមួយគត់ដែលគាត់ធ្លាប់ជួប គឺជាករណីពាក់ព័ន្ធនឹងជនខិលខូចជាជនបរទេស និងលើកឡើងថា គាត់គ្មានព័ត៌មានអំពីបញ្ហាទាក់ទងនឹងជនខិលខូចជាជនកម្ពុជាឡើយ។ នេះប្រហែលដោយសារករណី OCSE ជាច្រើនដែលមានអត្តសញ្ញាណរបស់ជនខិលខូច គឺត្រូវបានបញ្ជូនមកពីនគរបាលអន្តរជាតិ ដែលការផ្តោតការយកចិត្តទុកដាក់របស់ពួកគេ គឺទៅលើបទល្មើសឆ្លងដែន ដែលជាញឹកញាប់ត្រូវប្រព្រឹត្តដោយជនបរទេស។

**នៅក្នុងតំបន់ខេត្តសៀមរាប មន្ត្រី AHTJP ដ៏សំខាន់ម្នាក់ សង្កេតឃើញថា កុមារភាគច្រើន** ដែលពាក់ព័ន្ធក្នុង OCSE (ជាពិសេសCSAM) គឺជាកុមារដែលរស់នៅតាមផ្លូវ ដោយបង្ហាញថា ជនខិលខូចផ្តល់ការឧបត្ថម្ភជាហិរញ្ញវត្ថុ ហើយមានករណីខ្លះ ហូតចិញ្ចឹមពួកគេទៀតផង។ ទីភ្នាក់ងារ ឬស្ថាប័នអនុវត្តច្បាប់ បង្ហាញថា យុវវ័យនឹងមើលឃើញរូបភាព ឬវីឌីអូអាសអាភាសតាមប្រព័ន្ធអ៊ិនធឺណិត និងមានបំណងធ្វើតាមអ្វីដែលពួកគេឃើញ។ មន្ត្រីម្នាក់បង្ហាញពីការកើនឡើងចំនួនករណីនានា ដែលសមាជិកសហគមន៍រាយការណ៍អំពីកុមារដែលបានចូលរួមពាក់ព័ន្ធផ្លូវភេទជាមួយជនខិលខូច ដើម្បីប្តូរនឹងការឧបត្ថម្ភជាហិរញ្ញវត្ថុ មានជាទម្រង់ផ្សេងៗ។ ករណីបែបនេះ ជាច្រើនបង្ហាញនូវទំហំនៃការបង្កើតបណ្តាញ ក្នុងចំណោមយុវវ័យ ដែលមានការលើកឡើងថា ពួកគេបានជួលបន្ទប់ និងរស់នៅជាមួយគ្នា ដោយបែកចេញពីឪពុកម្តាយរបស់ពួកគេ។ មន្ត្រីទាំងឡាយ ហាក់ដូចជាភ្ជាប់ទំនាក់ទំនងជនរងគ្រោះ ក្នុងបរិបទនេះជាមួយនឹងកុមារដែលមិនស្តាប់បង្គាប់ ដោយរៀបរាប់ថា ពួកគេគឺជាអ្នកប្រើប្រាស់គ្រឿងញៀន ជាសិស្សឈប់រៀន និងជា "កុមារជំទង់ដែលមិនចូលចិត្តរស់នៅជាមួយគ្រួសាររបស់ខ្លួន"។

ស្របពេលដែលមន្ត្រីមួយចំនួន បង្ហាញនូវការយល់ដឹងតិចតួចអំពីការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអ៊ិនធឺណិត ទំនងថា អ៊ិនធឺណិត (ជាពិសេសកម្មវិធីទូរស័ព្ទដៃវៃឆ្លាត) អាចដើរតួនាទីយ៉ាងសំខាន់ក្នុងការសម្របសម្រួលករណី ដូចករណីទាំងនេះ នេះបើតាមការពិភាក្សាដោយកុមារ នៅក្នុងសិក្ខាសាលារៀនសូត្រ អំពីវិស័យនេះ។ ការស្រាវជ្រាវអំពី OCSE នៅក្នុងបរិបទស្រដៀងគ្នា នៅក្នុងប្រទេសហ្វីលីពីន[61] បានរកឃើញថា បាតុភូតស្រដៀងគ្នាអំពីកុមារដែលបានក្លាយជាសមាជិកនៃ"គ្រួសារពពោះជំនួស" ឬ "ក្រុមទំនើង" ដែលផ្តល់លុយកាក់ អត្តសញ្ញាណសង្គម និងកិច្ចការពារ ដើម្បីផ្តោះប្តូរនឹងការចូលរួមរបស់ពួកគេ ក្នុងការផ្សាយផ្ទាល់ OCSE ។ បុគ្គលិកសង្គម នៅប្រទេសហ្វីលីពីន បង្ហាញអំពីការរៀបចំកម្រិតខ្ពស់នៅក្នុងករណីទាំងនេះ។ វាមិនច្បាស់ទេថា តើអាចមានភាពស្រដៀងគ្នានេះដែរឬទេ នៅក្នុងបរិបទនេះ តែទោះបីយ៉ាងណា ជាចាំបាច់គឺត្រូវមានការស្រាវជ្រាវច្រើនទៀត។

ក្នុងករណីខ្លះ ទីភ្នាក់ងារ ឬស្ថាប័នអនុវត្តច្បាប់ បង្ហាញនូវការយល់ដឹងអំពីករណី OCSE ដែលអាចកើតមានដោយផ្អែកលើភស្តុតាងប្រមូលបានពីឧបករណ៍អេឡិចត្រូនិក ដែលត្រូវបានរឹបអូសនៅក្នុងអំឡុងពេលស៊ើបអង្កេតករណីកេងប្រវ័ញ្ចផ្លូវភេទកុមារ តាមបែបប្រពៃណី។ ក្នុងករណីបែបនេះ ឧបករណ៍អេឡិចត្រូនិក ដែលជារបស់ជនខិលខូច ត្រូវបានរឹបអូស និងស្រាវជ្រាវដោយអង្គភាពប្រឆាំងបទល្មើសបច្ចេកវិទ្យា (ពិភាក្សាខាងក្រោម) ហើយសម្ភារ CSAM ត្រូវបានរកឃើញ។ ថ្នាក់ដឹកនាំអង្គការ APLE បង្ហាញថា CSAM ត្រូវបានរកឃើញនៅក្នុងករណីប្រហែល ៦០% នៃករណីស៊ើបអង្កេតជនខិលខូចផ្លូវភេទកុមារទាំងអស់។ ទោះបីជាយ៉ាងណា នៅពេលរកឃើញការលាក់ទុក CSAM ដោយសម្ងាត់ (Cashe) នគរបាលចាប់អារម្មណ៍តែលើសំណាកមួយចំនួនតូចប៉ុណ្ណោះនៃរូបភាពទាំងនោះ សម្រាប់បញ្ជូនទៅព្រះរាជអាជ្ញា ដើម្បីបង្ហាញភស្តុតាង ពាក់ព័ន្ធនឹងការចោទប្រកាន់អំពីការរំលោភបំពាន។ មន្ត្រីទាំងឡាយមិនពិចារណាទូទៅថា ការលាក់ទុក CSAM ដោយសម្ងាត់យ៉ាងពេញលេញ ជាភស្តុតាងសម្រាប់បទល្មើសផ្សេងទៀតលើកុមារ ឬចែករំលែកភស្តុតាងបែបនោះជាមួយអង្គភាពអនុវត្តច្បាប់អន្តរជាតិ ដូចជានគរបាលអន្តរជាតិ ឬមូលដ្ឋានទិន្នន័យ ICSE ឡើយ។

មន្ត្រីលើកឡើងតែករណីទាក់ទងនឹងOCSEចំនួនតិចតួចប៉ុណ្ណោះ ដែលធ្លាប់ត្រូវបានបញ្ជូនទៅកាន់នគរបាល ហើយករណីស្ទើរតែទាំងអស់ គឺជាករណីលួងលោមតាមប្រព័ន្ធអ៊ិនធឺណិត ដើម្បីកេងប្រវ័ញ្ច នៅក្នុងបរិបទក្រៅអ៊ិនធឺណិត។ ភាគច្រើននៃករណីកេងប្រវ័ញ្ចផ្លូវភេទកុមារ ត្រូវបានរាយការណ៍ដោយជនរងគ្រោះ គ្រូបង្រៀន និងអ្នកជិតខាង ដែលបានមើលឃើញភស្តុតាងនៃការប្រព្រឹត្តបទល្មើស ហើយទៅរាយការណ៍ជូននគរបាល។ មន្ត្រីសំខាន់ម្នាក់អធិប្បាយអំពីករណីមនុស្សពេញវ័យម្នាក់ដែលត្រូវបានគេរាយការណ៍ថា កំពុងបង្ហាញហ្គេមលក្ខណៈផ្លូវភេទ និងខ្លឹមសារផ្លូវភេទផ្សេងទៀតតាមប្រព័ន្ធអ៊ិនធឺណិត។ ប្រជាជននៅក្នុងសហគមន៍ បានរាយការណ៍អំពីបុគ្គលនេះ ដោយសារពួកគេបានកត់សម្គាល់ថា កុមារជាច្រើននៅជាមួយជនខិលខូច ក្នុងបរិយាកាសក្រៅអ៊ិនធឺណិត។ បញ្ហាមួយទៀតនៅក្នុងបរិបទនេះ គឺមនុស្សជាច្រើននៅក្នុងសហគមន៍កម្ពុជា មិនប្រើប្រាស់ប្រព័ន្ធតុលាការឡើយ ក្នុងស្ថានភាពដែលមានការប្រព្រឹត្តបទល្មើសផ្លូវភេទ។ ផ្ទុយមកវិញ បើមានបទល្មើសផ្លូវភេទ ពួកគេមានទិន្នាការចរចាគ្នាក្រៅផ្លូវការ។ របាយការណ៍នៅឆ្នាំ ២០១៨ របស់អង្គការសកម្មភាពដើម្បីកុមារ (APLE) រៀបរាប់អំពីបញ្ហានេះ និងអាជ្ញាធរមូលដ្ឋានដែលមានចំណេះដឹង អំពីករណីលួងលោមតាមប្រព័ន្ធអ៊ិនធឺណិត និងគំរាមកំហែង ក្នុងគោលបំណងប៉ុនប៉ងផ្លូវភេទថា បានកើតឡើងតាមរយៈ Facebook ប៉ុន្តែមិនអាចបន្តធ្វើការស៊ើបអង្កេតបានឡើយ ដោយសារគ្រួសារពាក់ព័ន្ធ គ្មានបំណងរាយការណ៍ករណីនេះ និងបានចរចាឲ្យនគរបាលបិទករណីនេះ[62]។

[61] Terre des Hommes-Netherlands. (2018).

[62]អង្គការសកម្មភាពដើម្បីកុមារ។ (2018).

ការយល់ដឹងយ៉ាងលើសលុប ក្នុងចំណោមនគរបាលជាតិ (និងមនុស្សពេញវ័យ) អំពីកុមារកំពុងមានហានិភ័យ ហាក់ដូចជាមានកម្រិតត្រឹមពិភពក្រៅអ៊ីនធឺណិត និងមិនបង្ហាញអំពីលទ្ធភាពដែលកុមារជួបប្រទះនឹងការរំលោភបំពាន ឬការកេងប្រវ័ញ្ចផ្លូវភេទ តាមបរិយាកាសអ៊ីនធឺណិតឡើយ។ ការយល់ដឹងនេះ ហាក់ដូចជាមើលរំលងតួនាទីរបស់អ៊ីនធឺណិត ដែលអាចជាកន្លែងសម្រាប់កេងប្រវ័ញ្ចផ្លូវភេទកុមារ និងមិនអើពើចំពោះទម្រង់ផ្សេងទៀតនៃ OCSE ដែលអាចកើតមាន ដូចជា ការលួងលោមសម្រាប់ផលិត និងចែកចាយ CSAM តាមអ៊ីនធឺណិត ការផ្សាយផ្ទាល់នូវការកេងប្រវ័ញ្ចផ្លូវភេទ និងករណីគំរាមកំហែង ក្នុងគោលបំណងប៉ុនប៉ងផ្លូវភេទ ដែលសុទ្ធតែត្រូវបានបង្ហាញជាទូទៅ នៅក្នុងសិក្ខាសាលារៀនសូត្រ។ ដោយសារការសន្នត់ទាំងនេះ វាហាក់ដូចជាថា មិនមានការយល់ដឹង និងមានការរាយការណ៍អំពីក្តីបារម្ភទាក់ទងនឹងកិច្ចការពារកុមារនៅក្នុងបរិយាកាសអ៊ីនធឺណិតឡើយ នៅពេលមានបទល្មើសទាំងនេះកើតឡើង។

ជារួម ការពិភាក្សាជាមួយយុវវ័យ និងមន្ត្រីអនុវត្តច្បាប់ បង្ហាញនូវភាពដាច់ឆ្ងាយពីគ្នា រវាងមនុស្សពេញវ័យ និងយុវវ័យ ដែលកំពុងប្រើប្រាស់អ៊ីនធឺណិត។ មន្ត្រីអនុវត្តច្បាប់ជាន់ខ្ពស់ម្នាក់បង្ហាញយ៉ាងច្បាស់ថា ត្រូវការឲ្យមានការចូលរួមជាមួយនគរបាលជាតិ ពីសំណាក់ពលរដ្ឋកម្ពុជាវ័យក្មេង ដែលមានពិសោធន៍ច្រើនផ្នែកបច្ចេកវិទ្យា។ បច្ចុប្បន្ននេះ ទំហំនៃការស៊ើបអង្កេតទាក់ទងនឹងកិច្ចការពារកុមារ ក្នុងចំណោមនគរបាលជាតិ ស្ទើរតែផ្តោតការយកចិត្តទុកដាក់លើសកម្មភាពរបស់ជនខិលខូច នៅក្នុងបរិយាកាសខាងក្រៅតែមួយមុខ ជាជាងលើសកម្មភាពតាមប្រព័ន្ធឌីជីថល។

### ៥.១.១.២. នាយកដ្ឋានប្រឆាំងបទល្មើសបច្ចេកវិទ្យា

នាយកដ្ឋានប្រឆាំងបទល្មើសបច្ចេកវិទ្យា នៃអគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ បានចាប់ផ្តើមដំណើរការការងារដំបូងនៅឆ្នាំ២០១៦។ ជាទូទៅ អង្គភាពនេះទទួលបានសំណើពីនាយកដ្ឋានប្រឆាំងអំពើជួញដូរមនុស្ស ដើម្បីស្រាវជ្រាវរកឧបករណ៍អេឡិចត្រូនិក ដែលរឹបអូសបាន សំដៅរកមើលឯកសារ រូបភាព ឬសម្ភារផ្សេងទៀត សម្រាប់យកទៅប្រើប្រាស់ ក្នុងការផ្តន្ទាទោសករណី។ ស្របពេលដែលអង្គភាពប្រឆាំងបទល្មើសបច្ចេកវិទ្យាមានការទទួលខុសត្រូវចំពោះការស៊ើបអង្កេតបទល្មើស ទាក់ទងនឹង OCSE ទាំងអស់ អង្គភាព នេះក៏ទទួលខុសត្រូវចំពោះបទល្មើស ទាក់ទងនឹងកុំព្យូទ័រ ឬ បច្ចេកវិទ្យាផ្សេងទៀតផងដែរ មានដូចជា បទល្មើសលើវិស័យទូរគមនាគមន៍ បទល្មើសហិរញ្ញវត្ថុតាមប្រព័ន្ធបច្ចេកវិទ្យា បទល្មើសតាមប្រព័ន្ធបណ្តាញសង្គមបច្ចេកវិទ្យា ការវាយប្រហារតាមប្រព័ន្ធកុំព្យូទ័រ សារឥតបានការតាមអ៊ីម៉ែល កលល្បិចបោកប្រាស់តាមអ៊ិនធឺណិត ឬតាមអ៊ីម៉ែល ចោរលួចអត្តសញ្ញាណ គ្រោងការទុច្ចរិតតាមប្រព័ន្ធអ៊ិនធឺណិត និងការក្លែងបន្លំជាដើម។ ស្របពេលដែលអង្គភាពប្រឆាំងបទល្មើសបច្ចេកវិទ្យា គួរដើរតួនាទីជាមជ្ឈមណ្ឌលកណ្តាលសម្រាប់បទល្មើសពាក់ព័ន្ធនឹងប្រព័ន្ធ បច្ចេកវិទ្យា ប៉ុន្តែអង្គភាពនេះ នៅមានសមត្ថភាពតិចតួចក្នុងការស្រាវជ្រាវ ស៊ើបអង្កេតបទល្មើសនានា ដែលត្រូវបានប្រព្រឹត្តតាមប្រព័ន្ធអ៊ិនធឺណិត។ បច្ចុប្បន្ននេះ ការងារ និងការបណ្តុះបណ្តាលរបស់ពួកគេ ផ្តោត លើកិច្ចការកោសល្យវិច្ច័យផ្ទាល់ចំពោះភស្តុតាង ដែលមាននៅក្នុងឧបករណ៍អេឡិចត្រូនិកប្រមូលបានពីការបង្ក្រាបបទល្មើស ជាជាងចំពោះបទល្មើសដែលត្រូវបានប្រព្រឹត្តនៅតាមប្រព័ន្ធអ៊ិនធឺណិត។ ទោះបីជាយ៉ាងណាក៏ដោយ

ការខិតខំប្រឹងប្រែងបច្ចុប្បន្ន ចំពោះការធ្វើកោសល្យវិច្ច័យឧបករណ៍បច្ចេកវិទ្យាទាំងនោះ ក៏មិនមានធនធានគ្រប់គ្រាន់ដែរ។ បទពិសោធន៍របស់នាយកដ្ឋានប្រឆាំងបទល្មើសបច្ចេកវិទ្យានៅមានកម្រិតពាក់ព័ន្ធទៅនឹងការស៊ើបអង្កេតបទល្មើស OCSE។ ដោយសារជានាយកដ្ឋានថ្មីពួកគេបាន (នៅពេលសរសេររបាយការណ៍នេះ) ស៊ើបអង្កេតតែ០៣ករណី បទល្មើសប៉ុណ្ណោះដែលពាក់ព័ន្ធOCSEនឹង១៦ករណីជាកិច្ចការកោសល្យវិច័យឧបករណ៍អេឡិចត្រូនិកពាក់ព័ន្ធនឹងកុមារ។ មន្ត្រីសំខាន់ៗលើកឡើងថា បច្ចុប្បន្ននេះ ការិយាល័យនេះ ទទួលបានករណីទាក់ទងនឹងកុំព្យូទ័រ

១ឬ២ករណី ក្នុងមួយខែ ទោះបីជាយ៉ាងណាក៏ដោយ មានករណីចំនួនតិចណាស់ណាស់ក្នុងចំណោមករណីទាំងនេះ ដែលពាក់ព័ន្ធនឹងកិច្ចការពារកុមារ ហើយមានករណីកាន់តែតិចទៅទៀត ដែលមានប្រភេទជាOCSE។ កង្វះការងារលើករណី OCSE នេះ អាចដោយសារការងារអេង្គុតាពនាយកដ្ឋានប្រឆាំងបទល្មើសបច្ចេកវិទ្យានេះ ភាគច្រើនមានលក្ខណៈឆ្លើយតប ហើយជាញឹកញាប់ ពឹងផ្អែកលើករណី OCSE ដែលត្រូវបានរាយការណ៍ទៅកាន់ AHTJP បន្ទាប់មកត្រូវបានបញ្ជូនបន្តទៅកាន់នាយកដ្ឋានប្រឆាំងបទល្មើសបច្ចេកវិទ្យា។ បច្ចុប្បន្ននេះ ហាក់ដូចជាគ្មានកិច្ចខិតខំប្រឹងប្រែង មានលក្ខណៈត្រៀមទុកជាមុន ក្នុងការឆ្លើយតបទៅនឹង OCSE ការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមអ៊ីនធឺណិត ដែលជាបញ្ហាជាតិនោះឡើយ ផ្ទុយមកវិញ នាយកដ្ឋាននេះ ធ្វើសកម្មភាពតែចំពោះការទទួលពាក្យបណ្តឹងផ្ទាល់ពីសធារណៈជន ឬទទួលកោសល្យវិច័យឧបករណ៍អេឡិកត្រូនិកដែលបញ្ជូនដាក់ស្តែង ពីស្ថាប័នរដ្ឋាភិបាលផ្សេងទៀតប៉ុណ្ណោះ។

ជាបទពិសោធន៍នៃការស៊ើបអង្កេត "លើប្រព័ន្ធអ៊ីនធឺណិត" ភាគច្រើននាយកដ្ឋានទទួលពាក្យបណ្តឹង ផ្តោតលើទំព័រ Facebook ដែលមាក់ងាយមុខមាត់សាធារណៈរបស់ជនកម្ពុជា ហើយការពិនិត្យ និងស្រាវជ្រាវលើប្រព័ន្ធអ៊ីនធឺណិតនេះផ្តោតទៅលើការលក់របស់របរខុសច្បាប់ ដូចជា គ្រឿងញៀន ឬ ឧបករណ៍ ទាក់ទងនឹងផ្លូវភេទ។ ទំហំនៃការស៊ើបអង្កេតតាមប្រព័ន្ធអ៊ីនធឺណិត គឺមានកម្រិតខ្លាំងណាស់ ហើយត្រូវបានគេរៀបរាប់ថា ត្រូវធ្វើឡើងតាមរយៈការពិនិត្យគណនីបណ្តាញទំនាក់ទំនងសង្គម ដើម្បីរកលេខទូរស័ព្ទជាសាធារណៈ និងអាសយដ្ឋាន ហើយបន្ទាប់មកតម្រូវឲ្យម្ចាស់គណនី ដកខ្លឹមសារខុសច្បាប់ចេញ។ ទាក់ទងនឹងការស៊ើបអង្កេត "តាមប្រព័ន្ធអ៊ីនធឺណិត" ចំពោះករណី CSAM អ្នកផ្តល់ព័ត៌មានសំខាន់ លើកឡើងថា ភាគច្រើននៃការករណីទាំងនេះ គឺមាននៅតាម Facebook ។ មន្ត្រីទាំងឡាយបង្ហាញថា ពួកគេគ្រាន់តែបញ្ជូនករណីបែបនេះ ទៅកាន់ក្រុមហ៊ុនFacebook ប៉ុណ្ណោះ តាមរយៈតំណភ្ជាប់ដែល Facebook ផ្តល់ឲ្យដោយសារក្រុមនេះ បានរកឃើញថា ការធ្វើរបៀបនេះលឿន និងមានប្រសិទ្ធភាព។ សមាជិកនៃក្រុមនេះ នឹងបញ្ជូនសំណើមួយទៅ Facebook និងឯកសារយោងមួយ (ជាទូទៅ ជាតំណភ្ជាប់ក្នុងអ៊ីនធឺណិត) ទាក់ទងនឹងរូបភាព CSAM ដែលមានការសង្ស័យ។ ប្រសិនបើករណី កិច្ចការពារកុមារ ពាក់ព័ន្ធនឹងគេហទំព័រជាក់លាក់ នោះនាយកដ្ឋានប្រឆាំងបទល្មើសបច្ចេកវិទ្យា នឹងបញ្ជូនអាសយដ្ឋាន IP របស់គេហទំព័រនោះទៅកាន់ក្រុមហ៊ុនផ្តល់សេវាកម្មអ៊ីនធឺណិតឯកជន ដើម្បីផ្តល់ព័ត៌មានអំពីអ្នកប្រើប្រាស់ដែលមានការសង្ស័យ។ ទោះបីជាយ៉ាងណាជាញឹកញាប់ កិច្ចការនេះមិនអាចធ្វើបានឡើយ ដោយសារក្រុមហ៊ុនផ្តល់សេវាកម្មអ៊ីនធឺណិតភាគច្រើន មិនបានរក្សាទុកកំណត់ត្រាអំពីការកំណត់ IP របស់ពួកគេ ប្រកបដោយសង្គតភាពឡើយ នេះជាបញ្ហាមួយ ដែលនឹងត្រូវបង្ហាញនៅវគ្គក្រោយទៀតនៃរបាយការណ៍នេះ។

ភាពស្មុគស្មាញបន្ថែមទៀត ចំពោះការកំណត់ CSAM គឺជាបញ្ហាសង្គមនិងវប្បធម៌ ដែលប្រជាជនពុំសូវមានការយល់ដឹងឲ្យបានទូលំទូលាយអំពីបញ្ហានៃការបង្ហោះរូបភាពអាក្រាតរបស់កុមារ នៅលើបណ្តាញទំនាក់ទំនងសង្គម ដូចជា Facebook ជាដើម។ ជាមួយគ្នានេះ ទោះបីរូបភាពអាសអាភាសនៃកុមារ ត្រូវបានបង្ហោះនិងចែកចាយក៏ដោយ ក៏នៅមានភាពស្រពិចស្រពិលនៃការយល់ឃើញរបស់ប្រជាជនថាជាបទល្មើស ឬអត់។ ដោយសារហេតុនេះទើបបង្កើតបានជាឧបសគ្គក្នុងការដោះស្រាយបញ្ហា OCSE ព្រោះសមត្ថកិច្ចទទួលបានការរាយការណ៍ផ្ទាល់ពីប្រជាជនតិចតួច នៅពេលពួកគេឃើញរូបភាពកុមារដែលកំពុងស្ថិតក្នុងគ្រោះថ្នាក់ពាក់ព័ន្ធនឹងOCSE។

**ឧបសគ្គសំខាន់ៗក្នុងកិច្ចការពារកុមារពីOCSE :** ដោយសារភស្តុតាងបានមកពីសហគមន៍ និងការពិភាក្សាស៊ីជម្រៅជាមួយមន្ត្រីអនុវត្តច្បាប់ជាតិ និងអន្តរជាតិ ហាក់ដូចជាមានឧបសគ្គដែលអាចកើតមានមួយចំនួនចំពោះការកំណត់អត្តសញ្ញាណ ការស៊ើបអង្កេត និងការផ្តន្ទាទោសបទល្មើសទាក់ទងនឹងOCSE នៅប្រទេសកម្ពុជា។

**១- កង្វះចំណេះដឹងអំពីឧបករណ៍** ICT **និងនិន្នាការនៃបច្ចេកវិទ្យា:** នគរបាលជាតិលើកឡើងថា ការយល់ដឹងរបស់មន្ត្រីអំពីបច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍ និងនិន្នាការនៃការប្រើប្រាស់បច្ចេកវិទ្យាក្នុងចំណោមយុវវ័យនៅមានកម្រិត។ ថ្វីបើមានផ្នែកព័ត៌មាននៅក្នុងការិយាល័យរបស់ពួកគេក្តី ក៏មន្ត្រីទាំងឡាយលើកឡើងថា ការធ្វើការងារជាមួយការកេងប្រវ័ញ្ចកុមារនៅក្នុងបរិយាកាសអ៊ិនធឺណិតមានការលំបាកច្រើន ហើយជាញឹកញាប់ពោរពេញទៅដោយភាពខ្វះចន្លោះគួរឲ្យកត់សម្គាល់។ មន្ត្រីម្នាក់កត់សម្គាល់ថាមនុស្សវ័យក្មេងៗ មានចំណេះដឹងច្រើនជាងមន្ត្រីជាច្រើន ដែលកំពុងធ្វើការងារសម្រាប់ឆ្លើយតបចំពោះបទល្មើសទាក់ទងនឹងអ៊ិនធឺណិត។ ហេតុនេះ ដោយមិនមានចំណេះដឹងអំពីបរិយាកាសអ៊ិនធឺណិតរបស់យុវវ័យ ឬអំពីវិធីសាស្ត្រទូទៅ ដែលជនខិលខូចប្រើប្រាស់ ដើម្បីផ្តោតគោលដៅលើយុវវ័យ ការឆ្លើយតបចំពោះការគំរាមកំហែងតាមអ៊ិនធឺណិតដែលអាចកើតមាន និងការស៊ើបអង្កេតករណីទាក់ទងនឹង OCSE នៅកម្រិតមូលដ្ឋាន គឺស្ទើរតែមិនអាចធ្វើបានឡើយ។

**២- កង្វះធនធាន នៅសហគមន៍មូលដ្ឋាន:** ដោយសារកង្វះការយល់ដឹងអំពីបច្ចេកវិទ្យានៅថ្នាក់មូលដ្ឋានស្ទើរតែគ្រប់បទល្មើសទាក់ទងនឹងកុំព្យូទ័រទាំងអស់ ត្រូវបានបញ្ជូនទៅកាន់នាយដ្ឋានប្រឆាំងបទល្មើសបច្ចេកវិទ្យានៅរាជធានីភ្នំពេញ។ កិច្ចការនេះ ទាមទារឲ្យមានមន្ត្រី ធ្វើការបញ្ជាក់អំពីពត៌មានដែលពាក់ព័ន្ធនឹងករណីដែលបានកើតនៅមូលដ្ឋាននិងផ្តល់កំណត់ត្រានេះ ជូននាយដ្ឋានប្រឆាំងបទល្មើសបច្ចេកវិទ្យា។ ការធ្វើបែបនេះនាំឲ្យមានការពន្យាពេលស៊ើបអង្កេត និងមានភាពខ្វះចន្លោះជាមួយព័ត៌មានស្តីពីករណីនោះ។

**៣- កង្វះកិច្ចសហការជាមួយអ្នកជំនាញឯកទេស និងធនធានអន្តរជាតិ:** នៅពេលរកឃើញករណីពាក់ព័ន្ធនឹងCSAM (ជាទូទៅ ក្នុងអំឡុងពេលស៊ើបអង្កេតករណីរំលោភបំពាន/កេងប្រវ័ញ្ចផ្លូវភេទកុមារតាមបែបប្រពៃណី) ជាទូទៅ មន្ត្រីរក្សាទុកសំណាករូបភាពតែមួយចំនួនតូចប៉ុណ្ណោះសម្រាប់ជាភស្តុតាងឲ្យចៅក្រមជឿជាក់លើការចោទប្រកាន់អំពីការរំលោភបំពាន/កេងប្រវ័ញ្ចនោះ។ ដែលជាហេតុមិនអាចចែករំលែកបាននៅកម្រិតអន្តរជាតិ ជូនដល់អ្នកខិតខំប្រឹងប្រែងកំណត់អត្តសញ្ញាណកុមារ តាមរយៈមូលដ្ឋានទិន្នន័យ ICSE។ មានតម្រូវការ ជាពិសេសសម្រាប់នាយកដ្ឋាននេះ ក្នុងការភ្ជាប់ទំនាក់ទំនងឲ្យបានកាន់តែល្អ ជាមួយមូលដ្ឋានទិន្នន័យ ICSE របស់នគរបាលអន្តរជាតិ ដែលមិនត្រឹមតែអាចផ្តល់ជូនពួកគេនូវសមត្ថភាពកំណត់អត្តសញ្ញាណកុមារ មាននៅក្នុង CSAM ដែលត្រូវបានរកឃើញនៅក្នុង Cashe ពីជនខិលខូចផ្លូវភេទកុមារប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងអនុញ្ញាតឲ្យមានកិច្ចសហការ និងការកសាងសមត្ថភាពជាពហុភាគីផងដែរ។ ថ្នាក់ដឹកនាំក្នុងជួរនគរបាលជាតិ បង្ហាញថាត្រូវការឲ្យមានអ្នកជំនាញឯកទេសសម្រាប់គាំទ្រដល់ការតាមដានត្រួតពិនិត្យ និងការស៊ើបអង្កេតបទល្មើសប្រភេទទាំងនេះ សំដៅឲ្យពួកគេអាចសហប្រតិបត្តិការជាមួយអ្នកជំនាញ និងចែករំលែកព័ត៌មានបាន។

**៤- ភាពពឹងផ្អែកជ្រុល លើវិធីសាស្ត្រស៊ើបអង្កេតផ្ទាល់តាមបែបប្រពៃណី:** នគរបាលជាតិ ហាក់ដូចជាដាក់ការផ្តោតការយកចិត្តទុកដាក់ស្ទើរតែទាំងស្រុង ទៅលើការស៊ើបអង្កេតតាមបែបប្រពៃណី ដែលជាញឹកញាប់សន្មត់ថាបទល្មើសនានា ត្រូវបានប្រព្រឹត្តដោយផ្ទាល់ពីសំណាក់ជនខិលខូច ដែលមានវត្តមាននៅក្នុងសហគមន៍។ ក្នុងករណី OCSE ជនខិលខូចអាចមិនមានវត្តមាននៅក្នុងទីក្រុង ឬសូម្បីតែនៅក្នុងប្រទេសនោះឡើយ ហេតុនេះ វាទាមទារឲ្យទីភ្នាក់ងារ ឬស្ថាប័នអនុវត្តច្បាប់ ពឹងផ្អែកលើវិធីសាស្ត្រស៊ើបអង្កេតតាមប្រព័ន្ធអ៊ិនធឺណិត និងមានកិច្ចការសហការកាន់តែខ្លាំងជាមួយទីភ្នាក់ងារ ឬស្ថាប័ន អនុវត្តច្បាប់អន្តរជាតិ ដែលអាចផ្តល់ធនធានចាំបាច់សម្រាប់ការស៊ើបអង្កេត និងផ្តន្ទាទោសបទល្មើស ចំពោះកុមារកម្ពុជា ដែលប្រព្រឹត្តដោយជនខិលខូចពីក្រៅប្រទេស។ នៅក្នុងការសម្ភាសមួយចំនួនបទល្មើសដែលត្រូវបានប្រព្រឹត្តនៅក្នុងបរិយាកាសក្រៅអ៊ិនធឺណិត ត្រូវបានបញ្ជូនជា "ករណីជាក់ស្តែង"- ដោយ

សង្កត់ធ្ងន់បន្ថែមទៀត ឲ្យមានការទទួលស្គាល់ថា បទល្មើសដែលត្រូវបានប្រព្រឹត្តនៅក្នុងបរិយា កាសអ៊ិនធឺណិតគឺជា "ករណីជាក់ស្តែង"។

យោងតាមអ្នកតំណាងសំខាន់ម្នាក់ មកពីនគរបាលប្រឆាំងអំពើជួញដូរមនុស្សថា ការបណ្តុះបណ្តាលមន្ត្រីអនុវត្តច្បាប់អំពី OCSE ត្រូវបានរៀបចំឡើងសម្រាប់នគរបាលកម្ពុជា ដែលគាំទ្រដោយស្ថានទូតសហរដ្ឋអាមេរិក នៅទីក្រុងបាងកក ទោះបីជាយ៉ាងណា អ្នកចូលរួមមិនបានយល់ដឹងច្រើនអំពីភាពពាក់ព័ន្ធនៃការរៀនសូត្រអំពីបច្ចេកទេស និងវិធីសាស្ត្រថ្មីនៃការអនុវត្តច្បាប់ឡើយ ហេតុនេះការចូលរួម (និងការចងចាំព័ត៌មាន) គឺមានកម្រិតទាប។ បន្ថែមលើនេះ ការប្រើប្រាស់វាក្យស័ព្ទដ៏ស្មុគស្មាញនិងមិនដែលឮពីមុនមក ត្រូវបានគេគិតថាធ្វើឲ្យមន្ត្រីមានការពិបាកស្វែងយល់ពីវគ្គបណ្តុះបណ្តាលនោះ។ បញ្ហានេះ អាចសង្កត់ធ្ងន់ទៅលើតម្រូវការឲ្យមានការរៀបជាវគ្គបណ្តុះបណ្តាលមានលក្ខណៈគិតគូរចំពោះសិក្ខាកាម និងស្របទៅតាមបរិបទសម្រាប់មន្ត្រីបច្ចុប្បន្ន ព្រមទាំងតម្រូវការឲ្យមានការជ្រើសរើសមន្ត្រី ដែលមានបទពិសោធន៍ច្រើនផ្នែកបច្ចេកវិទ្យា នាពេលអនាគត។

**៥- កង្វះអភិក្រមដែលគិតគូរអំពីជនរងគ្រោះ:** អភិក្រមដែលគិតគូរអំពីជនរងគ្រោះ ព្យាយាមផ្តល់គុណតម្លៃចំពោះការកំណត់អត្តសញ្ញាណ និងការថែទាំជនរងគ្រោះ ស្មើគ្នានឹងគុណតម្លៃ ដែលផ្តល់ចំពោះការស៊ើបអង្កេត និងការផ្តន្ទាទោសជនខិលខូចដែរ។ ស្របពេលដែលមន្ត្រី AHTJP អាចដឹងអំពីការប្រើប្រាស់អភិក្រម គិតគូរអំពីជនរងគ្រោះ ក្នុងការឆ្លើយតបចំពោះជនរងគ្រោះ ដោយសារអំពើជួញដូរមនុស្ស ទីភ្នាក់ងារ ឬស្ថាប័នជាតិអនុវត្តច្បាប់ ហាក់ដូចជាប្រើប្រាស់អភិក្រម ដែលផ្តោតតែលើជនខិលខូចច្រើនជាងក្នុងការឆ្លើយតប និងការស៊ើបអង្កេតបទល្មើសទាក់ទងនឹងអ៊ិនធឺណិតចំពោះកុមារ។ ក្នុងការឆ្លើយតបចំពោះOCSE និងបទល្មើសទាក់ទងនឹងអ៊ិនធឺណិតដែលអាចមានផ្សេងទៀត ចំពោះកុមារ ទីភ្នាក់ងារ ឬស្ថាប័នអនុវត្តច្បាប់ ហាក់ដូចជាផ្តោតការយកទុកចិត្តទុកដាក់ច្រើន ទៅលើការកំណត់អត្តសញ្ញាណ និងការផ្តន្ទាទោសជនខិលខូច (ដែលជាទូទៅអាចស្ថិតនៅក្រៅប្រទេស) ជាជាងកំណត់អត្តសញ្ញាណ និងយកទុកចិត្តទុកដាក់ចំពោះជនរងគ្រោះ។ មានករណីមួយចំនួនទីភ្នាក់ងារ ឬស្ថាប័នជាតិអនុវត្តច្បាប់ ផ្ទេរការទទួលខុសត្រូវចំពោះOCSEទៅឲ្យនគរបាល នៅប្រទេសដែលជនខិលខូចរស់នៅជាជាងនៅក្នុងប្រទេសខ្លួនឯង ដែលជនរងគ្រោះកម្ពុជារស់នៅ។ បញ្ហានេះ ហាក់ដូចជាសង្កត់ធ្ងន់បន្ថែមទៅលើតម្រូវការឲ្យមានកិច្ចសហការនិងការគាំទ្រកាន់តែខ្លាំងពីថ្នាក់តំបន់ និងថ្នាក់អន្តរជាតិ ដើម្បីមិនត្រឹមតែចែករំលែកធនធាន សម្រាប់ការស៊ើបអង្កេតករណី និងការផ្តន្ទាទោសជនខិលខូចប៉ុណ្ណោះទេ គឺថែមទាំងដើម្បីគាំទ្រដល់ការបណ្តុះបណ្តាល និងការកសាងសមត្ថភាពជាក់ស្តែងផងដែរ។

ដោយសារបទល្មើសកំពុងតែផ្លាស់ទីចេញពីសហគមន៍កាន់តែច្រើនទៅជាបរិយាកាសអ៊ិនធឺណិត ដូចនេះកុមារងាយរងគ្រោះនៅក្នុងបរិបទនេះ អាចមិនត្រូវបានគេមើលឃើញច្រើនឡើយ។ បន្ថែមលើនេះ ដោយសារប្រតិបត្តិការកុំព្យូទ័រ ពឹងផ្អែកកាន់តែច្រើនលើព័ត៌មាន ដែលត្រូវបានរក្សាទុកនៅតាមបណ្តាញអ៊ិនធឺណិត ឬត្រូវបានផ្សាយផ្ទាល់ហាដឌីស (Hard disk) និងមធ្យោបាយអេឡិចត្រូនិចសម្រាប់រក្សាទុកទិន្នន័យ នឹងចាប់ផ្តើមលែងបន្សល់ដានដែលអាចផ្តន្ទាទោសបានទៀត ហើយចំពោះបទល្មើសដែលត្រូវបានប្រព្រឹត្ត។ ហេតុនេះ ការកសាងកាន់តែខ្លាំងក្នុងការអនុវត្តច្បាប់កម្ពុជាតាមបរិយាកាសអ៊ិនធឺណិតទាំងនេះមានសារៈសំខាន់ណាស់។

## ៥.២. ការផ្តល់សេវាអ៊ិនធឺណិត

និយ័តករទូរគមនាគមន៍កម្ពុជា (ន.ទ.ក.) គឺជាសេនាធិការរបស់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ដែលទទួលបន្ទុកលើការធ្វើនិយ័តកម្មស្របតាមគោលនយោបាយ និងក្របខណ្ឌគតិយុត្តនៃវិស័យទូរគមនាគមន៍ និង

៧៨១

បទដ្ឋានគតិយុត្ត ផ្សេងៗទៀតជាធរមាននៃព្រះរាជណាចក្រកម្ពុជា។ ន.ទ.ក មានតួនាទីគោលសំខាន់គឺ ត្រួតពនិត្យ និងតាមដានការផ្ដល់សេវាទូរគមនាគមន៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា និងផ្ដល់យោបល់លើវិសោធនកម្មប្រកាស ឬលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងវិស័យទូរគមនាគមន៍។

ន.ទ.ក. អនុវត្តភារកិច្ចដែលបានចែងក្នុងច្បាប់ស្ដីពីទូរគមនាគមន៍ និងបទប្បញ្ញត្តិដែលពាក់ព័ន្ធនឹងវិស័យទូរគមនាគមន៍នៅក្នុងព្រះរាជាណាចត្រកម្ពុជា។ ជាពិសេស ន.ទ.ក. បានធ្វើការសហការធ្វើការងារជាមួយក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ក្រសួងព័ត៌មាន និងក្រសួងមហាផ្ទៃ ដើម្បីរៀបចំចាត់វិធានការទប់ស្កាត់រាល់ការប្រើប្រាស់មាតិកា ឬខ្លឹមសារមិនសមរម្យ និងព័ត៌មានពាក់ព័ន្ធនឹងកុមារ។

ន.ទ.ក. មានលទ្ធភាពស្នើឱ្យប្រតិបត្តិករទូរគមនាគមន៍ ធ្វើការទប់ស្កាត់ ព័ត៌មាន ឬមាតិកាមិនសមរម្យក្នុងប្រព័ន្ធអ៊ិនធឺណិត នៅព្រះរាជាណាចក្រកម្ពុជា ទោះជាព័ត៌មាន ឬមាតិកាត្រូវបានបង្ហោះ ឬទិន្នន័យទុកក្នុងម៉ាស៊ីនមេ (Server) នៅក្រៅប្រទេសក៏ដោយ។ ដើម្បីឈានទៅលុបបំបាត់ និងបង្រ្កាបលើព័ត៌មាន ឬមាតិកាទាំងស្រុង ន.ទ.ក. ចាំបាច់ត្រូវមានការសហការណ៍ជាមួយ ក្រុមហ៊ុន និងស្ថាប័នពាក់ព័ន្ធនៅបរទេសដែលផ្ដល់សេវាបង្ហោះគេហទំព័រ និងបណ្ដាញសង្គមដើម្បីលុប តែករណីនេះលើសពីសមត្ថកិច្ចរបស់ ន.ទ.ក.។ ចំពោះក្រុមហ៊ុនផ្ដល់សេវាបង្ហោះនៅក្រៅប្រទេសកម្ពុជា អនុវត្តច្បាប់ដែលបង្កើតដោយក្រុមហ៊ុនផ្ទាល់ដូចជា Facebook, Google, Wechat...) នេះជាមូលហេតុធ្វើឱ្យស្ថាប័នពាក់ព័ន្ធត្រូវការរយៈពេលយូរ និងមានភាពស្មុគស្មាញលើបច្ចេកទេស។ ចំពោះព័ត៌មានដែលបង្ហោះនៅក្នុងគេហទំព័រ Facebook ចាំបាច់ត្រូវសហការណ៍ជាមួយនាយកដ្ឋានប្រឆាំងបទល្មើសបច្ចេកវិទ្យានៃក្រសួងមហាផ្ទៃ ដើម្បីធ្វើលុបបំបាច់ព័ត៌មាន ឬមាតិការនោះ។

ចំពោះការលេចឡើងនូវព័ត៌មានផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ ន.ទ.ក. មិនអាចធ្វើការទប់ស្កាត់បានទេ។ ទោះជា ន.ទ.ក. បង្កើតក្រុមការងារ ដើម្បីតាមដានបញ្ហានេះក៏នឹងមិនទទួលបានជោគជ័យបានដែរ ដោយសារខ្លឹមសារទាំងនោះ ត្រូវបានបង្ហោះក្នុងគេហទំព័រ ឬបណ្ដាញសង្គាម ដូចជា Facebook ក្រុមហ៊ុននេះមាន Server របស់ខ្លួនដំណើរការនៅក្រៅព្រះរាជាណាចក្រកម្ពុជា។ ដូច្នេះ ន.ទ.ក. មិនអាចធ្វើការឆ្លើយតប និងបិទមាតិកាជាក់លាក់ណាមួយនៅក្នុងបណ្ដាញសង្គមបានទេ ព្រោះប្រសិនបើបិទ ចាំបាច់ត្រូវបិទបណ្ដាញសង្គមទាំងអស់ យ៉ាងណាមិញ ន.ទ.ក. ជឿជាក់ថា បញ្ហាដែល OCSE បានលើកឡើងពីការកេងប្រវ័ញ្ចលើកុមារតាមប្រព័ន្ធអ៊ិនធឺណិត ពិតជាមានសារៈសំខាន់ណាស់ ដោយសារគ្រួសារ និងកុមារ មិនទាន់មានការយល់ដឹងអំពី ផលប៉ះពាក់នៃការចែករំលែកព័ត៌មានឯកជនរបស់កុមារទាក់ទងនឹងផ្លូវភេទតាមប្រព័ន្ធអ៊ិនធឺណិតឡើយ។

# ខណ្ឌទី៦: ការពិភាក្សា - អ្វីដែលយើងរៀនសូត្របាន

## ៦.១. អ្វីដែលយើងដឹងអំពីស្ថានភាព OCSE នៅក្នុងប្រទេសកម្ពុជា

ការពិភាក្សាជាមួយកុមារ និងគ្រូបង្រៀនរបស់កុមារ ពេញទូទាំងសិក្ខាសាលាទាំង១៦ នៅក្នុងរាជធានីភ្នំពេញ ខេត្តសៀមរាប និងខេត្តព្រះសីហនុ បង្ហាញរូបភាពយ៉ាងច្បាស់មួយអំពី ចរិតនៃហានិភ័យទាក់ទងនឹង OCSE នៅកម្រិតថ្នាក់មូលដ្ឋាន។ ជារួម ការយល់ដឹងអំពីហានិភ័យទាក់ទងនឹង OCSE មានកម្រិតខ្ពស់ គួរឲ្យកត់សម្គាល់ និងរួមមានការយល់ដឹងអំពីហានិភ័យនានា ដូចជា ការទាញយក និងការចែកចាយ CSAM មាន(២៧%) និងការយល់ដឹងអំពីទម្រង់ផ្សេងៗនៃការផ្សាយផ្ទាល់នូវការកេងប្រវ័ញ្ចផ្លូវភេទ មាន(២៤.១%) ការប្រើប្រាស់អ៊ិនធឺណិតជាកន្លែងសម្រាប់លួងលោមកុមារ ដើម្បីកេងប្រវ័ញ្ចផ្លូវភេទនៅក្នុងបរិយាកាសតាមអ៊ិនធឺណិត និងក្រៅអ៊ិនធឺណិតមាន (២៨%) ការចែកចាយសម្ភារអាសអាភាសរបស់មនុស្សពេញវ័យ និង CSAM ពីមនុស្សពេញវ័យ ទៅកុមារមាន(៦០.៣%) និងទម្រង់ផ្សេងៗទៀតនៃការគំរាមកំហែងតាមអ៊ិនធឺណិត ដោយប្រើប្រាស់ការបង្កភាពអាម៉ាស និងរូបថតផ្លូវភេទ ដែលទាក់ទងនឹងកុមារមាន (២៦%)។ ការអង្កេតតាមប្រព័ន្ធអ៊ិនធឺណិត ដែលប្រមូលបានពីយុវសិស្សថ្នាក់វិទ្យាល័យ ឆ្លុះបញ្ចាំងស្រដៀងគ្នានឹងរបកគំហើញទាំងនេះ។




ហានិភ័យ និងបទពិសោធន៍ទាក់ទងនឹង OCSE ភាគច្រើនត្រូវបានរៀបរាប់ថា កើតឡើងតាមកម្មវិធីពីរ គឺFacebook និងកម្មវិធីផ្ញើសាររបស់វា។ មានករណីជាច្រើនអន្តរទំនាក់ទំនងរវាងកម្មវិធីទាំងពីរនេះ ហាក់ដូចជាធ្វើឲ្យកុមារមានហានិភ័យកាន់តែខ្លាំង។ ស្របពេលដែលអ្នកប្រើប្រាស់ Facebook ដែលមិនធ្លាប់ស្គាល់គ្នាពីមុនមក មិនអាចផ្ញើសារបែបរំខានមកកុមារ តាមរយៈកម្មវិធី Messenger បាន ពួកគេអាចស្រាវជ្រាវរកប្រូហ្វាលរបស់កុមារ ពីកម្មវិធី Facebook បញ្ជូនសំណើសុំធ្វើមិត្ត ហើយពេលនោះ កុមារមានជម្រើសក្នុងការឆ្លើយតប តាមរយៈសារជាមួយនឹងអ្នកប្រើប្រាស់នោះ។ ប្រសិនបើ កុមារឆ្លើយតបក្នុងលក្ខណៈណាមួយ អ្នកប្រើប្រាស់ទទួលបានលទ្ធភាពផ្ញើសារ រូបថត និងវីឌីអូ ទៅកាន់កុមារដោយស្វ័យប្រវត្តិ ព្រមទាំងមានលទ្ធភាពផ្តួចផ្តើមការហៅទូរស័ព្ទ តាមរយៈសម្លេង ឬវីឌីអូ ជាមួយកុមារ។ មានករណីជាច្រើន កម្មវិធីនេះ នឹងបញ្ជូនសំណើធ្វើមិត្ត ដោយស្វ័យប្រវត្តិ នូវមិត្តភក្តិរបស់កុមារផ្សេងទៀត ដែលត្រូវបានអ្នកប្រើប្រាស់ មិនធ្លាប់ស្គាល់គ្នាពីមុនមក បានស្នើសុំធ្វើជាមិត្តជាមួយកុមារនោះរួចហើយ។ ដោយសារកុមារមើលឃើញថា ជាមិត្តភក្តិរួមគ្នា វាអាចបង្កើនលទ្ធភាពដែលកុមារនឹងឆ្លើយតបចំពោះសំណើធ្វើជាមិត្ត ពីអ្នកប្រើប្រាស់ដែលមិនធ្លាប់ស្គាល់គ្នាពីមុនមកនេះ តាមរយៈការទទួលសំណើធ្វើមិត្តនេះ ឬផ្ញើសារឆ្លើយតបវិញ ដែលផ្តល់លទ្ធភាពឲ្យអ្នកប្រើប្រាស់ មិនធ្លាប់ស្គាល់គ្នាពីមុននោះ អាចទំនាក់ទំនងជាមួយកុមារបាន។

ការទទួលបានសម្ភារអាសអាភាស ដែលមិនត្រូវបានស្នើសុំ (និងមានករណីខ្លះ CSAM) ពីមនុស្សពេញវ័យ គឺត្រូវបានគេរៀបរាប់ជាទូទៅថា ជាហានិភ័យនៅតាម Facebook និង Messenger របស់ Facebook ក្នុងចំណោមកុមារកម្ពុជា។ ហានិភ័យសំខាន់មួយ នៅក្នុងបរិយាកាសនេះ គឺជាការប្រើប្រាស់ Facebook ជាក្រុម។ នៅក្នុងសិក្ខាសាលារៀនសូត្រ មានការបង្ហាញថា កុមារត្រូវបានគេបន្ថែមទៅក្នុងក្រុម Facebook មួយ ដោយគ្មានការយល់ព្រមពីកុមារ ដែលនៅក្នុងក្រុមនោះ មានការចែករំលែកសម្ភារ ទាក់ទងនឹងផ្លូវភេទ។ មនុស្សពេញវ័យ ដែលកុមារមិនធ្លាប់ស្គាល់ពីមុនមក មិនអាចបន្ថែមកុមារទៅក្នុងក្រុម Facebook បានទេ ប្រសិនបើ កុមារនោះមិនមែនជា "មិត្តភក្តិ" របស់ពួកគេនៅក្នុង Facebook។ ទោះបីជាយ៉ាងណា ប្រសិនបើមិត្តភក្តិក្នុង Facebook ណាម្នាក់របស់កុមារ ត្រូវបានបញ្ចូលទៅក្នុងក្រុមមួយ នោះកុមារទាំងនោះ អាចបញ្ចូល មិត្តភក្តិក្នុង Facebook ណាម្នាក់របស់ពួកគេ ចូលក្នុងក្រុមនោះ ដោយគ្មានការយល់ព្រមជាមុនពីមិត្តភក្តិនោះ បាន។ ការធ្វើបែបនេះ នាំឲ្យកុមារចូលរួមក្នុងក្រុមដែលពាក់ព័ន្ធនឹងបញ្ហាផ្លូវភេទ ឬក្រុមដែលប្រកបដោយការកេងប្រវ័ញ្ចផ្លូវភេទ ដោយគ្មានការយល់ព្រមជាមុនពីពួកគេ។

ស្របពេលដែលវាហាក់ដូចជាមានភាពឆ្លងកាត់គ្នាច្រើន ទាក់ទងនឹងហានិភ័យនៅតាម Facebook និងកម្មវិធីផ្ញើសាររបស់វានោះ កម្មវិធីនីមួយៗមានមុខងារដោយឡែកទៀត ដែលបង្កើនហានិភ័យ OCSE។ ខណៈដែលកុមារទទួលស្គាល់ថា កម្មវិធីទាំងពីរ ជាកម្មវិធីសម្រាប់បញ្ជូន និងទទួលរូបភាព ឬវីឌីអូអាសអាភាសពីមនុស្សពេញវ័យ និង CSAM Facebook ហាក់ដូចជាមានតួនាទីច្រើន ជាចំណុចទំនាក់ទំនង សម្រាប់ជនខិលខូច ទាក់ទងជាមួយកុមារ ស្របពេលដែល Messenger (ព្រមទាំងកម្មវិធីផ្ញើសារផ្សេងទៀត) ត្រូវបានប្រើប្រាស់សម្រាប់លួងលោម និងភ្ជាប់ទំនាក់ទំនង មានលក្ខណៈឯកជន ជាមួយកុមារ។ មានកុមារលើសពីម្នាក់ក្នុងចំណោមកុមារបួននាក់ ដែលបានរៀបរាប់ថា Messenger គឺជាកម្មវិធីប្រកបដោយហានិភ័យនោះ យល់ថា វាគឺជាកម្មវិធី ដែលជនចម្លែកអាចប៉ុនប៉ងបង្កើតទំនាក់ទំនងជាមួយកុមារ ដើម្បីផ្ដោះប្ដូររូបភាពទាក់ទងនឹងផ្លូវភេទ ឬដើម្បីធ្វើសកម្មភាពខុសច្បាប់ផ្សេងទៀត។ បន្ថែមលើ Facebook កម្មវិធីហ្គេមផ្សេងទៀត ដូចជា "Rules of Survival" ក៏ត្រូវបានរៀបរាប់ថា ជាកម្មវិធីដែលជនខិលខូចអាចប្រើប្រាស់ សម្រាប់ទំនាក់ទំនងជាមួយកុមារ តាមបរិយាកាសនិមិត្តជាសាធារណៈ ដើម្បីធ្វើឲ្យមានទំនុកចិត្ត ទទួលបានព័ត៌មានទំនាក់ទំនងរបស់កុមារ សម្រាប់បង្កើតទំនាក់ទំនងមានលក្ខណៈឯកជន នៅតាមកម្មវិធីប្រាស្រ័យទាក់ទងគ្នា ផ្សេងទៀត ដូចជា Messenger ឬ Line ជាដើម។

ស្របពេលដែល Facebook និងកម្មវិធីផ្ញើសាររបស់ Facebook មានឥទ្ធិពលយ៉ាងខ្លាំងនៅក្នុងបរិយាកាសហានិភ័យរបស់កុមារ បញ្ហា OCSE នៅក្នុងប្រទេសកម្ពុជា មិនហាក់ដូចជាកើតឡើងតែនៅលើកម្មវិធីតែមួយនោះឡើយ ប៉ុន្តែវាហាក់ដូចជាកើតឡើងជាទូទៅលើកម្មវិធីជាច្រើន ដែលមានអន្តរទំនាក់ទំនងគ្នា។ មានករណីមួយចំនួនកុមារអាចជួបជាមួយជនអនាមិកម្នាក់ តាមរយៈការលេងហ្គេមមួយ ឬនៅក្នុងក្រុម ដែលមានលក្ខណៈជាឯកជន ក្នុងកម្មវិធីបណ្ដាញទំនាក់ទំនងសង្គម ហើយបន្ទាប់មក បញ្ចូលបុគ្គលនោះ ធ្វើជាមិត្តភក្តិ ឬពេលខ្លះ គ្រាន់តែចែករំលែកព័ត៌មាន នោះជនខិលខូចស្វែងរកកុមារ និងបញ្ចូលកុមារទៅក្នុងក្រុមនានា ឬផ្ញើសារជាលក្ខណៈឯកជន ក្នុងចេតនា OCSE ឬសកម្មភាពដែលប្រកបដោយគ្រោះថ្នាក់ផ្សេងទៀត។ កម្មវិធីហ្គេម និងកម្មវិធីបណ្ដាញទំនាក់ទំនងសង្គមហាក់ដូចជាដើរតួនាទីជាបរិយាកាសបើកចំហសម្រាប់មនុស្សពេញវ័យ ជនខិលខូចនិងកុមារ ដែលមានអាកប្បកិរិយាផ្លូវភេទ ប្រកបដោយគ្រោះថ្នាក់ ជួបជាមួយកុមារផ្សេងទៀត និងបញ្ជូនសំណើធ្វើមិត្តភក្តិទៅពួកគេតាម Facebook (ដែលបន្ទាប់មកនឹងផ្ដល់ឱកាសសម្រាប់ការផ្ញើសារមានលក្ខណៈជាឯកជន តាមរយៈកម្មវិធី Messenger) ឬកម្មវិធីផ្ញើសារមានលក្ខណៈជាឯកជនផ្សេងទៀត ដូចជា Line ឬ Skype ដែលអាចធ្វើឲ្យមានការលួងលោម ឬសកម្មភាពទាក់ទងនឹង OCSE ផ្សេងទៀតកើតឡើង បានតាមរយៈនោះ។

កុមារដែលបានចូលរួមក្នុងការសិក្សានេះ មិនរៀបរាប់អំពីឧទាហរណ៍ជាក់លាក់នៃការកេងប្រវ័ញ្ចផ្លូវភេទ ឬអំពើហិង្សាជាប្រព័ន្ធ ដូចបានរកឃើញនៅក្នុងប្រទេសហ្វីលីពីនឡើយ[63]។ ទោះបីជាយ៉ាងណា ក៏នៅតែមាននៅឡើយនូវភាពងាយរងគ្រោះ គួរឲ្យកត់សម្គាល់ និងភាពងាយរងគ្រោះចំពោះ OCSE ដែលកំពុងរីរាលដាលនៅទូទាំងតំបន់ទាំងអស់ និងក្នុងចំណោមក្រុមកុមារទាំងអស់នៅក្នុងគម្រោងនេះ ជាពិសេសទាក់ទងនឹងការលួងលោម ការផលិត និងការចែកចាយសម្ភារ ទាក់ទងនឹងការរំលោភបំពានផ្លូវភេទលើកុមារតាមប្រព័ន្ធអ៊ិនធឺណិត។ គួរត្រូវធ្វើការស្រាវជ្រាវ និងសាកសួរជាច្រើនបន្ថែមទៀតអំពីខ្លឹមសារនានា និងទម្រង់នានា ដែលត្រូវបានរកឃើញនៅក្នុងការសិក្សានេះ ដើម្បីឲ្យអាចយល់កាន់តែច្បាស់អំពីបទពិសោធន៍ និងភាពងាយរងគ្រោះរបស់កុមារកម្ពុជា នៅតាមអ៊ិនធឺណិត។

## ៦.២. អ្វីដែលយើងដឹងអំពីទំហំ OCSE នៅក្នុងប្រទេសកម្ពុជា

ការបង្កើតតួរស្ថិតិច្បាស់លាស់អំពីទំហំ OCSE នៅប្រទេសកម្ពុជា មិនអាចធ្វើបានទេ បើគ្មានការសិក្សាដែលមានលក្ខណៈតំណាងឲ្យជាតិទាំងមូលស្តីពីភាពកើតឡើងជាទូទៅ ដែលនឹងទំនងជាមានដែនកំណត់គួរឲ្យកត់សម្គាល់ ដោយសារចរិតលាក់បាំងនៃ OCSE និងកង្វះការបើកបង្ហាញ ក្នុងចំណោមជនរងគ្រោះនៃអំពើនេះ។ ទោះជាយ៉ាងណាតាមរយៈទិន្នន័យជាពាក្យសម្តី ដែលប្រមូលបានពីសិក្ខាសាលារៀនសូត្រ នៅក្នុងការសិក្សានេះ ការរៀនសូត្រពីការអង្កេតដែលមានរចនាសម្ព័ន្ធ មានកម្រិត និងការពិនិត្យទិន្នន័យ ដែលផ្តល់ព័ត៌មានអំពីទិន្នន័យផ្សេងទៀត ការសិក្សានេះ អាចបង្កើតជារូបភាពមួយ តាមពាក្យសម្តី ស្តីពីទំហំបញ្ហានេះ នៅក្នុងប្រទេសកម្ពុជា និងទំហំផលប៉ះពាល់ ដែលកុមារអាចជួបប្រទះ។

សិក្ខាសាលារៀនសូត្រជាមួយកុមារបង្ហាញថា ក្នុងចំណោមអ្នកចូលរួមជាកុមារចំនួន២២០នាក់ នៅរាជធានីភ្នំពេញ ខេត្តសៀមរាប និងខេត្តព្រះសីហនុ មានកុមារ៣៧នាក់ ឬ១៧% (មានប្រហែលម្នាក់ ក្នុងចំណោមប្រាំមួយនាក់) បានចែករំលែកយ៉ាងហោចណាស់ បទពិសោធន៍ផ្ទាល់ខ្លួនចំនួនមួយអំពីហានិភ័យទាក់ទងនឹង OCSE នៅតាមអ៊ិនធឺណិត។ ខណៈដែលចំណុចនេះ មិនអាចធ្វើតំណាងស្ថិតិបាន វាពិតជាបង្ហាញនូវហានិភ័យ ដែលអាចកើតមាន គួរឲ្យកត់សម្គាល់ក្នុងចំណោមកុមារនៅប្រទេសកម្ពុជា។ ភាគច្រើន មានកុមារ ២៩នាក់ ក្នុងចំណោមកុមារទាំង ៣៧ នាក់ រៀបរាប់អំពី OCSE មានទម្រង់ ឬ រូបភាព ជាការលួងលោម ឬទម្រង់ផ្សេងទៀត នៃការប៉ុនប៉ងទាក់ទងនឹងផ្លូវភេទ ដែលធ្វើឡើងដោយមនុស្សពេញវ័យនៅតាមប្រព័ន្ធអ៊ិនធឺណិត ភាគច្រើនតាមរយៈ Facebook ឬ Messenger របស់កម្មវិធី Facebook។ ការប៉ុនប៉ងទាក់ទងនឹងផ្លូវភេទ ជាច្រើន ក្នុងចំណោមការប៉ុនប៉ងទាំងនេះ ក៏រួមមានការចែករំលែកសម្ភារទាក់ទងនឹងផ្លូវភេទ ឬការចាប់ផ្តើមការហៅទូរស័ព្ទ វីឌីអូផ្សាយផ្ទាល់ជាមួយកុមារ ផងដែរ។

ស្របពេលដែលកុមារនៅក្នុងការសិក្សានេះ មិនបានរៀបរាប់អំពីឧទាហរណ៍ជាក់លាក់នៃការកេងប្រវ័ញ្ចផ្លូវភេទ ឬអំពើហិង្សាជាប្រព័ន្ធ ដូចបានរកឃើញនៅក្នុងប្រទេសហ្វីលីពីននោះ ក៏ដោយ ក៏នៅតែមានភាពងាយរងគ្រោះ គួរឲ្យកត់សម្គាល់ និងភាពងាយរងគ្រោះចំពោះ OCSE ដែលកំពុងរីករាលដាលនៅទូទាំងតំបន់ទាំងអស់ និងក្នុងចំណោមក្រុមកុមារទាំងអស់ នៅក្នុងគម្រោងនេះ ជាពិសេសទាក់ទងនឹងការលួងលោម និងការផលិត និងការចែកចាយសម្ភារ ទាក់ទងនឹងការរំលោភបំពានផ្លូវភេទលើកុមារ តាមប្រព័ន្ធអ៊ិនធឺណិត ដែរ។ គួរត្រូវធ្វើការស្រាវជ្រាវ និងសាកសួរជាច្រើនបន្ថែមទៀត អំពីខ្លឹមសារនានា និងទម្រង់នានា ដែលត្រូវបានរកឃើញនៅក្នុងការសិក្សានេះ ដើម្បីឲ្យអាចយល់កាន់តែច្បាស់អំពី បទពិសោធន៍ និងភាពងាយរងគ្រោះរបស់កុមារកម្ពុជា នៅតាមអ៊ិនធឺណិត។

[63] Terre des Hommes-Netherlands. (2018).

៨១

ទោះបីជាវិសាលភាពមានកម្រិតក៏ដោយ ក៏ការអង្កេតតាមប្រព័ន្ធអ៊ិនធឺណិតជាមួយកុមារបង្ហាញរបកគំហើញស្រដៀងគ្នា ដោយយុវវ័យចំនួន ១៦% បង្ហាញអារម្មណ៍គ្មានសុវត្ថិភាព ដោយសារជននៅតាមប្រព័ន្ធអ៊ិនធឺណិតដែលសុំឲ្យពួកគេធ្វើ "រឿងមិនសមរម្យ" ១៩% មានអារម្មណ៍គ្មានសុវត្ថិភាព ដោយសារជនដែលអាចចែករំលែករូបភាពផ្សេងទៀតមកកាន់ពួកគេតាមរយៈអ៊ិនធឺណិត។ លើសពីនេះ មាន១៣% បានលើកឡើងអំពីការប៉ុនប៉ង ក្នុងគោលបំណងផ្លូវភេទ នៅលើគេហទំព័របណ្ដាញទំនាក់ទំនងសង្គមថា ជាការគំរាមកំហែងធំបំផុតចំពោះសុវត្ថិភាពរបស់ពួកគេនៅតាមប្រព័ន្ធអ៊ិនធឺណិត។ បន្ថែមលើនេះ មានចំនួនជាងពាក់កណ្ដាលនៃយុវវ័យ បានបង្ហាញអំពីការនិយាយទូរស័ព្ទជាមួយជនដែលពួកគេបានជួបតាមប្រព័ន្ធអ៊ិនធឺណិត និងមានយុវវ័យចំនួនប្រាំពីរនាក់ (៧%) បានបង្ហាញអំពីការនិយាយរឿងរ៉ាវផ្លូវភេទ ជាមួយជនដែលពួកគេបានជួបតាមប្រព័ន្ធអ៊ិនធឺណិត។ ទាក់ទងនឹងវត្ថុមានរូបភាពផ្លូវភេទរបស់កុមារ មានស្ទើរតែមួយភាគបីនៃយុវវ័យ (៣២%) នៅក្នុងការអង្កេតតាមប្រព័ន្ធអ៊ិនធឺណិត បង្ហាញអំពីការបានឃើញសម្ភារអាសអាភាសរបស់កុមារ ដែលមានវ័យស្របាលគ្នានឹងពួកគេ ឬមានវ័យក្មេងជាងពួកគេ នៅពេលពួកគេ ចូលតាមប្រព័ន្ធអ៊ិនធឺណិត។

របាយការណ៍ស្ដីពី CSAM ទាក់ទងនឹងកម្ពុជា ដែល HSI នៅរាជធានីភ្នំពេញបានទទួល បានបង្ហាញពីការកើនឡើងជាលំដាប់ ចាប់ពីឆ្នាំ២០១៣ ដល់ឆ្នាំ២០១៧ ប៉ុន្តែរបាយការណ៍ ចាប់ពីខែមករា ដល់វិច្ឆិកា ឆ្នាំ២០១៨ បានបង្ហាញនូវការកើនឡើងយ៉ាងខ្លាំង រហូតដល់៤៩០% ជាមួយនឹងរបាយការណ៍ CSAM ចំនួន១២៣.៨៩៦ ក្នុងឡុងពេល១១ខែ ដើមឆ្នាំ២០១៨។ អ្វីដែលគួរឲ្យកត់សម្គាល់ជាងនេះ គឺមានស្ទើរតែមួយភាគបីនៃរបាយការណ៍ទាំងនេះ (២៩% ឬ ៣៥.៩១៣) ត្រូវបានចាត់ទុកថាជាករណីថ្មី និងដែលអាចស្ដែងចេញជាវិធានការបាន ដែលអាចជាសញ្ញាបង្ហាញនូវការកើនឡើង មិនត្រឹមតែការចែកចាយ CSAM ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងផលិតសម្ភារថ្មីៗទៀត ផងដែរ។ មានភាពខុសគ្នាគួរឲ្យកត់សម្គាល់ រវាងសេចក្ដីរាយការណ៍ទាក់ទងនឹង OCSE ពី NCMEC អង្គការ APLE និងបណ្ដាញទូរស័ព្ទជំនួយកុមារកម្ពុជា (CCH)។ ស្របពេលដែល NCMEC បានដំណើរការរបាយការណ៍ទាក់ទងនឹង OCSE ច្រើនជាង២០០.០០០ របាយការណ៍ចាប់តាំងពីឆ្នាំ២០១៥ មក អង្គការ APLE បានដំណើរការចំនួន២០៤ របាយការណ៍ និងCCH បានដំណើរការប្រាំពីររបាយការណ៍នៅក្នុងកំឡុងពេលដូចគ្នានេះ។ ភាពខុសគ្នាយ៉ាងខ្លាំងរវាងយន្តការទាំងនេះ គឺដោយសារសេចក្ដីរាយការណ៍មកពី NCMEC ភាគច្រើន គឺបានមកពីក្រុមហ៊ុនផ្ដល់សេវាកម្មអេឡិចត្រូនិកដែលមានមូលដ្ឋាននៅសហរដ្ឋអាមេរិក (ដូចជាFacebook) ដែលច្បាប់តម្រូវឲ្យរាយការណ៍គ្រប់ខ្លឹមសារទាក់ទងនឹងការរំលោភបំពានកុមារ ដែលត្រូវបានរាយការណ៍តាមកម្មវិធីរបស់ក្រុមហ៊ុនទាំងនេះ ឬត្រូវបានរកឃើញនៅក្នុង Servers សម្រាប់គេហទំព័ររបស់ពួកគេ។ ចំណែកឯសេចក្ដីរាយការណ៍របស់អង្គការ APLE និង CCH ផ្អែកលើសេចក្ដីរាយការណ៍តែពីសាធារណៈជនដែលទាមទារនូវការយល់ដឹង និងការឃ្លាំមើលដោយប្រុងប្រយ័ត្នរបស់សាធារណៈជនកម្ពុជាទូទៅ។

## ៦.៣. អ្វីដែលយើងបានរៀនសូត្រអំពីសមត្ថភាពរបស់យើងក្នុងការដោះស្រាយបញ្ហា

ការរៀនសូត្រពីសិក្ខាសាលានៅសហគមន៍ ទិន្នន័យពីអង្គការតាមដានត្រួតពិនិត្យអន្តរជាតិ និងទិន្នន័យពីការអង្កេតតាមរយៈអ៊ិនធឺណិត បានបង្ហាញឲ្យឃើញភាពងាយរងគ្រោះយ៉ាងច្បាស់ គួរឲ្យកត់សម្គាល់ចំពោះ OCSE នៅប្រទេសកម្ពុជា ពេញទូទាំងកម្មវិធីអ៊ិនធឺណិត ផ្សេងជាច្រើន។ បន្ថែមលើទិន្នន័យនេះ ការសម្ភាសស៊ីជម្រៅជាមួយអ្នកអនុវត្តការងារ និងទិន្នន័យពីសិក្ខាសាលាជាមួយកុមារ បង្ហាញថាមានកង្វះខាតគួរឲ្យកត់សម្គាល់នូវការយល់ដឹងការតាមដានត្រួតពិនិត្យ និងការគ្រប់គ្រង ក្នុងចំណោមឪពុកម្ដាយ និងសមាជិកសហគមន៍ ដែលអាចរារាំងការទទួលស្គាល់ករណី OCSE និងសេចក្ដីរាយការណ៍ទៅកាន់ទីភ្នាក់ងារ ឬស្ថាប័នអនុវត្តច្បាប់ក្នុងមូលដ្ឋាន និងយន្តការរាយ

ការណ៍តាមប្រព័ន្ធអ៊ិនធឺណិត ដូចជាបណ្តាញរាយការណ៍តាមប្រព័ន្ធអ៊ិនធឺណិតរបស់អង្គការ APLE។ ស្របពេលដែលបច្ចុប្បន្ននេះ មានសមត្ថភាពក្នុងប្រទេស និងអន្តរជាតិមួយចំនួន ដើម្បីឆ្លើយតបនឹង OCSE នៅក្នុងជួររដ្ឋាភិបាលកម្ពុជា ដូចជា អង្គភាពប្រឆាំងបទល្មើសបច្ចេកវិទ្យា និង AHTJP ក៏ដោយ ក៏គ្មានទីភ្នាក់ងារ ឬស្ថាប័នណាមួយរបស់កម្ពុជា ដែលអាចផ្តល់ការឆ្លើយតបពេញលេញ ឬគ្រប់គ្រាន់ចំពោះ OCSE បានដែរ។

**អង្គភាពប្រឆាំងបទល្មើសបច្ចេកវិទ្យា** ស្ថិតនៅក្រោមក្រសួងមហាផ្ទៃ គឺជាអង្គភាពជំនាញ ដែលអាចដើរតួនាទីយ៉ាងសំខាន់ ក្នុងការឆ្លើយតបចំពោះការគំរាមកំហែង ដែលកំពុងកើនឡើង ទាក់ទងនឹង OCSE នៅក្នុងប្រទេសកម្ពុជា។ ស្របពេលដែលអង្គភាពនេះ មានអាណត្តិទូលំទូលាយ លើការស៊ើបអង្កេតបទល្មើស ទាក់ទងនឹងកុំព្យូទ័រនៅក្នុងប្រទេសកម្ពុជា (រួមទាំងបទល្មើសលើកុមារផង) សមត្ថភាពរបស់ពួកគេសម្រាប់ការស៊ើបអង្កេត គឺនៅមានកម្រិត ត្រឹមតែការស្រាវជ្រាវឧបករណ៍អេឡិចត្រូនិកដោយផ្ទាល់ ដែលទទួលបានក្នុងពេលស៊ើបអង្កេតរបស់នគរបាល និងខ្វះលទ្ធភាពធ្វើការស៊ើបអង្កេតតាមប្រព័ន្ធអ៊ិនធឺណិត។ កង្វះសមត្ថភាពក្នុងការស៊ើបអង្កេតដោយផ្ទាល់ដើម្បីឆ្លើយតបនឹងបទល្មើស ដែលមានមូលដ្ឋានតាមប្រព័ន្ធអ៊ិនធឺណិតធ្វើឲ្យបទល្មើស OCSE ជាក់លាក់ ដែលត្រូវបានប្រព្រឹត្តនៅលើគេហទំព័រងងឹត និងតាមរយៈបណ្តាញ Peer-to-Peer អាចលាក់បាំងបាន ពីទីភ្នាក់ងារ ឬស្ថាប័នអនុវត្តច្បាប់ក្នុងប្រទេស។ បន្ថែមលើនេះ បច្ចុប្បន្ននេះ ការងាររបស់អង្គភាពប្រឆាំងបទល្មើសបច្ចេកវិទ្យា គឺមានលក្ខណៈឆ្លើយតបចំពោះការបញ្ជូនជាលក្ខណៈអន្តររដ្ឋាភិបាល ដើម្បីស៊ើបអង្កេតឧបករណ៍អេឡិចត្រូនិកដោយផ្ទាល់ ដែលជាផ្នែកមួយនៃការងារស៊ើបអង្កេតបទល្មើសនៅតាមសហគមន៍មូលដ្ឋាន។ មានតម្រូវការដ៏សំខាន់មួយឲ្យមានកិច្ចខិតខំប្រឹងប្រែងជាលក្ខណៈត្រៀមទប់ទល់ជាមុននៅក្នុងជួររដ្ឋាភិបាលកម្ពុជា ដើម្បីធ្វើការងារជាមួយទីភ្នាក់ងារ ឬស្ថាប័នអនុវត្តច្បាប់អន្តរជាតិនិងថ្នាក់តំបន់សម្រាប់តាមដានបន្តលើអង្គភាពរាយការណ៍អំពីCSAM/CSEM នៅក្នុងប្រទេសកម្ពុជា។

**នាយកដ្ឋានប្រឆាំងអំពើជួញដូរមនុស្ស និងការពារអនីតិជន** (AHTJP) បានទទួលភារកិច្ចសម្រាប់ឆ្លើយតបចំពោះការគំរាមកំហែងនៃអំពើជួញដូរកុមារ និងមានដែនសមត្ថកិច្ចលើទម្រង់ផ្សេងៗនៃ ការកេងប្រវ័ញ្ចផ្លូវភេទ និងអំពើហិង្សាលើកុមារ ទាំងក្នុង និងក្រៅអ៊ិនធឺណិត។ ទាក់ទងនឹង OCSE ទីភ្នាក់ងារ ឬស្ថាប័នអនុវត្តច្បាប់ជាតិ បង្ហាញនូវការផ្តោតលើជនខិលខូចដែលប្រព្រឹត្តបទល្មើស ទាក់ទងនឹង OCSE ដោយផ្តោតការយកចិត្តទុកដាក់ច្រើនលើការកំណត់អត្តសញ្ញាណ និងការផ្តន្ទាទោស ជនខិលខូច ដែលមានវត្តមាន នៅតាមសហគមន៍កម្ពុជា។ ការពិភាក្សាអំពី OCSE ជាមួយនឹងទីភ្នាក់ងារ ឬស្ថាប័នអនុវត្តច្បាប់ បានបង្ហាញការយល់ដឹងច្រើនអំពី ជនខិលខូចជាជនបរទេស នៅតាមសហគមន៍ ដែលពួកគេប្រើប្រាស់អ៊ិនធឺណិតជាឧបករណ៍ ដើម្បីជួបជាមួយជនរងគ្រោះ នៅក្រៅបរិយាកាសអ៊ិនធឺណិត។ ទោះបីជាយ៉ាងណា ការយល់ដឹងបែបនេះ អាចមើលរំលងបទល្មើសពាក់ព័ន្ធនឹង OCSE ភាគច្រើនដោយសារជាញឹកញាប់ ជនខិលខូច មិនស្ថិតនៅក្នុងប្រទេសមួយជាមួយគ្នានឹងជនរងគ្រោះ ដែលត្រូវបានកេងប្រវ័ញ្ចឡើយ។ នៅក្នុងសិក្ខាសាលារៀនសូត្រ កុមារមួយចំនួន បង្ហាញនូវការប៉ុនប៉ងក្នុងគោលបំណងផ្លូវភេទពីបុគ្គល ដែលកុមារជឿជាក់ថា កំពុងស្ថិតនៅក្នុងប្រទេសផ្សេងៗទៀត។ ដោយសារជនខិលខូច អាចស្ថិតនៅក្នុងប្រទេសមួយចំនួន ការឆ្លើយតបចំពោះបទសល្មើសទាក់ទងនឹង OCSE ទាមទារនូវសម្ព័ន្ធភាព និងកិច្ចព្រមព្រៀងសហការគ្នា ជាយុទ្ធសាស្ត្រជាមួយទីភ្នាក់ងារឬស្ថាប័នអនុវត្តច្បាប់( នគរបាលអន្តរជាតិ ) ដើម្បីជួយធ្វើឲ្យកុមារមានសុវត្ថិភាពនៅតាមសហគមន៍។

ការឆ្លើយតបពេលបច្ចុប្បន្ននេះចំពោះ OCSE ដោយទីភ្នាក់ងារឬស្ថាប័នអនុវត្តច្បាប់ គឺភាគច្រើនមានលក្ខណៈឆ្លើយតបចំពោះបទល្មើស ដោយឆ្លើយតបចំពោះការបញ្ជូនពីអង្គការមិនមែនរដ្ឋាភិបាល និងស្ថាប័នរដ្ឋាភិបាលផ្សេងទៀត។ ទោះបីជាយ៉ាងណា សេចក្តីរាយការណ៍ជាសាធារណៈនិងការបញ្ជូនពីអន្តរទីភ្នាក់ងារ អាចឆ្លុះបញ្ចាំងតែករណី OCSEដែលមានចំនួនតិចតួច។ មានតម្រូវការមួយឲ្យមានការអនុវត្តន៍ការងារមានលក្ខណៈត្រៀមទប់ទល់ជាមុន ក្នុង

ការស៊ើបអង្កេតបញ្ហាការពារកុមារ។ មានតម្រូវការយ៉ាងច្បាស់ និងមានឱកាសធ្វើការងារឲ្យកាន់តែជិតស្និទ្ធជាមួយអ្នកស៊ើបអង្កេតនិងភ្នាក់ងារ ឬស្ថាប័នអនុវត្តច្បាប់អន្តរជាតិលើករណីCSAM/CSEM តាមរយៈការធ្វើការងារប្រកបដោយកិច្ចសហការគ្នាជុំវិញមូលដ្ឋានទិន្នន័យICSE និងករណីដែលត្រូវបានបញ្ជូនទៅភ្នាក់ងារសន្តិសុខមាតុភូមិសហរដ្ឋអាមេរិក នៅរាជធានីភ្នំពេញពីNCMEC។

នៅឆាកអន្តរជាតិ មានធនធានដ៏មានឥទ្ធិពលមួយចំនួន ដែលទីភ្នាក់ងារ ឬស្ថាប័នអនុវត្តច្បាប់ កម្ពុជាអាចប្រើប្រាស់បាន ហើយធនធានទាំងនេះអាចផ្តល់ដល់ទីភ្នាក់ងារឬស្ថាប័នអនុវត្តច្បាប់នូវសមត្ថភាពកាន់តែច្រើនសម្រាប់ស៊ើបអង្កេតបទល្មើស ទាក់ទងនឹងអ៊ិនធឺណិត និងផ្តល់ឱកាសសម្រាប់កសាងសមត្ថភាពជាក់ស្តែង និងមានការគាំទ្រចំពោះការស៊ើបអង្កេត។

**នគរបាលអន្តរជាតិ** គឺជាអង្គភាពដ៏មានសារៈសំខាន់ ដែលធ្វើការងារលើបញ្ហា OCSE នៅទូទាំងតំបន់ តាមរយៈកិច្ចខិតខំប្រឹងប្រែងប្រកបដោយការសហការគ្នាដោយប្រើប្រាស់មូលដ្ឋានទិន្នន័យ ICSE។ អង្គភាពនេះអាចផ្តល់ជូនទីភ្នាក់ងារ ឬស្ថាប័នអនុវត្តច្បាប់ នូវធនធានប្រកបដោយឥទ្ធិពលសម្រាប់ឆ្លើយតបចំពោះការគំរាមកំហែងផ្នែក OCSEនៅប្រទេសកម្ពុជាដែលកំពុងមានចំនួនកើនឡើង។ ទោះបីជាយ៉ាងណា មានតម្រូវការដ៏មានសារៈសំខាន់មួយឲ្យមានកិច្ចសហប្រតិបត្តិការកាន់តែខ្លាំងពីប្រជាជាតិអាស៊ាននិងប្រជាជាតិអាស៊ីខាងកើតជាមួយនឹងមូលដ្ឋានទិន្នន័យ ICSE។ ដោយសារអ៊ិនធឺណិត មានលក្ខណៈទូទាំងពិភពលោក និងជាបណ្តាញព័ត៌មាន ដែលមានលក្ខណៈមិននៅមួយកន្លែង ដូច្នេះ បញ្ហាកេងប្រវ័ញ្ចផ្លូវភេទកុមារតាមប្រព័ន្ធអ៊ិនធឺណិតនៅប្រទេសកម្ពុជា គឺជាបញ្ហាអន្តរជាតិជាស្វ័យប្រវត្តិផងដែរដែលទាមទារនូវការឆ្លើយតបជាអន្តរជាតិ ដែលកសាងបន្ថែមលើកិច្ចសហការគ្នា ជាយុទ្ធសាស្ត្រប្រកបដោយការយកចិត្តទុកដាក់រវាងទីភ្នាក់ងារ ឬស្ថាប័នអនុវត្តច្បាប់ក្នុងប្រទេស និងអន្តរជាតិ។

បច្ចុប្បន្ននេះ ការិយាល័យកណ្តាលថ្នាក់ជាតិនៅរាជធានីភ្នំពេញ (ការិយាល័យអនុព័ន្ធនគរបាលអន្តរជាតិនៅប្រទេសកម្ពុជា) គ្មានលទ្ធភាពទទួលបានដោយផ្ទាល់ឡើយនូវកិច្ចខិតខំប្រឹងប្រែងអនុវត្តច្បាប់ប្រឆាំងនឹង CSAM/CSEM តាមរយៈមូលដ្ឋានទិន្នន័យ ICSE។ ដោយសារកង្វះកិច្ចសហការនេះ ពិបាកនឹងប្រើប្រាស់ឧបករណ៍ស៊ើបអង្កេតនេះឲ្យអស់សក្តានុពលរបស់វាណាស់នៅប្រទេសកម្ពុជា។ ដោយគ្មានការភ្ជាប់ទំនាក់ទំនងកម្រិតថ្នាក់ជាតិជាមួយមូលដ្ឋានទិន្នន័យ ICSE (និងដៃគូសហការនៃមូលដ្ឋានទិន្នន័យនេះ) ទីភ្នាក់ងារ ឬស្ថាប័នអនុវត្តច្បាប់អន្តរជាតិប្រឈមមុខនឹងការលំបាកការយល់អំពីខ្លឹមសារ និងទម្រង់នៃការប្រព្រឹត្តបទល្មើស OCSE នៅប្រទេសកម្ពុជា។ កិច្ចសហការផ្លូវការ រវាងទីភ្នាក់ងារ ឬស្ថាប័នអនុវត្តច្បាប់អន្តរជាតិ និងទីភ្នាក់ងារ ឬស្ថាប័នអនុវត្តច្បាប់ក្នុងប្រទេសនឹងជួយធានាថា គ្រប់រូបភាព CSAM/CSEM ដែលត្រូវបានរកឃើញនៅប្រទេសកម្ពុជា ត្រូវបានកំណត់មុខសញ្ញា (Hash) រៀបចំជាបញ្ជី និងបញ្ជូនរូបភាពទាំងនោះទៅដល់ទីភ្នាក់ងារ ឬស្ថាប័នអនុវត្តច្បាប់អន្តរជាតិ។ កិច្ចសហការបែបនេះ ផ្តល់ផលប្រយោជន៍ច្រើន ចំពោះកិច្ចខិតខំប្រឹងប្រែងកំណត់អត្តសញ្ញាណជនរងគ្រោះ ជាអន្តរជាតិ (រួមទាំងជនរងគ្រោះកម្ពុជារាប់ពាន់នាក់ ដែលមិនទាន់កំណត់អត្តសញ្ញាណបានផងដែរ) ដោយប្រើប្រាស់ឯកទេសក្នុងប្រទេស ដែលផ្តល់ដោយមន្ត្រីអនុវត្តច្បាប់កម្ពុជា ដើម្បីជួយកំណត់អត្តសញ្ញាណជនរងគ្រោះ និងផ្តន្ទាទោសជនខិលខូច។ បច្ចុប្បន្ននេះ នៅពេលដែលនគរបាលរកឃើញCSAM នៅប្រទេស Cashe ពេញលេញនៃរូបភាពដែលដកហូតបាន និងទិន្នន័យពាក់ព័ន្ធមិនត្រូវបានបញ្ជូនទៅកាន់នគរបាលអន្តរជាតិឡើយ។ ហេតុនេះ ទីភ្នាក់ងារ ឬស្ថាប័នអនុវត្តច្បាប់មូលដ្ឋាននៅប្រទេសកម្ពុជា មិនអាចទទួលបានផលប្រយោជន៍ពីការរៀនសូត្រ និងការកសាងសមត្ថភាព ដែលត្រូវបានផ្តល់តាមរយៈការចូលរួមជាមួយបទដ្ឋាន និងដំណើរការយ៉ាងហ្មត់ចត់នៃសហគមន៍អនុវត្តច្បាប់អន្តរជាតិឡើយ។ ដោយសារហេតុនេះ មានតម្រូវការឲ្យរៀបចំការភ្ជាប់ទំនាក់ទំនងប្រកបសុវត្ថិភាពរវាងការិយាល័យ NCB និង

នគរបាលអន្តរជាតិ និងធ្វើការងារឆ្ពោះទៅរកការពង្រឹងកិច្ចសហការជាមួយនឹងគំនិតផ្តួចផ្តើមអន្តរជាតិ ដែលមានស្រាប់ និងការទទួលបានផលប្រយោជន៍ពីលទ្ធភាពទទួលបានឧបករណ៍ និងធនធានឯកទេសនានា។

NCMEC ផ្តល់នូវករណីថ្មីៗ និងករណីដែលអាចចេញជាវិធានការបានជាច្រើននៃ CSAM ក្នុងមួយខែៗ ទៅឲ្យក្រុមស៊ើបអង្កេតសន្តិសុខមាតុភូមិ នៅស្ថានទូតសហរដ្ឋអាមេរិកប្រចាំរាជធានីភ្នំពេញ។ ទោះបីជាយ៉ាងណា ដើម្បីឆ្លើយតបចំពោះរបាយការណ៍សកម្ម នោះភ្នាក់ងារសន្តិសុខមាតុភូមិ ចាំបាច់ត្រូវធ្វើការជាមួយភ្នាក់ងារអនុវត្តច្បាប់កម្ពុជា និង ISPs ក្នុងប្រទេស ដើម្បីតាមដានអាសយដ្ឋាន IP ដែលល្មើស។ កិច្ចការនេះ មានការលំបាកនៅក្នុងបរិបទប្រទេសកម្ពុជា ដោយសារគ្មានបទដ្ឋានសម្រាប់រក្សាទុកកំណត់ត្រាអំពីការកំណត់IP។ ISPs អាចរក្សាទុកការកំណត់ត្រានេះ ក្នុងរយៈពេលគិតជាសប្តាហ៍ ជាថ្ងៃ ឬ មានករណីខ្លះ គិតជាម៉ោង ដែលជាហេតុធ្វើឲ្យការស៊ើបអង្កេតលើរបាយការណ៍ CSAM/CSEM ពិតជាមិនអាចធ្វើបានឡើយ។ បច្ចុប្បន្ននេះ គ្មានយន្តការសហប្រតិបត្តិការ ឬឆ្លើយតបជាផ្លូវការនៅក្នុងប្រទេសកម្ពុជា ដើម្បីទទួលបានវិភាគ និងដំណើរការព័ត៌មាន មកពីNCMEC តាមរយៈ HSI ឡើយ។ កិច្ចសហប្រតិបត្តិការបែបនេះ នឹងទាមទារការប្តេជ្ញាចិត្តពហុវិស័យ/វិជ្ជាជីវៈពីHSIទីភ្នាក់ងារ ឬស្ថាប័នអនុវត្តច្បាប់ ក្នុងប្រទេស ISPs និងអង្គភាពប្រឆាំងបទល្មើសបច្ចេកវិទ្យា ដើម្បីតាមដានបន្តលើរបាយការណ៍នានា និងអាចបើកការស៊ើបអង្កេត លើការចែកចាយដែលកំពុងកើនឡើងយ៉ាងរហ័សនូវរបាយការណ៍ CSAM/CSEM ដែលបានមកពី NCMEC។

## ខណ្ឌទី៧: ភាពជាដៃគូសម្រាប់ការអភិវឌ្ឍ

ការឆ្លើយតប ប្រកបដោយប្រសិទ្ធភាពចំពោះ OCSE នៅប្រទេសកម្ពុជា ត្រូវតែអាចប្រមូលផ្តុំអ្នកពាក់ព័ន្ធជាច្រើន អង្គភាពអន្តរវិជ្ជាជីវៈ និងពហុវិស័យនៃស្ថាប័នទាំងអស់ ដែលមានការទទួលខុសត្រូវ ចំពោះកិច្ចការពារកុមារនៅក្នុងបរិយាកាសអ៊ិនធឺណិត រួមទាំងសង្គមស៊ីវិល និងឧស្សាហកម្មឯកជន។ អ្វីដែលល្អបំផុតនោះគឺ កិច្ចខិតខំប្រឹងប្រែងបែបនេះ គួរត្រូវដឹកនាំដោយរដ្ឋាភិបាល និងជាកម្រិតថ្នាក់ខ្ពស់បំផុតនៃរដ្ឋាភិបាលជាតិ និងទីភ្នាក់ងារ ឬស្ថាប័នអនុវត្តច្បាប់។ មានតម្រូវការគួរឲ្យកត់សម្គាល់មួយ ដើម្បីធ្វើឲ្យអង្គភាពនេះមិនត្រឹមតែជាអ្នកតំណាង ឬជាអង្គភាពច្បាប់ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជាផ្នែកអនុវត្តជាក់ស្តែងជាមួយនឹងសមត្ថភាព ក្នុងការបង្កើតយន្តការឲ្យបានគ្រប់គ្រាន់ និងយន្តការឆ្លើយតប ដើម្បីឆ្លើយតបចំពោះ OCSE ដែលមានលក្ខណៈកាន់តែទូលំទូលាយ ព្រមទាំងរបាយការណ៍ CSAM/CSAM ពីអង្គភាពអន្តរជាតិ ដូចជា NCMEC ស្របពេលដែលធ្វើការងារមានលក្ខណៈត្រៀមជាមុន សម្រាប់តាមដានត្រួតពិនិត្យ និងការពារសុវត្ថិភាពកុមារ នៅក្នុងបរិយាកាសតាមអ៊ិនធឺណិត។ អង្គភាពបែបនេះត្រូវតែអាចដោះស្រាយបញ្ហា OCSE មានលក្ខណៈគ្រប់ជ្រុងជ្រោយ ដោយឆ្លើយតបចំពោះសមត្ថភាពនានា ដែលត្រូវបានកំណត់នៅក្នុងក្របខណ្ឌគំរូនៃការឆ្លើយតបជាតិ របស់ WePROTECT ដែលគំរូនេះ ទទួលបានការព្រមព្រៀងពីសមាជិករាជរដ្ឋាភិបាលកម្ពុជា នៅទីក្រុងអាប៊ុយដាប៊ី កាលពីឆ្នាំ២០១៥។ ស្របពេលដែលអនុសាសន៍ជាច្រើន មានភាពចាំបាច់ត្រូវបង្កើតរួមគ្នាជាមួយតំណាងរដ្ឋាភិបាលពហុវិស័យមានអនុសាសន៍មួយចំនួន ត្រូវបានកំណត់ខាងក្រោមនេះ៖

### ៧.១. គោលនយោបាយ និងអភិបាលកិច្ច

- គួរពិនិត្យ និងកែសម្រួលសេចក្តីព្រាងច្បាប់ស្តីពីបទល្មើសបច្ចេកវិទ្យាព័ត៌មាន ដោយកំណត់និយមន័យ និងបន្ថែមទោសប្បញ្ញត្តិពាក់ព័ន្ធការរំលោភបំពាននិងកេងប្រវ័ញ្ចផ្លូវភេទលើគ្រប់រូបភាព (CSAM) ដោយរាប់បញ្ចូលទាំងការលួងលោមតាមប្រព័ន្ធអ៊ិនធឺណិតជាបទល្មើស។ គួរជំរុញការអនុម័តសេចក្តីព្រាងច្បាប់នេះឲ្យបានឆាប់រហ័ស។
- រៀបចំលិខិតបទដ្ឋានគតិយុត្ត ដើម្បីអនុវត្តច្បាប់នេះ
- ផ្អែកលើច្បាប់កម្ពុជាពាក់ព័ន្ធ គួរកំណត់គោលការណ៍ណែនាំ និងកំណត់ស្តង់ដារ ដែលអាចរក្សាកំណត់ត្រាទិន្នន័យ IP (IP Assignment Log Preservation) តម្រូវឲ្យក្រុមហ៊ុនផ្តល់សេវាអ៊ិនធឺណិតទាំងអស់ បង្កើតគោលនយោបាយការពារកុមារឆ្លើយតបឱ្យបានឆាប់រហ័ស នឹងការទទួលខុសត្រូវចំពោះមាតិកា CSAM នៅក្នុងសេវូបករណ៍ (servers) របស់ក្រុមហ៊ុន។
- គួរបង្កើតយន្តការមួយ (ជាគណៈកម្មការ ឬក្រុមការងារ) ដោយមានការចូលរួមពីក្រសួងមហាផ្ទៃ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងវប្បធម៌ ក្រសួងយុត្តិធម៌ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងព័ត៌មាន និងក្រសួងកិច្ចការនារី ដែលធ្វើការជាក់លាក់លើ OCSE ក្នុងការដោះស្រាយបានទាន់ពេលវេលា។
- គួរធ្វើជាករណីសិក្សាទៅក្រៅប្រទេស ដើម្បីស្វែងយល់ពីបទពិសោធន៍លើករណីនេះ។

## ៧.២. ការផ្តល់សេវាអ៊ីនធឺណិត

### ១. ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ បង្កើនការឆ្លើយតបក្នុងការគ្រប់គ្រងបច្ចេកវិទ្យាទូរគមនាគមន៍ទៅនឹងCSAM

- បង្កើតគោលការណ៍ណែនាំដល់ក្រុមហ៊ុនផ្តល់សេវាអ៊ីនធឺណិត ត្រូវមានយន្តការអនុវត្តនីតិវិធីទាំងឡាយដើម្បីរាយការណ៍ កំណត់ប្រភេទរូបភាព និងសម្ភារអាសអាភាសកុមារCSAM និងលុបចេញរូបភាព និងសម្ភារអាសអាភាសកុមារពីប្រព័ន្ធផ្ទុកទិន្នន័យមេ(Server) ក្នុងប្រទេសកម្ពុជា។ ហើយធ្វើការសហការទំនាក់ទំនងជាមួយអ្នកផ្តល់សេវានៅអន្តរជាតិដើម្បីបិទឬដកចេញពីការអាចទាញយកបានសម្ភារCSAM។
- ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ក្រសួងកិច្ចការនារី និងក្រសួងនិងស្ថាប័នពាក់ព័ន្ធ គួរបង្កើតគោលការណ៍រួមកំណត់ពីខ្លឹមសារខុសច្បាប់ពាក់ព័ន្ធនឹង CSAM ដែលដាក់បង្ហាញលើអ៊ីនធឺណិត ឬបណ្តាញសង្គមដែលត្រូវបានចាត់ទុកថាប៉ះពាល់ដល់សីលធម៌ប្រពៃណីជាតិសាសនា។

### ២. បង្កើនការយល់ដឹងពីបញ្ហា CSAM និងជំរុញការឆ្លើយតបបន្ទាន់

- លើកកម្ពស់ការយល់ដឹងពីផលប៉ះពាល់ដោយសារ CSAM និងការឆ្លើយតបបញ្ហា CSAM ទាន់ពេលវេលា (ទាំងរដ្ឋាភិបាល និងក្រុមហ៊ុន)។
- លើកកម្ពស់ការយល់ដឹងអំពីការប៉ះពាល់ទាក់ទងនឹងCSAM មាននៅក្នុងបណ្តាញមេ ដែលធ្វើឲ្យកុមារដែលធ្លាប់រងគ្រោះអាចរងគ្រោះឡើងវិញ នៅពេលដែលរូបភាពត្រូវបានគេមើលហើយវាក៏ផ្តល់ឲ្យជនល្មើសមានលទ្ធភាពទទួលបានរូបភាព និងបន្តចែកចាយសម្ភារ CSAM បន្តទៀត។
- បង្កើនការផ្សព្វផ្សាយ និងបញ្ជ្រាបការយល់ដឹងអំពីបទល្មើស និងហានិភ័យបច្ចេកវិទ្យាព័ត៌មាន។
- បង្កើតជា Postter Video sport សម្រាប់ផ្សព្វផ្សាយពី CSAM (CNCC and MoT)។

### ៣. ទំនួលខុសត្រូវសង្គមរបស់វិស័យឯកជន

- ជំរុញ និងលើកទឹកចិត្តឲ្យក្រុមហ៊ុនផ្តល់សេវាអ៊ីនធឺណិត ណែនាំដល់អ្នកប្រើប្រាស់ឧបករណ៍ចែកចាយអ៊ីនធឺណិតដែលមានសុវត្ថិភាពចំពោះកុមារ(Parental control)។
- ជំរុញ និងលើកទឹកចិត្តឲ្យក្រុមហ៊ុនផ្តល់សេវាអ៊ីនធឺណិត ពិនិត្យលទ្ធភាពក្នុងការដាក់នូវឧបករណ៍ ដើម្បីគ្រប់គ្រង និងផ្តល់សញ្ញាហាមឃាត់មិនឲ្យប្រើប្រាស់ Webside អាសអាភាស ឬអាសអាភាសកុមារ។

## ៧.៣. យុត្តិធម៌ព្រហ្មទណ្ឌ

- ពង្រីកបណ្តាញប្រឆាំងបទល្មើសបច្ចេកវិទ្យានៅថ្នាក់ក្រោមជាតិ ដើម្បីបង្ការ ទប់ស្កាត់ និងឆ្លើយតបករណី CSAM បានទាន់ពេលវេលា។
- ពង្រឹងសមត្ថភាពមន្ត្រីជំនាញនៅថ្នាក់ជាតិ និងក្រោមជាតិរបស់នាយកដ្ឋានប្រឆាំងបទល្មើសបច្ចេកវិទ្យា និងអង្គភាពជំនាញពាក់ព័ន្ធ។
- បង្កើនធនធាន និងកិច្ចសហប្រតិបត្តិការជាមួយដៃគូជាតិ និងអន្តរជាតិនានា ក្នុងការឆ្លើយតបបញ្ហា CSAM ឲ្យកាន់តែមានប្រសិទ្ធភាព (រាប់បញ្ចូលទាំងលើកកម្ពស់ការយល់ដឹងអំពីការស៊ើបអង្កេតCSAM)។

- បង្កើនទំនាក់ទំនងជិតស្និទ្ធជាមួយការិយាល័យកណ្តាលជាតិទំនាក់ទំនងនគរបាលអន្តរជាតិ (NCB)ភ្នំពេញ ដែលនឹងផ្តល់ជំនួយ ក្នុងការកំណត់ដំណើរការចែកចាយ CSAM និងធ្វើឲ្យប្រាកដថារូបភាព CSAM ទាំងនោះអាចយកមកអនុវត្តវិធានការច្បាប់អន្តរជាតិ។

## ៧.៤. សង្គម

១. **លើកកម្ពស់ការយល់ដឹងពីផលប៉ះពាល់ពី OCSE ដល់អ្នកប្រើប្រាស់ (សុវត្ថិភាពក្នុងការប្រើប្រាស់ ដើម្បីការពារអ្នកប្រើប្រាស់ឲ្យមានការយល់ដឹង និងការជៀសវាងទំនាក់ទំនងជាមួយជនកេងប្រវ័ញ្ចផ្លូវភេទ)**

- លើកកម្ពស់ការយល់ដឹងអំពីការប្រើប្រាស់បណ្តាញសង្គម ការកំណត់ភាពឯកជន និងការរក្សារូបភាព និងរក្សាសុវត្ថិភាពព័ត៌មានបុគ្គល ការដាក់លេខសម្ងាត់ ជាដើម។
- បណ្តុះបណ្តាលអំពីការរាយការណ៍អំពីភាពរងគ្រោះ និងអាចធ្វើការលុបចោលមាតិការំលោភបំពាននៅលើបណ្តាញព័ត៌មានសង្គម។
- បង្កើនយុទ្ធនាការផ្សព្វផ្សាយក្នុងសហគមន៍ និងសាលារៀនអំពីបញ្ហាប្រឈម ក្នុងការប្រើសប្រាស់បណ្តាញព័ត៌មានសង្គម និងទីតាំង ឬប្រព័ន្ធអាចរាយការណ៍បាន។

២. **លើកកម្ពស់ការយល់ដឹងអំពីព័ត៌មានសង្គមដល់មាតាបិតា និងអ្នកមានទំនាក់ទំនងជាមួយកុមារ**

- ឪពុកម្តាយនិងអ្នកថែទាំកុមារ គួរមានការយល់ដឹងពីការប្រើប្រាស់ប្រព័ន្ធអ៊ិនធឺណិតដែលនឹងភ្ជាប់ទំនាក់ទំនងកុមារនៅក្នុងពិភពបច្ចេកវិជ្ជារបស់ពួកគេ។
- សង្គមស៊ីវិល និងក្រុមហ៊ុនឯកជន ធ្វើយុទ្ធនាការផ្សព្វផ្សាយតាមទូរទស្សន៍ ឬតាមប្រព័ន្ធផ្សព្វផ្សាយសង្គមទៅតាមសាលារៀន និងសហគមន៍ឲ្យបានយល់ដឹងអំពីបញ្ហាអាចកើតមានគ្រោះថ្នាក់តាមប្រព័ន្ធអ៊ិនធឺណិត និងផ្សព្វផ្សាយដល់អ្នកប្រើប្រាស់ពីរបៀបបង្ការចៀសវាងពីជនខិលខូចនៅក្នុងប្រប្រព័ន្ធអ៊ិនធឺណិត។
- ផ្សព្វផ្សាយអំពីប្រព័ន្ធរាយការណ៍ Internet Hotlines និងកន្លែងដែលអាចរាយការណ៍បានទៅដល់គ្រួសារអ្នកថែទាំកុមារ សហគមន៍ទូទៅ និងសាលារៀន។
- លើកកម្ពស់ការចូលរួមរបស់កុមារក្នុងការរៀបចំផែនការសកម្មភាព ដើម្បីឆ្លើយតបទៅនឹងបញ្ហាប្រឈមជុំវិញ OCSE។

# ឧបសម្ព័ន្ធ១: ការអង្កេតមានរចនាសម្ព័ន្ធ

ចេតនាដំបូងនៃការវិភាគស្ថានភាពដំបូងក្នុងផ្នែកនេះ គឺដើម្បីប្រមូលសំណាកក្នុងចំនួនកំណត់មួយ ប៉ុន្តែជាសំណាកតំណាងឲ្យយុវវ័យកម្ពុជានៅក្នុងសាលារៀនរដ្ឋ សាលារៀនឯជន និងសាលារៀនបំពេញវិជ្ជា។ ទោះបីជាយ៉ាងណា ដោយសារពេលវេលាមានកំណត់ ទំហំនៃការអង្កេតនេះ ត្រូវបានកម្រិតនៅត្រឹមចំនួនសំណាកដ៏តូចមួយ







ក្នុងចំណោមយុវសិស្ស នៅក្នុងតំបន់ភូមិសាស្ត្រមួយនៃប្រទេសកម្ពុជា។ ស្របពេលដែលទិន្នន័យ ដែលត្រូវបានផ្តល់នៅទីនេះ មិនអាចតំណាងឲ្យជាតិទាំងមូលបាន ដូច្នេះ ទិន្នន័យនេះ នៅតែអាចផ្តល់នូវបណ្តុំនៃការរៀនសូត្រ ដ៏មានសារៈប្រយោជន៍អំពី ការប្រើប្រាស់អ៊ិនធឺណិត ក្នុងចំណោមក្រុមយុវវ័យជាក់លាក់នេះ និងផ្តល់នូវការប្រៀបធៀបដ៏មានសារៈសំខាន់ចំពោះការរៀនសូត្រនានា ដែលបានមកពីសិក្ខាសាលាជាមួយកុមារ នៅរាជធានីភ្នំពេញ ខេត្តសៀមរាប និងខេត្តព្រះសីហនុ។ ជាសរុប ការអង្កេតតាមប្រព័ន្ធអ៊ិនធឺណិតបានប្រមូលទិន្នន័យ ពីយុវសិស្សចំនួន ១៣៩ នាក់ ដែលការអង្កេតនេះ ត្រូវបានធ្វើឡើងនៅក្នុងថ្នាក់រៀន កុំព្យូទ័រ ក្នុងចំណោមយុវសិស្សសាលារៀនរដ្ឋ នៅខេត្តបាត់ដំបង។

## ប្រជាសាស្ត្រ៖

ក្នុងចំណោមយុវវ័យទាំង ១៣៩ នាក់ ដែលបានចូលរួមក្នុងការអង្កេតនេះ ភាគច្រើន ឬ៨៩ នាក់ (៦៤%) មានអាយុពី១៥ ដល់១៧ឆ្នាំ ស្របពេលដែលមាន៣៣នាក់ (២៣.៧%) មានអាយុពី១៨ ដល់២០ឆ្នាំ និង១៦នាក់ (១១.៥%) មានអាយុពី ១១ ដល់១៤ឆ្នាំ។ មានតែអ្នកផ្តល់ចម្លើយម្នាក់ប៉ុណ្ណោះ ដែលលើកឡើងថា មានអាយុចន្លោះពី ៨ ទៅ១៤ឆ្នាំ។



ភាគច្រើនបំផុត (៨៤.៩%) គឺសិស្សកម្រិតវិទ្យាល័យ ចំណែកឯ ១៤.៤% ស្ថិតនៅក្នុងកម្រិតបឋមសិក្សា ឬអនុវិទ្យាល័យ។ កុមារចំនួន ១៣៧នាក់ រៀននៅសាលារៀនរដ្ឋ និងពីរនាក់ទៀតរៀននៅសាលារៀនបំពេញវិជ្ជា ឬសាលារៀនរបស់អង្គការមិនមែនរដ្ឋាភិបាល។

**ការប្រើប្រាស់អ៊ិនធឺណិត:** ការប្រើប្រាស់សេវាកម្មអ៊ិនធឺណិតចល័ត ជាមួយទូរស័ព្ទដៃវៃឆ្លាត គឺជាមធ្យោបាយទូទៅបំផុតនៃការភ្ជាប់អ៊ិនធឺណិត ដែលត្រូវបានលើកឡើងដោយយុវសិស្សចំនួន ១០៧ នាក់ ឬ ៧៩% នៃយុវសិស្ស ១៣៦ នាក់ ដែលឆ្លើយតបចំពោះសំណួរនេះ។ ក្រៅពីសេវាកម្មចល័ត មានយុវសិស្សប្រហែលជិតម្នាក់ ក្នុងចំណោមប្រាំមួយនាក់ (២៤ នាក់ ឬ ១៨%) បានលើកឡើងអំពីការភ្ជាប់អ៊ិនធឺណិតតាមរយៈ Wifi នៅផ្ទះ មានយុវសិស្សបីនាក់ (២%) លើកឡើងអំពីការភ្ជាប់អ៊ិនធឺណិតភាគច្រើន នៅអង្គការមិនមែនរដ្ឋាភិបាល និងយុវសិស្សពីរនាក់ (១%) លើកឡើងអំពី ការភ្ជាប់អ៊ិនធឺណិតតាមរយៈ Wifi សាធារណៈ។

មានយុវសិស្សភាគច្រើន (៧១នាក់ ឬ៦៥%) លើកឡើងអំពីការចំណាយពេលតិចជាងបីម៉ោង ក្នុងមួយថ្ងៃតាមប្រព័ន្ធអ៊ិនធឺណិត ដោយមាន ២៩% ចំណាយពេលតិចជាងមួយម៉ោង និង៣៦% ចំណាយពេលចន្លោះពីមួយទៅបីម៉ោង តាមប្រព័ន្ធអ៊ិនធឺណិត។ យុវសិស្ស១៧នាក់ (១២%) លើកឡើងអំពី ការចំណាយពេលលើសពីបីម៉ោងក្នុងមួយថ្ងៃ ជាមួយអ៊ិនធឺណិត មានប្រាំបីនាក់ ក្នុងចំណោមនោះ (៦%) លើកឡើងពីការចំណាយពេលលើសពី ៥ ម៉ោង ជាមួយអ៊ិនធឺណិត។ ជាចុងក្រោយ មានយុវសិស្សចំនួន ៥ នាក់ ឬ ៤% បានលើកឡើងថា ពួកគេមិនច្បាស់ថាតើពួកគេចំណាយពេលប៉ុន្មាន នោះឡើយ លើអ៊ិនធឺណិត។ មានរបាយការណ៍មួយនិយាយពី ការប្រើប្រាស់អ៊ិនធឺណិត ក្នុងចំណោមជនកម្ពុជាវ័យក្មេងៗ បានលើកឡើងនូវរបកគំហើញស្រដៀងគ្នានេះ ដោយមានអ្នកប្រើប្រាស់អ៊ិនធឺណិតវ័យក្មេងចំនួន ៤៩% កំពុងប្រើប្រាស់អ៊ិនធឺណិត មានរយៈពេល លើសពី ៣០នាទី ក្នុងមួយថ្ងៃ។

ឪពុកម្តាយ ត្រូវបានគេលើកឡើងថា ជាអ្នកផ្តល់លុយដល់យុវសិស្សទាំងនេះ ភាគច្រើន (៨២នាក់ ឬ ៥៩%) ដើម្បីភ្ជាប់អ៊ិនធឺណិត ភាគច្រើនតាមរយៈការចំណាយតាមប្រព័ន្ធអ៊ិនធឺណិតចល័ត ស្របពេលដែលមានយុវសិស្សចំនួនជិតដល់ម្នាក់ ក្នុងចំណោមយុវសិស្សប្រាំមួយនាក់ (២៤នាក់ ឬ១៧%) បានលើកឡើង អំពីការចំណាយតាមប្រព័ន្ធអ៊ិនធឺណិត ដោយប្រើប្រាស់លុយផ្ទាល់ខ្លួនរបស់ពួកគេ។ មានចំនួនតិចជាងនេះ គឺយុវសិស្សប្រាំមួយនាក់លើកឡើងអំពីការភ្ជាប់អ៊ិនធឺណិត តាមរយៈអង្គការមិនមែនរដ្ឋាភិបាល ហើយពីរនាក់លើកឡើងអំពីការទទួលលុយពីអ្នកដទៃដើម្បីភ្ជាប់អ៊ិនធឺណិត។

## មូលហេតុសម្រាប់ប្រើប្រាស់អ៊ិនធឺណិត

យុវសិស្សត្រូវបានសុំឲ្យពិចារណាលើមូលហេតុចម្បងនិងមូលហេតុទីពីរ ដែលពួកគេតែងតែភ្ជាប់អ៊ិនធឺណិត។ ជាងពីរភាគបីនៃយុវសិស្សទាំងអស់ (៩២នាក់ ឬ៦៧%) លើកឡើងថា មូលហេតុចម្បងដែលពួកគេភ្ជាប់អ៊ិនធឺណិតគឺដើម្បីការសិក្សារបស់ពួកគេ និងយុវសិស្ស៥២នាក់ (៤១%) លើកឡើងថា ការសិក្សារបស់ពួកគេ គឺជាមូលហេតុទីពីរសម្រាប់ការប្រើប្រាស់អ៊ិនធឺណិតរបស់ពួកគេ។ គួរឲ្យកត់សម្គាល់ដែរ គឺមានយុវសិស្ស៤១នាក់ លើកឡើងថា(៣០% នៃយុវសិស្សដែលឆ្លើយថា "ស្រាវជ្រាវ/ធ្វើកិច្ចការសាលា") ជាទូទៅ ការសិក្សា គឺជាមូលហេតុចម្បង និងជាមូលហេតុទីពីរដែលពួកគេភ្ជាប់អ៊ិនធឺណិត។

ដោយសារការអង្កេតតាមប្រព័ន្ធអ៊ិនធឺណិត ត្រូវបានធ្វើឡើងនៅក្នុងថ្នាក់រៀន ដូច្នេះ អ្នកផ្តល់ចម្លើយអាចទំនងជាឆ្លើយថា "ការសិក្សា" គឺជាមូលហេតុចម្បងសម្រាប់ការភ្ជាប់អ៊ិនធឺណិតច្រើនជាង បើប្រៀបធៀបនឹងការអង្កេតដែលធ្វើឡើងក្នុងបរិបទមិនទាក់ទងនឹងការអប់រំ ដូចជានៅកាហ្វេអ៊ិនធឺណិត ឬនៅបណ្តាញទំនាក់ទំនងសង្គម។

ក្រៅពីការសិក្សា មូលហេតុចម្បងសម្រាប់ការភ្ជាប់អ៊ិនធឺណិត រួមមាន យុវសិស្ស១៨នាក់ ឬ១៣% លើកឡើងពីការប្រើប្រាស់អ៊ិនធឺណិត ដើម្បីមើលវីឌីអូ បន្ទាប់មក ដើម្បីទាញយកឯកសារ និងវីឌីអូ (៨នាក់ ឬ ៦០%) លេងហ្គេម (៦ នាក់ ឬ ៤%) និងបណ្តាញទំនាក់ទំនងសង្គម (៤ នាក់ ឬ ៣%) ក្នុងចំណោមមូលហេតុផ្សេងទៀត (១០ នាក់ ឬ ៧%)។ មូលហេតុទីពីរ សម្រាប់ការភ្ជាប់អ៊ិនធឺណិត បន្ទាប់ពីការសិក្សា រួមមាន ទាញយកឯកសារ និងវីឌីអូ (២៥ នាក់ ឬ ១៨%) មើលវីឌីអូ (២៥ នាក់ ឬ ១៨%) បណ្តាញទំនាក់ទំនងសង្គម (១២ នាក់ ឬ ៩%) និងលេងហ្គេម (១១ នាក់ ឬ ៨%) ក្នុងចំណោមមូលហេតុផ្សេងទៀត (៨ នាក់ ឬ ៦%)។

## កម្មវិធីដែលត្រូវបានប្រើប្រាស់ និងភាពញឹកញាប់នៃការប្រើប្រាស់

ហាក់ដូចជាផ្ទុយនឹងមូលហេតុសម្រាប់ការភ្ជាប់អ៊ិនធឺណិតរបស់យុវសិស្សទាំងនេះអ្នកឆ្លើយតបបានបង្ហាញអំពីការប្រើប្រាស់បណ្តាញទំនាក់ទំនងសង្គម និងសេវាកម្មផ្សាយវីឌីអូផ្ទាល់ជាប្រចាំនិងជាញឹកញាប់ នៅពេលដែល




ពួកគេប្រើប្រាស់អ៊ិនធឺណិត។ កម្មវិធីដែលត្រូវបានប្រើប្រាស់ទូទៅជាងគេគឺ Youtube (៨៩%), Facebook (៩៤%) និង Messenger នៃ Facebook (៧៥%)។ TikTok ដែលជាកម្មវិធីផ្សាយចម្រៀងផ្ទាល់ ក៏ត្រូវបានលើកឡើង ជាទូទៅផងដែរ ដោយយុវវ័យ ៨៤ នាក់ ឬ ៦០%។ កម្មវិធីលេងហ្គេម ដូចជា Rules of Survival (៣១%), PUBG (២៨%) និង Minecraft (១៦%) ត្រូវបានប្រើប្រាស់ដោយយុវសិស្សភាគតិច។ របកគំហើញនៅទីនេះ គឺមានសង្គតភាពជាមួយនឹងទម្រង់នៃការប្រើប្រាស់កម្មវិធីនៅក្នុងសិក្ខាសាលារៀនសូត្រនៅខេត្តសៀមរាប ខេត្តព្រះសីហនុ និងរាជធានីភ្នំពេញ ព្រមទាំងការសិក្សាអំពីបណ្តាញទំនាក់ទំនងសង្គម ដែលត្រូវបានធ្វើឡើងដោយអង្គការ UNDP ដែលលើកឡើងថា មនុស្សវ័យក្មេងៗប្រើប្រាស់អ៊ិនធឺណិត ដើម្បីអានព័ត៌មាន (៧៣%) ហើយការប្រើប្រាស់ប្រចាំថ្ងៃរបស់ពួកគេ ភាគច្រើនគឺលើទម្រង់នៃការផ្សព្វផ្សាយព័ត៌មានតាមបែបប្រពៃណី (៦៦%) បណ្តាញទំនាក់ទំនងសង្គម (៦៣%) មើលគេហទំព័រទូទៅ (៤២%) លេងហ្គេម (៣១%) ការសិក្សា និងការអាន (៣០%) និងការមើលទូរទស្សន៍ និងវីឌីអូ (២៧%)[64]។

ដោយពិចារណាលើកម្មវិធី ដែលត្រូវបានប្រើប្រាស់ទូទៅបំផុត (YouTube, Facebook, Messenger នៃ Facebook និង TikTok) YouTube គឺត្រូវបានប្រើប្រាស់ជាទូទៅបំផុត ក្នុងចំណោមយុវវ័យ ព្រមទាំងជាកម្មវិធីដែលត្រូវបានប្រើប្រាស់ជាទៀងទាត់ជាងគេ ដោយយុវសិស្ស ៤២% ប្រើប្រាស់វាជារៀងរាល់ថ្ងៃ និង ៥៦% ប្រើប្រាស់វាជារៀងរាល់សប្តាហ៍។ យុវសិស្សប្រុស និងយុវសិស្សស្រី ប្រើប្រាស់ YouTube ក្នុងកម្រិតស្រដៀងគ្នា ប៉ុន្តែ

---

[64] UNDP. (2014), 24.

យុវសិស្សប្រុស ទំនងជាអ្នកប្រើប្រាស់ជាទៀងទាត់ជាងបន្តិច (៥៥% នៃយុវសិស្សជាប្រុសបង្ហាញអំពី ការប្រើប្រាស់ជាប្រចាំថ្ងៃ ឬ សប្តាហ៍ ធៀបនឹងយុវសិស្សស្រី ដែលមានចំនួន ៤៣%)។ ជាងពាក់កណ្តាល (៥៦%) នៃយុវសិស្សអាយុពី ១១ ទៅ ១៤ ឆ្នាំ និងជិតពីរភាគបី (៦៤%) នៃយុវសិស្ស អាយុពី ១៥ ទៅ ១៧ ឆ្នាំ ប្រើប្រាស់ YouTube ជារៀងរាល់ថ្ងៃ ឬជារៀងរាល់សប្តាហ៍។ YouTube ត្រូវបានប្រើប្រាស់មានកម្រិតតិចជាង (៣៦%) ក្នុងចំណោមយុវវ័យអាយុ ១៨ ឆ្នាំ ឬលើសពីនេះ។ របកគំហើញនៅទីនេះ មានសង្គត ភាពជាមួយរបាយការណ៍ខាងលើរបស់អង្គការ UNDP ដែលរកឃើញថា កម្មវិធីដែលមានប្រជាប្រិយភាពជាងគេពីរគឺ Facebook (៧៩%) បន្ទាប់មកគឺ YouTube (៦៣%) ក្នុងចំណោមសំណាកនៃមនុស្សវ័យក្មេង ដែលប្រើប្រាស់អ៊ិនធឺណិត។

ទាក់ទងនឹង Facebook ជារួម កម្មវិធីបណ្តាញទំនាក់ទំនងសង្គមនេះ ត្រូវបានប្រើប្រាស់ទូទៅ ជាងកម្មវិធីផ្ញើសាររបស់វា "Messenger" (៨៩% ធៀបនឹង ៧៥%) ទោះបីជាយ៉ាងណា ក្នុងចំណោមអ្នកប្រើប្រាស់ទៀងទាត់កម្មវិធីផ្ញើសារ គឺត្រូវបានប្រើប្រាស់ញឹកញាប់ ប្រហាក់ប្រហែលគ្នានឹង (៤៦% ធៀបនឹង ៤៧%)។ ទាក់ទងនឹងអាយុវិញ ភាគច្រើននៃអ្នកប្រើប្រាស់ Facebook ជាប្រចាំ មានអាយុចាប់ពី ១៥ ដល់ ១៧ ឆ្នាំ។ ជាងពាក់កណ្តាល (៥៣%) នៃយុវសិស្ស អាយុ ១៥ ដល់ ១៧ ឆ្នាំ ប្រើប្រាស់ Facebook ជារៀងរាល់ថ្ងៃ ឬ ជារៀងរាល់សប្តាហ៍។ មានកម្រិតតិចជាងនេះ ៣១% នៃយុវសិស្ស មានអាយុពី ១១ ទៅ ១៤ ឆ្នាំ និង ៣៦% នៃយុវសិស្ស អាយុពី ១៨ ឆ្នាំ ឬលើសពីនេះ បង្ហាញនូវការប្រើប្រាស់ Facebook ជារៀងរាល់ថ្ងៃ ឬជារៀងរាល់ សប្តាហ៍។ គ្មានភាពខុសគ្នា គួរឲ្យកត់សម្គាល់ទេ រវាងអ្នកប្រើប្រាស់ ជាយុវសិស្សប្រុស និងយុវសិស្សស្រី។

ដោយពិចារណាលើ Messenger ដែលជាកម្មវិធីផ្ញើសាររបស់ Facebook យុវសិស្ស អាយុពី ១៥ ទៅ ១៧ ឆ្នាំ បង្ហាញនូវការប្រើប្រាស់ Messenger ជាទៀងទាត់ជាង ដោយមានយុវសិស្ស ៥៧% បង្ហាញនូវការប្រើប្រាស់កម្មវិធីជារៀងរាល់ថ្ងៃ ឬជារៀងរាល់សប្តាហ៍។ ជាការប្រៀបធៀប មានជាងមួយភាគបីនៃយុវសិស្ស អាយុពី ១១ ដល់ ១៤ ឆ្នាំ (៣៧.៥%) និង ២៧.២% នៃយុវវ័យ អាយុ ១៨ឆ្នាំ និងលើសពីនេះ បង្ហាញនូវការប្រើប្រាស់កម្មវិធីនេះ ជារៀងរាល់ថ្ងៃ ឬជារៀងរាល់សប្តាហ៍។ គ្មានភាពខុសគ្នា គួរឲ្យកត់សម្គាល់ទេ រវាងអ្នកប្រើប្រាស់ជាយុវសិស្សប្រុស និងយុវសិស្សស្រី (៥១% ក្នុងចំណោមយុវសិស្សប្រុស និង ៤៩% ក្នុងចំណោមយុវសិស្សស្រី)។

## ការចូលរួម និងការត្រួតពិនិត្យរបស់ឪពុកម្តាយ

យុវសិស្សត្រូវបានសួរអំពីកម្រិតនៃការនិយាយជាមួយឪពុកម្តាយ ឬអ្នកថែទាំរបស់ពួកគេអំពីអ្វីដែលពួកគេធ្វើនៅតាមប្រព័ន្ធអ៊ិនធឺណិត។ ស្របពេលដែលយុវសិស្សភាគច្រើន (១០២ ឬ៧៥%) បង្ហាញថា ពួកគេនិយាយជាមួយឪពុកម្តាយរបស់ពួកគេអំពីអ្វីដែលពួកគេធ្វើនៅតាមប្រព័ន្ធអ៊ិនធឺណិត មានយុវសិស្សម្នាក់ ក្នុងចំណោមបួននាក់ លើកឡើងថា ជាទូទៅ ពួកគេមិននិយាយជាមួយឪពុកម្តាយរបស់ពួកគេ អំពីសកម្មភាពរបស់ពួកគេតាមអ៊ិនធឺណិតឡើយ។ អ្វីដែលជាក់លាក់ជាងនេះគឺ យុវសិស្ស២០នាក់ ក្នុងចំណោម១៣៩នាក់ ឬ១៥% លើកឡើងថា ពួកគេកម្រនិយាយជាមួយឪពុកម្តាយរបស់ពួកគេណាស់ និងមាន១៥នាក់ ឬ១១% លើកឡើងថា ពួកគេមិនដែលនិយាយជាមួយឪពុកម្តាយអំពីសកម្មភាពរបស់ពួកគេតាមប្រព័ន្ធអ៊ិនធឺណិតឡើយ។ យុវសិស្សប្រុសទំនងជានិយាយជាមួយឪពុកម្តាយរបស់ពួកគេច្រើនជាងបន្តិច បើប្រៀបធៀបនឹងយុវសិស្សស្រី ដោយយុវសិស្សប្រុសមាន៧៧% និងយុវសិស្សស្រីមាន៧១% និយាយជាមួយឪពុកម្តាយ "ជាញឹកញាប់" ឬ "ម្តងម្កាល" អំពីសកម្មភាពរបស់ពួកគេតាមប្រព័ន្ធអ៊ិនធឺណិត។

យុវសិស្សភាគច្រើន (៧៤នាក់ ឬ ៥៣%) លើកឡើងថា មិនមានការរិតត្បិតណាមួយ ចំពោះការប្រើប្រាស់អ៊ិនធឺណិតឡើយ។ ក្នុងចំណោមយុវសិស្ស៤៧% ដែលមានការកំណត់ ឬការរិតត្បិតចំពោះការប្រើប្រាស់អ៊ិនធឺណិតរបស់ពួកគេ ១៩% លើកឡើងថា មានការរិតត្បិចចំពោះពេលវេលា ដែលពួកគេចំណាយជាមួយអ៊ិនធឺណិត ១៨% លើកឡើងថា ឪពុកម្តាយរបស់ពួកគេ ដាក់ការរិតត្បិតលើខ្លឹមសារ ដែលពួកគេអាចមើលបាន និង ៩% បង្ហាញថា មានការរិតត្បិត ទាំងលើពេលវេលា និងទាំងលើខ្លឹមសារ។ យុវសិស្សស្រី ទំនងជាមានការរឹតត្បិតលើសកម្មភាពតាមប្រព័ន្ធអ៊ិនធឺណិតរបស់ពួកគេច្រើនជាង បើប្រៀបធៀបនឹងយុវសិស្សប្រុស ដោយ៥៥% នៃយុវសិស្សស្រី និង៤០% នៃយុវសិស្សប្រុស មានការរិតត្បិតក្នុងទម្រង់ណាមួយ។

## បទពិសោធន៍ប្រកបដោយហានិភ័យតាមប្រព័ន្ធអ៊ិនធឺណិត




មានយុវសិស្សភាគតិចប៉ុណ្ណោះ ឬ មានម្នាក់ក្នុងចំណោមប្រាំនាក់ (២០%) បង្ហាញថា ពួកគេមានអារម្មណ៍ថាមានសុវត្ថិភាព នៅពេលពួកគេប្រើប្រាស់អ៊ិនធឺណិត។ មានយុវវ័យលើសពីម្នាក់ ក្នុងចំណោមបួននាក់ (២៧%) លើកឡើងថា ពួកគេគ្មានអារម្មណ៍ថា មានសុវត្ថិភាពទេ នៅតាមប្រព័ន្ធអ៊ិនធឺណិត ហើយភាគច្រើន ឬ ៥៤% លើកឡើងថា "ពេលខ្លះ" ពួកគេមានអារម្មណ៍ថា មានសុវត្ថិភាពនៅតាមប្រព័ន្ធអ៊ិនធឺណិត។ យុវសិស្សប្រុសទំនងជាមានអារម្មណ៍ថា មានសុវត្ថិភាពនៅតាមប្រព័ន្ធអ៊ិនធឺណិត ច្រើនជាងយុវសិស្សស្រី រហូតដល់ទៅពីរដង (៤៧%នៃយុវសិស្សប្រុស ធៀបនឹង២១%នៃយុវសិស្សស្រី)។ ទោះបីជាយ៉ាងណា យុវសិស្សស្រីទំនងជាលើកឡើងអំពីអារម្មណ៍គ្មានសុវត្ថិភាពនៅតាមប្រព័ន្ធអ៊ិនធឺណិត តិចជាងយុវសិស្សប្រុស ដោយយុវសិស្សស្រីមាន១៨% មានអារម្មណ៍ថាគ្មានសុវត្ថិភាព ហើយយុវសិស្សប្រុស ២១% បង្ហាញថា ពួកគេមានអារម្មណ៍ថា មានសុវត្ថិភាពនៅតាមប្រព័ន្ធអ៊ិនធឺណិត។ ស្របពេលដែលមានការកត់សម្គាល់ចំពោះភាពខុសគ្នានេះ គួរពិចារណាថា ភាពខុសគ្នានៃ "អារម្មណ៍" មានសុវត្ថិភាពតាមអ៊ិនធឺណិត អាចមិនឆ្លុះបញ្ចាំងនូវបទពិសោធន៍ពិតប្រាកដនៃហានិភ័យ ឬសុវត្ថិភាពតាមប្រព័ន្ធអ៊ិនធឺណិតឡើយ ប៉ុន្តែអាចឆ្លុះបញ្ចាំងច្រើនជាង លើសង្គមរូបនីយកម្ម ផ្នែកយេនឌ័ររបស់យុវវ័យ ដែលសន្មត់ជាទូទៅថា ស្ត្រីមានភាពងាយរងគ្រោះច្រើនជាង ហើយបុរសមានភាពស៊ាំច្រើនជាង។

យុវសិស្ស បង្ហាញនូវបទពិសោធន៍ តាមប្រព័ន្ធអ៊ិនធឺណិតមួយចំនួន ដែលធ្វើឲ្យពួកគេមានអារម្មណ៍ថា គ្មានសុវត្ថិភាព ដែលមានសង្គតភាពជាមួយនឹង OCSE។ មានយុវសិស្សម្នាក់ ក្នុងចំណោមប្រាំមួយនាក់ (១៩%) បង្ហាញអារម្មណ៍ថា គ្មានសុវត្ថិភាពដោយសារ (ឬភ័យខ្លាចចំពោះ) បុគ្គលតាមប្រព័ន្ធអ៊ិនធឺណិត ដែលនឹងប្រើប្រាស់រូបភាពរបស់ពួកគេ និងចែកចាយរូបភាពទាំងនោះតាមប្រព័ន្ធអ៊ិនធឺណិត។ មានយុវសិស្សចំនួនជិតម្នាក់ ក្នុងចំណោមប្រាំនាក់ (១៦%) បង្ហាញអារម្មណ៍ថាគ្មានសុវត្ថិភាព ដោយសារ "បុគ្គលតាមប្រព័ន្ធអ៊ិនធឺណិត ដែលសុំឲ្យខ្ញុំធ្វើរឿងមិនសមរម្យ"។ លើសពីនេះ មានយុវសិស្ស ១៣% បង្ហាញអារម្មណ៍ថា គ្មានសុវត្ថិភាព ដោយសារការមើលឃើញរូបភាព

ហិង្សា និង ១៣% ទៀត លើកឡើងអំពី អារម្មណ៍គ្មានសុវត្ថិភាព ដោយសាររូបភាពផ្លូវភេទ នៅពេលដែលពួកគេប្រើប្រាស់អ៊ិនធឺណិត។ បន្ថែមលើកត្តាទាក់ទងនឹង OCSE ដែលអាចមាន គឺគ្រោងការទុច្ចរិតតាមអ៊ិនធឺណិត ឬការទទួលរងនូវការបោកប្រាស់លុយកាក់  គឺជាមូលហេតុទូទៅបំផុត  ដែលធ្វើឲ្យយុវសិស្សមានអារម្មណ៍ថា  គ្មានសុវត្ថិភាពនៅតាមប្រព័ន្ធអ៊ិនធឺណិត  ដែលត្រូវបានលើកឡើងដោយយុវសិស្សចំនួនជិតម្នាក់  ក្នុងចំណោមបីនាក់។  មានយុវសិស្សចំនួនជិតម្នាក់ ក្នុងចំណោមបួននាក់ (២៣%) លើកឡើងថា ពួកគេមានអារម្មណ៍ថា គ្មានសុវត្ថិភាព ដោយសារការចំអក ឬការរំខាន ពីមនុស្សនៅតាមអ៊ិនធឺណិត។

យុវសិស្សភាគច្រើន(៥៧%) លើកឡើងថា ពួកគេបានឃើញរូបភាពអាសអាភាសនៅតាមអ៊ិនធឺណិតដែលមានលក្ខណៈទូទៅ ជាងនៅក្នុងចំណោមយុវសិស្សប្រុស (៦៧% ធៀបនឹង ៤៦%ក្នុងចំណោមយុវសិស្សស្រី)។ គួរឲ្យកត់សម្គាល់ជាងនេះ គឺអ្នកឆ្លើយតបវ័យក្មេង១១នាក់ ក្នុងចំណោម១៧នាក់ (អាយុពី៨ ទៅ១៤ឆ្នាំ) លើកឡើងអំពីការមើលឃើញរូបភាពអាសអាភាសនៅតាមប្រព័ន្ធអ៊ិនធឺណិត។ ស្របពេលដែលការអង្កេតនេះត្រូវធ្វើឡើងជាមួយសំណាកយុវសិស្សចំនួនតូច ប៉ុន្តែមានលក្ខណៈគួរឲ្យកត់សម្គាល់ដោយសារអ្នកឆ្លើយតបវ័យក្មេង (យុវសិស្ស១១នាក់ក្នុងចំណោម១៧នាក់) ដែលលើកឡើងអំពី ការមើលឃើញសម្ភារអាសអាភាសតាមអ៊ិនធឺណិត មានសមាមាត្រខ្ពស់ជាង បើប្រៀបធៀបជាមួយយុវសិស្សវ័យច្រើនជាងនេះដោយយុវសិស្សចំនួន៦៧នាក់ ក្នុងចំណោម១២១នាក់។

អ្វីដែលគួរឲ្យកត់សម្គាល់គឺ ក្នុងចំណោមយុវសិស្ស ដែលលើកឡើងអំពី ការមើលឃើញសម្ភារអាសអាភាសតាមប្រព័ន្ធអ៊ិនធឺណិត ពួកគេចំនួន ៣២% បង្ហាញថា ពួកគេបានឃើញសម្ភារអាសអាភាស ដែលបង្ហាញអំពីយុវវ័យដែលមានវ័យស្របាលនឹងពួកគេ ឬក្មេងជាងពួកគេ។ យុវសិស្ស ៤៩% បន្ថែមទៀត លើកឡើងថា ពួកគេមិនច្បាស់ទេថា តើពួកគេបានឃើញសម្ភារអាសអាភាស ដែលបង្ហាញអំពី យុវវ័យ ដែលមានវ័យស្របាលនឹងពួកគេ ឬក្មេងជាងពួកគេ។ មានយុវសិស្សតែម្នាក់ប៉ុណ្ណោះ  ក្នុងចំណោមប្រាំនាក់ ដែលបានឃើញសម្ភារអាសអាភាស លើកឡើងថាពួកគេមិនបានឃើញសម្ភារអាសអាភាស  ដែលបង្ហាញអំពីយុវវ័យ  ដែលមានវ័យស្របាលនឹងពួកគេ  ឬក្មេងជាងពួកគេឡើយ។  ស្របពេលដែលមិនអាចធ្វើសេចក្តីសន្និដ្ឋានបាន  ចំពោះរបកគំហើញទាំងនេះ  ជាចាំបាច់គឺត្រូវមានការស្រាវជ្រាវបន្ថែមទៀត  ដើម្បីយល់ដឹងអំពីខ្លឹមសារផ្សេងៗ ដែលអ្នកប្រើប្រាស់អ៊ិនធឺណិតជាយុវវ័យ  ជួបប្រទះនៅក្នុងប្រទេសកម្ពុជា។

មានយុវសិស្សម្នាក់ ក្នុងចំណោមប្រាំនាក់(២០%) បង្ហាញថា បានយល់ព្រមបញ្ចូលជនចម្លែកជាមិត្តភក្តិ ក្នុងបណ្តាញទំនាក់ទំនងសង្គម ដោយអត្រាស្រដៀងគ្នា ក្នុងចំណោមយុវសិស្សប្រុស និងយុវសិស្សស្រី។ ស្របពេលដែលមានយុវសិស្សត្រឹមតែ ២០% ប៉ុណ្ណោះបង្ហាញថា បានបញ្ចូលជនចម្លែក ជាមិត្តភក្តិនៅតាមប្រព័ន្ធអ៊ិនធឺណិត មានយុវសិស្សចំនួន ជាងពាក់កណ្តាល (៥១%) លើកឡើងអំពីការនិយាយទូរស័ព្ទជាមួយអ្នក ដែលពួកគេបានជួបតាមប្រព័ន្ធអ៊ិនធឺណិត ដោយមានយុវសិស្ស ២៦% ឬ ៣៥ នាក់ ធ្វើបែបនេះ "ម្តង" យុវសិស្ស ១៤% ឬ ១៩ នាក់ ធ្វើបែបនេះពីពីរទៅប្រាំដង យុវសិស្ស ៥% ឬ ៧ នាក់ ធ្វើបែបនេះពី ៥ ទៅដប់ដង និងយុវសិស្ស ៧% ឬប្រាំបួននាក់ ធ្វើបែបនេះ ច្រើនជាងដប់ដង។ ក្នុងចំណោមអ្នកដែលបាននិយាយ ឬជជែកជាមួយអ្នកដែលពួកគេបានជួបតាមប្រព័ន្ធអ៊ិនធឺណិត មានយុវសិស្សប្រាំបួននាក់ បង្ហាញអំពីការនិយាយគ្នាទាក់ទងនឹងផ្លូវភេទ ជាមួយបុគ្គលដែលពួកគេបានជួបដោយបេកគំហើញ ក្នុងចំណោមទាំងយុវសិស្សប្រុស និងយុវសិស្សស្រី មានលក្ខណៈស្រដៀងគ្នា។ ការជួបផ្ទាល់ជាមួយបុគ្គល ដែលយុវសិស្សបានជួបតាមប្រព័ន្ធអ៊ិនធឺណិត គឺមានលក្ខណៈទូទៅ ដោយមានយុវសិស្សប្រុស ៨៨% និងយុវសិស្សស្រី ៦០% (ឬ ៧៣% នៃយុវសិស្សទាំងអស់) បង្ហាញថា ពួកគេបានជួបដោយផ្ទាល់ជាមួយបុគ្គលដែលពួកគេបានជួបតាមប្រព័ន្ធអ៊ិនធឺណិត យ៉ាងហោចណាស់ម្តង។ ក្នុងចំណោមយុវសិស្សទាំងអស់ មានយុវសិស្ស ២៩ នាក់ ឬ ២៧% លើកឡើងអំពីការធ្វើបែបនេះម្តង ២៦ នាក់ ឬ ២៨% លើកឡើងអំពីការធ្វើបែបនេះពីពីរដងទៅប្រាំដង ប្រាំពីរនាក់ ឬ ៧% លើកឡើងអំពី ការធ្វើបែបនេះ ពីប្រាំដងទៅដប់ដង និង១៤នាក់ ឬ១៣% លើកឡើងអំពីការធ្វើបែបនេះលើសពីដប់ដង។ ស្របពេលដែលកាលៈទេសៈនៃការជួបគ្នានេះ មិនត្រូវបានបង្ហាញ និងភាពចាំបាច់ក្នុងការធ្វើការស្រាវជ្រាវច្រើនថែមទៀត លើការអនុវត្តន៍នានា តាមប្រព័ន្ធអ៊ិនធឺណិត នៅប្រទេសកម្ពុជា របកគំហើញទាំងនេះហាក់ដូចជាបង្ហាញនូវតម្រូវការ គួរឲ្យកត់សម្គាល់ ដើម្បីធ្វើឲ្យការប្រើប្រាស់អ៊ិនធឺណិត កាន់តែមានសុវត្ថិភាព។




| តើអ្នកគិតថា មានអ្វីដែលជាការគំរាមកំហែងធំជាងគេឬទេនៅពេលអ្នកប្រើប្រាស់អ៊ិនធឺណិត? | | |
|---|---|---|
| នឹងមានជនណាម្នាក់ ប្រើប្រាស់រូបថតរបស់ខ្ញុំ ក្នុងលក្ខណៈមិនសមរម្យ | ៣៣ | ២៤,០៩% |
| ការចំអក ឬការរំខានដោយមិត្តភក្តិ ឬមិត្តស្និទ្ធស្នាល | ៣២ | ២៣,៣៦% |
| ការចំអក ឬការរំខាង ដោយជនចម្លែក | ៣១ | ២២,៦៣% |
| ការសួរនាំទាក់ទងនឹងផ្លូវភេទ ដែលមិនជាទីចង់បានពីក្នុងការជជែកគ្នាតាមគេហទំព័រនៃបណ្តាញទំនាក់ទំនងសង្គម ឬតាមអ៊ីម៉េល | ១៨ | ១៣,១៤% |
| ការមើលឃើញរូបភាព ឬខ្លឹមសារផ្លូវភេទ | ១៨ | ១៣,១៤% |
| មានជនណាម្នាក់ ថតរូប ដែលមិនជាទីចង់បានរបស់ខ្ញុំ និងចែករំលែករូបថតទាំងនោះ | ១៧ | ១២,៤១% |

| | | |
|---|---|---|
| ការគំរាមកំហែង នៅតាមកន្លែង/បរិយាកាស ដែលខ្ញុំប្រើប្រាស់អ៊ិនធឺណិត | ៩ | ៦,៥៧% |
| ខ្ញុំមិនគិតថា មានហានិភ័យច្រើនឡើយ | ២៨ | ២០,៤៤% |
| ផ្សេងៗទៀត | ៨ | ៥,៨៤% |

យុវសិស្សក៏ត្រូវបានសុំឲ្យឆ្លុះបញ្ចាំងពីបទពិសោធន៍របស់ពួកគេតាមប្រព័ន្ធអ៊ិនធឺណិត និងបង្ហាញនូវអ្វីដែលពួកគេជឿជាក់ថា ជាការគំរាមកំហែងធំជាងគេ ចំពោះសុវត្ថិភាពរបស់ពួកគេ។ ការគំរាមកំហែងទាក់ទងនឹង OCSE គឺត្រូវបានបង្ហាញជាទូទៅ ពេញទូទាំងចម្លើយទាំងឡាយចំពោះសំណួរនេះ។ ជាទូទៅ យុវសិស្សបានបង្ហាញថា បុគ្គលដែលប្រើប្រាស់រូបថតរបស់ពួកគេ មានលក្ខណៈមិនសមរម្យ គឺជាការគំរាមកំហែងធំជាងគេ នៅពេលពួកគេប្រើប្រាស់អ៊ិនធឺណិត ដែលត្រូវបានលើកឡើងដោយយុវសិស្សចំនួន៣៣នាក់ ឬ២៤%។ ស្រដៀងគ្នានេះដែរ គឺមានយុវសិស្សចំនួន១៧នាក់ ឬ១២% បង្ហាញអំពី ការគំរាមកំហែងនៃការថតរូប ដែលមិនជាទីចង់បានរបស់ពួកគេ និងចែកចាយតាមប្រព័ន្ធអ៊ិនធឺណិត និងមានចំនួនតិចជាងនេះ គឺមានយុវសិស្សចំនួន១៨នាក់ (ឬ១៣%) បង្ហាញអំពីការគំរាមកំហែងនៃការសាកសួរទាក់ទងនឹងផ្លូវភេទ ដែលមិនជាទីចង់បាន មាន១៨នាក់ (១៣%) បានបង្ហាញអំពីការគំរាមកំហែងនៃការមើលឃើញខ្លឹមសារផ្លូវភេទ។ ការគំរាមកំហែងផ្សេងទៀត ដែលមិនទាក់ទងនឹង OCSE រួមមានទម្រង់ផ្សេងៗនៃការចំអកតាមប្រព័ន្ធអ៊ិនធឺណិត ដោយយុវសិស្សចំនួន៣២នាក់ (២៣.៤%) លើកឡើងអំពីការចំអកពីមិត្តភក្តិ ឬ មិត្តស្និទ្ធស្នាល និង មាន៣១នាក់ (២២.៦%) បង្ហាញអំពីការចំអក ឬការរំខានពីជនចម្លែក។ លើសពីនេះ យុវសិស្សចំនួនប្រាំបួននាក់ ឬ ៦% លើកឡើងនូវការគំរាមកំហែងផ្នែកបរិយាកាស នៅកន្លែងដែលពួកគេប្រើប្រាស់អ៊ិនធឺណិត ហើយដែលជាខ្លឹមសារមួយមានលក្ខណៈទូទៅផងដែរ ក្នុងចំណោមយុវវ័យ មកពីសហគមន៍ងាយរងគ្រោះ នៅក្នុងសិក្ខាសាលារៀនសូត្រ នៅរាជធានីភ្នំពេញ ខេត្តសៀមរាប និងខេត្តព្រះសីហនុ។ ជាចុងក្រោយ មានយុវវ័យម្នាក់ ក្នុងចំណោមប្រាំនាក់ (២៨ នាក់ ឬ ២០%) មិនជឿថា មានហានិភ័យច្រើនឡើយចំពោះសុវត្ថិភាពរបស់ពួកគេ នៅពេលពួកគេប្រើប្រាស់អ៊ិនធឺណិត។

ជារួម យុវសិស្សដែលចូលរួមក្នុងការអង្កេត បែបជាលក្ខណៈមានរចនាសម្ព័ន្ធនេះ បង្ហាញនូវហានិភ័យគួរឲ្យកត់សម្គាល់លើបញ្ហាជាច្រើន រួមមាន ការមើលឃើញខ្លឹមសារផ្លូវភេទ ដែលបង្ហាញរូបភាពទាំងរបស់មនុស្សពេញវ័យ និងទាំងរបស់កុមារ ផ្សេងទៀត ព្រមទាំងការជួបជាមួយនឹងបុគ្គលផ្ទាល់ ដែលពួកគេបានជួបតាមអ៊ិនធឺណិត។ បន្ថែមលើនេះ យុវសិស្សបានបង្ហាញនូវភាពងាយរងគ្រោះជាច្រើន មិនត្រឹមតែទាក់ទងនឹងការបំពានឯកជនភាពរបស់ពួកគេ និងហានិភ័យទាក់ទងនឹង OCSE ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងមានការចំអកតាមអ៊ិនធឺណិតផងដែរ។

# បញ្ជីឈ្មោះឯកសារយោង


- អង្គការសកម្មភាពដើម្បីកុមារកម្ពុជា (ឆ្នាំ២០១៦) ការពិភាក្សាតុមូលអំពីការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទកុមារ។ កំណត់ហេតុប្រជុំ នៅរាជធានីភ្នំពេញ។
- អង្គការសកម្មភាពដើម្បីកុមារកម្ពុជា (ឆ្នាំ២០១៨) ការយល់ឃើញបច្ចុប្បន្នអំពីការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទកុមារ នៅក្នុងប្រទេសកម្ពុជា ៖ ការសិក្សានៅក្នុងខេត្តចំនួនប្រាំ។
- អង្គការសកម្មភាពដើម្បីកុមារ៖ រាជធានីភ្នំពេញ។
- Chan, S. (ថ្ងៃទី ២៧ ខែមិថុនា ឆ្នាំ ២០១៨) រដ្ឋាភិបាលចេញកាលបរិច្ឆេទកំណត់ចុងក្រោយ ឲ្យចុះបញ្ជីអ្នកប្រើប្រាស់ស៊ីមកាត។ បានអាននៅថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៨ ពី ៖ https://www.khmertimeskh.com/50505669/government-issues-final-deadline-to-register-sim-card-users/
- Craven, et al., (ឆ្នាំ២០០៦) វេទិកាអន្តរវិស័យអន្តរជាតិសម្រាប់ការស្រាវជ្រាវ ទ្រឹស្តី និងការអនុវត្តវ៉ុលូម១២ លេខ ៣។ ការលួងលោមផ្លូវភេទកុមារ ៖ ការពិនិត្យឯកសារ និងការពិចារណាផ្នែកទ្រឹស្តី។ បានអានពី៖ https://www.tandfonline.com/doi/abs/10.1080/13552600601069414
- ECPAT អន្តរជាតិ (ឆ្នាំ ២០១៦) ជនខិលខូចកំពុងផ្លាស់ទី។ របាយការណ៍នៃការសិក្សាសាកលអំពីការកេងប្រវ័ញ្ចផ្លូវភេទក្នុងវិស័យធ្វើដំណើរ និងទេសចរណ៍។ អង្គការ ECPAT អន្តរជាតិ៖ ទីក្រុងបាងកក។ បានអាននៅថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៧ពី ៖ http://globalstudysectt.org/global-report/
- ECPAT អន្តរជាតិ (ឆ្នាំ២០១៧) ការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអ៊ិនធឺណិត៖ ការយល់ដឹងជារួមមួយ
- អង្គការ ECPAT អន្តរជាតិ៖ ទីក្រុងបាងកក។ បានអាននៅថ្ងៃទី ១២ ខែមករា ឆ្នាំ ២០១៨ ពី៖ http://www.ecpat.org/wp-content/uploads/2017/05/SECO-Booklet_ebook-1.pdf
- ECPAT អន្តរជាតិ និងនគរបាលអន្តរជាតិ (ឆ្នាំ ២០១៨) ឆ្ពោះទៅរកសូចនាករសាកលស្តីពី ជនរងគ្រោះដែលត្រូវកំណត់អត្តសញ្ញាណបាន នៅក្នុងសម្ភារ ទាក់ទងនឹងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ។បានអាននៅថ្ងៃទី៩ ខែមីនា ឆ្នាំ ២០១៨ ពី ៖ http://www.ecpat.org/resources/towards-global-indicator-unidentified-victims-child-sexual-exploitation-material-summary-report/
- Elliot, I.A., & Ashfield, S. (ឆ្នាំ ២០១១) ការប្រើប្រាស់បច្ចេកវិទ្យា អ៊ិនធឺណិត តាមរបៀបជនខិលខូចផ្លូវភេទជាស្ត្រី។ ទិនានុប្បវត្តិ ស្តីពីការរំលោភបំពានផ្លូវភេទ ១៧ (១), ៩២-១០៤។
- ទីភ្នាក់ងារសហភាពអឺរ៉ុប ដើម្បីកិច្ចសហប្រតិបត្តិការក្នុងការអនុវត្តច្បាប់ (នគរបាលអឺរ៉ុប ឆ្នាំ២០១៧) ការប៉ាន់ប្រមាណមើលការគំរាមកំហែង ដោយអង្គការឧក្រិដ្ឋកម្មតាមប្រព័ន្ធអ៊ិនធឺណិត។
- Hurley, R., Wolak, J., Prusty, S., Soroush, H., Walls, R. J., Albrecht, J., Lynn, B. (ឆ្នាំ ២០១៣) ការវាស់វែង និងការវិភាគ លើការការជួញដូររូបភាព ឬវីឌីអូអាសអាភាសកុមារ តាមបណ្តាញ P2P។ បន្តពីសន្និសីទអន្តរជាតិ លើកទី២២ ស្តីទី World Wide Web - WWW ′13. doi:10.1145/2488388.2488444
- INHOPE (ឆ្នាំ ២០១៦) ការពិនិត្យតួលេខ និងនិន្នាការ ក្នុងឆ្នាំ២០១៦។ ការប្រយុទ្ធប្រឆាំងនឹងការរំលោភបំពានផ្លូវភេទកុមារ តាមប្រព័ន្ធអ៊ិនធឺណិត ដោយការពិចារណាគ្រប់ជ្រុងជ្រោយ។ បានអានពី៖ http://www.inhope.org/tns/resources/statistics-and-infographics/statistics-and-infographics-2016.aspx


៩.៨-១

- ក្រុមការងារអន្តរទីភ្នាក់ងារ ស្តីពីការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ (ឆ្នាំ២០១៦) គោលការណ៍ណែនាំវាក្យស័ព្ទសម្រាប់ កិច្ចការពារកុមារពីការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទ។ បានអាននៅថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១៦ ពី http://luxembourgguidelines.org
- Kierkegaard, S. (ឆ្នាំ២០០៨) ការប្រើប្រាស់បច្ចេកវិទ្យាការលួងលោមតាមប្រព័ន្ធអ៊ិនធឺណិត និងការសម្តែងតួទៅតាមអាយុ។ ច្បាប់ទាក់ទងនឹងកុំព្យូទ័រ និងរបាយការណ៍សន្តិសុខ, ២៤, ៤១-៥៥។
- Kloess, J. A., Beech, A. R., & Harkins, L.(ឆ្នាំ២០១៤) ការកេងប្រវ័ញ្ចផ្លូវភេទកុមារតាមប្រព័ន្ធអ៊ិនធឺណិត
- របួសស្នាមផ្លូវចិត្ត អំពើហិង្សា និងការរំលោភបំពាន ១៥ (២), ១២៦-១៣៩។
- LIRNEasia (ឆ្នាំ ២០១៨) បន្ទាប់ពីទទួលបាន ៖ ការទទួលបាន និងការប្រើប្រាស់ ICT នៅក្នុងប្រទេសកម្ពុជា និង ប្រទេសចំណូលទាប និង មធ្យម, ភ្នំពេញ ប្រទេសកម្ពុជា។
- McAlinden, A-M. (ឆ្នាំ ២០០៦) (2006) "Setting 'em up": ការលួងលោមផ្ទាល់ខ្លួន គ្រួសារ និងស្ថាប័ននៅ ក្នុងការរំលោភបំពានផ្លូវភេទលើកុមារ។ ការសិក្សាសង្គម និងច្បាប់, ១៥(៣) ៣៣៩-៣៦២។
- ក្រសួងកិច្ចការនារី ផែនការសកម្មភាពជាតិ ដើម្បីទប់ស្កាត់អំពើហិង្សាលើស្ត្រី ២០១៤-២០១៨។ បានអានពី ៖ http://cambodia.unfpa.org/sites/asiapacific/files/pub-pdf/NAPVAW2014-2018%28Eng%29.pdf នៅថ្ងៃទី២១ ខែមិថុនា ឆ្នាំ ២០១៦
- NetClean. (ឆ្នាំ ២០១៧) របាយការណ៍របស់ NetClean ឆ្នាំ ២០១៧។ បានអាននៅថ្ងៃទី ១៤ ខែធ្នូ ឆ្នាំ ២០១៨ ពី https://www.netclean.com/netclean-report-2017/download/
- OHCHR (ឆ្នាំ ២០១៦) បច្ចេកវិទ្យាឌីជីថលថ្មី បង្កើតឲ្យមានសម្ភាររំលោភបំពានកុមារតាមប្រព័ន្ធអ៊ិនធឺណិតក្នុងកម្រិតមិនធ្លាប់មានពីមុនមក។ បានអាននៅថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៦ ពី៖ http://www.ohchr.org/EN/NewsEvents/Pages/Childsexualexploitationonlineontherise.aspx
- Steel, C. M. S. (ឆ្នាំ ២០០៩) រូបភាព ឬវីឌីអូអាសអាភាសកុមារ នៅក្នុងបណ្តាញ Peer-To-Peer ។ ការរំលោភបំពាន និងការមិនអើពើចំពោះកុមារ ៣៣(៨), ៥៦០-៥៦៨។ doi:10.1016/j.chiabu.2008.12.011
- អង្គការដែនដីមនុស្សហូ-ឡង់ដ៏ (ឆ្នាំ ២០១៣). ការបង្ហាញរូបភាពពេញលេញ៖ ការសិក្សាបែបស្វែងរកស្តីពីសារតា និងផលវិបាក ផ្នែកចិត្តសាស្ត្រសង្គម នៃទេសចរណ៍ផ្លូវភេទកុមារ តាម វ៉ែបខែម នៅប្រទេសហ្វីលីពីន។ ទីក្រុងឡាអេ ប្រទេសហូឡង់។
- អង្គការដែនដីមនុស្ស-ហូឡង់ដ៏ (ឆ្នាំ ២០១៤)។ ទេសចរណ៍ផ្លូវភេទកុមារ តាមវ៉ែបខែម
- ការក្លាយទៅជា Sweetie ៖ អតិក្រមប្រលោមលោក ដើម្បីបញ្ឈប់ការកើនឡើងជាសាកលនូវទេសចរណ៍ផ្លូវភេទកុមារតាមវ៉ែបខែម។ ទីក្រុងឡាអេ ប្រទេសហូឡង់។
- អង្គការដែនដីមនុស្ស-ហូឡង់ដ៏ (ឆ្នាំ២០១៦)។ កុមារនៃវ៉ែបខែម៖ របាយការណ៍បច្ចុប្បន្នភាព ស្តីពីទេសចរណ៍ផ្លូវភេទកុមារតាមវ៉ែបខែម។ ទីក្រុងឡាអេ ប្រទេសហូឡង់។
- អង្គការដែនដីមនុស្ស-ហូឡង់ដ៏ (ឆ្នាំ២០១៨)។ ការផ្សាយផ្ទាល់នូវការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមអ៊ិនធឺណិតនៅប្រទេសហ្វីលីពីន (តំបន់ III និង VII)។ ភ្នំពេញកម្ពុជា។
- UNDP (ឆ្នាំ ២០១៤)។ យុវវ័យនៅប្រទេសកម្ពុជា: ទម្លាប់ចំពោះឧបករណ៍កំសាន្ត និងប្រភពព័ត៌មាន។ បានអានពី៖ http://www.kh.undp.org/content/dam/cambodia/docs/DemoGov/Media%20Habits%20and%20Information%20Sources%20of%20Youth%20in%20Cambodia.pdf

- UNICEF (ឆ្នាំ២០១៦). ជនរងគ្រោះ មិនមែនជាការនិមិត្តទេ៖ ការប៉ាន់ប្រមាណស្ថានភាពនៃការកេងប្រវ័ញ្ចផ្លូវភេទកុមារ តាមប្រព័ន្ធអ៊ិនធឺណិតនៅអាស៊ីខាងត្បូង។បានអានពី https://www.unicef.org/rosa/Victims_are_not_virtual.pdf
- UNICEF (ឆ្នាំ២០១៧)។ ឯកជនភាពរបស់កុមារ នៅសម័យ Web ២.០ និង ៣.០៖ បញ្ហាប្រឈម និងឱកាសសម្រាប់គោលនយោបាយ។ បានអានពី ៖ https://www.unicef-irc.org/publications/926-child-privacy-in-the-age-of-web-20-and-30-challenges-and-opportunities-for-policy.html
- ក្រសួងយុត្តិធម៌សហរដ្ឋអាមេរិក នគរបាលអន្តរជាតិ (ឆ្នាំ ២០១៨)។ ការដោះស្រាយការរំលោភបំពានផ្លូវភេទកុមារ ជាការផ្តោតការយកចិត្តទុកដាក់នៃកិច្ចប្រជុំអ្នកជំនាញនគរបាលអន្តរជាតិ។ បានអានពី៖ https://www.interpol.int/News-and-media/News/2018/N2018-141
- We Are Social (ឆ្នាំ ២០១៧)។ ឌីជីថល នៅឆ្នាំ២០១៧៖ អាស៊ីអាគ្នេយ៍។ បានអានពី៖ https://www.slideshare.net/wearesocialsg/digital-in-2017-southeast-asia.
- WePROTECT (ឆ្នាំ២០១៦)។ ការទប់ស្កាត់ និងការដោះស្រាយការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទកុមារ (CSEA)៖ គំរូនៃការឆ្លើយតបកម្រិតថ្នាក់ជាតិ។
- ធនាគារពិភពលោក (ឆ្នាំ ២០១៥). កិច្ចការពារកុមារ ពីបទល្មើសបច្ចេកវិទ្យា៖ ការឆ្លើយតបផ្នែកច្បាប់នៅអាស៊ីដើម្បីប្រយុទ្ធប្រឆាំងនឹងរូបភាព ឬវីឌីអូអាសអាភាសកុមារ ការលួងលោមតាមប្រព័ន្ធអ៊ិនធឺណិត និងការចំអកតាមប្រព័ន្ធបច្ចេកវិទ្យា។ បានអានពី ៖ http://documents.worldbank.org/curated/en/652251468206670506/pdf/94492-WP-REVISED-PUBLIC-Box385442B-Protecting-Children-from-Cybercrime-Legislative-Responses-in-Asia-to-Fight-Child-Pornography-Online-Grooming-and-Cyberbull.pdf.


-----------------------------